ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញ-មញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្ប-យុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ និស្ស-យប្បច្ច័យ ឈានប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៧ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្ស-យប្បច្ច័យ ឈានប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្ស-យប្បច្ច័យ ឈានប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ និស្ស-យប្បច្ច័យ ឈានប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឈានប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឈានប្បច្ច័យ អត្ថិប្បច្ច័យ

អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហ-ជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឈានប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឈានប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឈានប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហ-ជាតប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៧ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជា-តប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហ-

ជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ សហជាតប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៧ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ សហជាតប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា អធិប-

តិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ សហជាតប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៤ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ សហ-ជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ សហជាតប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ សហ-ជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ

វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ អធិបតិប្បច្ច័យ សហជាតប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៤ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ អធិបតិប្បច្ច័យ សហជាតប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ អធិបតិប្បច្ច័យ សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះ

មគ្គប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ អធិបតិប្បច្ច័យ សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះមគ្គប្បច្ច័យ ។

## សម្បយុត្តមូលកៈ

[ ៣៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ព្រោះសម្បយុត្តប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៣៧ ] ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះសម្បយុត្តប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះសម្បយុត្តប្បច្ច័យ ។

## វិប្បយុត្តមូលកៈ

[ ៣៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ព្រោះវិប្បយុត្តប្បច្ច័យ... ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុង

សហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ៣៩ ] ពាក្យថា អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៥ ព្រោះវិប្បយុត្តប្បច្ច័យ ។ ពាក្យថា និស្សយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៥ ព្រោះវិប្បយុត្តប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៤ ព្រោះវិប្បយុត្តប្បច្ច័យ ។ ពាក្យថា និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះវិប្បយុត្តប្បច្ច័យ ។ ពាក្យថា បច្ឆាជាតប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះវិប្បយុត្តប្បច្ច័យ ។ ពាក្យថា និស្សយប្បច្ច័យ បុរេជាតប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះវិប្បយុត្តប្បច្ច័យ ។ ពាក្យថា អារម្មណប្បច្ច័យ និស្សយប្បច្ច័យ បុរេជាតប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះវិប្បយុត្តប្បច្ច័យ ។ ពាក្យថា អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ

បុរេជាតប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះវិប្បយុត្តប្បច្ច័យ ។ ពាក្យថា និស្សយប្បច្ច័យ បុរេជាតប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះវិប្បយុត្តប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះវិប្បយុត្តប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះវិប្បយុត្តប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះវិប្បយុត្តប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះវិប្បយុត្តប្បច្ច័យ ។

## អត្ថិមូលកៈ

[ ៤០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ព្រោះអត្ថិប្បច្ច័យ ... ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៨ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៧ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងឈានប្បច្ច័យ មានវារៈ

៧ ក្នុងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

[ ៤១ ] ពាក្យថា អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១៣ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា និស្សយប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១៣ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៨ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ និស្សយប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៨ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា អាហារប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៧ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា ឥន្ទ្រិយប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៧ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៧ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា វិប្បយុត្តប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៥ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា និស្សយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៥ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ និស្សយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៤ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា បច្ឆាជាតប្បច្ច័យ វិប្បយុត្តប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា បុរេជាតប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះ

អត្ថិប្បច្ច័យ ។ ពាក្យថា និស្សយប្បច្ច័យ បុរេជាតប្បច្ច័យ វិប្បយុត្តប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា អារម្មណប្បច្ច័យ បុរេជាតប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា អារម្មណប្បច្ច័យ និស្សយប្បច្ច័យ បុរេជាតប្បច្ច័យ វិប្បយុត្តប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ វិប្បយុត្តប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា និស្សយប្បច្ច័យ បុរេជាតប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះអត្ថិប្បច្ច័យ ។

## នេះឈ្មោះបកិណ្ណកៈ

[ ៤២ ] ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៩ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញ-

មញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ សម្បយុត្តប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ វិប្បយុត្តប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះអត្ថិប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ វិប្បយុត្តប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះអត្ថិប្បច្ច័យ ។

## នត្ថិមូលកៈ

[ ៤៣ ] ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ព្រោះនត្ថិប្បច្ច័យ ... ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងអាសេវនប្បច្ច័យមានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ១ ក្នុងវិបាកប្បច្ច័យ មានវារៈ ៧ ។

[ ៤៤ ] ពាក្យថា អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ វិគតប្បច្ច័យ ដូច្នេះ មានវារៈ ៧ ព្រោះនត្ថិប្បច្ច័យ ។ ពាក្យថា អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ អាសេវនប្បច្ច័យ វិគ-

តប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះនត្ថិប្បច្ច័យ ។ ពាក្យថា អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ កម្មប្បច្ច័យ វិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះនត្ថិប្បច្ច័យ ។

## វិគតមូលកៈ

[ ៤៥ ] ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ព្រោះវិគតប្បច្ច័យ ... ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ១ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ។

[ ៤៦ ] ពាក្យថា អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ នត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ៧ ព្រោះវិគតប្បច្ច័យ ។ ពាក្យថា អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះវិគតប្បច្ច័យ ។ ពាក្យថា អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ កម្មប្បច្ច័យ នត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះវិគតប្បច្ច័យ ។

## អវិគតមូលកៈ

[ ៤៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ព្រោះអវិគតប្បច្ច័យ ... ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៨ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុង

និស្សយប្បច្ច័យ មានវារៈ ១៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៧ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងឈានប្បច្ច័យ មានវារៈ ៧ ក្នុងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៣ ។

[ ៤៨ ] ពាក្យថា អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ១៣ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា និស្សយប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ១៣ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ៨ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ៨ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា អាហារប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ៧ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា ឥន្ទ្រិយប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ៧ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ៧ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ៥ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា និស្សយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ៥ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ និស្សយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ៤ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្ប-

យុត្តប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា បច្ឆាជាតប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា បុរេជាតប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា និស្សយប្បច្ច័យ បុរេ-ជាតប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា អារម្មណប្បច្ច័យ បុរេជាតប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា អារម្មណប្បច្ច័យ និស្សយប្បច្ច័យ បុរេជាតប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ និស្ស-យប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា និស្សយប្បច្ច័យ បុរេជាតប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះអវិគតប្បច្ច័យ ។

## នេះឈ្មោះបកិណ្ណកៈ

[ ៤៩ ] ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ៩ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះ

អវិគតប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្ស-យប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិប្ប-យុត្តប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា សហ-ជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្ស-យប្បច្ច័យ វិបាកប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះអវិគតប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្ស-យប្បច្ច័យ វិបាកប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះអវិគតប្បច្ច័យ ។

បញ្ហាវារៈ អនុលោមគណនា ចប់

# អដ្ឋកថា

## បញ្ហាវារយជនាអនុលោមគណនា

[ ១-៣ ] ឥឡូវនេះ ដើម្បីសម្តែងវិសជ្ជនាតាមដែលបានក្នុងបញ្ហាវារៈនេះដោយអំណាចការរាប់ ទើបព្រះមានព្រះភាគទ្រង់ត្រាស់បទថា **ហេតុយា សត្ត** ជាដើម ។ បណ្តាបទទាំងនោះ បទថា **សត្ត** គឺមានវិសជ្ជនា ៧ វារៈ យ៉ាងនេះ គឺវិសជ្ជនា ៣ វារៈ បានដល់ កុសល និងកុសល អព្យាកតៈ និងកុសល កុសលាព្យាកតៈ និងកុសល ។ អកុសល មាន ៣ វារៈ ដូចគ្នានឹងកុសល អព្យាកតៈ និងអព្យាកតៈ មាន ១ វារៈប៉ុណ្ណោះ ។

បទថា **អារម្មណេ នវ** គឺក្នុងអារម្មណប្បច្ច័យ មានវិសជ្ជនា ៩ វារៈ តែ ១ វារៈ មានបទដើម ១ បទ បទចុង ១ បទ ។ បទថា **អធិបតិយា ទស** គឺក្នុងអធិបតី មានវិសជ្ជនា ១០ វារៈ យ៉ាងនេះ គឺវិសជ្ជនា ៤ វារៈ ដែលមានកុសលជាមូល គឺកុសលជាបច្ច័យដល់កុសល ដោយសហជាតប្បច្ច័យ និងអារម្មណប្បច្ច័យ ជាបច្ច័យដល់កុសល ដោយអារម្មណប្បច្ច័យប៉ុណ្ណោះ ជាបច្ច័យដល់អព្យាកតៈ ដោយជាសហជាតប្បច្ច័យ និងដោយអារម្មណប្បច្ច័យ ជាបច្ច័យដល់កុសលាព្យាកតៈ ដោយសហជាតប្បច្ច័យប៉ុណ្ណោះ ។ វិសជ្ជនា ៣ ដែលមានអកុសលជាមូល គឺអកុសលជាបច្ច័យដល់អកុសល ដោយសហជាតប្បច្ច័យ និងអារម្មណប្បច្ច័យ ជាបច្ច័យដល់អព្យាកតៈដោយសហជាតប្បច្ច័យប៉ុណ្ណោះ ជាបច្ច័យដល់អកុសលាព្យាកតៈ ដោយសហជាតប្បច្ច័យប៉ុណ្ណោះ ។ វិសជ្ជនា ៣ ដែលមានអព្យាកតៈជាមូល គឺអព្យាកតៈជាបច្ច័យដល់អព្យាកតៈ ដោយសហជាតប្បច្ច័យ និង

អារម្មណប្បច្ច័យ ជាបច្ច័យដល់កុសលដោយអារម្មណប្បច្ច័យប៉ុណ្ណោះ ជាបច្ច័យដល់អកុសល ដោយអារម្មណប្បច្ច័យដូចគ្នា ក្នុងអធិបតិប្បច្ច័យនេះ រមែងបានអារម្មណាធិបតី ៧ វារៈ និងសហជាតាធិបតី ៧ វារៈ ដូចគ្នា ។

បទថា **អនន្តរេ សត្ត** បានដល់ ក្នុងអនន្តរប្បច្ច័យ មានវិសជ្ជនា ៧ វារៈយ៉ាងនេះ គឺវិសជ្ជនា ២ វារៈ មានកុសលជាមូល វិសជ្ជនា ២ វារៈ មានអកុសលជាមូល វិសជ្ជនា ៣ វារៈ មានអព្យាកតៈជាមូល ក្នុងសមនន្តរប្បច្ច័យ ក៏មានវិសជ្ជនា ៧ វារៈទាំងនេះដូចគ្នា ។

បទថា **សហជាតេ នវ** សេចក្តីថា ក្នុងសហជាតប្បច្ច័យមានវិសជ្ជនា ៩ វារៈ យ៉ាងនេះ គឺវិសជ្ជនាមានកុសលជាមូល ៣ វារៈ មានអកុសលជាមូល ៣ វារៈ មានអព្យាកតៈជាមូល ១ វារៈ មានកុសលាព្យាកតៈជាមូល ១ វារៈ មានអកុសលាព្យាកតៈជាមូល ១ វារៈ ។

បទថា **អញ្ញមញ្ញេ តីណិ** បានដល់ ក្នុងអញ្ញមញ្ញប្បច្ច័យមានវិសជ្ជនា ៣ វារៈ យ៉ាងនេះ គឺកុសល និងកុសល ១ វារៈ អកុសល និងអកុសល ១ វារៈ អព្យាកតៈ និងអព្យាកតៈ ១ វារៈ ។

បទថា **និស្សយេ តេរស** សេចក្តីថា ក្នុងនិស្សយប្បច្ច័យមានវិសជ្ជនា ១៣ វារៈ យ៉ាងនេះ គឺវិសជ្ជនាដែលមានកុសលជាមូល ៣ វារៈ មានអកុសលជាមូល ៣ វារៈ មានអព្យាកតៈជាមូល ៣ វារៈ ដោយសហ-ជាតប្បច្ច័យនោះឯង ។ ក្នុងវិសជ្ជនាមានអព្យាកតៈជាមូលនេះ រមែងបានបុរេជាតប្បច្ច័យផងដែរ ។ មែនពិត អព្យាកតៈ និងអព្យាកតៈ ជាសហជាតៈ

នឹងគ្នាក៏បាន ជាបុរេជាតក៏បាន ។ អព្យាកតៈជាបច្ច័យដល់កុសល ដោយបុរេជាតប៉ុណ្ណោះ ជាបច្ច័យដល់អកុសលក៏ដូចគ្នា ។ កុសលាព្យាកតៈ ជាបច្ច័យដល់កុសល ដោយសហជាត និងបុរេជាត ជាបច្ច័យដល់អព្យាកតៈ ដោយសហជាតប៉ុណ្ណោះ ។ អកុសលាព្យាកតៈ ជាបច្ច័យដល់អកុសល ដោយសហជាត និងបុរេជាត ជាបច្ច័យដល់អព្យាកតៈ ដោយភាពជាសហជាតតែម្យ៉ាង ។

បទថា **ឧបនិស្សយេ នវ** សេចក្តីថា ក្នុងឧបនិស្សយប្បច្ច័យ មានវិសជ្ជនា ៩ វារៈ គ្រប់វារៈ មានបទដើម ១ បទ និងបទចុង ១ បទ ។ ក្នុងវិភង្គនៃបច្ច័យទាំងនោះ ព្រះមានព្រះភាគ ទ្រង់សម្តែងប្រភេទទុក ២៣ វារៈ បណ្តាវារៈទាំងនោះ អារម្មណូបនិស្សយប្បច្ច័យ មាន ៧ វារៈ អនន្តរូបនិស្សយប្បច្ច័យ មាន ៧ វារៈ បកតូបនិស្សយប្បច្ច័យ មាន ៩ វារៈ ។

បទថា **បុរេជាតេ តីណិ** សេចក្តីថា ក្នុងបុរេជាតប្បច្ច័យ មានវិសជ្ជនា ៣ វារៈ យ៉ាងនេះ គឺអព្យាកតៈជាបច្ច័យដល់អព្យាកតៈ អព្យាកតៈជាបច្ច័យដល់កុសល អព្យាកតៈជាបច្ច័យដល់អកុសល ។

បទថា **បច្ឆាជាតេ តីណិ** សេចក្តីថា ក្នុងបច្ឆាជាតប្បច្ច័យមានវិសជ្ជនា ៣ វារៈយ៉ាងនេះ គឺកុសលជាបច្ច័យដល់អព្យាកតៈ អកុសលជាបច្ច័យដល់អព្យាកតៈ អព្យាកតៈជាបច្ច័យដល់អព្យាកតៈ ។

បទថា **អាសេវនេ តីណិ** គឺក្នុងអាសេវនប្បច្ច័យ មានវិសជ្ជនា ៣

វារៈ ដូចគ្នានឹងអញ្ញមញ្ញប្បច្ច័យ ។

បទថា **កម្មេ សត្ត** គឺក្នុងកម្មប្បច្ច័យ មានវិសជ្ជនា ៧ វារៈ ដូចហេតុប្បច្ច័យ ។ បណ្ដាវិសជ្ជនា ៧ វារៈនោះ នានាខណិកកម្មប្បច្ច័យមកក្នុងវិសជ្ជនា ២ វារៈ ។ ក្នុង ៥ វារៈដ៏សេស មកបានចំពោះសហជាតប្បច្ច័យប៉ុណ្ណោះ ។

បទថា **វិបាកេ ឯកំ** បានដល់ វិបាកប្បច្ច័យមាន ១ វារៈ គឺអព្យាកតៈនិងអព្យាកតៈ ។

ក្នុងអាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ មានវិសជ្ជនាបច្ច័យនីមួយៗ ៧ វារៈ ដូចគ្នានឹងហេតុប្បច្ច័យនោះឯង ក្នុងអធិការនេះ ឥន្ទ្រិយប្បច្ច័យ មកហើយដោយអំណាចសហជាត និងបុរេជាត ។

បទថា **សម្បយុត្តេ តីណិ** បានដល់ ក្នុងសម្បយុត្តប្បច្ច័យមានវិសជ្ជនា ៣ វារៈ ដូចគ្នានឹងអញ្ញមញ្ញប្បច្ច័យ ។

បទថា **វិប្បយុត្តេ បញ្ច** សេចក្ដីថា ក្នុងវិប្បយុត្តប្បច្ច័យ មានវិសជ្ជនា ៥ វារៈ យ៉ាងនេះ គឺវិសជ្ជនាដែលមានកុសលជាមូល ១ វារៈ មានអកុសលជាមូល ១ វារៈ មានអព្យាកតៈជាមូល ៣ វារៈ គឺអព្យាកតៈជាមួយកុសល និងអព្យាកតៈជាមួយអកុសល ជាបច្ច័យដោយសហជាត និងបច្ឆាជាត អព្យាកតៈជាមួយអព្យាកតៈ ជាបច្ច័យដោយសហជាត បុរេជាត និងបច្ឆាជាត កុសលជាមួយអព្យាកតៈ និងអកុសលជាមួយអព្យាកតៈ ជាបច្ច័យដោយវត្ថុបុរេជាតៈ ។

បទថា **អត្ថិយា តេរស** សេចក្ដីថា ក្នុងអត្ថិប្បច្ច័យ មានវិសជ្ជនា ១៣ វារៈ យ៉ាងនេះ គឺមានកុសលជាមូល ៣ វារៈ គឺកុសលជាមួយកុសល ជាបច្ច័យដោយសហជាត អព្យាកតៈជាមួយកុសល ជាបច្ច័យដោយសហ-ជាត និងបច្ឆាជាត កុសលាព្យាកតៈជាមួយកុសល ជាបច្ច័យដោយសហជាត តែម្យ៉ាង ដែលមានអកុសលជាមូល ក៏មាន ៣ វារៈដូចគ្នា តែអព្យាកតៈ ជាមួយអព្យាកតៈ ជាបច្ច័យដោយសហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយប្បច្ច័យ កុសលជាមួយអព្យាកតៈ និងអកុសលជាមួយអព្យាកតៈ ជាបច្ច័យដោយវត្ថារម្មណបុរេជាតប្បច្ច័យ កុសល និងអព្យាកតៈ ជាបច្ច័យ ដល់កុសល ដោយសហជាត និងបុរេជាត អកុសល និងអព្យាកតៈនោះ ឯង ជាបច្ច័យដល់អព្យាកតៈ ដោយសហជាត បច្ឆាជាត អាហារ និង ឥន្ទ្រិយប្បច្ច័យ អកុសល និងអព្យាកតៈ ជាបច្ច័យដល់អកុសល ដោយ សហជាត បុរេជាត និងអកុសលជាមួយអព្យាកតៈនោះឯង ជាបច្ច័យដល់ អព្យាកតៈ ដោយសហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយប្បច្ច័យ ។

ក្នុងនត្ថិប្បច្ច័យ និងវិគតប្បច្ច័យ មានវិសជ្ជនា ៧ វារៈ ដូចអនន្តរប្បច្ច័យ ( និងសមនន្តរប្បច្ច័យដែរ ) ។ ក្នុងបទនេះថា **អវិគតេ តេរស** គឺក្នុង អវិគតប្បច្ច័យ មាន ១៣ វារៈ ដូចអត្ថិប្បច្ច័យ ហេតុនោះ ក្នុងបញ្ហា-វារអនុលោមនេះ មានការកំណត់វិធីរាប់ ៧ យ៉ាង យ៉ាងនេះ គឺវិសជ្ជនា ១ វារៈ ៣ វារៈ ៥ វារៈ ៧ វារៈ ៩ វារៈ ១០ វារៈ ១៣ វារៈ ។ ក្នុងចំនួនវិសជ្ជនា ៧ យ៉ាងនោះ វិសជ្ជនា ១ វារៈ មាន ១ បច្ច័យប៉ុណ្ណោះ

ដោយអំណាចរបស់វិបាកប្បច្ច័យ ។

វិសជ្ជនា ៣ វារៈ មាន ៥ បច្ច័យ ដោយអំណាចអញ្ញមញ្ញប្បច្ច័យ បុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ អាសេវនប្បច្ច័យ និងសម្បយុត្តប្បច្ច័យ ។

វិសជ្ជនា ៥ វារៈ មាន ១ បច្ច័យប៉ុណ្ណោះ ដោយអំណាចរបស់វិប្បយុត្តប្បច្ច័យ ។

វិសជ្ជនា ៧ វារៈ មាន ១០ បច្ច័យ ដោយអំណាចហេតុប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ នត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។

ក្នុងវិសជ្ជនា ៩ វារៈ មាន ៣ បច្ច័យ ដោយអំណាចអារម្មណប្បច្ច័យ សហជាតប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ។

វិសជ្ជនា ១០ វារៈ មាន ១ បច្ច័យ ដោយអំណាចអធិបតិប្បច្ច័យ ។

វិសជ្ជនា ១៣ វារៈ មាន ៣ បច្ច័យ ដោយអំណាចនិស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ ហេតុនោះ អ្នកសិក្សាកំណត់វារៈទាំងឡាយដែលសម្តែងទុកក្នុងបច្ច័យនោះៗ ដូចបានចង្អុលបង្ហាញមកនេះដោយអំណាចនៃចំនួនឲ្យល្អ ហើយគប្បីជ្រាបចំនួនក្នុងការប្រៀបធៀបបច្ច័យ ក្នុងទុកមូល និងតិកមូលជាដើម ដោយអំណាចនៃបច្ច័យទាំងនោះ ។ បណ្ឌិតមិនគួរប្រកបបច្ច័យដែលជាវិសភាគៈ ឬជំទាស់គ្នា ទុកជាមួយគ្នា សេចក្តីនេះ ដូចម្តេច គឺអធិបតីដ៏សេស វៀរវីមំសាធិបតី ក្នុងអារម្មណប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ

កម្មប្បច្ច័យ អាសេវនប្បច្ច័យ អាហារប្បច្ច័យ ឈានប្បច្ច័យ នត្ថិប្បច្ច័យ និងអធិបតិប្បច្ច័យ ។ វិគតប្បច្ច័យ ជាវិសភាគៈនៃហេតុប្បច្ច័យមុន ។ សហជាតប្បច្ច័យជាដើម ជាសភាគៈនៃហេតុប្បច្ច័យនោះ ព្រោះហេតុណា ព្រោះមានសភាពដូចគ្នា ។ ពិតហើយ ហេតុប្បច្ច័យ ជាបច្ច័យដោយហេតុ ដល់ធម៌ទាំងឡាយណា ក៏ជាសហជាតប្បច្ច័យជាដើម ដល់ធម៌ទាំងនោះផង ដែរ តែមិនជាអារម្មណប្បច្ច័យជាដើម ដល់ធម៌ទាំងនោះឡើយ ហេតុនោះ អារម្មណប្បច្ច័យជាដើម ឈ្មោះថា ជាវិសភាគៈដល់ហេតុប្បច្ច័យនោះ ព្រោះ ហេតុនោះ ទើបហេតុប្បច្ច័យនោះ មិនគួរប្រកបទុកជាមួយអារម្មណប្បច្ច័យ ជាដើមនោះ ឬមិនគួរប្រកបអារម្មណប្បច្ច័យជាដើមនោះទុកជាមួយហេតុប្បច្ច័យ នោះ ។

សូម្បីបុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្ប-យុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ និងអវិគតប្បច្ច័យ ក៏ ជំទាស់គ្នានិងគ្នា ទើបមិនគួរប្រកបទុកជាមួយគ្នាទៀត ។ បណ្ដាធម៌ទាំងនោះ អ្នកសិក្សានឹងបានវារៈទាំងឡាយណា ក្នុងការប្រកបជាមួយធម៌ដែលចូលគ្នា បាន វៀរធម៌ដែលចូលគ្នាមិនបាន ដើម្បីសម្ដែងវារៈទាំងនោះដោយសង្ខេប ទើបព្រះមានព្រះភាគត្រាស់ថា **ហេតុប្បច្ចយា អធិបតិយា ចត្តារិ** ជាដើម បណ្ដាវារៈទាំងនោះ ព្រោះការប្រៀបធៀបហេតុប្បច្ច័យ និងអធិបតិប្បច្ច័យ ព្រោះយកហេតុប្បច្ច័យ រួមជាមួយអធិបតិប្បច្ច័យ បាន ៧ វារៈ ដោយ អំណាចនៃការរាប់បច្ច័យ ដែលតិចជាង ក៏ពិត តែព្រោះបណ្ដាអធិបតីទាំង

ឡាយ វីមំសាធិបតីប៉ុណ្ណោះជាហេតុប្បច្ច័យ ក្រៅអំពីនេះ មិនជាហេតុប្បច្ច័យទ្បើយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់វៀរធម៌ដែលជាវិសភាគៈ គឺធម៌ដែលចូលគ្នាមិនបានចោល ហើយត្រាស់ថា **ចត្តារិ** ដោយអំណាចនៃធម៌ដែលជាសភាគៈដល់គ្នានិងគ្នា ។ វិសជ្ជនា ៤ វារៈនោះ អ្នកសិក្សាគប្បីជ្រាបយ៉ាងនេះ គឺកុសលធម៌ ជាបច្ច័យដល់កុសលធម៌ដោយហេតុប្បច្ច័យ ដោយអធិបតិប្បច្ច័យ គឺវីមំសាដែលជាកុសលជាបច្ច័យដល់ខន្ធដែលសម្បយុត្ត កុសលធម៌ជាបច្ច័យ ដល់អព្យាកតធម៌ ដោយហេតុប្បច្ច័យ ដោយអធិបតិប្បច្ច័យ គឺវីមំសាធិបតីដែលជាកុសល ជាបច្ច័យដល់រូបដែលមានចិត្តជាសមុដ្ឋាន កុសលធម៌ ជាបច្ច័យដល់កុសលធម៌ និងអព្យាកតធម៌ ដោយហេតុប្បច្ច័យ ដោយអធិបតិប្បច្ច័យ គឺវីមំសាធិបតីដែលជាកុសលជាបច្ច័យដល់ខន្ធដែលសម្បយុត្ត និងរូបដែលមានចិត្តជាសមុដ្ឋាន អព្យាកតធម៌ ជាបច្ច័យដល់អព្យាកតធម៌ ដោយហេតុប្បច្ច័យ ដោយអធិបតិប្បច្ច័យ គឺវីមំសាធិបតីដែលជាវិបាកាព្យាកតៈ និងកិរិយាព្យាកតៈ ជាបច្ច័យដល់ខន្ធដែលសម្បយុត្ត និងរូប ដែលមានចិត្តជាសមុដ្ឋាន ។ ក្នុងទីនេះ គប្បីកាន់យកវិបាកាព្យាកតៈ អំពីលោកុត្តរធម៌ប៉ុណ្ណោះ ចំណែកអារម្មណប្បច្ច័យ និងអនន្តរប្បច្ច័យជាដើម លោកមិនប្រកបទុក ព្រោះជាវិសភាគៈ ដល់គ្នានិងគ្នា អ្នកសិក្សា កាលជ្រាបវារៈ ដែលមានបាន និងមិនបាន ក្នុងបច្ច័យទាំងអស់ ដោយឧបាយនេះហើយ គប្បីប្រកបជាវារៈដោយអំណាចដែលមានបាន ។

បទថា **សហជាតេ សត្ត** សេចក្តីថា វិសជ្ជនា ដែលបានហើយក្នុង

ហេតុប្បច្ច័យ ។ បទថា **អញ្ញមញ្ញោ តីណិ** បានដល់ គឺវិសជ្ជនាដែលបាន ក្នុងសុទ្ធិកអញ្ញមញ្ញប្បច្ច័យនោះឯង ។ បទថា **និស្សយេ សត្ត** បានដល់ វិសជ្ជនាដែលបានក្នុងហេតុប្បច្ច័យ ។ បទថា **វិបាកេ ឯកំ** គឺដែលបានក្នុង វិបាកប្បច្ច័យសុទ្ធៗ ។ បទថា **ឥន្ទ្រិយមគ្គេសុ ចត្តារិ** មានន័យដូចពោល ហើយខាងដើមនោះឯង ។ បទថា **សម្បយុត្តេ តីណិ** បានដល់ វិសជ្ជនា ដែលបានក្នុងសុទ្ធិកសម្បយុត្តប្បច្ច័យនោះឯង ។ បទថា **វិប្បយុត្តេ តីណិ** បានដល់ អ្នកសិក្សាគប្បីជ្រាបវិសជ្ជនាដែលលើកយករូប មានកុសលចិត្ត ជាដើម ជាសមុដ្ឋានឡើងជាបច្ចយុប្បន្ន ។ បទថា **អត្ថិអវិគតេសុ សត្ត** គឺវិសជ្ជនាដែលបានក្នុងហេតុប្បច្ច័យនោះឯង ។

ហេតុប្បច្ច័យ បានការប្រកបអធិប្បាយ រួមជាមួយបច្ច័យ ២១ មាន អធិបតិប្បច្ច័យជាដើម ទាំងឡាយណា ព្រះមានព្រះភាគ កាលទ្រង់សម្ដែង វិធីរាប់ក្នុងទុមូលកន័យដោយអំណាចនៃបច្ច័យទាំងនោះ ដូច្នេះហើយ ឥឡូវ នេះ ដើម្បីទ្រង់សម្ដែងវិធីរាប់ ក្នុងតិមូលកន័យជាដើម ទើបទ្រង់តាំងគោល កំណត់ត្រាស់ថា **ហេតុសហជាតនិស្សយអត្ថិអវិគតន្តិ សត្ត** ជាដើម ដោយប្រការដូច្នេះ ។

តែក្នុងគម្ពីរទាំងឡាយ អាចារ្យរចនាឈ្មោះបច្ច័យ មានអក្ខរៈធ្លាក់ទៅ យ៉ាងនេះគឺ **និស្ស ឧបនិស្ស អធិប** ពាក្យនោះ លោកសរសេរដោយអំណាច មិនបានដាក់ចិត្ត ព្រោះហេតុនោះ ក្នុងឋានៈបែបនោះ ទើបគួរបន្ថែមបាលីឲ្យ ពេញ ក្នុងគោលកំណត់ដែលលោកតាំងទុកនោះ រមែងសម្ដែងដល់អត្ថនេះ

ថា ហេតុប្បច្ច័យនេះ រមែងបាននូវវិសជ្ជនា ៧ វារៈ ដែលបានក្នុងវិភង្គ របស់ខ្លួនប៉ុណ្ណោះ ព្រោះរួមចូលជាមួយបច្ច័យ ៤ មានសហជាតប្បច្ច័យ ជាដើម ។ បើរួមអញ្ញមញ្ញប្បច្ច័យ ចូលក្នុងអធិការនេះ រមែងបានវិសជ្ជនា ៣ វារៈ ដែលបានក្នុងអញ្ញមញ្ញប្បច្ច័យ បើរួមសម្បយុត្តប្បច្ច័យចូលផង ក៏គង់បានវិសជ្ជនា ៣ វារៈនោះឯង ។ បើរួមវិប្បយុត្តប្បច្ច័យចូលជាមួយផង ក៏បានវិសជ្ជនា ៣ វារៈ ដែលបានក្នុងហេតុវិប្បយុត្តទុកៈ ។ បើរួមវិបាកប្បច្ច័យចូលផង រមែងបានវិសជ្ជនា ១ វារៈប៉ុណ្ណោះ ព្រោះប្រៀបធៀបបច្ច័យទាំងអស់ដែលជាសភាគៈ ជាមួយវិបាក ។ បើរួមឥន្ទ្រិយប្បច្ច័យ និងមគ្គប្បច្ច័យចូលទៅក្នុងទីនេះផង រមែងបានវិសជ្ជនា ៤ វារៈ ដែលបានក្នុងទុមូលកន័យជាមួយឥន្ទ្រិយ និងមគ្គប្បច្ច័យទាំងនោះ ។ បើរួមអញ្ញមញ្ញប្បច្ច័យជាមួយបច្ច័យទាំង ២ នោះ ឲ្យនាំវិសជ្ជនាចេញ ២ វារៈ គឺកុសលធម៌ជាបច្ច័យដល់អព្យាកតៈ កុសលធម៌ជាបច្ច័យដល់កុសលធម៌ និងអព្យាកតៈ ។ បណ្តាវិសជ្ជនា ៤ វារៈ ដែលសម្តែងទុកក្នុងហេតាធិបតិទុកៈ រមែងបានវិសជ្ជនា ២ វារៈដ៏សេស ទោះបីបន្ថែមសម្បយុត្តប្បច្ច័យចូលទៅក្នុងទីនោះទៀត ក៏គង់បានវិសជ្ជនា ២ វារៈទាំងនោះឯង ។ បើបន្ថែមវិប្បយុត្តប្បច្ច័យចូលទៅ នឹងបានវិសជ្ជនា ២ វារៈក្រៅអំពីនោះផងដែរ ។ បើបន្ថែមវិបាកប្បច្ច័យ ចូលទៅក្នុងបច្ច័យទាំងនោះ រមែងបានវិសជ្ជនា ១ វារៈ ក្នុងទីគ្រប់អន្លើ ។ បើមិនបន្ថែមបច្ច័យ ដែលមានវិធីគណនាបានតិចជាងហេតាធិបតិទុកៈ ជាមួយអធិបតិប្បច្ច័យ រមែងបានវិសជ្ជនា ៤ វារៈប៉ុណ្ណោះ ។

កាលបន្ថែមចូលទៅផង រមែងបានវិសជ្ជនា ២ វារៈ និង ១ វារៈ ដោយអំណាចនៃបច្ច័យទាំងនោះឯង ។ អ្នកសិក្សា កាលជ្រាបចំនួនដែលបានក្នុងការប្រកបប្រួមគ្នានៃបច្ច័យនោះៗ ដូចពណ៌នាមកនេះហើយ គប្បីពង្រីកចំនួនគឺវិធីរាប់ក្នុងតិមូលកន័យជាដើមតទៅ ។

បណ្ដាយជនាទាំងនេះ យជនា ៤ មុនគេបង្អស់[១] ( សព្វបឋមយជនា ) ព្រះមានព្រះភាគត្រាស់ទុកដោយអំណាចហេតុប្បច្ច័យ ដែលមាន ៩ យជនាដោយសាមញ្ញ មិនមានវិបាកយជនាឡើយ តែក្នុងពេលវិសជ្ជនាអព្យាកតៈជាមួយអព្យាកតៈ រមែងបានវិបាកជាហេតុ ក្នុងទីនេះផង ។ យជនា ៥ បន្ទាប់អំពីនោះ ត្រាស់ទុកដោយអំណាចហេតុដែលជាវិបាក វិបាកដែលជាសហជាត និងរូបដែលជាសហជាត ជាមួយវិបាកទាំងអស់ ក៏ត្រាស់ទុកក្នុងទីនោះផងដែរ ។ បណ្ដាយជនាទាំងនោះ វិបាក និងរូបដែលមានវិបាកនោះជាសមុដ្ឋាន រមែងបានក្នុងយជនាដំបូង ។ វិបាក និងវត្ថុរូបក្នុងបដិសន្ធិកាលបានក្នុងយជនាទី ២ ។ ក្នុងយជនាទី ៣ បានចំពោះអរូបធម៌តែម្យ៉ាង ។ យជនាទី ៤ បានចំពោះរូបដែលមានវិបាកចិត្តជាសមុដ្ឋានតែម្យ៉ាង យជនាទី ៥ បានចំពោះវត្ថុរូបប៉ុណ្ណោះ ។

យជនា ១៥ បន្ទាប់អំពីនោះទាក់ទងនឹងឥន្ទ្រិយ ត្រាស់ទុកដោយអំណាច

---

១- ក្នុងហេតុយជនា មានយជនា ២៤ គឺសាមញ្ញយជនា ៩ សឥន្ទ្រិយមគ្គយជនា ៩ សាធិបតិឥន្ទ្រិយមគ្គយជនា ៦ ( សូមរាប់ត្រង់លេខឃ្នាបទី ៣ គឺ ១ កថាខណ្ឌជា ១ យជនា ) ក្នុងបច្ច័យដ៏សេស គប្បីជ្រាបយជនាក្នុងទីនោះៗ ចុះ ។

អមោហហេតុ ។ បណ្តាយជនា ១៥ នោះ ពួកទី ១ មាន ៩ យជនា មិនមានអធិបតី ។ ពួកខាងក្រោយ មាន ៦ យជនា មានអធិបតី ។ បណ្តាយជនាដែលមិនមានអធិបតី ៤ យជនាដំបូង ក្នុងទីគ្រប់អន្វើ ត្រាស់ដោយអមោហហេតុ ដូចគ្នាទាំងអស់ដោយសាមញ្ញ ។ យជនា ៥ ខាងក្រោយ ត្រាស់ដោយអំណាចអមោហហេតុដែលជាវិបាក ។

បណ្តាយជនាដែលមិនមានអធិបតីទាំងនោះ យជនាដំបូង ទ្រង់សម្តែងទុកក្នុងហេតាធិបតិទុកៈខាងដើមថា មាន ៤ វារៈ ។ ក្នុងយជនាទី ២ កាត់ ( ដក ) រូបដែលមានចិត្តជាសមុដ្ឋាន ។ ក្នុងយជនាទី ៣ មិនមានវត្ថុរូប ។ ក្នុងយជនាទី ៤ បានកុសលធម៌ ជាបច្ច័យដល់ចិត្តជរូប អព្យាកតៈ រមែងបានរូបដែលមានអព្យាកតៈ ជាសមុដ្ឋានប៉ុណ្ណោះ ( ចិត្តជរូប និងបដិសន្ធិ-កម្មជរូប ) ។ យជនាទី ៥ ដែលប្រកបដោយវិបាកក្រៅអំពីនោះ មានន័យដូចពោលហើយខាងដើម ។ បណ្តាយជនាដែលមានអធិបតី ៣ ខាងដើម ត្រាស់ទុកដោយអំណាចនៃហេតុ ទាំងដែលជាវិបាក និងមិនមែនវិបាក ដោយសាមញ្ញ ។ បណ្តាយជនាទាំងនោះ ក្នុងយជនាទី ១ មាន ៤ វារៈ មានន័យដូចពោលហើយនោះឯង ។ ក្នុងយជនាទី ២ មិនមានរូប ។ ក្នុងយជនាទី ៣ មិនមានអរូប ។ ៣ យជនាបន្ទាប់អំពីនោះ ត្រាស់ទុកដោយអំណាចនៃហេតុខាងវិបាក ។ បណ្តាយជនាទាំងនោះ យជនាទី ១ បានទាំងរូប និងនាម ។ យជនាទី ២ បានតែនាមប៉ុណ្ណោះ ។ យជនាទី ៣ បានចំពោះរូប ។

អ្នកសិក្សា កាលជ្រាបវិធីគណនា ដែលបានក្នុងការប្រកបរួមនៃបច្ច័យនោះៗ ដូចពណ៌នាមកហើយ គប្បីប្រកបវិធីគណនាក្នុងតិមូលកន័យជាដើមតទៅ ។

## ហេតុមូលកន័យ ចប់

[ ៤-៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងយជនា ដែលមានអារម្មណ៍ជាមូល ដូចតទៅនេះថា បច្ច័យ ៧ មានអធិបតិប្បច្ច័យជាដើម ជាសភាគៈជាមួយអារម្មណប្បច្ច័យ បច្ច័យដែលសេសសល់ ១៦ ជាវិសភាគៈ ព្រោះហេតុនោះ កុំបីប្រកបបច្ច័យ ១៦ នោះជាមួយនឹងអារម្មណប្បច្ច័យ ប្រកបចំពោះ ៧ បច្ច័យប៉ុណ្ណោះ ។ បណ្ដាបទទាំងនោះ បទថា **អធិបតិយា សត្ត** សេចក្ដីថា ក្នុងអធិបតិប្បច្ច័យ មានវិសជ្ជនា ៧ វារៈ គឺវិសជ្ជនា ៣ វារៈ ដែលមានកុសលជាមូលយ៉ាងនេះ គឺកុសលធម៌ជាបច្ច័យដល់កុសលធម៌ ១ ដល់អកុសលធម៌ ១ ដល់អព្យាកតធម៌ ១ វិសជ្ជនា ១ វារៈ មានអកុសលជាមូល វិសជ្ជនា ៣ វារៈ មានអព្យាកតៈជាមូល ។ បទថា **និស្សយេ តីណិ** គឺវិសជ្ជនា ៣ វារៈ មានអព្យាកតៈជាមូល ដោយអំណាចនៃវត្ថុនោះឯង ។ បទថា **ឧបនិស្សយេ សត្ត** ដូចដែលពោលទុកខាងដើម ។ បទថា **បុរេជាតេ តីណិ** គឺវិសជ្ជនា ៣ វារៈ ដែលមានអព្យាកតៈជាមូលដោយអំណាចវត្ថុ និងអារម្មណ៍ ។ បទថា **វិប្បយុត្តេ តីណិ** គឺវិសជ្ជនា ៣ វារៈ មានអព្យាកតៈជាមូល ដោយអំណាចវត្ថុតែម្យ៉ាង ។ បទថា **អត្ថិ-អវិគតេសុ តីណិ** គឺវិសជ្ជនា ៣ វារៈ មានអព្យាកតៈជាមូលដោយអំណាច

វត្ថុ និងអារម្មណ៍ ដូចក្នុងហេតុមូលកន័យ ។ លោកតាំងយជនាទុក ដើម្បីសម្តែងគោលកំណត់យ៉ាងណា សូម្បីក្នុងអារម្មណមូលកន័យជាដើមក៏យ៉ាងនោះដូចគ្នា ។

បណ្តាយជនាទាំងនោះ យជនា ៥ ដែលលោកតាំងទុកក្នុងអារម្មណ-មូលកន័យនេះ យជនាទី ១ ក្នុងយជនាទាំងនោះ មានអធិបតីដោយអំណាចអារម្មណាធិបតិប្បច្ច័យ ។ បណ្តាបទទាំងនោះ បទថា **សត្ត** គឺវិសជ្ជនាដែលបានក្នុងអារម្មណាធិបតិទុក:នោះឯង ។ យជនាទី ២ មិនមានអធិបតី ។ បណ្តាបទទាំងនោះ បទថា **តីណិ** គឺវិសជ្ជនា ដែលមានអព្យាកត:ជាមូលដោយអំណាចនៃវត្ថុ និងអារម្មណ៍ឬអារម្មណ៍តែម្យ៉ាង ។ យជនាទី ៣ ប្រកបក្នុងនិស្សយប្បច្ច័យ ។ បណ្តាបទទាំងនោះ បទថា **តីណិ** គឺមានអព្យាកត:ជាមូលដោយអំណាចវត្ថុ ។ យជនាទី ៤ និងយជនាទី ៥ មានអធិបតីក្នុងយជនា ២ នោះ បទថា **ឯកំ** ក្នុងយជនាទី ៤ បានដល់ អកុសលដែលមានអព្យាកត:ជាមូលដោយអំណាចវត្ថុ និងអារម្មណ៍ ឬដោយអំណាចអារម្មណ៍តែម្យ៉ាង ។ បទថា **ឯកំ** ក្នុងយជនាទី ៥ បានដល់ អកុសលដែលមានអព្យាកត:ជាមូល ដោយជានិស្សយប្បច្ច័យ ។

អ្នកសិក្សាគប្បីជ្រាបវិធីរាប់ក្នុងតិមូលកន័យជាដើម ដោយអំណាចបច្ច័យដែលបានក្នុងអធិការនេះ ដូចពណ៌នាមកហើយ ។ ក្នុងន័យដែលមានអធិប-តិប្បច្ច័យជាមូល ក៏ដូចគ្នា ។ តែសម្រាប់ខ្ញុំ នឹងមិនពោលអធិប្បាយដោយពិស្តារដោយអំណាចអារម្មណ ឥន្ទ្រិយ និងវិបាកប្បច្ច័យ នឹងពោលចំពោះ

តែសមគួរក្នុងទីនោះៗ ប៉ុណ្ណោះ ។

[ ៦-៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអធិបតិមូលកន័យ ដូចតទៅនេះថា បទថា **សហជាតេ សត្ត** គឺវិសជ្ជនា ៣ វារៈ មានកុសលជាមូលដោយអំណាចសហជាតាធិបតិប្បច្ច័យ វិសជ្ជនា ៣ វារៈ មានអកុសលជាមូល វិសជ្ជនា ១ វារៈទៀត មានអព្យាកតៈជាមូល ។ អារម្មណាធិបតិប្បច្ច័យ រមែងមិនបានសហជាតប្បច្ច័យ សហជាតប្បច្ច័យ ក៏រមែងមិនបានអារម្មណាធិបតិប្បច្ច័យ ។ បទថា **អញ្ញមញ្ញេ តីណិ** គឺមានវិសជ្ជនា ៣ វារៈ ដោយអំណាចសហជាតាធិបតិប្បច្ច័យប៉ុណ្ណោះ ។ បទថា **និស្សយេ អដ្ឋ** គឺមានកុសលជាមូល ៣ វារៈ មានអកុសលជាមូល ៣ វារៈ មានអព្យាកតៈជាមូល ២ វារៈ ។ ពិតហើយ អធិបតីដែលជាអព្យាកតៈ រមែងជាទីអាស្រ័យនៃអព្យាកតធម៌ដោយជាសហជាតប្បច្ច័យ និងអារម្មណប្បច្ច័យ ជាទីអាស្រ័យនៃអកុសល ដោយជាអារម្មណប្បច្ច័យតែម្យ៉ាង តែមិនជាទីអាស្រ័យនៃកុសលធម៌ដោយប្រការទាំងពីរ ។ វិសជ្ជនាដែលមានអព្យាកតៈជាមូល មាន ២ វារៈប៉ុណ្ណោះ រួមជាវិសជ្ជនា ៨ វារៈ ដោយអធិប្បាយមកនេះ ។

វិសជ្ជនា ៧ វារៈ ក្នុងឧបនិស្សយប្បច្ច័យ ដូចគ្នានឹងអារម្មណប្បច្ច័យនោះឯង ។ បទថា **បុរេជាតេ ឯកំ** គឺអព្យាកតាធិបតី ជាបច្ច័យដល់អកុសល ដោយអំណាចអារម្មណ៍ ។ បទថា **វិបាកេ ឯកំ** គឺលោកុត្តរអព្យាកតៈជាមួយនឹងអព្យាកតៈ ។ វិសជ្ជនា ៧ វារៈ ក្នុងអាហារប្បច្ច័យជាដើម បានហើយក្នុងឯកមូលកន័យខាងដើមនោះឯង ។ បទថា **វិប្បយុត្តេ**

**ចត្តារិ** គឺអព្យាកតៈជាមួយកុសល អព្យាកតៈជាមួយអកុសល អព្យាកតៈជាមួយអព្យាកតៈ និងកុសលជាមួយអព្យាកតៈ ។ វិសជ្ជនា ៨ វារៈ ក្នុងអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ដូចគ្នានឹងនិស្សយប្បច្ច័យនោះឯង ។

ក្នុងអធិការនេះយជនាទាំងឡាយ លោកមិនប្រកបជាមួយអារម្មណប្បច្ច័យជាដើមតាមលំដាប់ ប្រកបជាមួយអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យមុន ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះរួមអធិបតីទាំងពីរបច្ច័យជាមួយគ្នា ។

បណ្តាយជនាទាំងនោះ ក្នុងយជនាដើម បានវត្ថុដែលជាអារម្មណ៍ គឺវត្ថារម្មណៈ ដោយអារម្មណាធិបតិប្បច្ច័យ ។

ក្នុងយជនាទី ២ បានវត្ថុតែម្យ៉ាង សម្រាប់បុគ្គលដែលត្រេកអរក្រៃលែងដោយអំណាចជាទីអាស្រ័យ សម្រាប់បុគ្គលដែលធ្វើឲ្យធ្ងន់ ដោយអំណាចជាទីអាស្រ័យ ហើយត្រេកអរ ។

ក្នុងយជនាទី ៣ បានធម៌ មានកុសលជាដើមជាបច្ច័យដល់រូបទាំងឡាយ ដោយសហជាតាធិបតិប្បច្ច័យ ។ បានវត្ថុជាបច្ច័យ ដល់អកុសល ដោយអារម្មណាធិបតិប្បច្ច័យ ។ យជនា ៣ ក្រៅអំពីនោះ ត្រាស់ដោយអំណាចអារម្មណាធិបតិប្បច្ច័យ ។

បណ្តាយជនាទាំងនោះ បទថា **សត្ត** ក្នុងយជនាទី ១ ខ្ញុំពោលស្រេចបាច់ហើយខាងដើមនោះឯង ។

បទថា **ឯកំ** ក្នុងយជនាទី ២ គឺវត្ថុ និងអារម្មណ៍ដែលកើតមុនជាបច្ច័យដល់អកុសល ។ ក្នុងយជនាទី ៣ វត្ថុប៉ុណ្ណោះ ជាបច្ច័យដល់អកុសល ។

*យជនា ៣ បន្ទាប់អំពីនោះ ទូទៅដល់ធម៌ដែលជាវិបាកផង មិនមែនវិបាកផង ត្រាស់ដោយអំណាចសហជាតាធិបតិប្បច្ច័យ ។ បណ្ដាយជនាទាំងនោះ ក្នុងយជនាទី ១ បានទាំងរូប និងអរូប ។*

*យជនាទី ២ បានចំពោះអរូបតែម្យ៉ាង យជនាទី ៣ បានរូបប៉ុណ្ណោះ ។ យជនា ៣ ក្រៅអំពីនោះ ត្រាស់ដោយអំណាចវិបាកាធិបតិប្បច្ច័យ ។*

*បណ្ដាយជនា ៣ នោះ យជនាទី ១ បានទាំងរូប និងអរូប ។ យជនាទី ២ បានអរូប ។ យជនាទី ៣ បានចំពោះរូបប៉ុណ្ណោះ ។ យជនា ៦ បន្ទាប់អំពីនោះ ប្រកបដោយអាហារ និងឥន្ទ្រិយប្បច្ច័យ ត្រាស់ដោយអំណាចនៃចិត្តាធិបតិប្បច្ច័យ ។ បណ្ដាយជនា ៦ យជនាទាំងនោះ មិនមានវិបាក ៣ មានវិបាក ៣ ។ វិធីរាប់ក្នុងយជនាទាំងនោះ ជាក់ច្បាស់ហើយ ។ យជនា ៦ បន្ទាប់អំពីនោះ ត្រាស់ដោយអំណាចវីរិយាធិបតី ។*

*សួរថា បើពោលតាមលំដាប់អធិបតីហើយ ព្រះមានព្រះភាគគប្បីត្រាស់យជនាដោយអំណាចវីរិយាធិបតីជាលំដាប់ដំបូង មិនមែនឬ តែហេតុអ្វីទើបទ្រង់មិនត្រាស់យ៉ាងនោះ ឆ្លើយថា ព្រោះយជនាទាំងនោះ ដូចគ្នានឹងយជនាដែលត្រាស់ដោយអំណាចហេតុខាងមុខ ។ ពិតហើយ យជនាដែលត្រាស់ដោយអំណាចហេតុខាងមុខ ទាក់ទងដោយមគ្គ ព្រោះអមោហ-ហេតុ ជាវីមំសាធិបតី និងព្រោះវីមំសាធិបតី ជាតួសម្មាទិដ្ឋិ ។ ម្យ៉ាងទៀតសូម្បីវីរិយៈ ក៏ចាត់ជាមគ្គ ព្រោះជាសម្មាវាយាមៈ និងមិច្ឆាវាយាមៈ ព្រោះហេតុនោះ យជនាទាំងឡាយ ទើបព្រះមានព្រះភាគ ត្រាស់បង្កិលជាមួយនឹង*

វីរិយៈនោះថា ដូចគ្នានឹងយជនាដែលត្រាស់ដោយអំណាចនៃហេតុខាងមុខ ។ វិធីគណនាក្នុងយជនាទាំងនោះ ជាក់ច្បាស់ហើយនោះឯង ។

[ ៨-១១ ] បទថា **សត្ត** ក្នុងយជនាដែលមានអនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យជាមូល សេចក្ដីថា មានវិសជ្ជនា ៧ វារៈយ៉ាងនេះ គឺកុសលជាបច្ច័យដល់កុសល និងដល់អព្យាកតៈ អកុសលជាបច្ច័យដល់អកុសល និងដល់អព្យាកតៈ អព្យាកតៈជាបច្ច័យដល់កុសល ដល់អកុសល និងដល់អព្យាកតៈទាំង ៣ ។ បទថា **កម្មេ ឯកំ** គឺកុសលមគ្គចេតនា ជាបច្ច័យដល់វិបាកាព្យាកតៈរបស់ខ្លួន ក្នុងបច្ច័យទាំងនោះ មានយជនា ៣ ប៉ុណ្ណោះ យជនាទាំងនោះ ប្រកបតាមលំដាប់វិសជ្ជនាដែលមានវារៈច្រើន ។

គប្បីជ្រាបវិនិច្ឆ័យក្នុងយជនាដែលមានសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និងនិស្សយប្បច្ច័យជាមូល ដូចតទៅនេះថា បច្ច័យណាមួយ ដែលត្រាស់ក្នុងទុមូលកន័យ បច្ច័យនោះ ជាសភាគៈជាមួយបច្ច័យដែលនៅខាងដើម ព្រោះហេតុនោះ អ្នកសិក្សា កាលជ្រាបវិធីគណនាក្នុងទុមូលកន័យហើយ គប្បីជ្រាបវិធីគណនាក្នុងយជនាទាំងឡាយ ក្នុងទីគ្រប់អន្លើ ដោយអំណាចបច្ច័យដែលគណនាបានតិចជាងបណ្ដាបច្ច័យដែលនាំមកភ្ជាប់ខាងចុង ។

[ ១២-១៣ ] បណ្ដាយជនាទាំងនោះ យជនាដែលមានសហជាតប្បច្ច័យជាមូល មាន ១០ យជនា ក្នុងយជនា ១០ នោះ ដែលជាអវិបាកយជនា មាន ៥ ជាសវិបាកយជនា មាន ៥ ។

ក្នុង ២ យ៉ាងនោះនឹងពណ៌នាអវិបាកយជនាមុន ក្នុងយជនាទី ១ មាន

វិសជ្ជនា ៩ វារៈយ៉ាងនេះ គឺកុសលជាបច្ច័យដល់កុសល ដល់អព្យាកតៈ និងដល់កុសលាព្យាកតៈ កុសលាព្យាកតៈជាបច្ច័យដល់អព្យាកតៈ រួមជា ៤ វារៈ ។ អកុសលជាបច្ច័យដល់អកុសល ដល់អព្យាកតៈ ដល់អកុស-លាព្យាកតៈ អកុសលាព្យាកតៈជាបច្ច័យដល់អព្យាកតៈ អព្យាកតៈជាបច្ច័យដល់អព្យាកតៈប៉ុណ្ណោះ ។ បណ្ដាវិសជ្ជនាទាំងនោះ ក្នុងវិសជ្ជនា ៨ វារៈ មានកុសល និងអកុសលជាដើម បានទាំងអរូប និងរូប ដែលមានចិត្តជាសមុដ្ឋាន ក្នុងអព្យាកតៈ បានវត្ថុរូប ។ បណ្ដារូបទាំងឡាយ វត្ថុរូបប៉ុណ្ណោះមានក្នុងវិសជ្ជនា ចំណែកអព្យាកតៈ ក្នុងឃដនាទី ២ ។

បណ្ដាឃដនាទី ៣ អរូបប៉ុណ្ណោះ មានក្នុងឃដនាទី ៣ ។ ក្នុងឃដនាទី ៤ បានចំពោះរូប ដែលមានចិត្តជាសមុដ្ឋានប៉ុណ្ណោះ ។ ក្នុងឃដនាទី ៥ បានអរូបធម៌ និងវត្ថុរូបក្នុងបដិសន្ធិកាល ។ ក្នុងសវិបាកឃដនា ក្នុងឃដនាទី ១ បានវិបាកចិត្ត និងរូបដែលមានវិបាកចិត្តជាសមុដ្ឋាន ។ ក្នុងឃដនាទី ២ បានវិបាក និងវត្ថុរូប ។ ក្នុងឃដនាទី ៣ បានវិបាកតែម្យ៉ាង ។ ក្នុងឃដនាទី ៤ បានរូបដែលមានវិបាកចិត្តជាសមុដ្ឋានតែម្យ៉ាង ។ ក្នុងឃដនាទី ៥ បានចំពោះវត្ថុរូប ។

[ ១៤-១៥ ] ក្នុងអញ្ញមញ្ញមូលកន័យ មានឃដនា ៦ បណ្ដាឃដនា ៦ នោះ ឃដនា ៣ ដំបូង ជាអវិបាកឃដនា ឃដនា ៣ ខាងចុងជាសវិបាក-ឃដនា ។ វិធីគណនាក្នុងឃដនាទាំងនោះ ជាក់ច្បាស់ហើយ ។

[ ១៦-១៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងន័យ ដែលមាននិស្សយបច្ច័យ ជា

មូល ដូចតទៅនេះថា បទថា **និស្សយប្បច្ចយា អារម្មណេ តីណិ** អ្នកសិក្សាគប្បីជ្រាបវិសជ្ជនា ៣ វារៈ ដោយអំណាចនៃកុសលជាដើមដែលលើកវត្ថុឡើងជាអារម្មណ៍ប្រព្រឹត្តទៅ គឺប្រព្រឹត្តទៅដោយយកវត្ថុជាអារម្មណ៍ ។ បទថា **ឧបនិស្សយេ ឯកំ** គឺអកុសលដែលទាញយកវត្ថុ ជាអារម្មណូបនិស្សយប្បច្ច័យកើតឡើង ។ ពាក្យដ៏សេស គប្បីជ្រាបតាមន័យដែលខ្ញុំពោលហើយ ក្នុងទុកមូលកន័យខាងដើមនោះឯង ។

ក្នុងនិស្សយប្បច្ច័យនេះ មានយជនា ២០ ។ បណ្ដាយជនាទាំងនោះ ៦ យជនាខាងដើម ត្រាស់ដោយអំណាចសហជាត និងបុរេជាត ។ យជនា ៤ បន្ទាប់អំពីនោះ ត្រាស់ដោយអំណាចបុរេជាតតែម្យ៉ាង ។ យជនា ១០ ទៀត ត្រាស់ដោយអំណាចសហជាតតែម្យ៉ាង ។

បណ្ដាយជនាទាំងនោះ បទថា **តេរស** ក្នុងយជនាទី ១ បានដល់ វិសជ្ជនា ១៣ វារៈ ដែលព្រះមានព្រះភាគ ត្រាស់ក្នុងនិស្សយប្បច្ចយវិភង្គនោះឯង ។ បទថា **អដ្ឋ** ក្នុងយជនាទី ២ បានដល់ វិសជ្ជនា ៨ វារៈ គឺវិសជ្ជនា ៧ វារៈ ដោយអំណាចនៃសហជាតាធិបតិប្បច្ច័យ និង ១ វារៈ ដែលជាអកុសលដោយធ្វើវត្ថុឲ្យធ្ងន់ ។

បទថា **សត្ត** ក្នុងយជនាទី ៣ គឺវិសជ្ជនា ៧ វារៈ ដែលបានហើយក្នុងឥន្ទ្រិយប្បច្ច័យនោះឯង ។

បទថា **បញ្ច** ក្នុងយជនាទី ៤ គឺវិសជ្ជនា ៥ វារៈ ដែលបានហើយក្នុងវិប្បយុត្តប្បច្ច័យនោះឯង ។

បទថា **ចត្តារិ** ក្នុងយជនាទី ៥ បានដល់ វិសជ្ជនាដែលមានកុសលជាដើម ជាបច្ច័យដល់រូប ដែលមានចិត្តជាសមុដ្ឋាន និងវត្ថុជាបច្ច័យដល់អកុសល ។

បទថា **តីណិ** ក្នុងយជនាទី ៦ គឺកុសលជាដើមជាបច្ច័យដល់រូបដែលមានចិត្តជាសមុដ្ឋាន ។ បណ្ដាយជនា ៤ ដោយអំណាចនៃបុរេជាតប្បច្ច័យ បទថា **តីណិ** ក្នុងយជនាទី ១ វត្ថុជាបច្ច័យដល់កុសលជាដើម និងវត្ថុ មានចក្ខុជាដើម ជាបច្ច័យដល់អព្យាកតៈ ។ ក្នុងយជនាទី ២ វត្ថុប៉ុណ្ណោះ ជាបច្ច័យដល់កុសលជាដើម ។ ក្នុងយជនាទី ៣ បទថា **ឯកំ** គឺវត្ថុជាបច្ច័យដល់អកុសល ។ ក្នុងយជនាទី ៤ វត្ថុ មានចក្ខុជាដើម ជាបច្ច័យដល់បញ្ចកៈនៃវិញ្ញាណចិត្ត គឺទ្វិបញ្ចវិញ្ញាណ ។ អ្នកសិក្សាគប្បីជ្រាបដោយន័យដែលខ្ញុំចែកយជនា ១០ ចេញជាពីរចំណែក គឺសវិបាកយជនា និងអវិបាកយជនា ដោយសហជាតប្បច្ច័យ ហើយពោលក្នុងសហជាតមូលកន័យ ។

[ ១៨-១៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងយជនាដែលមានឧបនិស្សយប្បច្ច័យជាមូល ដូចតទៅនេះថា បទថា **អារម្មណោ សត្ត** គឺវិសជ្ជនាដែលបានក្នុងអារម្មណូបនិស្សយប្បច្ច័យ ។ បទថា **អធិបតិយា សត្ត** ក៏បានដល់វារៈទាំងនោះដូចគ្នា ។ បណ្ដាអនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យ វិសជ្ជនាទាំងនោះឯង បានក្នុងអនន្តរូបនិស្សយប្បច្ច័យផងដែរ ។ បទថា **និស្សយេ ឯកំ** គឺវត្ថុជាបច្ច័យដល់អកុសល ។ បទថា **បុរេជាតេ ឯកំ** បានដល់ វត្ថុ ឬ អារម្មណ៍ ជាបច្ច័យដល់អកុសលនោះឯង ។ បទថា **អាសេវនេ តីណិ**

ត្រាស់ដោយអំណាចអនន្តរូបនិស្សយប្បច្ច័យ ។ បទថា **កម្មំ ចេ** ត្រាស់ដោយអំណាចបកតូបនិស្សយប្បច្ច័យ តែលោកុត្តរកុសលចេតនា រមែងជាអនន្តរូបនិស្សយប្បច្ច័យផងដែរ ។ បទថា **វិប្បយុត្តេ ឯកំ** ត្រាស់ដោយអំណាចអារម្មណូបនិស្សយប្បច្ច័យ ។ ក្នុងអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យក៏ដូចគ្នា ។

វិសជ្ជនា ៧ វារៈ ក្នុងនត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ដូចគ្នានឹងអនន្តរប្បច្ច័យ ។

យជនាដែលមានឧបនិស្សយប្បច្ច័យជាមូល មាន ៧ យជនា បណ្ដាយជនាទាំងនោះ យជនា ៣ ខាងដើម ទ្រង់ត្រាស់ដោយអំណាចអារម្មណូបនិស្សយប្បច្ច័យ ។ ក្នុងយជនា ៣ នោះ យជនាទី ១ បទថា **សត្ត** សេចក្ដីថា មានវិសជ្ជនា ៧ យ៉ាងនេះ គឺកុសលជាបច្ច័យដល់កុសលជាដើម អព្យាកតៈក៏ដូចគ្នា ( រួមជា ៦ ) អកុសលជាបច្ច័យដល់អកុសលតែម្យ៉ាង ។ បទថា **ឯកំ** ក្នុងយជនាទី ២ សេចក្ដីថា អព្យាកតៈ មានចក្ខុជាដើម ជាបច្ច័យដល់អកុសល ។

ក្នុងយជនាទី ៣ បានដល់ វត្ថុជាបច្ច័យដល់អកុសល ។ យជនា ២ បន្ទាប់អំពីនោះ ត្រាស់ដោយអំណាចអនន្តរូបនិស្សយប្បច្ច័យ ។ ការរាប់ក្នុងយជនាទាំងនោះ ជាក់ច្បាស់ហើយ ។ បន្ទាប់អំពីនោះ យជនា ២ ទៀត ត្រាស់ដោយអំណាចអនន្តរូបនិស្សយប្បច្ច័យ និងបកតូបនិស្សយប្បច្ច័យ ។ ក្នុងយជនា ២ នោះ លោកិយកុសល និងអកុសលចេតនា លោកកាន់យក

ដោយភាពជាបច្ច័យក្នុងយជនាទី ១ ឯក្នុងយជនាទី ២ កាន់យកលោកុត្តរ-កុសលតែម្យ៉ាង ។

[ ២០-២១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងយជនា ដែលមានបុរេជាតប្បច្ច័យជាមូល ដូចតទៅនេះថា បទថា **អារម្មណេ តីណិ** គឺអព្យាកតៈ ជាបច្ច័យដល់កុសលជាដើម ។ បទថា **អធិបតិយា ឯកំ** គឺអព្យាកតៈ ជាបច្ច័យដល់អកុសល ។ ក្នុងយជនាដ៏សេសក៏ន័យនេះដូចគ្នា ។ ក្នុងន័យនេះ មានយជនា ៧ ពួក ក្នុងយជនាទាំងនោះ យជនាទី ១ ត្រាស់ដោយអំណាចវត្ថុនិងអារម្មណ៍ ។ យជនាទី ២ ត្រាស់ដោយអំណាចវត្ថុ ។ យជនាទី ៣ ត្រាស់ដោយអំណាចអារម្មណ៍ ។ យជនាទី ៤ ត្រាស់ដោយអំណាចនៃវេលាដែលវត្ថុជាអារម្មណ៍ ។ យជនាទី ៥ ត្រាស់ដោយអំណាចអារម្មណា-ធិបតិប្បច្ច័យ ។ យជនាទី ៦ ត្រាស់ដោយអំណាចវេលា ដែលវត្ថុជាអារម្មណាធិបតី ។ យជនាទី ៧ ត្រាស់ដោយអំណាចចក្ខុវត្ថុជាដើម ។

[ ២២-២៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងយជនា ដែលមានបច្ឆាជាតប្បច្ច័យជាមូលដូចតទៅនេះថា បច្ច័យ ២០ រមែងប្រកបមិនបាន ប្រកបបានចំពោះបច្ច័យ ៣ ប៉ុណ្ណោះ ក្នុងន័យនេះមានយជនា ១ ប៉ុណ្ណោះឯង យជនានោះគប្បីជ្រាបដោយអំណាចកុសលជាដើម ជាបច្ច័យដល់កាយ ។ ក្នុងន័យដែលមានអាសេវនប្បច្ច័យជាមូល ក៏មានយជនា ១ ដូចគ្នា ។

[ ២៤-២៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងយជនា ដែលមានកម្មប្បច្ច័យជាមូលដូចតទៅនេះថា បទថា **អនន្តរេ ឯកំ** លោកពោលដោយអំណាចចេតនា

ក្នុងមគ្គ ។ ក្នុងបទថា **អញ្ញមញ្ញោ តីណិ** គប្បីកាន់យក សុម្បីវត្ថុក្នុងបដិសន្ធិកាលផងដែរ ។ បទថា **ឧបនិស្សយេ ទ្វេ** គឺវារៈ ២ ដែលពោលខាងដើម ដោយអំណាចអនន្តរូបនិស្សយប្បច្ច័យ និងបកតូបនិស្សយប្បច្ច័យ ។ សូម្បីយជនាដ៏សេស គប្បីជ្រាបតាមន័យដែលពោលហើយខាងដើមនោះឯង ។ ក្នុងន័យនេះ មានយជនា ១១ ពួក បណ្ដាយជនាទាំងនោះ យជនា ២ ដំបូង ត្រាស់ដោយអំណាចនានាខណិកកម្មប្បច្ច័យ ដោយចែកជាបកតូបនិស្សយ និងអនន្តរូបនិស្សយ បន្ទាប់អំពីនោះទៀត ៤ យជនាត្រាស់ដោយអំណាចឯកខណិកកម្មប្បច្ច័យ អំពីធម៌ទាំងដែលជាសវិបាក និងអវិបាក ។ ក្នុងយជនា ៤ នោះ យជនាទី ១ បានចិត្តសមុដ្ឋានរូប ព្រមទាំងអរូប ។ យជនាទី ២ បានវត្ថុ ព្រមទាំងអរូប ។ យជនាទី ៣ បានចំពោះអរូបតែម្យ៉ាង ។ យជនាទី ៤ បានចំពោះចិត្តសមុដ្ឋានរូប ចំណែកកដត្តារូប បានក្នុងបដិសន្ធិកាល ។

យជនា ៥ ទៀត បន្ទាប់អំពីនោះ ជាសវិបាក មានន័យដូចខ្ញុំពោលហើយខាងដើមនោះឯង ។

[ ២៦-២៧ ] យជនា ៥ ក្នុងន័យដែលមានវិបាកប្បច្ច័យជាមូល មានអត្ថក្លីច្បាស់ហើយ ។

[ ២៨-២៩ ] បទថា **សត្ត** ជាដើម ក្នុងន័យដែលមានអាហារប្បច្ច័យជាមូល មានន័យដូចខ្ញុំពោលហើយនោះឯង ។ ក្នុងន័យនេះ មានយជនា ៣៤ ។ បណ្ដាយជនាទាំងនោះ យជនា ៥ ដំបូង លោកពោលដោយ

សវិបាកយជនាផង អវិបាកយជនាផង ។ ក្នុងយជនានោះ អាហារទាំង ៤ រមែងបានក្នុងយជនាទី ១ ។ចំពោះនាមអាហារ ៣ បានក្នុងយជនាទី ២ ។ យជនាទី ៣ មានវត្ថុជាបច្ចយុប្បន្នផងដែរ ។ ក្នុងយជនាទី ៤ មិនមានវត្ថុ ។ ក្នុងយជនាទី ៥ មានរូបប៉ុណ្ណោះ ជាបច្ចយុប្បន្ន ។ យជនា ៥ បន្ទាប់អំពីនោះ មានន័យដូចខ្ញុំពោលហើយខាងដើមនោះឯង ។

យជនា ៩ បន្ទាប់អំពីនោះ ព្រះមានព្រះភាគ ត្រាស់ដោយអំណាចនៃអាហារ គឺចេតនា ( មនោសញ្ចេតនាហារ ) ។ យជនា ៩ បន្ទាប់អំពីនោះ ត្រាស់ដោយអំណាចវិញ្ញាណាហារដែលមិនមានអធិបតី ។ យជនា ៦ បន្ទាប់អំពីនោះ ត្រាស់ដោយអំណាចវិញ្ញាណាហារ ដែលមានអធិបតី ក្នុងយជនា ៦ នោះ យជនា ៣ ត្រាស់ដោយអំណាចធម៌ ដែលជាសវិបាក-យជនាផង អវិបាកយជនាផង ( រួមគ្នា ) យជនា ៣ ទៀត ត្រាស់ដោយអំណាចសវិបាកយជនាតែម្យ៉ាង ក្នុងយជនា ៣ នោះ មិនមានវត្ថុរូប ព្រោះមិនមានលោកិយវិបាក ។

[ ៣០-៣១ ] បទថា **ឫបេជាតេ ឯកំ** ក្នុងន័យដែលមានឥន្ទ្រិយប្បច្ច័យជាមូល មានយជនា ១ គឺអព្យាកតៈជាមួយអព្យាកតៈ ដោយអំណាចនៃចក្ខុន្ទ្រិយជាដើម ។

យជនាដែលមានមូល ២ ដ៏សេស គប្បីជ្រាបតាមន័យដែលខ្ញុំពោលហើយខាងដើម ។ ក្នុងន័យនេះ មានយជនា ៧៦ ។

បណ្តាយជនា ៧៦ នោះ យជនាទី ១ បានឥន្ទ្រិយទាំងអស់ ដោយ

អត្ថថា ជាបច្ច័យ ។ ក្នុងឃដនាទី ២ មិនមានរូបជីវិតិន្ទ្រិយ ព្រោះថារូបជីវិតិន្ទ្រិយនោះ រមែងមិនជាទីអាស្រ័យ ។ ក្នុងឃដនាទី ៣ បានដល់អរូបជីវិតិន្ទ្រិយ ជាបច្ច័យដល់រូប ។ ក្នុងឃដនាទី ៤ បានដល់ ចក្ខុន្ទ្រិយជាដើម ជាបច្ច័យដល់ចក្ខុវិញ្ញាណជាដើម ។ ឃដនា ៩ បន្ទាប់អំពីនោះ ព្រះមានព្រះភាគ ត្រាស់ដោយអំណាចអរូបជីវិតិន្ទ្រិយ ដែលកើតព្រមគ្នា ។ ឃដនា ៩ បន្ទាប់អំពីនោះ ត្រាស់ដោយអំណាចឥន្ទ្រិយ ដែលជាតួមគ្គ ។ ឃដនា ៩ បន្ទាប់អំពីនោះ ត្រាស់ដោយអំណាចឥន្ទ្រិយដែលជាអង្គឈាន ។ ឃដនា ៩ បន្ទាប់អំពីនោះ ត្រាស់ដោយអំណាចឥន្ទ្រិយ ដែលជាឈានផងមគ្គផង ។ ឃដនា ៩ បន្ទាប់អំពីនោះ ត្រាស់ដោយអំណាចមនិន្ទ្រិយតែម្យ៉ាង ។ ឃដនា ៦ បន្ទាប់អំពីនោះ មានអធិបតី ។ ឃដនា ៦ បន្ទាប់អំពីនោះ ប្រកបដោយមគ្គដោយអំណាចវីរិយាធិបតី និងវីមំសាធិបតី ។ ឃដនា ៩ បន្ទាប់អំពីនោះ មិនមានអធិបតី ដោយអំណាចអមោហហេតុ ។ ឃដនា ៦ មានអធិបតី ។ បណ្តាឃដនាទាំងអស់នោះ ឃដនាដែលមិនប្រកប និងប្រកបដោយវិបាកប្បច្ច័យ គប្បីជ្រាបតាមន័យដែលខ្ញុំពោលហើយខាងដើមនោះឯង ។

[ ៣២-៣៣ ] ក្នុងឃដនាដែលមានឈានប្បច្ច័យជាមូល ឃដនាដែលមានមូល ២ គប្បីជ្រាបតាមន័យដែលខ្ញុំពោលហើយខាងដើមដូចគ្នា ។ ក្នុងន័យនេះ មានឃដនា ៣៦ ។ បណ្តាឃដនាទាំងនោះ ឃដនា ៩ ខាងដើម ព្រះមានព្រះភាគត្រាស់ដោយអំណាចអង្គឈានទូទៅ មិនសំដៅដល់ភាពជា

ឥន្ទ្រិយ និងមគ្គឡើយ ។ យជនា ៩ បន្ទាប់អំពីនោះ ត្រាស់ដោយអង្គឈាន ដែលជាឥន្ទ្រិយ ។ យជនា ៩ បន្ទាប់អំពីនោះ ត្រាស់ដោយអង្គឈានដែលជាតួមគ្គ ។ យជនា ៩ បន្ទាប់អំពីនោះ ត្រាស់ដោយអង្គឈាន ដែលជាឥន្ទ្រិយ និងមគ្គ ។ ម្យ៉ាងទៀត បណ្ដាពួក ៩ បួនពួកនេះ យជនា ៤ ខាងដើម ទូទៅដល់វិបាក និងអវិបាក យជនា ៥ ខាងចុង បានវិបាកប៉ុណ្ណោះ ។ យជនាទាំងនោះ ខ្ញុំពោលហើយខាងដើមដូចគ្នា ។

[ ៣៤-៣៥ ] យជនាដែលមានមូល ២ ក្នុងន័យដែលមានមគ្គប្បច្ច័យជាមូល គប្បីជ្រាបតាមន័យដែលខ្ញុំពោលហើយនោះឯង ។ ក្នុងន័យនេះ មានយជនា ៥៧ បណ្ដាយជនាទាំងនោះ យជនា ៩ ខាងដើម ព្រះមានព្រះភាគ ត្រាស់ដោយអង្គមគ្គសុទ្ធៗ មិនបញ្ចូលភាពជាឥន្ទ្រិយ និងឈាន យជនា ៩ បន្ទាប់អំពីនោះ ត្រាស់ដោយអំណាចមគ្គ ដែលជាឥន្ទ្រិយ ។ យជនា ៩ បន្ទាប់អំពីនោះ ត្រាស់ដោយអំណាចមគ្គដែលជាឈាន ។ យជនា ៩ បន្ទាប់អំពីនោះ ត្រាស់ដោយអំណាចមគ្គ ជាឥន្ទ្រិយផង ឈានផង ។ យជនា ៦ បន្ទាប់អំពីនោះ ត្រាស់ដោយមគ្គដែលជាអធិបតី ។ យជនា ៩ បន្ទាប់អំពីនោះ ត្រាស់ដោយមគ្គ និងហេតុដែលមិនជាអធិបតី ។ យជនា ៦ បន្ទាប់អំពីនោះ ត្រាស់ដោយមគ្គ និងហេតុ ដែលជាអធិបតី ។ ក្នុងពួកដែល

មានឃដនា ៩ មាន ៥ ពួក ជាសវិបាកឃដនា មួយពួក ៥ ។ ក្នុងពួក ដែលមានឃដនា ៦ ជាសវិបាកឃដនា មួយពួក ៣ ។ ឃដនាដ៏សេស ជាសាធារណៈ ។ ឃដនាទាំងនោះ មានន័យដូចខ្ញុំពោលហើយ ខាងដើម នោះឯង ។

[ ៣៦-៣៧ ] ឃដនាដែលមានមូល ២ ក្នុងន័យដែលមានសម្បយុត្តប្បច្ច័យជាមូលជាក់ច្បាស់ហើយ ។ ក្នុងន័យនេះមានឃដនា ២ ប៉ុណ្ណោះ ក្នុងឃដនានោះ ឃដនា ១ ព្រះមានព្រះភាគត្រាស់ដោយអំណាចធម៌ទូទៅ ឃដនា ១ ទៀត ត្រាស់ដោយអំណាចនៃវិបាក ។

[ ៣៨-៣៩ ] ក្នុងន័យដែលមានវិប្បយុត្តប្បច្ច័យជាមូល ឃដនាដែល មានមូល ២ ជាក់ច្បាស់ហើយ ។ ក្នុងន័យនេះ មានឃដនា ១៣ បណ្ដា ឃដនាទាំងនោះ បទថា **បញ្ច** ក្នុងឃដនាទី ១ គឺកុសល ជាបច្ច័យដល់ អព្យាកតៈ អកុសល ជាបច្ច័យដល់អព្យាកតៈ អព្យាកតៈ ជាបច្ច័យដល់ កុសល ដល់អកុសល និងដល់អព្យាកតៈទាំង ៣ ។

ក្នុងន័យនេះ មានវិប្បយុត្តប្បច្ច័យជាដើមនេះ កើតព្រមគ្នាក៏មាន កើត ក្រោយ និងកើតមុនក៏មាន ។ ក្នុងឃដនាទី ២ កើតមុន និងកើតព្រមគ្នា ប៉ុណ្ណោះ ។ បច្ច័យទាំងនោះឯង ព្រះមានព្រះភាគត្រាស់ក្នុងឃដនាទី ៣

*ដោយអំណាចនៃអធិបតី ។ បណ្តាបច្ច័យទាំងនោះ បានវារៈ ៤ យ៉ាង គឺ កុសលជាបច្ច័យដល់អព្យាកតៈ អកុសលជាបច្ច័យដល់អព្យាកតៈ តែ អព្យាកតៈ ជាបច្ច័យដល់អព្យាកតៈផង ដល់អកុសលផង ដោយអំណាចនៃ អារម្មណាធិបតិប្បច្ច័យ ។*

*បទថា* **តីណិ** *ក្នុងយជនាទី ៤ គឺកុសលជាដើម ជាបច្ច័យដល់ អព្យាកតៈ ។ ក្នុងទីនេះបានទាំងរូបឥន្ទ្រិយ និងនាមឥន្ទ្រិយ ។ ក្នុងយជនាទី ៥ នាមប៉ុណ្ណោះជាបច្ច័យ ។ ក្នុងយជនាទី ៦ រូប គឺវត្ថុរូបជាបច្ច័យ ។ ក្នុងយជនា ទី ៧ រូបជាបច្ច័យដល់កុសល និងអព្យាកតៈ ដោយអំណាចនៃវិបស្សនា ។ ហទយវត្ថុប៉ុណ្ណោះ ជាបច្ច័យដល់អកុសល ដោយអំណាចជាទីត្រេកអរ ។*

*ក្នុងយជនាទី ៨ ហទយវត្ថុនោះឯង ជាបច្ច័យដល់អកុសល ។ ក្នុង យជនាទី ៩ ចក្ខុជាដើម ជាបច្ច័យដល់អព្យាកតៈ ។ ក្នុងយជនាទី ១០ កុសលជាដើម ជាបច្ច័យដល់រូបដែលមានចិត្តជាសមុដ្ឋាន ។ ក្នុងយជនាទី ១១ វត្ថុជាបច្ច័យដល់ខន្ធទាំងឡាយ ក្នុងបដិសន្ធិកាល ។ ក្នុងយជនាទី ១២ ខន្ធទាំងឡាយជាបច្ច័យដល់កដត្តារូបក្នុងបដិសន្ធិកាល ។ ក្នុងយជនាទី ១៣ ខន្ធទាំងឡាយជាបច្ច័យដល់វត្ថុរូប ក្នុងបដិសន្ធិកាល ។*

[ ៤០-៤២ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងន័យ ដែលមានអត្ថិប្បច្ច័យជាមូល*

ដូចតទៅនេះថា បទថា **ឧបនិស្សយេ ឯកំ** គឺអព្យាកតៈ ជាបច្ច័យដល់អកុសល ដោយអំណាចអារម្មណូបនិស្សយ ។ យជនាដ៏សេស ក្នុងទុមូលកន័យ មានអត្ថងាយយល់ហើយ ។ ក្នុងន័យនេះ មានយជនា ២៩ ។ បណ្តាយជនាទាំងនោះ ក្នុងយជនាទី ១ បានសហជាតប្បច្ច័យ បុរេជាតប្បច្ច័យ និងបច្ឆាជាតប្បច្ច័យ ដោយអំណាចអរូប វត្ថុអារម្មណ៍ មហាភូតរូប ឥន្ទ្រិយ និងអាហារ ។ ក្នុងយជនាទី ២ បានកពឡិង្ការាហារ និងរូបជីវិតិន្ទ្រិយ ដែលកើតខាងក្រោយ ។ យជនាទី ១ និងទី ២ ប៉ុណ្ណោះ ជាមួយអធិបតិប្បច្ច័យ លោកចាត់ជាយជនាទី ៣ និងយជនាទី ៤ ក្នុងយជនាតទៅ[១] ។ ចំពោះយជនាទី ១ ជាមួយអាហារ ៤ ចាត់ជាយជនាទី ៥ ។ យជនាទី ១ ជាមួយរូបជីវិតិន្ទ្រិយ ចាត់ជាយជនាទី ៦ បើជាមួយរូប និងអរូបឥន្ទ្រិយចាត់ជាយជនាទី ៧ ឬចំពោះយជនាទី ២ ប៉ុណ្ណោះ ជាមួយឥន្ទ្រិយទាំងឡាយ ចាត់ជាយជនាទី ៧ ។ ចំពោះយជនាទី ១ និងទី ២ ជាមួយនឹងវិប្បយុត្តប្បច្ច័យចាត់ជាយជនាទី ៨ និងទី ៩ ។ បណ្តាយជនាទាំងនោះ យជនាទី ៩ ជាមួយអធិបតិប្បច្ច័យ ចាត់ជាយជនាទី ១០ ។ ក្នុងយជនាទី ១១ បន្ទាប់អំពីនោះ ដកវត្ថុរូបចេញដោយអំណាចជាបច្ច័យ ។ ក្នុងយជនាទី ១២ អរូបធម៌ទាំងឡាយប៉ុណ្ណោះ ជាបច្ច័យ ។ ក្នុងយជនាទី ១៣ មានវត្ថុជា

---

១- ក្នុងយជនាទី ១ មានបច្ច័យ ២ គឺអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ឯយជនាទី ៣ ត្រូវបន្ថែមអធិបតិប្បច្ច័យចូលមកទៀត យជនាទី ២ មានបច្ច័យ ៣ គឺអត្ថិប្បច្ច័យ អវិគតប្បច្ច័យ និងនិស្សយប្បច្ច័យ ឯយជនាទី ៤ ត្រូវបន្ថែមអធិបតិប្បច្ច័យ ចូលមកទៀត សូមមើលត្រង់លេខឃ្នាប ៤១ ។

អារម្មណ៍ ជាបច្ច័យ ។ ក្នុងយជនាទី ១៤ មានវត្ថុប៉ុណ្ណោះ ជាបច្ច័យ ។ ក្នុងយជនាទី ១៥ មានអារម្មណ៍ប៉ុណ្ណោះជាបច្ច័យ ។ ក្នុងយជនាទី ១៦ មានវត្ថុប៉ុណ្ណោះជាអារម្មណ៍ ។ ក្នុងយជនាទី ១៧ វត្ថុនោះឯងជាអារម្មណ៍ ដោយភាពជាអារម្មណាធិបតី ។ ក្នុងយជនាទី ១៨ វត្ថុនោះឯងជាអារម្មណ៍ ដោយអំណាចអារម្មណូបនិស្សយបច្ច័យ ។ ក្នុងយជនាទី ១៩ ចក្ខុជាដើម ប៉ុណ្ណោះជាបច្ច័យ ។

យជនាទាំង ១៩ នេះ ឈ្មោះថា បកិណ្ណកយជនា ដែលទ្រង់ត្រាស់ ដោយមិនកាន់យកនូវសហជាត ។ យជនា ១០ បន្ទាប់អំពីនោះ ត្រាស់ ដោយអំណាចសហជាតយជនា ។

[ ៤៣-៤៦ ] ក្នុងន័យដែលមាននត្ថិ និងវិគតប្បច្ច័យជាមូល មានយជនា ៣ ដោយអំណាចឧបនិស្សយប្បច្ច័យ អាសេវនប្បច្ច័យ និងកម្មប្បច្ច័យ ដូចក្នុងន័យដែលមានអនន្តរ និងសមនន្តរប្បច្ច័យ ជាមូលនោះឯង ។

[ ៤៧-៤៩ ] យជនាដែលមានអវិគតប្បច្ច័យជាមូល ដូចគ្នានឹងដែលមានអត្ថិប្បច្ច័យ ជាមូលនោះឯង ។

យជនាដែលពោលក្នុងបញ្ហាវារៈនេះ ទាំងអស់មាន ២ យ៉ាងប៉ុណ្ណោះ គឺបកិណ្ណកយជនា និងសហជាតយជនា ។

ឥន្ទ្រិយប្បច្ច័យ មាន ២ យ៉ាង ដោយជារូប និងអរូប ។ ក្នុង ២ យ៉ាងនោះ ឥន្ទ្រិយប្បច្ច័យដែលជាអរូប រមែងឲ្យសម្រេចភាពជាឥន្ទ្រិយប្បច្ច័យដល់ធម៌ទាំងឡាយ ដែលកើតព្រមគ្នាជាមួយខ្លួន ព្រោះហេតុនោះ ទើបសង្គ្រោះចូលក្នុងសហជាតប្បច្ច័យ ចំណែករូបឥន្ទ្រិយប្បច្ច័យ មាន ២ យ៉ាង ដោយចែកជាខាងក្នុង និងខាងក្រៅ ។ ក្នុង ២ យ៉ាងនោះ ឥន្ទ្រិយប្បច្ច័យខាងក្នុងកើតឡើងមុន ជាឥន្ទ្រិយប្បច្ច័យដល់ចក្ខុវិញ្ញាណជាដើម ព្រមទាំងធម៌ដែលសម្បយុត្តដែលកើតឡើងខាងក្រោយ ព្រោះហេតុនោះ ទើបសង្គ្រោះចូលក្នុងបុរេជាតប្បច្ច័យនោះឯង ។ ឥន្ទ្រិយប្បច្ច័យខាងក្រៅ បានដល់ នាមរូបជីវិតិន្ទ្រិយ នាមរូបជីវិតិន្ទ្រិយនោះ ទោះបីជាបច្ច័យ ដល់ធម៌ទាំងឡាយដែលកើតរួមគ្នា ក៏រមែងកើតដោយអំណាច ត្រឹមតែការតាមចិញ្ចឹម រក្សាប៉ុណ្ណោះ មិនមែនដោយអំណាចនៃការឲ្យកើតឡើង ព្រោះហេតុនោះ ទើបចាត់ជាឥន្ទ្រិយប្បច្ច័យប៉ុណ្ណោះ ។ បច្ច័យទាំង ៨ នេះ គប្បីជ្រាបថា រមែងសង្គ្រោះចូលគ្នានិងគ្នា ដោយប្រការដូច្នេះ នេះជាសង្គហន័យ ដោយអំណាចជាអញ្ញមញ្ញនៃបច្ច័យ ១៦ ដ៏សេស និងនៃបច្ច័យ ៨ នោះឯង ក្នុងបច្ច័យ ៨ ត្រឹមប៉ុណ្ណោះ ។

ឥឡូវនេះ អ្នកសិក្សាគប្បីជ្រាបបច្ច័យទាំង ២៤ ដែលសង្គ្រោះចូលក្នុងបច្ច័យនីមួយៗ ក្នុងបច្ច័យទាំង ៨ នេះ ។ បណ្តាបច្ច័យ ២៤ នោះ អារម្មណប្បច្ច័យប៉ុណ្ណោះ រមែងសង្គ្រោះចូលក្នុងអារម្មណប្បច្ច័យ ដែលជា

បច្ច័យដំបូងនៃបច្ច័យទាំង ៨ នោះមុន បច្ច័យដ៏សេស ២៣ រមែងសង្គ្រោះចូលមិនបាន ។ បច្ច័យ ១៥ គឺហេតុប្បច្ច័យ សហជាតាធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ សហជាតនិស្សយប្បច្ច័យ សហជាតកម្មប្បច្ច័យ វិបាកប្បច្ច័យ សហជាតាហារប្បច្ច័យ សហជាតិន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ សហជាតវិប្បយុត្តប្បច្ច័យ សហជាតត្ថិប្បច្ច័យ សហជាតអវិគតប្បច្ច័យ រមែងសង្គ្រោះចូលក្នុងសហជាតប្បច្ច័យទី ២ ។ បច្ច័យ ៩ គឺអារម្មណប្បច្ច័យ ដែលជាអធិបតី អធិបតិប្បច្ច័យដែលជាអារម្មណ៍ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ អាសេវនប្បច្ច័យ ពលវកម្មប្បច្ច័យ ដែលជានានាខណិកៈ នត្ថិប្បច្ច័យ វិគតប្បច្ច័យ រមែងសង្គ្រោះចូលក្នុងឧបនិស្សយប្បច្ច័យទី ៣ ។

បច្ច័យ ៦ គឺបុរេជាតប្បច្ច័យ បុរេជាតនិស្សយប្បច្ច័យ បុរេជាតិន្ទ្រិយប្បច្ច័យ បុរេជាតវិប្បយុត្តប្បច្ច័យ បុរេជាតត្ថិប្បច្ច័យ បុរេជាតអវិគតប្បច្ច័យ សង្គ្រោះចូលក្នុងបុរេជាតប្បច្ច័យទី ៤ ។

បច្ច័យ ៤ គឺបច្ឆាជាតប្បច្ច័យ បច្ឆាជាតវិប្បយុត្តប្បច្ច័យ បច្ឆាជាតត្ថិប្បច្ច័យ បច្ឆាជាតអវិគតប្បច្ច័យ រមែងសង្គ្រោះចូលក្នុងបច្ឆាជាតប្បច្ច័យទី ៥ ។ នានាខណិកកម្មប្បច្ច័យ លោកសង្គ្រោះហើយក្នុងកម្មប្បច្ច័យទី ៦ ។ បច្ច័យ ៣ គឺអាហារប្បច្ច័យ អាហារត្ថិប្បច្ច័យ អាហារអវិគតប្បច្ច័យ លោកសង្គ្រោះ ដោយអំណាចកពឡិង្ការាហារ ក្នុងអាហារប្បច្ច័យទី ៧ ។

បច្ច័យ ៣ គឺរូបជីវិតិន្ទ្រិយប្បច្ច័យ ឥន្ទ្រិយត្ថិប្បច្ច័យ ឥន្ទ្រិយអវិគតប្បច្ច័យ

សង្គ្រោះចូលក្នុងឥន្ទ្រិយប្បច្ច័យទី ៨ ។ អ្នកសិក្សាគាលជ្រាបថា បច្ច័យទាំងនោះ សង្គ្រោះចូលហើយក្នុងបច្ច័យនីមួយៗ បណ្តាបច្ច័យ ៨ ទាំងនេះ យ៉ាងនេះហើយ គប្បីជ្រាបថា បច្ច័យទាំងឡាយណា ដល់នូវការសង្គ្រោះចូលក្នុងបច្ច័យណា បច្ច័យទាំងនោះ លោកកាន់យកហើយដោយចំនួននៃបច្ច័យដែលសង្គ្រោះចូលនោះ ។

បញ្ហាទាំង ១៥ នេះ គឺកុសលធម៌ជាបច្ច័យដល់កុសលធម៌ ដោយអារម្មណប្បច្ច័យ ដូច្នេះជាដើម ក្នុងបច្ចនីយន័យនេះ ក្នុងបញ្ហា ៤៩ ដែលលោកលើកឡើងវិសជ្ជនាហើយ ដោយអំណាចនៃបច្ច័យ ៨ នេះ ដែលជាទីរួមនៃបច្ច័យទាំងអស់ ដោយប្រការដូច្នេះ ។ បណ្តាបញ្ហាទាំងនោះ បញ្ហាដែលផ្តើមដោយកុសល មាន ៤ គឺកុសលជាបច្ច័យដល់កុសល កុសលជាបច្ច័យដល់អកុសល កុសលជាបច្ច័យដល់អព្យាកតៈ កុសលជាបច្ច័យដល់កុសលាព្យាកតៈ ។ បញ្ហាដែលផ្តើមដោយអកុសលក៏មាន ៤ ដូចគ្នា ។ ចំណែកបញ្ហាដែលផ្តើមដោយអព្យាកតៈ មាន ៣ គឺអព្យាកតៈ ជាបច្ច័យដល់អព្យាកតៈ អព្យាកតៈ ជាបច្ច័យដល់កុសល អព្យាកតៈ ជាបច្ច័យដល់អកុសល ។ បញ្ហាដែលផ្តើមដោយមូល ២ បញ្ចប់ដោយមូល ១ មាន ៤ គឺកុសល និងអព្យាកតៈជាបច្ច័យដល់កុសល កុសល និងអព្យាកតៈជាបច្ច័យដល់អព្យាកតៈ អកុសល និងអព្យាកតៈជាបច្ច័យដល់អកុសល អកុសល និងអព្យាកតៈជាបច្ច័យដល់អព្យាកតៈ ។ បណ្តាបញ្ហាទាំងនោះ បច្ច័យណាគប្បីបានក្នុងបញ្ហាទី ១ លោកសង្គ្រោះបច្ច័យទាំងអស់ ហើយពោលបច្ច័យ

៣ ។ ក្នុងបញ្ហាទី ២ មានបច្ច័យ ២ ។ ក្នុងបញ្ហាទី ៣ មានបច្ច័យ ៥ ។ ក្នុងបញ្ហាទី ៤ មានបច្ច័យ ១ ប៉ុណ្ណោះ ។ ក្នុងបញ្ហាទី ៥ មានបច្ច័យ ៣ ។ ក្នុងបញ្ហាទី ៦ មានបច្ច័យ ២ ។ ក្នុងបញ្ហាទី ៧ មានបច្ច័យ ៥ ។ ក្នុងបញ្ហាទី ៨ មានបច្ច័យ ១ ប៉ុណ្ណោះ ។ ក្នុងបញ្ហាទី ៩ មានបច្ច័យ ៧ ។ ក្នុងបញ្ហាទី ១០ មានបច្ច័យ ៣ ។ ក្នុងបញ្ហាទី ១១ មានបច្ច័យ ៣ ។ ក្នុងបញ្ហាទី ១២ មានបច្ច័យ ២ ។ ក្នុងបញ្ហាទី ១៣ មានបច្ច័យ ៤ ។ ក្នុងបញ្ហាទី ១៤ មានបច្ច័យ ២ ។ ក្នុងបញ្ហាទី ១៥ ក៏មានបច្ច័យ ៤ ដូចគ្នា ។ បច្ច័យទាំងនោះ ព្រះមានព្រះភាគទ្រង់មិនត្រាស់ថា **សហជាតបច្ចយេន** តែត្រាស់ថា **សហជាតំ បច្ឆាជាតំ** ខ្ញុំនឹងពណ៌នាហេតុក្នុងការត្រាស់យ៉ាងនោះខាងមុខ ។

កាលពោលដោយសង្ខេបក្នុងអធិការនេះ មានការកំណត់បច្ច័យ ៦ ពួកប៉ុណ្ណោះ គឺបច្ច័យ ១-២-៣-៤-៥ និង ៧ ។ ពិតហើយ បណ្ដាបច្ចយបច្ចនីយៈទាំង ២៤ មានការកំណត់បញ្ហា ដោយអំណាចការកំណត់យ៉ាងខ្ពស់ ក្នុងបច្ចនីយៈនៃបញ្ហាវារៈ និងការកំណត់បច្ច័យដែលលោកសង្គ្រោះបច្ច័យនោះៗសម្ដែងទុកនេះ មានហេតុប្បច្ច័យជាដើម បច្ច័យនៃបញ្ហាវារៈបន្ទាប់អំពីនេះទៅ រមែងមិនបានក្នុងបច្ចនីយៈ ១ តែនឹងបានក្នុងខាងក្រោយ ព្រោះហេតុនោះ បច្ច័យ ១ ប៉ុណ្ណោះ មកហើយយ៉ាងនេះថា កុសលធម៌ជាបច្ច័យដល់កុសល និងអព្យាកតៈ ដោយសហជាតប្បច្ច័យ ។ ក្នុងបញ្ហាទាំងឡាយណា កាលបច្ច័យនោះ ត្រូវបដិសេធហើយ បញ្ហាទាំងនោះ រមែងបន្ថយទៅ ។

បច្ច័យទាំង ២ មកហើយក្នុងបញ្ហាណា យ៉ាងនេះថា កុសលធម៌ ជាបច្ច័យដល់អកុសលធម៌ ដោយអារម្មណប្បច្ច័យ និងដោយឧបនិស្សយប្បច្ច័យ ។ បណ្ដាបច្ច័យទាំងនោះ កាលបច្ច័យ ១ ត្រូវបដិសេធហើយ យ៉ាងនេះថា **នារម្មណប្បច្ចយា** បញ្ហានោះ រមែងបានដោយអំណាចនៃបច្ច័យ ក្រៅអំពីនេះ តែកាលបច្ច័យទាំង ២ នោះ ត្រូវបដិសេធហើយ ទើបវារៈនោះដាច់ទៅ បច្ច័យទាំងឡាយក្នុងពួក ៣ ពួក ៤ ពួក ៥ ឬពួក ៧ រមែងបានក្នុងបញ្ហាទាំងឡាយណា បញ្ហាទាំងឡាយនោះ រមែងបានក្នុងបច្ច័យទាំងនោះ ដោយអំណាចនៃបច្ច័យទាំងឡាយដ៏សេស វៀរបច្ច័យដែលលោកបដិសេធហើយ ដូចពណ៌នាមកនេះ កាលបច្ច័យទាំងអស់ត្រូវបដិសេធ វារៈទាំងអស់ រមែងដាច់ទៅដូច្នេះឯង នេះជាលក្ខណៈក្នុងសេចក្ដីនេះ ។ បណ្ឌិតគប្បីជ្រាបប្រភេទនៃបច្ច័យទាំងឡាយ ដែលលោកសង្ខេបពោលក្នុងបញ្ហានោះៗ តាំងអំពីដើម និងការបន្ថយ ឬមិនបន្ថយបញ្ហានោះៗ ក្នុងបច្ច័យនោះៗ ដោយលក្ខណៈនេះ ។

បន្ទាប់អំពីនេះ ជាសេចក្ដីពិស្ដារក្នុងរឿងនោះ ក្នុងបញ្ហាទី ១ មុន បច្ច័យ ១៩ លោកសម្ដែងហើយដោយបច្ច័យ ៣ ។ សេចក្ដីនេះ ដូចម្ដេច ពិតហើយ កុសល រមែងមិនជាបច្ច័យដល់កុសល ដោយបុរេជាត បច្ឆាជាត វិបាក និងវិប្បយុត្តប្បច្ច័យប៉ុណ្ណោះ តែរមែងជាបច្ច័យដោយបច្ច័យ ២០ ដ៏សេស ។ បណ្ដាបច្ច័យទាំងនោះ អារម្មណប្បច្ច័យមាន ១ ប៉ុណ្ណោះ ចំណែកបច្ច័យ ១៥ ដោយរួមបច្ច័យទាំងអស់ចូលគ្នា លោកពោលថា រមែងសង្គ្រោះ

ចូលក្នុងសហជាតប្បច្ច័យ ។ កាលហេតុប្បច្ច័យ ត្រូវបដិសេធ ទើបបច្ច័យទាំងនោះ មាន ១៤ ។ ពាក្យថា កុសលជាបច្ច័យដល់កុសល ដោយសហជាតប្បច្ច័យ ទ្រង់ត្រាស់សំដៅដល់បច្ច័យ ១២ ដ៏សេស ដោយដកបច្ច័យ ២ ចេញ ព្រោះកុសលមិនជាវិបាកប្បច្ច័យ និងមិនជាវិប្បយុត្តប្បច្ច័យដល់កុសល ។ លោកពោលថា បច្ច័យ ៩ រមែងសង្គ្រោះចូលក្នុងឧបនិស្សយប្បច្ច័យ ដោយអំណាចជាទីរួមចុះនៃបច្ច័យទាំងអស់ ។

បណ្តាបច្ច័យទាំងនោះ អារម្មណប្បច្ច័យ ដែលជាអធិបតី និងអធិបតិប្បច្ច័យ ដែលជាអារម្មណ៍ បន្ថែមចូលជាមួយឧបនិស្សយប្បច្ច័យ ដោយអំណាចជាអារម្មណូបនិស្សយ ។ ចំណែកកុសល រមែងមិនជានានាខណិកកម្មប្បច្ច័យដល់កុសល ព្រោះហេតុនោះ ទើបលោកដកចេញ ហើយពោលថា **ឧបនិស្សយប្បច្ចយេន បច្ចយោ** ព្រោះសំដៅយកបច្ច័យ ៦ ដ៏សេស ។

បច្ច័យ ១៩ គប្បីជ្រាបថា លោកសម្តែងហើយ ដោយបច្ច័យ ៣ ក្នុងបញ្ហាទី ១ ( កុសលជាបច្ច័យដល់កុសល ) ដោយប្រការដូច្នេះ ។

បណ្តាបច្ច័យទាំងនោះ ក្នុងនហេតុបច្ចនីយៈនេះ កុសលធម៌ រមែងជាបច្ច័យដល់កុសលធម៌ ដោយនហេតុប្បច្ច័យ ព្រោះហេតុនោះ បណ្ឌិតគប្បីលើកបាលីឡើងសម្តែង ដោយន័យដែលលោកពោលក្នុងអារម្មណប្បច្ច័យយ៉ាងនេះថា កុសលធម៌ជាបច្ច័យនៃកុសលធម៌ ដោយនហេតុប្បច្ច័យ គឺបុគ្គលឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ហើយពិចារណាកុសលនោះ

ពិចារណាពួកកុសលដែលខ្លួនធ្លាប់សន្សំហើយ ក្នុងកាលមុន ដូច្នេះជាដើម ។

កាលអារម្មណប្បច្ច័យត្រូវបដិសេធហើយ បណ្ឌិតគប្បីនាំសេចក្តីពិស្តារនៃអារម្មណប្បច្ច័យនោះចេញ បន្ថែមសេចក្តីពិស្តារនៃហេតុប្បច្ច័យ ហើយគប្បីសម្តែងបាលីនោះឯង ដដែលទៀត ក្នុងការបដិសេធបច្ច័យដ៏សេស ក៏ន័យនេះដូចគ្នា កាលបច្ច័យណាមួយត្រូវដកចេញ វារៈពួកណាថយចុះ ខ្ញុំនឹងពណ៌នាវារៈទាំងនោះខាងមុខ ។

ក្នុងបញ្ហាទី ២ ( កុសល ជាបច្ច័យដល់អកុសល ) លោកសម្តែងបច្ច័យ ៣ ដោយបច្ច័យ ២ ។ សេចក្តីនេះដូចម្តេច គឺកុសល រមែងមិនជាបច្ច័យដល់អកុសល ដោយអំណាចអនន្តរប្បច្ច័យជាដើម ព្រោះហេតុនោះទើបទ្រង់ដកអនន្តរប្បច្ច័យជាដើមនោះចេញ ហើយត្រាស់ថា **ឧបនិស្សយប្បច្ចយេន បច្ចយោ** ដោយសំដៅយកអារម្មណាធិបតី និងបកតូបនិស្សយប្បច្ច័យដែលលោកសង្គ្រោះហើយដោយអារម្មណូបនិស្សយប្បច្ច័យ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបថា បច្ច័យទាំងឡាយ ៣ នេះ ព្រះមានព្រះភាគទ្រង់សម្តែងហើយដោយបច្ច័យ ២ ក្នុងបញ្ហាទី ២ គឺអារម្មណប្បច្ច័យសុទ្ធៗជាមួយនឹងអធិបតិប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ដោយអំណាចអារម្មណាធិបតី ។

ក្នុងបញ្ហាទី ៣ ( កុសល ជាបច្ច័យដល់អព្យាកតៈ ) បច្ច័យ ១៨ លោកសម្តែងហើយដោយបច្ច័យ ៥ ។ សេចក្តីនេះ ដូចម្តេច គឺកុសលរមែងមិនជាបច្ច័យដល់អព្យាកតៈ ដោយអំណាចអញ្ញមញ្ញ បុរេជាត អាសេវនៈ

វិបាក និងសម្បយុត្តប្បច្ច័យប៉ុណ្ណោះ តែកើតដោយអំណាចរបស់បច្ច័យ ១៩ ដ៏សេស ។ បណ្តាបច្ច័យទាំងនោះ អារម្មណប្បច្ច័យមាន ១ ។ កុសល រមែង មិនជាបច្ច័យដល់អព្យាកតៈដោយអញ្ញមញ្ញ វិបាក និងសម្បយុត្តប្បច្ច័យ ។ ហេតុប្បច្ច័យត្រូវដកចេញ កម្មប្បច្ច័យលោកកាន់យកមួយផ្នែកទៀត ព្រោះ ហេតុនោះ ទើបលោកនាំបច្ច័យ ៥ នេះចេញ ហើយសម្តែងបច្ច័យ ១០ ដោយសហជាតប្បច្ច័យ ។ បណ្តាបច្ច័យ ៦ ដែលលោកពោលខាងដើម ដោយឧបនិស្សយប្បច្ច័យ បច្ច័យដ៏សេស វៀរអាសេវនប្បច្ច័យ ទើបមាន ៥ ។ បច្ឆាជាតប្បច្ច័យមាន ១ ប៉ុណ្ណោះ ។ ម្យ៉ាងទៀត កម្មប្បច្ច័យ មាន ២ យ៉ាង ដោយអំណាចសហជាតកម្មប្បច្ច័យ និងនានាខណិកកម្មប្បច្ច័យ ព្រោះ ហេតុនោះ អ្នកសិក្សាគប្បីជ្រាបថា បច្ច័យ ១៨ នេះ លោកសម្តែងហើយ ដោយបច្ច័យ ៥ ក្នុងបញ្ហាទី ៣ យ៉ាងនេះ ដោយប្រការដូច្នេះ ។

ក្នុងបញ្ហាទី ៤ ( កុសលជាបច្ច័យដល់កុសល និងអព្យាកតៈ ) បច្ច័យ ១០ លោកសម្តែងហើយដោយបច្ច័យ ១ ប៉ុណ្ណោះ ។ សេចក្តីនេះ ដូចម្តេច ពិតហើយ កុសល រមែងមិនជាបច្ច័យដល់កុសលាព្យាកតៈ ដោយអញ្ញមញ្ញ វិបាក សម្បយុត្ត និងវិប្បយុត្តប្បច្ច័យ បណ្តាបច្ច័យ ១៥ ដែលលោក ពោលហើយ ក្នុងសហជាតប្បច្ច័យ ហេតុប្បច្ច័យត្រូវបដិសេធចេញហើយ ហេតុនោះ អ្នកសិក្សាគប្បីដកបច្ច័យទាំង ៥ នេះចេញ ហើយគប្បីជ្រាបថា លោកសម្តែងបច្ច័យ ១០ ដ៏សេស ដោយបច្ច័យ ១ ក្នុងបញ្ហាទី ៤ នេះ ។

បច្ច័យទាំងនោះ លោកសម្តែងហើយ ដោយបច្ច័យនោះៗ ។

ក្នុងបញ្ហា ៤ មានកុសលជាដើមនេះយ៉ាងណា អ្នកសិក្សាគប្បីជ្រាបថា បច្ច័យនោះៗ ព្រះមានព្រះភាគទ្រង់សម្តែងហើយ ដោយបច្ច័យនោះៗ ក្នុងបញ្ហា ៤ ( អកុសល ជាបច្ច័យដល់អកុសល ១ អកុសល ជាបច្ច័យដល់កុសល ១ អកុសល ជាបច្ច័យដល់អព្យាកតៈ ១ អកុសល ជាបច្ច័យដល់អកុសល និងអព្យាកតៈ ១ ) មានអកុសលជាដើម ក៏យ៉ាងនោះ ។

បច្ច័យ ២៣ លោកសម្តែងហើយដោយបច្ច័យ ៧ ក្នុងបញ្ហាទី ១ នៃបញ្ហា ៣ ( អព្យាកតៈ ជាបច្ច័យដល់អព្យាកតៈ អព្យាកតៈ ជាបច្ច័យដល់កុសល អព្យាកតៈ ជាបច្ច័យដល់អកុសល ) មានអព្យាកតៈជាដើម បន្ទាប់អំពីនោះ សេចក្តីនេះដូចម្តេច គឺអព្យាកតៈ ជាបច្ច័យដល់អព្យាកតៈ ដោយបច្ច័យ ២៤ កាលហេតុប្បច្ច័យត្រូវបដិសេធ រមែងមានបច្ច័យ ២៣ ។ បណ្តាបច្ច័យទាំងនោះ អារម្មណប្បច្ច័យមាន ១ ប៉ុណ្ណោះ ព្រោះអាហារប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យ លោកកាន់យកមួយផ្នែក ដើម្បីសង្គ្រោះធម៌ដែលមិនកើតរួមគ្នា ក្នុងអធិការនេះផងដែរ ព្រោះហេតុនោះ ទើបលោកនាំបច្ច័យ ៣ នេះចេញ ហើយសម្តែងបច្ច័យ ១២ ដោយសហជាតប្បច្ច័យ ។ បច្ច័យដែលលោកពោលខាងដើម ដោយឧបនិស្សយប្បច្ច័យ មាន ៦ ។ បុរេជាតប្បច្ច័យ មាន ១ ប៉ុណ្ណោះ ។ បច្ឆាជាត អាហារ និងឥន្ទ្រិយប្បច្ច័យ ក៏ដូចគ្នា ។ បណ្ឌិតគប្បីជ្រាបថា បច្ច័យ ២៣ នេះ លោកសម្តែងហើយ ដោយបច្ច័យ ៧ ក្នុងអធិការនេះ ដោយប្រការដូច្នេះ ។

ក្នុងបញ្ហាទី ២ លោកសម្តែងបច្ច័យ ១២ ដោយបច្ច័យ ៣ ។ សេចក្តី

នេះដូចម្ដេច គឺអារម្មណប្បច្ច័យ មាន ១ ។ បច្ច័យ ៦ គឺអារម្មណាធិបតី អនន្តរ សមនន្តរ នត្ថិ វិគត និងឧបនិស្សយប្បច្ច័យ លោកសម្ដែងហើយ ដោយអំណាចនៃអារម្មណូបនិស្សយ ដោយឧបនិស្សយប្បច្ច័យ ។ បុរេជាត និស្សយ វិប្បយុត្ត អត្ថិ និងអវិគតប្បច្ច័យ លោកសម្ដែងហើយ ដោយបុរេជាតប្បច្ច័យ ។ បណ្ឌិតគប្បីជ្រាបថា បច្ច័យ ១២ លោកសម្ដែងហើយ ដោយបច្ច័យ ៣ ក្នុងបញ្ហាទី ២ នេះ ( អព្យាកតៈ ជាបច្ច័យដល់កុសល ) ដោយប្រការដូច្នេះ សូម្បីក្នុងបញ្ហាទី ៣ ( អព្យាកតៈ ជាបច្ច័យដល់អកុសល ) ក៏ន័យនេះ ។

ក្នុងបញ្ហាទី ១ នៃបញ្ហា ៤ ដែលមានមូល ២ ( កុសល និងអព្យាកតៈ ជាបច្ច័យដល់កុសល កុសល និងអព្យាកតៈ ជាបច្ច័យដល់អព្យាកតៈ អកុសល និងអព្យាកតៈ ជាបច្ច័យដល់អកុសល អកុសល និងអព្យាកតៈ ជាបច្ច័យដល់អព្យាកតៈ ) បន្ទាប់អំពីនោះ ទ្រង់មិនត្រាស់ថា **សហជាតប្បច្ចយេន បុរេជាតប្បច្ចយេន** ហើយសម្ដែងបច្ច័យ ៣ ដោយអំណាចនិស្សយ អត្ថិ និងអវិគតប្បច្ច័យ ដោយបច្ច័យ ២ ដែលទ្រង់ត្រាស់ថា **សហជាតំ បុរេ-ជាតំ** ។ ពិតហើយ កុសលក្ខន្ធទាំងឡាយ កាលឲ្យសម្រេចភាពជាបច្ច័យដល់កុសល មួយអន្លើដោយវត្ថុរូបជាសហជាតក៏ពិត តែក៏មិនជាសហជាតប្បច្ច័យ ព្រោះហេតុអ្វី ព្រោះលាយឡំដោយវត្ថុរូប ព្រោះហេតុនោះ ទើបលោកពោលថា **សហជាតំ** ដោយអំណាចនៃនិស្សយ អត្ថិ និងអវិគត ដែលជាសហ-ជាតទាំងនោះ ។ ក្នុងវត្ថុរូបក៏ន័យនេះដូចគ្នា ។ ពិតហើយ វត្ថុរូបនោះនឹងកើត

មុនក៏ពិត តែមិនជាបុរេជាតប្បច្ច័យ ព្រោះរួមជាមួយខន្ធ ។ បទថា **បុរេជាតំ** ត្រាស់ហើយដោយអំណាចនៃនិស្សយប្បច្ច័យជាដើមដែលកើតមុនតែម្យ៉ាង ។

បច្ច័យ ៤ ដោយអំណាចសហជាត និស្សយ អត្ថិ និងអវិគតៈ ព្រះអង្គ ទ្រង់សម្តែងហើយដោយបច្ច័យ ៤ ដែលទ្រង់ត្រាស់ថា **សហជាតំ បច្ឆាជាតំ អាហារំ ឥន្ទ្រិយំ** ក្នុងបញ្ហាទី ២ ។ ពិតហើយ ក្នុងវារៈនេះ រមែងបានសហជាតប្បច្ច័យ មិនបានបច្ឆាជាតប្បច្ច័យជាដើម ពាក្យនោះ លោកពោលដោយអំណាចនៃបច្ឆាជាត អត្ថិ និងអវិគតៈ ពោល គឺអាហារ និងឥន្ទ្រិយ ព្រោះថា កុសលក្ខន្ធទាំងឡាយ អព្យាកតៈ និងមហាភូតរូប ជាបច្ច័យដល់ឧបាទារូបដោយចំណែក ៤ គឺសហជាតប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ។ កុសលដែលកើតខាងក្រោយ ជាបច្ច័យដល់ឧបាទារូបទាំងនោះឯង ជាមួយភូតរូបទាំងនោះដូចគ្នា ដោយអំណាចអត្ថិ និងអវិគតប្បច្ច័យ ។ កពឡិង្ការាហារ ជាមួយនឹងកុសលដែលកើតខាងក្រោយ ក៏ជាបច្ច័យដល់កាយដែលកើតមុន ដោយអត្ថិ និងអវិគតប្បច្ច័យ ។ រូបជីវិតិន្ទ្រិយ និងកុសលដែលកើតខាងក្រោយ ក៏ជាបច្ច័យដល់កដត្តារូប ដោយអត្ថិ និងអវិគតប្បច្ច័យនោះឯង ។ បទនេះថា **សហជាតំ បច្ឆាជាតំ អាហារំ ឥន្ទ្រិយំ** ទ្រង់ត្រាស់សំដៅដល់ភាពជាបច្ច័យ ដោយចំណែក ៤ នេះ ។ បច្ឆាជាត អាហារ និងឥន្ទ្រិយប្បច្ច័យ រមែងមិនបានក្នុងអធិការនេះ ។ ក្នុងបញ្ហា ២ ដែលរួមជាមួយអកុសលខាងមុខ ក៏ន័យនេះដូចគ្នា ។ បណ្ឌិតគប្បីជ្រាបប្រភេទនៃបច្ច័យទាំងឡាយ ដែលលោកពោលសង្ខេបក្នុងបញ្ហាទាំង

*នោះ ក្នុងអធិការនេះ ដោយប្រការដូច្នេះ ។ ខ្ញុំនឹងធ្វើឲ្យជាក់ច្បាស់នូវការ ជយចុះ និងការមិនជយចុះនៃបញ្ហាទាំងនោះ ក្នុងបច្ច័យនោះៗ ខាងមុខនោះ ឯង ។*

**អដ្ឋកថាបច្ចយុទ្ធារៈ ចប់**

# បច្ចនីយគណនា

[ ៥៥-៧០ ] *វារៈទាំង ១៥ នោះ គឺ* **កុសលោ ធម្មោ កុសលស្ស ធម្មស្ស** *ជាដើម ព្រះមានព្រះភាគ ទ្រង់សម្តែងហើយ ដោយអំណាច អនុលោម ព្រោះក្នុងបច្ចនីយៈ វារៈទាំងនេះឯង មិនមានច្រើនជាងនេះ មាន តែតិចជាងនេះ ហេតុនោះ ឥឡូវនេះ ដើម្បីសម្តែងវារៈដែលមិនមាន ក្នុង បច្ចនីយៈនៃវារៈណាមួយ តាំងអំពីដើម ដោយអំណាចនៃចំនួន ទើបព្រះ មានព្រះភាគ ទ្រង់ផ្តើមពាក្យថា* **នហេតុយា បន្នរស** *ជាដើម ។*

*បណ្តាបទទាំងនោះ បទថា* **នហេតុយា** *គឺវារៈ ១៥ ដែលបានដោយ អំណាចនៃបច្ច័យទាំងឡាយ តាមដែលបានសម្តែងទាំងអស់ ។ ក្នុងនអា- រម្មណៈ ហេតុប្បច្ច័យ រមែងបន្ថែមចូលក្នុងសហជាតប្បច្ច័យ ។ ក្នុងវារៈ នោះៗ អារម្មណប្បច្ច័យសុទ្ធៗ រមែងជាច់ទៅ ។ វារៈទាំងនោះ រមែងបាន វិសជ្ជនា ដោយអំណាចនៃបច្ច័យដ៏សេស ។ ក្នុងបច្ច័យដ៏សេសក៏ដូចគ្នានឹង*

នអារម្មណប្បច្ច័យ ។ ហេតុប្បច្ច័យ រមែងចូលគ្នាបានក្នុងសហជាតប្បច្ច័យ ។ បច្ច័យទាំងឡាយ ដែលតាំងនៅដោយបច្ចនីយៈ យ៉ាងនេះ គឺ **នឧបនិស្សយេ នអនន្តរេ** បច្ច័យនោះៗ រមែងដាច់ទៅក្នុងវារៈនោះៗ ។ វារៈទាំងនោះ រមែងបានទទួលវិសជ្ជនាដោយអំណាចបច្ច័យដ៏សេស ។ ចំណែកក្នុងនសហជាតប្បច្ច័យ ទាំង ៤ វារៈនោះ រមែងដាច់ទៅ គឺកុសលធម៌ ជាបច្ច័យដល់កុសល និងអព្យាកតៈ អកុសលធម៌ ជាបច្ច័យដល់អកុសល និងអព្យាកតៈ កុសល និងអព្យាកតធម៌ ជាបច្ច័យដល់កុសលអកុសល និងអព្យាកតធម៌ ជាបច្ច័យដល់អកុសល ។ ពិតហើយ លោកពោលបច្ចយសង្គហៈពួក ១ ដោយអំណាចនៃបច្ច័យ ១១ ថា **សហជាតប្បច្ចយេន បច្ចយោ** ក្នុងវារៈ ២ ខាងដើមនៃវារៈ ៤ នេះ កាលបច្ចយសង្គហៈនោះត្រូវបដិសេធ វារៈទាំងនោះ រមែងមិនបានទទួលវិសជ្ជនា ដោយអាការដទៃ ។ បទថា **សហជាតំ បុរេជាតំ** លោកពោលសំដៅយកនិស្សយ អត្ថិ និងអវិគតប្បច្ច័យ ក្នុងវារៈ ២ ខាងចុង ។ កាលសហជាតប្បច្ច័យត្រូវបដិសេធ វារៈទាំងនោះ រមែងមិនបានវិសជ្ជនាដោយអំណាចនៃបច្ច័យដ៏សេស មានហេតុប្បច្ច័យជាដើម និងមិនបានបុរេជាតប្បច្ច័យ និស្សយ អត្ថិ អវិគតប្បច្ច័យផងដែរ ព្រោះហេតុនោះ ទើបវារៈទាំង ៤ នេះដាច់ទៅ ។ បទថា **ឯកោធស** លោកពោលដោយអំណាចនៃវារៈដ៏សេស ។

ក្នុងសេចក្តីនោះ គប្បីមានពាក្យសួរថា កាលហេតុប្បច្ច័យត្រូវបដិសេធ ទើបវារៈទាំងនោះ មានដោយអំណាចនៃអធិបតិប្បច្ច័យជាដើមដ៏សេស ព្រោះ

ហេតុអ្វី កាលសហជាតប្បច្ច័យត្រូវបដិសេធចេញ ទើបវារៈមិនមានដោយអំណាចនៃហេតុប្បច្ច័យជាដើម ដ៏សេស ឆ្លើយថា ព្រោះមិនមានធម៌ មកអាស្រ័យ ។ ពិតហើយ ហេតុប្បច្ច័យជាដើម ឈ្មោះថា នៅមានធម៌អាស្រ័យ ព្រោះនៅមានសហជាតប្បច្ច័យមួយចំណែកទៀត ព្រោះហេតុនោះ កាលហេតុប្បច្ច័យជាដើមនោះ ត្រូវបដិសេធហើយ វារៈទាំងនោះ រមែងបានទទួលវិសជ្ជនាដោយអំណាចនៃបច្ច័យដទៃ តែសហជាតប្បច្ច័យមិនមានធម៌អាស្រ័យ រមែងរួមយកហេតុប្បច្ច័យទាំងអស់ជាដើម ចូលមកផងដែរ ព្រោះហេតុនោះ កាលសហជាតប្បច្ច័យនោះត្រូវបដិសេធ ហេតុប្បច្ច័យទាំងអស់នោះជាដើម ទើបឈ្មោះថា ត្រូវបដិសេធផងដែរ ព្រោះថា ឈ្មោះថា ហេតុប្បច្ច័យជាដើម ដែលមិនកើតព្រមគ្នា រមែងមិនមាន ។ ព្រោះសហជាតប្បច្ច័យ មិនមានធម៌អាស្រ័យ កាលសហជាតប្បច្ច័យនោះត្រូវបដិសេធ ទើបវារៈទាំង ២ នោះមិនមាន ដោយប្រការដូច្នេះ ។ ក្នុងវារៈដែលលោកវិសជ្ជនាហើយថា **សហាជាតំ បុរេជាតំ** ទោះបីសហជាតប្បច្ច័យប៉ុណ្ណោះ មិនមានក៏ពិត តែព្រោះក្នុងអធិការនេះ អរូបក្ខន្ធ ដែលកើតរួមគ្នាប៉ុណ្ណោះ ជាបច្ច័យដោយអំណាចនិស្សយ អត្ថិ និងអវិគតៈ កាលសហជាតប្បច្ច័យ ត្រូវបដិសេធហើយនិស្សយ អត្ថិ និងអវិគតប្បច្ច័យដែលកើតរួមគ្នា ដោយចំណែកមួយ ដោយពិតប្រាកដ ក៏ឈ្មោះថា ត្រូវបដិសេធផងដែរ ហេតុនោះ សូម្បីវារៈទាំងនោះក៏មិនបានវិសជ្ជនា ព្រោះសហជាតប្បច្ច័យនោះ ត្រូវបដិសេធទៅនោះឯង ។ វារៈទាំង ៤ នោះ ក្នុងអធិការនេះ ក៏ដាច់ទៅដោយប្រការទាំងពួង ដោយ

ប្រការដូច្នេះ ។ បទថា **ឯកាទស** លោកពោលដោយអំណាចវារៈដ៏សេស ប៉ុណ្ណោះ ។

ក្នុងនអញ្ញមញ្ញ ននិស្សយ និងនសម្បយុត្តប្បច្ច័យ វារៈទាំងនោះឯង ដាច់ទៅ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមានគតិដូចសហជាតប្បច្ច័យ ។ សហជាតប្បច្ច័យដែលជាអរូបធម៌ រមែងរួមអរូបក្ខន្ធ ៤ ដោយមិនសេស សល់ យ៉ាងណា សូម្បីអញ្ញមញ្ញ និស្សយ និងសម្បយុត្តប្បច្ច័យ ក៏យ៉ាង នោះ ព្រោះហេតុនោះ គប្បីជ្រាបថា កាលបច្ច័យទាំងនេះត្រូវបដិសេធហើយ ទើបវារៈទាំងនោះ មិនបានវិសជ្ជនា ព្រោះបច្ច័យទាំងនេះ មានគតិដូចគ្នានឹង សហជាតប្បច្ច័យ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **នអញ្ញ-មញ្ញេ ឯកាទស ននិស្សយេ ឯកាទស នសម្បយុត្តេ ឯកាទស ។**

ក្នុងសេចក្តីនោះ គប្បីមានពាក្យសួរថា បច្ច័យទាំងនេះ មានគតិដូច សហជាតប្បច្ច័យ ព្រោះជាទីរួមនៃខន្ធ ៤ មានកុសលជាដើមដោយមិនប្លែក គ្នាក៏ពិត វៀរសហជាតប្បច្ច័យ កុសលមិនជាបច្ច័យដោយប្រការដទៃ ដល់ កុសលាព្យាកតៈឡើយ ព្រោះហេតុនោះ កាលកុសលនោះ ត្រូវបដិសេធ វារៈនោះក៏ដាច់ទៅជាធម្មតា តែកុសលមិនជាអញ្ញមញ្ញប្បច្ច័យដល់កុសលា-ព្យាកតៈ កាលកុសលនោះត្រូវបដិសេធ ហេតុអ្វី ទើបវារៈនោះ ត្រូវដាច់ទៅ ដែរ ឆ្លើយថា ព្រោះមានការប្រព្រឹត្តទៅដោយអំណាចនៃធម៌ដែលអាស្រ័យ គ្នានិងគ្នា ដូចកុសលាព្យាកតៈ មិនជាសហជាតប្បច្ច័យដល់កុសល តែវារៈ នោះក៏ដាច់ទៅ ក្នុងកាលលើកកុសលនោះចេញ ព្រោះមានការប្រព្រឹត្តទៅ

ដោយនិស្សយប្បច្ច័យជាដើម ដោយអំណាចនៃធម៌ដែលកើតរួមគ្នា យ៉ាងណា ក្នុងអធិការនេះ កាលលើកកុសលនោះចេញ វារៈនោះ រមែងដាច់ទៅ ព្រោះមានការប្រព្រឹត្តទៅ ដោយសហជាតជាដើម ដោយអំណាចនៃធម៌ដែលជាអញ្ញមញ្ញប្បច្ច័យ ក៏យ៉ាងនោះ ។

បទថា **នអញ្ញមញ្ញប្បច្ចយេន បច្ចយោ** មានអត្ថដូចតទៅនេះ ធម៌ទាំងឡាយណា ដល់នូវការរាប់ថា ជាអញ្ញមញ្ញប្បច្ច័យ ភាពជាបច្ច័យដោយធម៌ទាំងនោះ រមែងមិនមាន តែកុសល កាលជាបច្ច័យដល់កុសលាព្យាកតៈដោយអំណាចសហជាតប្បច្ច័យជាដើម រមែងមិនកើតដោយធម៌ គឺអញ្ញមញ្ញប្បច្ច័យប៉ុណ្ណោះ ព្រោះហេតុនោះ កាលកុសលនោះ ត្រូវបដិសេធ វារៈនោះក៏ដាច់ទៅ វារៈនោះ រមែងដាច់ទៅ យ៉ាងណា វារៈ ៣ ដ៏សេស ក៏រមែងដាច់ទៅយ៉ាងនោះ វារៈទាំង ៤ នោះ រមែងដាច់ទៅ ដោយប្រការដូច្នេះ ។

ក្នុងបទថា **ននិស្សយេ ឯកាទស** នេះ មានវិនិច្ឆ័យដូចតទៅនេះ ព្រោះបច្ចយធម៌ទាំងឡាយ ដែលកើតរួមគ្នាដោយចំណែកមួយ ជាទីអាស្រ័យនៃវារៈទាំងនោះ ដូច្នោះ កាលធម៌ជាទីអាស្រ័យ ត្រូវបដិសេធ ទើបវារៈទាំងនោះ ដាច់ទៅផងដែរ ។

បទថា **នបុរេជាតេ តេរស** សេចក្តីថា មានវារៈ ១៣ ព្រោះនាំចេញនូវវារៈ ២ ដែលមានមូល ២ ដែលមានវិសជ្ជនា ដែលលោកពោលថា **សហជាតំ បុរេជាតំ** និងដូចកាលលើកយកសហជាតប្បច្ច័យចេញ វារៈទាំងនោះ រមែងមិនបាននូវវិសជ្ជនា ដោយអំណាចនៃនិស្សយ អត្ថិនិងអវិ-

គតប្បច្ច័យ ដែលជាបុរេជាតប៉ុណ្ណោះ យ៉ាងណា កាលបុរេជាតប្បច្ច័យ ត្រូវលើកចេញហើយ វារៈទាំងនោះ រមែងមិនបានវិសជ្ជនាដោយអំណាចនិស្សយ អត្ថិ និងអវិគតប្បច្ច័យ ដែលជាសហជាតប៉ុណ្ណោះក៏យ៉ាងនោះ ព្រោះហេតុនោះ អ្នកសិក្សាគប្បីជ្រាបថា មានវារៈ ១៣ ព្រោះនាំចេញនូវវារៈទាំងនោះ ។

ក្នុងបទថា **នបច្ឆាជាតេ បន្នរស** នេះ រមែងបានបញ្ហាទាំងឡាយនោះដោយអំណាចនៃបច្ច័យដ៏សេស វៀរបច្ឆាជាតប្បច្ច័យ ក្នុងអាគតដ្ឋានទាំងឡាយថា **បច្ឆាជាតប្បច្ចយេន បច្ចយោ** ឬថា **សហជាតំ បុរេជាតំ អាហារំ ឥន្ទ្រិយំ** ដូច្នេះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ១៥ វារៈប៉ុណ្ណោះ ។

ក្នុងបទទាំងឡាយថា **នកម្មេ** ជាដើម មានវិនិច្ឆ័យថា ព្រោះកម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ ក៏ជាចំណែកមួយប៉ុណ្ណោះនៃខន្ធ ៤ មានកុសលជាដើម ដូច្នោះ វៀរធម៌ទាំងនោះចេញ ទើបធម៌ដែលកើតរួមគ្នា ចាត់ជាបច្ច័យបានដោយអំណាចនៃធម៌ដ៏សេស ព្រោះហេតុនោះ ទើបការវិសជ្ជនាបញ្ហាមិនថយចុះ សូម្បីត្រឹមតែមួយ ។

បទថា **នសម្បយុត្តេ ឯកាទស** សេចក្តីថា ព្រោះធម៌ដែលសម្បយុត្តគ្នា ជាបច្ច័យដោយអំណាចនៃធម៌ ដែលអាស្រ័យនូវគ្នានិងគ្នា មានសហជាតប្បច្ច័យជាដើម ក្នុងវារៈ ៤ នោះ ហេតុនោះ គប្បីជ្រាបថា វារៈទាំងនោះ

ប៉ុណ្ណោះដាច់ទៅ ព្រោះបដិសេធសម្បយុត្តប្បច្ច័យ ។

បទថា **នវិប្បយុត្តេ នវ** សេចក្តីថា វារៈ ៦ នេះ គឺវារៈ ៤ ដែលមានបទខាងចុងមួយ ដែលកើតអំពីធម៌ ដែលមានមូល ២ និង ២ វារៈ ដែលមានបទខាងចុង ដែលកើតអំពីធម៌ ដែលមានមូល ១ និងមូល ២ ប្រកបហើយដោយបច្ច័យធម៌ ដែលវិប្បយុត្តគ្នាដោយចំណែកមួយ ។ វារៈទាំងនោះ រមែងជាបច្ច័យដោយអំណាចសហជាតជាដើម ព្រោះហេតុនោះ កាលវិប្បយុត្តប្បច្ច័យត្រូវបដិសេធ វារៈទាំងអស់នោះ រមែងដាច់ទៅផងដែរ ព្រោះហេតុនោះ ទើបបាន ៩ វារៈប៉ុណ្ណោះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **នវិប្បយុត្តេ នវ** ។

ក្នុងនោនត្ថិ និងនោអវិគតប្បច្ច័យ អ្នកសិក្សាគប្បីជ្រាបវារៈ ៩ ទាំងនោះប៉ុណ្ណោះ ។ ពិតហើយ វារៈទាំងនោះ ប្រកបដោយធម៌ គឺអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យពិតប្រាកដ ព្រោះហេតុនោះ ទើបវារៈទាំងនោះដាច់ទៅ ព្រោះការបដិសេធអត្ថិ និងអវិគតប្បច្ច័យទាំងនោះ វារៈទាំងឡាយណាដែលបាន អ្នកសិក្សាគប្បីចងវិសជ្ជនាក្នុងវារៈទាំងនោះ ដោយអំណាចអារម្មណប្បច្ច័យ ឬដោយអំណាចអនន្តរប្បច្ច័យជាដើម ។ អ្នកសិក្សាគប្បីចងវិសជ្ជនាដោយអំណាចនៃបច្ច័យ ៥ មានសហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយប្បច្ច័យ ឬដោយអំណាចនៃធម៌ដែលវិប្បយុត្តដែលនៅមាន និងមិនទាន់ប្រាសទៅ ដូច្នេះឯង ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងវារៈដែលបានក្នុងបច្ចនីយន័យ ដោយ

ការរាប់យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្តែងការរាប់បច្ច័យដោយអំណាចនៃបច្ច័យដែលមានមូល ២ ជាដើម ទើបទ្រង់ផ្តើមពាក្យថា **ឆហេតុប្បច្ចយា ឆារម្មណេ បន្នរស** ជាដើម គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនោះដូចតទៅ

ក្នុងទហេតុមូលកទុកៈ ជាបច្ច័យដែលរាប់បានច្រើនជាង កាលប្រកបជាមួយបច្ច័យដែលរាប់បានតិចជាង រមែងជាបច្ច័យដែលរាប់បានតិចជាងផងដែរ ។

ក្នុងតិមូលកន័យ វារៈ ២ គឺកុសលជាបច្ច័យដល់អកុសល អកុសលជាបច្ច័យដល់កុសល ក្នុងបទថា **ឆឧបនិស្សយេ តេរស** រមែងដាច់ទៅ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះនឧបនិស្សយប្បច្ច័យ លោកភ្ជាប់ជាមួយនអារម្មណប្បច្ច័យ ។ ពិតហើយ វារៈទាំងនេះ ប្រព្រឹត្តទៅដោយអំណាចអារម្មណប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ហើយបច្ច័យទាំង ២ នោះ ត្រូវបដិសេធចេញហើយ ទើបវារៈនោះ លោកកាន់យកហើយ ដោយចំនួននៃអារម្មណាធិបតី និងអារម្មណូបនិស្សយប្បច្ច័យប៉ុណ្ណោះ ។

ក្នុងឆមូលកន័យ បទថា **ឆឧបនិស្សយេ តេរស** គឺវារៈទាំង ១៣ នោះឯង ។

ក្នុងសត្តមូលកន័យ បទថា **ឆឧបនិស្សយេ សត្ត** បានដល់ វារៈ ៨ គឺវារៈ ៤ ដែលប្រព្រឹត្តទៅ ដោយអំណាចនៃអនន្តរូបនិស្សយប្បច្ច័យ និងបកតូបនិស្សយប្បច្ច័យទាំងនេះ គឺកុសលជាបច្ច័យដល់កុសល ១ កុសលជាបច្ច័យដល់អកុសល ១ អកុសលជាបច្ច័យដល់អកុសល ១ អកុសល

ជាបច្ច័យដល់កុសល ១ មួយអន្លើដោយវារៈ ៤ ដែលដាច់ទៅក្នុងអធិការនោះ ព្រោះទាក់ទងជាមួយនសហជាតប្បច្ច័យរមែងដាច់ទៅ ព្រោះហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា **សត្ត** គឺដោយអំណាចនៃបច្ច័យដ៏សេស ។

បទថា **នបុរេជាតេ ឯកាទស** គឺមានវារៈ ១១ ព្រោះទាក់ទងជាមួយនសហជាតប្បច្ច័យ ។

បទថា **នបច្ឆាជាតេ នវ** សេចក្ដីថា ពិតហើយ ក្នុងវារៈ ១១ នេះ ព្រោះនាំចេញនូវវារៈ ២ ដែលមានមូល ២ និងមានអព្យាកតៈ ជាបទខាងចុងមានវិសជ្ជនាដែលបានហើយថា **សហជាតំ បច្ឆាជាតំ អាហារំ ឥន្ទ្រិយំ** កាលមានការបដិសេធសហជាតប្បច្ច័យ វារៈទាំងនោះ ក៏មិនទាន់ដាច់ ដោយអំណាចបច្ឆាជាតប្បច្ច័យ តែកាលមានការបដិសេធបច្ឆាជាតប្បច្ច័យ និងសហ-ជាតប្បច្ច័យ វារៈទាំងនេះ រមែងដាច់ទៅ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **នវ** គឺដោយអំណាចនៃបច្ច័យដ៏សេស ។

បទថា **ននិស្សយេ ឯកាទស** ក្នុងអដ្ឋមូលកន័យ ពាក្យអធិប្បាយទាំងអស់ ដូចគ្នាដែលខ្ញុំពោលហើយខាងដើមនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនវមូលកន័យដូចតទៅនេះ បទថា **នឧបនិស្សយេ បញ្ច** សេចក្ដីថា មាន ៥ វារៈ គឺវារៈ ៣ មានពួក ៣ នៃកុសលជាដើមដែលមានអព្យាកតៈជាទីបំផុត និងវារៈ ២ ដែលមានមូល ២ មានអព្យាកតៈជាបទខាងចុង គប្បីជ្រាបវិសជ្ជនាក្នុងវារៈទាំង ៥ នោះដោយអំណាចនៃធម៌គឺនានាខណិកកម្មប្បច្ច័យ កពឡិង្ការាហារ រូបជីវិតិន្ទ្រិយ និងបច្ឆាជាតប្បច្ច័យ ។

ក្នុងទសមូលកន័យ វារៈទាំងនោះឯង រមែងមាន ក្នុងពាក្យជាដើមថា **នបុរេជាតេ បញ្ច** ។ បទថា **នបច្ឆាជាតេ តីណិ** គឺវារៈដ៏សេស ព្រោះដកវារៈ ២ ដែលមានមូល ២ មានអព្យាកតៈ ជាបទខាងចុង ដែលបានដោយអំណាចបច្ឆាជាតប្បច្ច័យ ។ វារៈ ៣ នោះឯង រមែងមានក្នុងនវិប្ប-យុត្តប្បច្ច័យ ។ បទថា **នោអត្ថិយា ទ្វេ** គឺកុសល និងអកុសល ជាបច្ច័យដល់កដត្តារូបដោយអំណាចនៃនានាខណិកកម្មប្បច្ច័យ ក្នុងអធិការនេះ រមែងមិនបានវិបាក ព្រោះទាក់ទងនឹងនឧបនិស្សយប្បច្ច័យ ។ ការរាប់ក្នុងឯកា-ទសមូលកន័យ ដូចគ្នាតាមដែលខ្ញុំពោលហើយខាងដើមនោះឯង ។

ក្នុងទ្វាទសមូលកន័យ បទថា **នកម្មេ ឯកំ** គឺអព្យាកតៈជាមួយអព្យាកតៈ ក្នុងសេចក្តីនោះ អ្នកសិក្សាគប្បីជ្រាបវិសជ្ជនាដោយអំណាចអាហារ និងឥន្ទ្រិយ ។

ក្នុងតេរសមូលកន័យជាដើម អ្នកសិក្សាគប្បីកាន់យកវិសជ្ជនានេះឯង ក្នុងអាគតដ្ឋានថា **ឯកំ** ក្នុងបច្ច័យទាំងពួង តែក្នុងនអាហារប្បច្ច័យ គប្បីជ្រាបវិសជ្ជនាដោយអំណាចនៃឥន្ទ្រិយ ក្នុងនឥន្ទ្រិយប្បច្ច័យ គប្បីជ្រាបវិសជ្ជនាដោយអំណាចនៃអាហារ ។

ក្នុងចុទ្ទសមូលកន័យជាដើម រមែងមិនបាននោអត្ថិប្បច្ច័យ និងនោអវិគ-តប្បច្ច័យ ព្រោះទាក់ទងនឹងកម្មប្បច្ច័យ ហេតុនោះ ទើបលោកមិនពោល ។ លោកពោលទុកនូវបទថា **នាហារប្បច្ចយា នឈានប្បច្ចយា** ដោយនាំយកនឥន្ទ្រិយប្បច្ច័យចេញ ព្រោះហេតុនោះ ក្នុងឋានៈបែបនោះ អ្នកសិក្សា

*គប្បីជ្រាបវិសជ្ជនា ១ វារៈ ដោយអំណាចនៃឥន្ទ្រិយប្បច្ច័យ ។ បទថា* **នវិបាកប្បច្ចយា នឥន្ទ្រិយប្បច្ចយា** *លោកពោល ដោយដកអាហារចេញ ព្រោះហេតុនោះ ក្នុងឋានៈនោះ គប្បីជ្រាបវិសជ្ជនាមួយដោយអំណាចនៃអាហារប្បច្ច័យ ឈ្មោះថា ការរាប់ក្នុងវារៈ ២ នេះ ដែលតាំងនៅដោយភាពជាបច្ចនីយៈ រមែងមិនមាន ព្រោះហេតុនោះ ទើបលោកមិនបានសម្ដែងជាមួយគ្នា ដូច្នេះ ។*

## នហេតុមូលកន័យ ចប់

[ *៧១-១២៧* ] *ក្នុងនអារម្មណមូលកន័យជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ការកំណត់ចំនួនមូលក្នុងទុកៈទាំងពួង មាន ៤ ប៉ុណ្ណោះ គឺ ១៥-១៣-១១-៩ ចំណែកក្នុងតិមូលកន័យជាដើម រមែងបានវិសជ្ជនា ដែលមានចំនួនដែលលោកកំណត់ទុកហើយ គឺ ៧-៥-៣-២-១ ក្រៅអំពីនេះទៀត ព្រោះការប្រកបរួមគ្នានៃបច្ច័យជាច្រើន វិសជ្ជនាណាមួយ រមែងមានព្រោះការប្រកបរួមគ្នានៃបច្ច័យទាំងឡាយណា បណ្ដាបច្ច័យទាំងឡាយនោះ អ្នកសិក្សាគប្បីកំណត់វិសជ្ជនានឹងបច្ច័យនោះៗ ឲ្យល្អ ហើយលើកឡើងអធិប្បាយតាមន័យដែលខ្ញុំពោលហើយខាងដើមនោះឯង តែក្នុងនអារម្មណមូលកន័យជាដើម អ្នកសិក្សាគប្បីភ្ជាប់បទទាំងឡាយ មាននារម្មណបទជាដើម និងនហេតុបទដែលកន្លងមកហើយជាដំបូង ហើយធ្វើជាចក្កៈ គឺឲ្យវិលទៅ ព្រោះបទទាំងនោះ ដូចគ្នាតាមដែលពោលហើយ ក្នុងនហេតុមូលកន័យនោះឯង ហេតុនោះ ទើបលោកមិនសម្ដែងឲ្យពិស្ដារ សម្ដែងទុកត្រឹមសង្ខេបៗ*

*ប៉ុណ្ណោះ ។*

*គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងនោះដូចតទៅនេះថា ក្នុងនហេតុមូលកន័យ ព្រោះនអារម្មណៈ និងព្រោះនឧបនិស្សយប្បច្ច័យ រមែងបានវារៈ ១៥ ដោយការបំបែក បានវារៈ ១៣ ព្រោះការប្រកបរួមគ្នា យ៉ាងណា រមែងបានវារៈ ១៣ ប៉ុណ្ណោះក្នុងទីទូទៅ ក៏យ៉ាងនោះ ។ ក្នុងនឧបនិស្សយប្បច្ច័យ វារៈ ៧ រមែងមានព្រមគ្នា ដោយនអារម្មណៈ និងនសហជាតប្បច្ច័យ យ៉ាងណា ក្នុងនសហជាតប្បច្ច័យ ក៏មានវារៈ ៧ មួយអន្លើដោយនឧបនិស្សយ និងនអារម្មណប្បច្ច័យ ក៏យ៉ាងនោះ ។*

*បទថា* **ននិស្សយប្បច្ចយា នឧបនិស្សយប្បច្ចយា នបច្ឆាជាតេ តីណិ** *គឺវិសជ្ជនា ៣ វារៈ មានកុសលជាខាងដើម មានអព្យាកតៈជាទីបំផុត ក្នុងបច្ច័យទាំងនោះ មានកដត្តារូប និងអាហារជរូប ជាបច្ចយុប្បន្ន ។*

*ក្នុងពួក ៤ មាននអាហារ និងនឥន្ទ្រិយជាមូល រមែងមិនបានវារៈដោយពិតប្រាកដ ដូចក្នុងនហេតុមូលកន័យ ព្រោះមិនភ្ជាប់ជាមួយកម្មប្បច្ច័យ ។*

*ក្នុងនឥន្ទ្រិយមូលកន័យ បទថា* **នាហារេ តីណីតិ កាតព្វំ** *អធិប្បាយថា វៀរនឧបនិស្សយប្បច្ច័យ និងនបុរេជាតប្បច្ច័យ អ្នកសិក្សាគប្បីភ្ជាប់បច្ច័យ ២ នេះ អំពីនឥន្ទ្រិយប្បច្ច័យ ហើយធ្វើការរាប់ដោយនអាហារប្បច្ច័យជាមួយបច្ច័យទាំង ២ នេះ យ៉ាងនេះ គឺ* **នឥន្ទ្រិយប្បច្ចយា ។បេ។ នឧបនិស្សយប្បច្ចយា នាហារេ តីណិ ។ ន ឥន្ទ្រិយប្បច្ចយា ។បេ។ នបុរេជាតប្បច្ចយា នាហារេ តីណិ** ។ *បណ្ដាបទទាំងនោះ បទថា* **តីណិ** *គឺ*

កុសលជាដើមនោះឯង ជាបច្ច័យដល់អព្យាកតៈ ។

ក្នុងពាក្យនោះ មានអធិប្បាយ ដូចតទៅនេះថា កុសល និងអកុសល ជាបច្ច័យដល់កដត្តារូប និងដល់កាយដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ចំណែកចិត្ត និងចេតសិក ដែលជាអព្យាកតៈ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ តែម្យ៉ាង អ្នកសិក្សាគប្បីចងវិសជ្ជនាប្រការ ៣ ដោយអំណាចនៃបច្ច័យទាំងនេះ ដូចអធិប្បាយមកនេះ ។

ព្រះមានព្រះភាគ ត្រាស់ថា **អាហារេ ទ្វេ** ព្រោះភ្ជាប់ជាមួយបច្ឆាជាតប្បច្ច័យខាងមុខ ក្នុងសេចក្ដីនោះ បានវិសជ្ជនាប្រមាណប៉ុណ្ណេះ គឺកុសល ជាបច្ច័យដល់អព្យាកតៈ ដោយអំណាចជាកដត្តារូប និងអកុសល ជាបច្ច័យដល់អព្យាកតៈ ដោយអំណាចជាកដត្តារូបដូចគ្នា តែព្រោះអាហារត្រូវបដិសេធចេញ ទើបកពឡិង្ការាហារ មិនបានភាពជាបច្ច័យដោយអំណាចអត្ថិ និងអវិគតប្បច្ច័យ ។

ក្នុងចតុមូលកន័យ ក្នុងវគ្គដែលពោលអំពីបដ្ឋាន ដែលមាននវិប្បយុត្តប្បច្ច័យជាមូល ។ បទថា **នឧបនិស្សយេ បញ្ច** គឺមានវិសជ្ជនា ៥ វារៈ គឺកុសល ជាបច្ច័យដល់កុសលដែលកើតព្រមគ្នា កុសល ជាបច្ច័យដល់អព្យាកតៈ ពោល គឺកដត្តារូប អកុសល ជាបច្ច័យដល់អកុសល ដែលកើតព្រមគ្នា អកុសល ជាបច្ច័យដល់អព្យាកតៈ គឺកដត្តារូប អព្យាកតៈ ជាបច្ច័យដល់អព្យាកតៈ ដែលកើតព្រមគ្នា ។ បទថា **នវិប្បយុត្តប្បច្ចយា ។បេ។ នឧបនិស្សយេ តីណិ** គឺវារៈ ៣ មានកុសលជាដើម ជាបច្ច័យដល់អព្យាកតៈ

*តាមន័យដែលខ្ញុំពោលហើយខាងដើម ។*

*បទថា* **នោអត្ថិប្បច្ចយា នហេតុយា នវ** *គឺវារៈ ៩ ដែលលោកពោលថា កើតព្រោះនហេតុប្បច្ច័យ ក្នុងនោអត្ថិប្បច្ច័យ ។ ពិតហើយ វារៈទាំងអស់នោះ វារៈ ១ ដែលមានមូល ១ ជាទីបំផុត រមែងបានដោយអំណាចអនន្តរប្បច្ច័យ និងបកតូបនិស្សយប្បច្ច័យ ។*

*ក្នុងបទថា* **នារម្មណេ នវ** *អ្នកសិក្សាគប្បីតាំងវារៈទាំងនោះឯង ក្នុងនអារម្មណប្បច្ច័យ ហើយបែងនឧបនិស្សយប្បច្ច័យចេញជា ២ ។ បទថា* **យាវ និស្សយម្បិ** *សេចក្តីថា ក្នុងន័យដែលមាននោអត្ថិប្បច្ច័យជាមូល អ្នកសិក្សា គប្បីតាំងទុកក្នុងនអារម្មណប្បច្ច័យ ដោយការបន្ថែមយ៉ាងនេះ គឺ* **នោអត្ថិប្បច្ចយា នហេតុប្បច្ចយា នអារម្មណប្បច្ចយា** *រហូតដល់និស្សយប្បច្ច័យ ហើយគប្បីចងវិសជ្ជនា ២ វារៈ ក្នុងនឧបនិស្សយប្បច្ច័យជាមួយបច្ច័យយ៉ាងនេះ ឬបច្ច័យឯណានីមួយ មាននអធិបតិប្បច្ច័យជាដើម បន្ទាប់អំពីនេះទៅ ។*

*ព្រះមានព្រះភាគ ទ្រង់តាំងលក្ខណៈយ៉ាងនេះហើយ ទ្រង់កាន់យកបច្ច័យ ៧ តាំងអំពីនអារម្មណប្បច្ច័យ រហូតដល់ននិស្សយប្បច្ច័យទៀត ហើយត្រាស់ថា* **នឧបនិស្សយេ ទ្វេ** *ក្នុងសេចក្តីនោះ អ្នកសិក្សាគប្បីចងយោជនាអំពីនារម្មណប្បច្ច័យជាមួយនឹងបទទាំងពួង មានននិស្សយប្បច្ច័យជាទីបំផុតខាងមុខ និងខាងក្រោយ យ៉ាងនេះ គឺ* **នោអត្ថិប្បច្ចយា នហេតុប្បច្ចយា នារម្មណប្បច្ចយា នឧបនិស្សយេ ទ្វេ នោអត្ថិប្បច្ចយា នហេតុនា-**

**រម្មណាធិបតិប្បច្ចយា ឆឧបនិស្សយេ ទ្វេ។** *បទថា* **ទ្វេ** *ក្នុងអធិការនេះ អ្នកសិក្សាគប្បីជ្រាបដោយអំណាចបច្ច័យនៃកដត្តារូប ដោយអំណាចនៃនា-នាខណិកកម្ម គឺកុសល ជាបច្ច័យដល់អព្យាកតៈ អកុសល ជាបច្ច័យដល់អព្យាកតៈ ។ ក្នុងនបុរេជាតប្បច្ច័យជាដើម និងនឧបនិស្សយបទ គប្បីជ្រាបថា មានវិសជ្ជនា ២ វារៈ ក្នុងទីគ្រប់អន្ទើ ។ ក្នុងអធិការនេះ លោកមិនកាន់យកកម្មប្បច្ច័យ ។ ពិតហើយ កាលកាន់យកកម្មប្បច្ច័យនោះ វារៈទាំង ២ នោះ រមែងដាច់ទៅផងដែរ រមែងមិនបានវិសជ្ជនា ក្នុងការប្រៀបធៀបវិសជ្ជនាណាមួយ ជាមួយវិសជ្ជនាណាមួយ វិសជ្ជនាណាមាន និងវិសជ្ជនាណាដាច់ទៅ អ្នកសិក្សាគប្បីកំណត់វិសជ្ជនាទាំងអស់នោះ ឲ្យល្អ ហើយគប្បីពង្រីកចំនួនក្នុងបច្ចនីយៈទាំងអស់ ៚*

**អដ្ឋកថាបច្ចនីយគណនា ចប់**

# អភិធម្មបិដក

## បញ្ហាវារៈ អនុលោមប្បច្ចនីយគណនា

### ហេតុមូលកៈ

[ ១២៨ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៧ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៧ ក្នុងនកម្មប្បច្ច័យ មានវារៈ ៧ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៧ ក្នុងនអាហារប្បច្ច័យ មានវារៈ ៧ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងនឈានប្បច្ច័យ មានវារៈ ៧ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៧ ។

[ ១២៩ ] ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៧ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៧ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៧ ក្នុង

នកម្មប្បច្ច័យ មានវារៈ ៧ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៧ ក្នុងនអាហារប្បច្ច័យ មានវារៈ ៧ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងនឈានប្បច្ច័យ មានវារៈ ៧ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៧ ។

[ ១៣០ ] ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនអាហារប្បច្ច័យ មានវារៈ ៣ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងនឈានប្បច្ច័យ មានវារៈ ៣ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១៣១ ] ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣

ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនអាហារប្បច្ច័យ មានវារៈ ៣ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងនឈានប្បច្ច័យ មានវារៈ ៣ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១៣២ ] ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ក្នុងនអារម្មណប្បច្ច័យព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនអាហារប្បច្ច័យ មានវារៈ ៣ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងនឈានប្បច្ច័យ មានវារៈ ៣ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១៣៣ ] ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ

អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១ ។

[ ១៣៤ ] ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ

មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១ ។

[ ១៣៥ ] ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១ ។

[ ១៣៦ ] ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងន-

អាហារប្បច្ច័យ មានវារៈ ១ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងឈានប្បច្ច័យ មានវារៈ ១ ក្នុងមគ្គប្បច្ច័យ មានវារៈ ១ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១ ។

[ ១៣៧ ] ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១ ។

[ ១៣៨ ] ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៤ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៤

ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៤ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៤ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៤ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងនអាហារប្បច្ច័យ មានវារៈ ៤ ក្នុងនឈានប្បច្ច័យ មានវារៈ ៤ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៤ ។

[ ១៣៩ ] ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ក្នុងនអាហារប្បច្ច័យ មានវារៈ ២ ក្នុងនឈានប្បច្ច័យ មានវារៈ ២ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ២ ក្នុងនោវិគតប្បច្ច័យ មានវារៈ ២ ។

[ ១៤០ ] ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុង

នអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបា-កប្បច្ច័យ មានវារៈ ២ ក្នុងនអាហារប្បច្ច័យ មានវារៈ ២ ក្នុងនឈានប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ២ ក្នុងនោវិគតប្បច្ច័យ មានវារៈ ២ ។

[ ១៤១ ] ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ២ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ក្នុងនអាហារប្បច្ច័យ មានវារៈ ២ ក្នុងនឈានប្បច្ច័យ មានវារៈ ២ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ២ ក្នុងនោវិគតប្បច្ច័យ មានវារៈ ២ ។

[ ១៤២ ] ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១

ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១ ។

[ ១៨៣ ] ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១ ។

[ ១៨៤ ] ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ

វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យមានវារៈ ១ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១ ។

[ ១៨៥ ] ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១ ។

[ ១៤៦ ] ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១ ។

[ ១៤៧ ] ពាក្យថា អធិបតិប្បច្ច័យ សហជាតប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៤ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៤ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៤ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៤ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងនអាហារប្បច្ច័យ មានវារៈ ៤ ក្នុងនឈានប្បច្ច័យ មានវារៈ ៤ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុង

នោនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៤ ។

[ ១៤៨ ] ពាក្យថា អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ក្នុងនអាហារប្បច្ច័យ មានវារៈ ២ ក្នុងនឈានប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ២ ក្នុងនោវិគតប្បច្ច័យ មានវារៈ ២ ។

[ ១៤៩ ] ពាក្យថា អធិបតិប្បច្ច័យ សហជាតប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ២ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ក្នុងនអាហារប្បច្ច័យ មានវារៈ ២ ក្នុង

នឈានប្បច្ច័យ មានវារៈ ២ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ២ ក្នុងនោវិគតប្បច្ច័យ មានវារៈ ២ ។

[ ១៥០ ] ពាក្យថា អធិបតិប្បច្ច័យ សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១ ។

[ ១៥១ ] ពាក្យថា អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ... ក្នុងនអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនអាហារប្បច្ច័យ មានវារៈ

១ ក្នុងនឈានបច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តបច្ច័យ មានវារៈ ១ ក្នុងនោនត្ថិបច្ច័យ មានវារៈ ១ ក្នុងនោវិគតបច្ច័យ មានវារៈ ១ ។

[ ១៥២ ] ពាក្យថា អធិបតិបច្ច័យ សហជាតបច្ច័យ និស្សយបច្ច័យ វិបាកបច្ច័យ ឥន្ទ្រិយបច្ច័យ មគ្គបច្ច័យ វិប្បយុត្តបច្ច័យ អត្ថិបច្ច័យ អវិគតបច្ច័យ ដូច្នេះ មានវារៈ ១ ក្នុងនអារម្មណបច្ច័យ ព្រោះហេតុបច្ច័យ ... ក្នុងនអនន្តរបច្ច័យ មានវារៈ ១ ក្នុងនសមនន្តរបច្ច័យ មានវារៈ ១ ក្នុងនអញ្ញមញ្ញបច្ច័យ មានវារៈ ១ ក្នុងនឧបនិស្សយបច្ច័យ មានវារៈ ១ ក្នុងនបុរេជាតបច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតបច្ច័យ មានវារៈ ១ ក្នុងនអាសេវនបច្ច័យ មានវារៈ ១ ក្នុងនកម្មបច្ច័យ មានវារៈ ១ ក្នុងនអាហារបច្ច័យ មានវារៈ ១ ក្នុងនឈានបច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តបច្ច័យ មានវារៈ ១ ក្នុងនោនត្ថិបច្ច័យ មានវារៈ ១ ក្នុងនោវិគតបច្ច័យ មានវារៈ ១ ។

ហេតុមូលកៈ ចប់

## អារម្មណមូលកៈ

[ ១៥៣ ] ក្នុងនហេតុបច្ច័យ មានវារៈ ៩ ព្រោះអារម្មណបច្ច័យ ... ក្នុងនអធិបតិបច្ច័យ មានវារៈ ៩ ក្នុងនអនន្តរបច្ច័យ មានវារៈ ៩ ក្នុងនសមនន្តរបច្ច័យ មានវារៈ ៩ ក្នុងនសហជាតបច្ច័យ មានវារៈ ៩ ក្នុងនអញ្ញមញ្ញបច្ច័យ មានវារៈ ៩ ក្នុងននិស្សយបច្ច័យ មានវារៈ ៩ ក្នុងនឧបនិស្សយបច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតបច្ច័យ មានវារៈ ៩ ក្នុង

នបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៩ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ៩ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងនឈានប្បច្ច័យ មានវារៈ ៩ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៥៤ ] ពាក្យថា អធិបតិប្បច្ច័យ ឧបនិស្សយប្បច្ច័យ ដូច្នេះ មានវារៈ ៧ ក្នុងនហេតុប្បច្ច័យ ព្រោះអារម្មណប្បច្ច័យ ... ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនសហជាតប្បច្ច័យ មានវារៈ ៧ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៧ ក្នុងននិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៧ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៧ ក្នុងនកម្មប្បច្ច័យ មានវារៈ ៧ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៧ ក្នុងនអាហារប្បច្ច័យ មានវារៈ ៧ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងនឈានប្បច្ច័យ មានវារៈ ៧ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៧ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៧ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៧ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៧ ។

[ ១៥៥ ] ពាក្យថា បុរេជាតប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ

ដូច្នេះ មានវារៈ ៣ ក្នុងនហេតុប្បច្ច័យ ព្រោះអារម្មណប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងននិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនអាហារប្បច្ច័យ មានវារៈ ៣ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងនឈានប្បច្ច័យ មានវារៈ ៣ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១៥៦ ] ពាក្យថា និស្សយប្បច្ច័យ បុរេជាតប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ក្នុងនហេតុប្បច្ច័យ ព្រោះអារម្មណប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនអាហារប្បច្ច័យ មានវារៈ ៣ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងនឈានប្បច្ច័យ មានវារៈ ៣ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងនសម្ប-

យុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១៥៧ ] ពាក្យថា អធិបតិប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ក្នុងនហេតុប្បច្ច័យ ព្រោះអារម្មណប្បច្ច័យ ... ក្នុងនអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនសហជាតប្បច្ច័យ មានវារៈ ១ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងននិស្សយប្បច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១ ។

[ ១៥៨ ] ពាក្យថា អធិបតិប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ក្នុងនហេតុប្បច្ច័យ ព្រោះអារម្មណប្បច្ច័យ ... ក្នុងនអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនសហជាតប្បច្ច័យ មានវារៈ ១ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យ មានវារៈ

១ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១ ។

អារម្មណមូលកៈ ចប់

## អធិបតិមូលកៈ

[ ១៥៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១០ ព្រោះអធិបតិប្បច្ច័យ ... ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ១០ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ១០ ក្នុងនសហជាតប្បច្ច័យ មានវារៈ ៧ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៨ ក្នុងននិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១០ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១០ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១០ ក្នុងនកម្មប្បច្ច័យ មានវារៈ ១០ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១០ ក្នុងនអាហារប្បច្ច័យ មានវារៈ ១០ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១០ ក្នុងនឈានប្បច្ច័យ មានវារៈ ១០ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១០ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៨ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៧ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១០ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១០ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៧ ។

[ ១៦០ ] ពាក្យថា អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៨

ក្នុងនហេតុប្បច្ច័យ ព្រោះអធិបតិប្បច្ច័យ ... ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៨ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៨ ក្នុងនសហជាតប្បច្ច័យ មានវារៈ ១ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៤ ក្នុងននិស្សយប្បច្ច័យ មានវារៈ ១ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៨ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៨ ក្នុងនកម្មប្បច្ច័យ មានវារៈ ៨ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៨ ក្នុងនអាហារប្បច្ច័យ មានវារៈ ៨ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ៨ ក្នុងនឈានប្បច្ច័យ មានវារៈ ៨ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៨ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៨ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៨ ។

[ ១៦១ ] ពាក្យថា និស្សយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៨ ក្នុងនហេតុប្បច្ច័យ ព្រោះអធិបតិប្បច្ច័យ ... ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៨ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៨ ក្នុងនសហជាតប្បច្ច័យ មានវារៈ ១ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៤ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៨ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៨ ក្នុងនកម្មប្បច្ច័យ មានវារៈ ៨ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៨ ក្នុងនអាហារប្បច្ច័យ មានវារៈ ៨ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ៨ ក្នុង

នឈានប្បច្ច័យ មានវារៈ ៨ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៨ ក្នុងនសម្ប-យុត្តប្បច្ច័យ មានវារៈ ៤ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោ-នត្ថិប្បច្ច័យ មានវារៈ ៨ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៨ ។

[ ៥១៩ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយសុខវេទនា ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ដោយចិត្តដែលប្រកបដោយសុខវេទនា ហើយពិចារណា ដោយចិត្តដែលប្រកបដោយសុខវេទនា ចេញអំពីឈាន ដែលប្រកបដោយសុខវេទនា ចេញអំពីមគ្គ ចេញអំពីផល ហើយពិចារណាដោយចិត្តដែលប្រកបដោយសុខវេទនា ។ ពួកព្រះអរិយៈ ពិចារណានូវពួកកិលេសដែលលះបង់ហើយ ដែលប្រកបដោយសុខវេទនា ដោយចិត្តដែលប្រកបដោយសុខវេទនា ពិចារណានូវពួកកិលេសដែលខ្លួនសង្កត់សង្កិនបានហើយ ដឹងនូវពួកកិលេសដែលខ្លួនធ្លាប់សន្សំហើយ ក្នុងកាលមុន ឃើញច្បាស់នូវពួកខន្ធដែលប្រកបដោយសុខវេទនា ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ដោយចិត្តដែលប្រកបដោយសុខវេទនា ហើយត្រេកអររីករាយ រាគៈដែលប្រកបដោយសុខវេទនា កើតឡើង ព្រោះប្រារព្ធនូវវត្ថុទាំងនោះ ទិដ្ឋិកើតឡើង ។បេ។ ពួកខន្ធដែលប្រកបដោយសុខវេទនា កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយសុខវេទនា ។

[ ៥២០ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយទុក្ខវេទនា ដោយអារម្មណប្បច្ច័យ គឺទោមនស្ស របស់បុគ្គលអ្នកមានសេចក្តីស្តាយក្រោយ កើតឡើង ព្រោះឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ដោយចិត្តដែលប្រកបដោយសុខវេទនា ទោមនស្ស របស់

បុគ្គលអ្នកមានសេចក្តីស្តាយក្រោយ កើតឡើង ព្រោះលះបង់ឈាន ដែលប្រកបដោយសុខវេទនា ពួកខន្ធដែលប្រកបដោយទុក្ខវេទនា កើតឡើងព្រោះប្រារព្ធនូវពួកខន្ធដែលប្រកបដោយសុខវេទនា ។

[ ៥២១ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ដោយចិត្តដែលប្រកបដោយសុខវេទនា ហើយពិចារណា ដោយចិត្តដែលប្រកបដោយអទុក្ខមសុខវេទនា ចេញអំពីឈាន ដែលប្រកបដោយសុខវេទនា ចេញអំពីមគ្គ ចេញអំពីផល ហើយពិចារណា ដោយចិត្តដែលប្រកបដោយអទុក្ខមសុខវេទនា ។ ពួកព្រះអរិយៈពិចារណានូវពួកកិលេសដែលលះបង់ហើយ ដែលប្រកបដោយសុខវេទនា ដោយចិត្ត ដែលប្រកបដោយអទុក្ខមសុខវេទនា ពិចារណានូវពួកកិលេសដែលខ្ជួនសង្កត់សង្កិនហើយ ដឹងនូវពួកកិលេស ដែលខ្ជួនធ្លាប់សន្សំហើយក្នុងកាលមុន ឃើញច្បាស់នូវពួកខន្ធ ដែលប្រកបដោយសុខវេទនា ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ដោយចិត្តដែលប្រកបដោយអទុក្ខមសុខវេទនា រមែងត្រេកអរ រីករាយ រាគៈដែលប្រកបដោយអទុក្ខមសុខវេទនា រមែងកើតឡើងព្រោះប្រារព្ធនូវវត្ថុទាំងនោះ ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ឧទ្ធច្ចៈកើតឡើង ។ ( ពួកព្រះអរិយៈ ) ដឹងនូវចិត្តរបស់បុគ្គលអ្នកព្រមព្រៀងដោយចិត្តដែលប្រកបដោយសុខវេទនា ដោយចេតោបរិយញ្ញាណ ។ ពួកខន្ធដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃការពិចារណានូវចេតោបរិយញ្ញាណ

បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណដោយ អារម្មណប្បច្ច័យ ។ ពួកខន្ធដែលប្រកបដោយអទុក្ខមសុខវេទនា កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយសុខវេទនា ។

[ ៥២២ ] ធម៌ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយទុក្ខវេទនា ដោយអារម្មណប្បច្ច័យ គឺទោសៈកើតឡើង ព្រោះប្រារព្ធនូវទោសៈ មោហៈកើតឡើង មោហៈកើតឡើងព្រោះប្រារព្ធនូវមោហៈ ដែលប្រកបដោយទុក្ខវេទនា ទោសៈកើតឡើង ទោសៈកើតឡើង ព្រោះប្រារព្ធនូវកាយវិញ្ញាណ ដែលច្រឡំដោយទុក្ខ មោហៈកើតឡើង ពួកខន្ធ ដែលប្រកបដោយទុក្ខវេទនា កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធដែលប្រកបដោយទុក្ខវេទនា ។

[ ៥២៣ ] ធម៌ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយសុខវេទនា ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈពិចារណានូវពួកកិលេសដែលខ្លួនលះបង់ហើយ ដែលប្រកបដោយទុក្ខវេទនា ដោយចិត្តដែលប្រកបដោយសុខវេទនា ពិចារណានូវពួកកិលេស ដែលខ្លួនសង្កត់សង្កិនបានហើយ ដឹងនូវពួកកិលេសដែលខ្លួនធ្លាប់សន្សំហើយ ក្នុងកាលមុន ឃើញច្បាស់នូវពួកខន្ធ ដែលប្រកបដោយទុក្ខវេទនា ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ដោយចិត្តដែលប្រកបដោយសុខវេទនា ។ ពួកខន្ធ ដែលប្រកបដោយសុខវេទនា កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធដែលប្រកបដោយទុក្ខ-វេទនា ។

[ ៥២៤ ] ធម៌ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃធម៌ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈពិចារណានូវពួកកិលេស ដែលខ្លួនលះបង់បានហើយ ដែលប្រកបដោយទុក្ខវេទនា ដោយចិត្ត ដែលប្រកបដោយអទុក្ខមសុខវេទនា ពិចារណានូវពួកកិលេសដែលខ្លួនសង្កត់សង្កិនបានហើយ ដឹងនូវពួកកិលេសដែលខ្លួនធ្លាប់សន្សំហើយក្នុងកាលមុន ឃើញច្បាស់នូវពួកខន្ធ ដែលប្រកបដោយទុក្ខវេទនា ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ដោយចិត្តដែលប្រកបដោយអទុក្ខមសុខវេទនា ដឹងនូវចិត្តរបស់បុគ្គលអ្នកព្រមព្រៀងដោយចិត្ត ដែលប្រកបដោយទុក្ខវេទនា ដោយចេតោបរិយញ្ញាណ ។ ពួកខន្ធដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃការពិចារណានូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ ពួកខន្ធដែលប្រកបដោយអទុក្ខមសុខវេទនា កើតឡើងព្រោះប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយទុក្ខវេទនា ។

[ ៥២៥ ] ធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃធម៌ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយអារម្មណប្បច្ច័យ គឺពួកបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ដោយចិត្ត ដែលប្រកបដោយអទុក្ខមសុខវេទនា ហើយពិចារណា ដោយចិត្តដែលប្រកបដោយអទុក្ខមសុខវេទនា ចេញអំពីឈានដែលប្រកបដោយអទុក្ខមសុខវេទនា ចេញអំពីមគ្គ ចេញអំពីផល ហើយពិចារណាដោយចិត្តដែលប្រកបដោយអទុក្ខម-

សុខវេទនា ។ ពួកព្រះអរិយៈ ពិចារណានូវពួកកិលេស ដែលខ្លួនលះបង់បានហើយដែលប្រកបដោយអទុក្ខមសុខវេទនា ដោយចិត្តដែលប្រកបដោយអទុក្ខមសុខវេទនា ពិចារណានូវពួកកិលេសដែលខ្លួនសង្កត់សង្កិនបានហើយ ដឹងនូវពួកកិលេសដែលខ្លួនធ្លាប់សន្សំហើយ ក្នុងកាលមុន ឃើញច្បាស់នូវពួកខន្ធដែលប្រកបដោយអទុក្ខមសុខវេទនា ថាមិនទៀង ជាទុក្ខ មិនមែនខ្លួនដោយចិត្ត ដែលប្រកបដោយអទុក្ខមសុខវេទនា ហើយត្រេកអរ រីករាយរាគៈ ដែលប្រកបដោយអទុក្ខមសុខវេទនា កើតឡើង ព្រោះប្រារព្ធនូវវត្ថុទាំងនោះ ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ឧទ្ធច្ចៈកើតឡើង ។ ( ពួកព្រះអរិយៈ ) ដឹងនូវចិត្តរបស់បុគ្គល អ្នកព្រមព្រៀងដោយចិត្ត ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយចេតោបរិយញ្ញាណ ។ អាកាសានញ្ចាយតនៈ ជាបច្ច័យនៃវិញ្ញាណញ្ចាយតនៈ ដោយអារម្មណប្បច្ច័យ ។បេ។ អាកិញ្ចញ្ញាយតនៈ ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនៈ ដោយអារម្មណប្បច្ច័យ ។ ពួកខន្ធ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ ពួកខន្ធដែលប្រកបដោយអទុក្ខមសុខវេទនា កើតឡើងព្រោះប្រារព្ធនូវពួកខន្ធដែលប្រកបដោយអទុក្ខមសុខវេទនា ។

[ ៥២៦ ] ធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃធម៌ដែលប្រកបដោយសុខវេទនា ដោយអារម្មណប្បច្ច័យ គឺពួកបុគ្គលឲ្យទាន

សមាទានសីល ធ្វើឧបោសថកម្ម ដោយចិត្តដែលប្រកបដោយអទុក្ខមសុខ-វេទនា ហើយពិចារណា ដោយចិត្តដែលប្រកបដោយសុខវេទនា ចេញអំពីឈាន ដែលប្រកបដោយអទុក្ខមសុខវេទនា ចេញអំពីមគ្គ ចេញអំពីផល ហើយពិចារណា ដោយចិត្តដែលប្រកបដោយសុខវេទនា ។ ពួកព្រះអរិយៈពិចារណានូវពួកកិលេសដែលខ្លួនលះបង់ហើយ ដែលប្រកបដោយអទុក្ខម-សុខវេទនា ដោយចិត្តដែលប្រកបដោយសុខវេទនា ពិចារណានូវពួកកិលេសដែលខ្លួនសង្កត់សង្កិនបានហើយ ដឹងនូវពួកកិលេសដែលខ្លួនធ្លាប់សន្សំហើយក្នុងកាលមុន ឃើញច្បាស់នូវពួកខន្ធ ដែលប្រកបដោយអទុក្ខមសុខវេទនាថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ដោយចិត្តដែលប្រកបដោយសុខវេទនាត្រេកអររីករាយ រាគៈដែលប្រកបដោយសុខវេទនា កើតឡើង ព្រោះប្រារព្ធនូវវត្ថុទាំងនោះ ទិដ្ឋិកើតឡើង ។បេ។ ពួកខន្ធដែលប្រកបដោយសុខវេទនាកើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយអទុក្ខមសុខវេទនា ។

[ ៥២៧ ] ធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃធម៌ដែលប្រកបដោយទុក្ខវេទនា ដោយអារម្មណប្បច្ច័យ គឺទោមនស្ស របស់បុគ្គលអ្នកមានសេចក្តីស្តាយក្រោយ កើតឡើងព្រោះឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ដោយចិត្តដែលប្រកបដោយអទុក្ខមសុខវេទនា ទោមនស្សរបស់បុគ្គលអ្នកមានសេចក្តីស្តាយក្រោយ កើតឡើង ព្រោះលះបង់ឈានដែលប្រកបដោយអទុក្ខមសុខវេទនា ពួកខន្ធ ដែលប្រកបដោយទុក្ខវេទនាកើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយអទុក្ខមសុខវេទនា ។

[ ៥២៨ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយសុខវេទនា ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ដោយចិត្តដែលប្រកបដោយសុខវេទនា ហើយធ្វើនូវកុសលនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយពិចារណាដោយចិត្ត ដែលប្រកបដោយសុខវេទនា ចេញអំពីឈាន ដែលប្រកបដោយសុខវេទនា ចេញអំពីមគ្គ ចេញអំពីផល ហើយធ្វើនូវពួកកុសលនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ដោយចិត្ត ដែលប្រកបដោយសុខវេទនា ហើយពិចារណា បុគ្គលធ្វើនូវពួកខន្ធ ដែលប្រកបដោយសុខវេទនាឲ្យធ្ងន់ ( ក្នុងចិត្ត ) ដោយចិត្ត ដែលប្រកបដោយសុខវេទនា ហើយត្រេកអរ រីករាយ រាគៈដែលប្រកបដោយសុខវេទនាកើតឡើង ព្រោះធ្វើនូវពួកធម៌នោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ទិដ្ឋិកើតឡើង ។បេ។ សហជាតាធិបតិ គឺអធិបតិធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។

[ ៥២៩ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ដោយចិត្តដែលប្រកបដោយសុខវេទនា ធ្វើនូវពួកកុសលនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ដោយចិត្ត ដែលប្រកបដោយអទុក្ខមសុខវេទនា ហើយពិចារណា ចេញអំពីឈាន ដែលប្រកបដោយសុខវេទនា ចេញអំពីមគ្គ ចេញអំពី

ផល ហើយធ្វើនូវពួកកុសលនោះ ឲ្យធ្ងន់ ( ក្នុងចិត្ត ) ដោយចិត្តដែលប្រកបដោយអទុក្ខមសុខវេទនា ហើយពិចារណា ធ្វើនូវពួកខន្ធដែលប្រកបដោយសុខវេទនាឲ្យធ្ងន់ ( ក្នុងចិត្ត ) ដោយចិត្តដែលប្រកបដោយអទុក្ខមសុខវេទនា ហើយត្រេកអរ រីករាយ រាគៈដែលប្រកបដោយអទុក្ខមសុខវេទនា កើតឡើង ព្រោះធ្វើនូវពួកកុសលនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ទិដ្ឋិកើតឡើង ។បេ។

[ ៥៣០ ] ធម៌ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយទុក្ខវេទនា ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ ។ សហជាតាធិបតិ គឺអធិបតិធម៌ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។

[ ៥៣១ ] ធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃធម៌ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ដោយចិត្តដែលប្រកបដោយអទុក្ខមសុខវេទនា ធ្វើនូវពួកកុសលនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ហើយពិចារណា ដោយចិត្តដែលប្រកបដោយអទុក្ខមសុខវេទនា ចេញអំពីឈាន ដែលប្រកបដោយអទុក្ខមសុខវេទនា ចេញអំពីមគ្គ ចេញអំពីផល ធ្វើនូវពួកកុសលនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ដោយចិត្ត ដែលប្រកបដោយអទុក្ខមសុខវេទនា ហើយពិចារណា ធ្វើនូវពួកខន្ធ ដែលប្រកបដោយអទុក្ខមសុខវេទនា ឲ្យធ្ងន់ ( ក្នុងចិត្ត )

ហើយត្រេកអរ រីករាយដោយចិត្តដែលប្រកបដោយអទុក្ខមសុខវេទនា រាគៈដែលប្រកបដោយអទុក្ខមសុខវេទនា កើតឡើង ព្រោះធ្វើនូវពួកកុសលនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ទិដ្ឋិកើតឡើង ។បេ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។

[ ៥៣២ ] ធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃធម៌ដែលប្រកបដោយសុខវេទនា ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ដោយចិត្តដែលប្រកបដោយអទុក្ខមសុខវេទនា ធ្វើនូវពួកកុសលនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ដោយចិត្តដែលប្រកបដោយសុខវេទនា ហើយពិចារណា ចេញអំពីឈាន ដែលប្រកបដោយអទុក្ខមសុខវេទនា ចេញអំពីមគ្គ ចេញអំពីផល ធ្វើនូវពួកកុសលនោះ ឲ្យធ្ងន់ ( ក្នុងចិត្ត ) ដោយចិត្តដែលប្រកបដោយសុខវេទនា ហើយពិចារណា ធ្វើនូវពួកខន្ធដែលប្រកបដោយអទុក្ខមសុខវេទនា ឲ្យធ្ងន់ ( ក្នុងចិត្ត ) ដោយចិត្តដែលប្រកបដោយសុខវេទនា ហើយត្រេកអរ រីករាយ រាគៈដែលប្រកបដោយសុខវេទនា កើតឡើង ព្រោះធ្វើនូវពួកកុសលនោះឲ្យធ្ងន់ ( ក្នុងចិត្ត ) ទិដ្ឋិកើតឡើង ។បេ។

[ ៥៣៣ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយសុខវេទនា ដោយអនន្តរប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយសុខវេទនាមុនៗ ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយសុខវេទនាក្រោយៗ

ដោយអនន្តរប្បច្ច័យ អនុលោម ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃគោត្រភូ ដែលប្រកបដោយសុខវេទនា ដោយអនន្តរប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃវោទាន: គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទាន: ( ជាបច្ច័យ ) នៃមគ្គ មគ្គ ( ជាបច្ច័យ ) នៃផល ផល ( ជាបច្ច័យ ) នៃផល អនុលោម ជាបច្ច័យនៃផលសមាបត្តិ ដែលប្រកបដោយសុខវេទនា ដោយអនន្តរប្បច្ច័យ ។ ពួកខន្ធ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃវុដ្ឋាន: ដែលប្រកបដោយសុខវេទនា ដោយអនន្តរប្បច្ច័យ ។

[ ៥៣៤ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយអនន្តរប្បច្ច័យ គឺចុតិចិត្តដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃឧបបត្តិចិត្តដែលប្រកបដោយអទុក្ខមសុខវេទនា ដោយអនន្តរប្បច្ច័យ ភវង្គ: ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃការពិចារណា ដោយអនន្តរប្បច្ច័យ កាយវិញ្ញាណ ដែលច្រឡំដោយសុខ ជាបច្ច័យនៃវិបាកមនោធាតុ ដោយអនន្តរប្បច្ច័យ វិបាកមនោវិញ្ញាណធាតុដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃកិរិយាមនោវិញ្ញាណធាតុ ដោយអនន្តរប្បច្ច័យ ភវង្គ: ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃភវង្គ: ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយអនន្តរប្បច្ច័យ កុសល និងអកុសល ដែលប្រកបដោយសុខវេទនា ( ជាបច្ច័យ ) នៃវុដ្ឋាន: ដែលប្រកបដោយអទុក្ខមសុខវេទនា កិរិយា ( ជាបច្ច័យ ) នៃវុដ្ឋាន: ផលជាបច្ច័យនៃវុដ្ឋាន: ដោយអនន្តរប្បច្ច័យ ។

[ ៥៣៥ ] ធម៌ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយទុក្ខវេទនា ដោយអនន្តរបច្ច័យ គឺពួកខន្ធ ដែលប្រកបដោយទុក្ខវេទនាមុនៗ ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយទុក្ខវេទនាក្រោយៗ ដោយអនន្តរបច្ច័យ ។

[ ៥៣៦ ] ធម៌ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយអនន្តរបច្ច័យ គឺកាយវិញ្ញាណ ដែលប្រឡំដោយទុក្ខ ជាបច្ច័យនៃវិបាកមនោធាតុ ដោយអនន្តរបច្ច័យ ពួកខន្ធ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃវុដ្ឋានៈ ដែលប្រកបដោយអទុក្ខម-សុខវេទនា ដោយអនន្តរបច្ច័យ ។

[ ៥៣៧ ] ធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយអនន្តរបច្ច័យ គឺពួកខន្ធ ដែលប្រកបដោយអទុក្ខមសុខវេទនាមុនៗ ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយអទុក្ខមសុខវេទនាក្រោយៗ ដោយអនន្តរបច្ច័យ អនុលោម ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃគោត្រភូ ដែលប្រកបដោយអទុក្ខម-សុខវេទនា ដោយអនន្តរបច្ច័យ អនុលោម ( ជាបច្ច័យ ) នៃវោទានៈ គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទានៈ ( ជាបច្ច័យ ) នៃមគ្គ មគ្គ ( ជាបច្ច័យ ) នៃផល ផល ( ជាបច្ច័យ ) នៃផល អនុលោម ( ជាបច្ច័យ ) នៃផលសមាបត្តិ នេវសញ្ញានាសញ្ញាយតនៈ របស់បុគ្គលកាលចេញអំពីនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដែលប្រកបដោយអទុក្ខមសុខ-

វេទនា ដោយអនន្តរប្បច្ច័យ ។ ពួកខន្ធដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃវុដ្ឋានៈដែលប្រកបដោយអទុក្ខមសុខវេទនា ដោយអនន្តរប្បច្ច័យ ។

[ ៥៣៨ ] ធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃធម៌ដែលប្រកបដោយសុខវេទនា ដោយអនន្តរប្បច្ច័យ គឺចុតិចិត្ត ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃឧបបត្តិចិត្ត ដែលប្រកបដោយសុខ-វេទនា ដោយអនន្តរប្បច្ច័យ ការពិចារណា ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយសុខវេទនា ដោយអនន្តរប្បច្ច័យ វិបាកមនោធាតុ ជាបច្ច័យនៃវិបាក-មនោវិញ្ញាណធាតុដែលប្រកបដោយសុខវេទនា ដោយអនន្តរប្បច្ច័យ ភវង្គៈដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃភវង្គៈ ដែលប្រកបដោយសុខវេទនា ដោយអនន្តរប្បច្ច័យ កុសល និងអកុសល ដែលប្រកបដោយអទុក្ខមសុខវេទនា ( ជាបច្ច័យ ) នៃវុដ្ឋានៈ ដែលប្រកបដោយសុខវេទនា កិរិយា ( ជាបច្ច័យ ) នៃវុដ្ឋានៈ ផលជាបច្ច័យនៃវុដ្ឋានៈ នេវសញ្ញានា-សញ្ញាយតនៈ របស់បុគ្គលកាលចេញអំពីនិរោធ ជាបច្ច័យនៃផលសមាបត្តិដែលប្រកបដោយសុខវេទនា ដោយអនន្តរប្បច្ច័យ ។

[ ៥៣៩ ] ធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃធម៌ដែលប្រកបដោយទុក្ខវេទនា ដោយអនន្តរប្បច្ច័យ គឺការពិចារណាជាបច្ច័យនៃពួកខន្ធដែលប្រកបដោយទុក្ខវេទនា ដោយអនន្តរប្បច្ច័យ ។

[ ៥៤០ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យ នៃធម៌ដែលប្រកបដោយសុខវេទនា ដោយសមនន្តរប្បច្ច័យ គឺដូចជាអនន្តរប្បច្ច័យដែរ ។

[ ៥៤១ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយសុខវេទនា ដោយសហជាតប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃខន្ធ ២ ដោយសហជាតប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ១ ដោយសហជាតប្បច្ច័យ ខន្ធ ១ ដែលប្រកបដោយសុខ-វេទនា ជាបច្ច័យនៃខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ដោយសហជាតប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ១ ដោយសហជាតប្បច្ច័យ ។

[ ៥៤២ ] ធម៌ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយទុក្ខវេទនា ដោយសហជាតប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃខន្ធ ២ ដោយសហជាតប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ១ ដោយសហជាតប្បច្ច័យ បដិសន្ធិដែលប្រកបដោយទុក្ខវេទនា យើងមិនបាន ( និយាយ ) ទេ ។

[ ៥៤៣ ] ធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយសហជាតប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃខន្ធ ២ ដោយសហជាតប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ១ ដោយសហជាតប្បច្ច័យ ខន្ធ ១ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ដោយសហជាតប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ១ ដោយសហជាតប្បច្ច័យ ។

[ ៥៤៤ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយសុខវេទនា ដោយអញ្ញមញ្ញប្បច្ច័យ ... ជាបច្ច័យដោយនិស្ស-

យប្បច្ច័យ ។ អញ្ញមញ្ញប្បច្ច័យក្តី និស្សយប្បច្ច័យក្តី ដូចគ្នានឹងសហជាតប្បច្ច័យដែរ ។

[ ៥៤៥ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយសុខវេទនា ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ដែលប្រកបដោយសុខវេទនាហើយឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ដោយចិត្តដែលប្រកបដោយសុខវេទនា ញុំាងឈានដែលប្រកបដោយសុខវេទនា ឲ្យកើតឡើង ញុំាងវិបស្សនា ឲ្យកើតឡើង ញុំាងមគ្គ ឲ្យកើតឡើង ញុំាងអភិញ្ញា ឲ្យកើតឡើង ញុំាងសមាបត្តិ ឲ្យកើតឡើង ដំឡើងមានះ ប្រកាន់ទិដ្ឋិ ។ នូវសីលដែលប្រកបដោយសុខវេទនា ... នូវសុតៈ ចាគៈ បញ្ញា រាគៈ មោហៈ មានះ ទិដ្ឋិ សេចក្តីប្រាថ្នា ... បុគ្គលអាស្រ័យនូវកាយវិញ្ញាណ ដែលប្រឡំដោយសុខ ហើយឲ្យទានដោយចិត្ត ដែលប្រកបដោយសុខវេទនា ។ សេចក្តីបន្រ្ទញ ។ ញុំាងសមាបត្តិ ឲ្យកើតឡើង ។ បណ្ឌិតគប្បីធ្វើ ( នូវសេចក្តីចូលចិត្ត ) ថា ដំឡើងមានះ ប្រកាន់ទិដ្ឋិ ដូច្នេះ ក្នុងធម៌ទាំងឡាយ ដែលមានសទ្ធាជាគម្រប់ ៥ ក្នុងធម៌ទាំងឡាយសល់ពីនេះ បណ្ឌិតមិនគប្បីធ្វើទេ ។ បុគ្គលកាន់យកទ្រព្យដែលគេមិនបានឲ្យ ដោយចិត្តដែលប្រកបដោយសុខវេទនា និយាយពាក្យកុហក និយាយពាក្យញុះញង់ និយាយពាក្យអាក្រក់ និយាយពាក្យរោយរាយ កាត់ទី-ត លបចក់យកទ្រព្យគេ ប្លន់យកទ្រព្យក្នុងផ្ទះមួយ ឈរស្កាត់ត្រង់កណ្តាល

ផ្លូវ គប់រកប្រពន្ធអ្នកដទៃ សម្លាប់អ្នកស្រុក សម្លាប់អ្នកនិគម ។ សទ្ធា ដែលប្រកបដោយសុខវេទនា ... សីលៈ សុតៈ ចាគៈ បញ្ញា រាគៈ មោហៈ មានះ ទិដ្ឋិ សេចក្ដីប្រាថ្នា ... កាយវិញ្ញាណ ដែលប្រឡំដោយសុខ ជាបច្ច័យ នៃសទ្ធាដែលប្រកបដោយសុខវេទនា នៃសីលៈ សុតៈ ចាគៈ បញ្ញា រាគៈ មោហៈ មានះ ទិដ្ឋិ សេចក្ដីប្រាថ្នា កាយវិញ្ញាណ ដែលប្រឡំដោយសុខ និងពួកខន្ធ ដែលប្រកបដោយសុខវេទនា ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៤៦ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយទុក្ខវេទនា ដោយឧបនិស្សយប្បច្ច័យ បានដល់ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ដែលប្រកបដោយសុខវេទនា ហើយធ្វើខ្លួន ឲ្យក្ដៅ ឲ្យក្ដៅសព្វ រងនូវទុក្ខ ដែលមានការស្វែងរកជាមូល ។ នូវសីល ដែលប្រកបដោយសុខវេទនា ... នូវសុតៈ ... ចាគៈ ... បុគ្គលអាស្រ័យនូវបញ្ញា ហើយធ្វើខ្លួនឲ្យក្ដៅ ឲ្យក្ដៅសព្វ រងនូវទុក្ខដែលមានការស្វែងរកជាមូល ។ នូវរាគៈ ដែលប្រកបដោយសុខវេទនា ... នូវមោហៈ មានះ ទិដ្ឋិ សេចក្ដីប្រាថ្នា ... បុគ្គលអាស្រ័យនូវកាយវិញ្ញាណ ដែលប្រឡំដោយសុខ ហើយសម្លាប់សត្វ ។ កាន់យកទ្រព្យដែលគេមិនបានឲ្យ ដោយចិត្តដែលប្រកបដោយទុក្ខវេទនា និយាយពាក្យកុហក និយាយពាក្យញុះញង់ និយាយពាក្យអាក្រក់ និយាយពាក្យរោយរាយ កាត់ទី-ត លបចក់យកទ្រព្យគេ ប្លន់យកទ្រព្យគេក្នុងផ្ទះមួយ ឈរស្កាត់ត្រង់កណ្ដាលផ្លូវ គប់រកប្រពន្ធអ្នកដទៃ សម្លាប់អ្នកស្រុក សម្លាប់អ្នកនិគម ផ្ដាច់បង់មាតាចាកជីវិត ផ្ដាច់បង់បិតា

បាកជីវិត ផ្តាច់បង់ព្រះអរហន្តចាកជីវិត ញុំាងលោហិតរបស់ព្រះតថាគតឲ្យពុរពងដោយចិត្តទ្រុស្ត បំបែកសង្ឃ ។ សទ្ធាដែលប្រកបដោយសុខវេទនា ... សីលៈ សុតៈ ចាគៈ បញ្ញា រាគៈ មោហៈ មានះ ទិដ្ឋិ សេចក្តីប្រាថ្នា ... កាយវិញ្ញាណ ដែលប្រទូសដោយសុខ ( ជាបច្ច័យ ) នៃទោសៈ ។បេ។ នៃមោហៈ កាយវិញ្ញាណដែលប្រទូសដោយទុក្ខ និងពួកខន្ធដែលប្រកបដោយទុក្ខវេទនា ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៤៧ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ដែលប្រកបដោយសុខវេទនា ហើយឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ដោយចិត្តដែលប្រកបដោយអទុក្ខមសុខ-វេទនា ញុំាងឈាន ដែលប្រកបដោយអទុក្ខមសុខវេទនា ឲ្យកើតឡើង ញុំាងវិបស្សនា ឲ្យកើតឡើង ញុំាងមគ្គឲ្យកើតឡើង ញុំាងអភិញ្ញាឲ្យកើតឡើង ញុំាងសមាបត្តិ ឲ្យកើតឡើង ដំឡើងមានះ ប្រកាន់ទិដ្ឋិ ។ នូវសីល ដែលប្រកបដោយសុខវេទនា ... នូវសុតៈ ចាគៈ បញ្ញា រាគៈ មោហៈ មានះ ទិដ្ឋិ សេចក្តីប្រាថ្នា ... អាស្រ័យនូវកាយវិញ្ញាណ ដែលប្រទូសដោយសុខ ហើយឲ្យទាន ដោយចិត្តដែលប្រកបដោយអទុក្ខមសុខវេទនា ។ សេចក្តី បន្ទ្រញ ។ ញុំាងសមាបត្តិឲ្យកើតឡើង បុគ្គលកាន់យកទ្រព្យដែលគេមិនបានឲ្យ ដោយចិត្តដែលប្រកបដោយអទុក្ខមសុខវេទនា និយាយពាក្យកុហក

និយាយពាក្យញុះញង់ និយាយពាក្យអាក្រក់ និយាយពាក្យរោយរាយ កាត់ទី-ត លបចក់យកទ្រព្យគេ ប្ដន់យកទ្រព្យក្នុងផ្ទះមួយ ឈរស្កាត់ត្រង់កណ្ដាលផ្លូវ គប់រកប្រពន្ធអ្នកដទៃ សម្លាប់អ្នកស្រុក សម្លាប់អ្នកនិគម ។ សទ្ធា ដែលប្រកបដោយសុខវេទនា ... សីលៈ សុតៈ ចាគៈ បញ្ញា រាគៈ មោហៈ មានះ ទិដ្ឋិ សេចក្ដីប្រាថ្នា ... កាយវិញ្ញាណ ដែលប្រឡំដោយសុខ ជាបច្ច័យនៃសទ្ធា ដែលប្រកបដោយអទុក្ខមសុខវេទនា នៃសីលៈ សុតៈ ចាគៈ បញ្ញា រាគៈ មោហៈ មានះ ទិដ្ឋិ សេចក្ដីប្រាថ្នា កាយវិញ្ញាណ ដែលប្រឡំដោយសុខ និងពួកខន្ធដែលប្រកបដោយអទុក្ខមសុខវេទនា ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៤៨ ] ធម៌ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយទុក្ខវេទនា ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវទោសៈ ហើយសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ដោយចិត្តដែលប្រកបដោយទុក្ខវេទនា ។ សេចក្ដីបង្រ្គួញ ។ បំបែកសង្ឃ ។ អាស្រ័យនូវមោហៈ និងកាយវិញ្ញាណដែលប្រឡំដោយទុក្ខ ហើយសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យដោយចិត្ត ដែលប្រកបដោយទុក្ខវេទនា ។ សេចក្ដីបង្រ្គួញ ។ បំបែកសង្ឃ ។ ទោសៈ មោហៈ កាយវិញ្ញាណដែលប្រឡំដោយទុក្ខ ជាបច្ច័យនៃទោសៈ មោហៈ កាយវិញ្ញាណ ដែលប្រឡំដោយទុក្ខ និងពួកខន្ធដែលប្រកបដោយទុក្ខវេទនា ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៤៩ ] ធម៌ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយសុខវេទនា ដោយឧបនិស្សយប្បច្ច័យ បានដល់ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវទោសៈ ហើយឲ្យទាន ដោយចិត្ត ដែលប្រកបដោយសុខវេទនា ។ សេចក្តីបង្រួញ ។ ញុំាងសមាបត្តិឲ្យកើតឡើង បុគ្គលកាន់យកទ្រព្យដែលគេមិនបានឲ្យ ដោយចិត្ត ដែលប្រកបដោយសុខវេទនា ។ សេចក្តីបង្រួញ ។ សម្ងាប់អ្នកនិគម ។ នូវមោហៈ ... អាស្រ័យនូវកាយវិញ្ញាណដែលប្រទ្បំដោយទុក្ខ ហើយឲ្យទាន ដោយចិត្ត ដែលប្រកបដោយសុខវេទនា ។ សេចក្តីបង្រួញ ។ សម្ងាប់អ្នកនិគម ។ ទោសៈ មោហៈ កាយវិញ្ញាណ ដែលប្រទ្បំដោយទុក្ខ ជាបច្ច័យនៃសទ្ធា ដែលប្រកបដោយសុខវេទនា ។បេ។ នៃកាយវិញ្ញាណ ដែលប្រទ្បំដោយសុខ និងពួកខន្ធដែលប្រកបដោយសុខវេទនា ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៥០ ] ធម៌ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវទោសៈ ហើយឲ្យទាន ដោយចិត្តដែលប្រកបដោយអទុក្ខមសុខវេទនា ។ សេចក្តីបង្រួញ ។ សម្ងាប់អ្នកនិគម ។ នូវមោហៈ ... អាស្រ័យនូវកាយវិញ្ញាណ ដែលប្រទ្បំដោយទុក្ខ ហើយឲ្យទាន ដោយចិត្តដែលប្រកបដោយអទុក្ខមសុខវេទនា ។ សេចក្តីបង្រួញ ។ សម្ងាប់អ្នកនិគម ។ ទោសៈ មោហៈ កាយវិញ្ញាណដែលប្រទ្បំដោយទុក្ខ ជាបច្ច័យនៃសទ្ធា ដែលប្រកប

ដោយអទុក្ខមសុខវេទនា ។បេ។ នៃសេចក្ដីប្រាថ្នា និងពួកខន្ធដែលប្រកប ដោយអទុក្ខមសុខវេទនា ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៥១ ] ធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ដែលប្រកបដោយអទុក្ខមសុខវេទនា ហើយឲ្យទាន ដោយចិត្តដែលប្រកបដោយអទុក្ខមសុខវេទនា ។ ប្រកាន់ទិដ្ឋិ នូវសីល ដែលប្រកបដោយអទុក្ខមសុខវេទនា ... នូវសុតៈ ចាគៈ បញ្ញា រាគៈ មោហៈ មានះ ទិដ្ឋិ ... អាស្រ័យនូវសេចក្ដីប្រាថ្នា ហើយឲ្យទាន ដោយចិត្តដែលប្រកប ដោយអទុក្ខមសុខវេទនា ។ សេចក្ដីបន្រ្ទញ ។ ញុំាងសមាបត្តិឲ្យកើតឡើង បុគ្គលកាន់យកទ្រព្យដែលគេមិនបានឲ្យ ដោយចិត្តដែលប្រកបដោយអទុក្ខ-មសុខវេទនា ។បេ។ សម្លាប់អ្នកនិគម ។ សទ្ធាដែលប្រកបដោយអទុក្ខម-សុខវេទនា សីលៈ សុតៈ ចាគៈ បញ្ញា រាគៈ មោហៈ មានះ ទិដ្ឋិ សេចក្ដីប្រាថ្នា ( ជាបច្ច័យ ) នៃសទ្ធា ដែលប្រកបដោយអទុក្ខមសុខវេទនា ។ សេចក្ដីបន្រ្ទញ ។ ... ជាបច្ច័យនៃសេចក្ដីប្រាថ្នា និងពួកខន្ធ ដែលប្រកប ដោយអទុក្ខមសុខវេទនា ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៥២ ] ធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយសុខវេទនា ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូ-បនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺ

បុគ្គលអាស្រ័យនូវសទ្ធា ដែលប្រកបដោយអទុក្ខមសុខវេទនា ហើយឲ្យទាន ដោយចិត្តដែលប្រកបដោយសុខវេទនា ។បេ។ ជំឡើងមានះ ប្រកាន់ទិដ្ឋិ នូវសីល ដែលប្រកបដោយអទុក្ខមសុខវេទនា ... ។បេ។ ... អាស្រ័យនូវសេចក្តីប្រាថ្នា ហើយឲ្យទាន ដោយចិត្តដែលប្រកបដោយសុខវេទនា ។បេ។ ញុំាងសមាបត្តិឲ្យកើតឡើង បុគ្គលកាន់យកទ្រព្យដែលគេមិនបានឲ្យ ដោយចិត្តដែលប្រកបដោយសុខវេទនា ។បេ។ សម្លាប់អ្នកនិគម ។ សទ្ធាដែលប្រកបដោយអទុក្ខមសុខវេទនា ។បេ។ ... សេចក្តីប្រាថ្នា កាយវិញ្ញាណ ដែលច្រឡំដោយសុខ ជាបច្ច័យនៃសទ្ធា ដែលប្រកបដោយសុខវេទនា ។បេ។ ... នៃសេចក្តីប្រាថ្នា នៃកាយវិញ្ញាណដែលច្រឡំដោយសុខ និងពួកខន្ធដែលប្រកបដោយសុខវេទនា ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៥៣ ] ធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃធម៌ដែលប្រកបដោយទុក្ខវេទនា ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ដែលប្រកបដោយអទុក្ខមសុខវេទនា ហើយធ្វើខ្លួនឯងឲ្យក្តៅ ឲ្យក្តៅសព្វ រងនូវទុក្ខ ដែលមានការស្វែងរកជាមូល ។ ... សីល ដែលប្រកបដោយអទុក្ខមសុខវេទនា ... ។ សេចក្តីបន្ទ្រញ ។ ... អាស្រ័យនូវសេចក្តីប្រាថ្នាហើយសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ដោយចិត្តដែលប្រកបដោយទុក្ខវេទនា ។ សេចក្តីបន្ទ្រញ ។ បំបែកសង្ឃ ។ សទ្ធាដែលប្រកបដោយអទុក្ខមសុខវេទនា ។បេ។ ... សេចក្តីប្រាថ្នា ជាបច្ច័យនៃទោសៈ នៃមោហៈ នៃ

កាយវិញ្ញាណ ដែលច្រឡំដោយទុក្ខ និងពួកខន្ធដែលប្រកបដោយទុក្ខវេទនា ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៥៤ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយសុខវេទនា ដោយអាសេវនប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយសុខវេទនាមុនៗ ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយសុខវេទនាក្រោយៗ ដោយអាសេវនប្បច្ច័យ អនុលោម ដែលប្រកបដោយសុខវេទនា ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទានៈ គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទានៈ ជាបច្ច័យនៃមគ្គ ដោយអាសេវនប្បច្ច័យ ។

[ ៥៥៥ ] ធម៌ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយទុក្ខវេទនា ដោយអាសេវនប្បច្ច័យ គឺពួកខន្ធ ដែលប្រកបដោយទុក្ខវេទនាមុនៗ ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយទុក្ខវេទនាក្រោយៗ ដោយអាសេវនប្បច្ច័យ ។

[ ៥៥៦ ] ធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយអាសេវនប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយអទុក្ខមសុខវេទនាមុនៗ ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយអទុក្ខមសុខវេទនាក្រោយៗ ដោយអាសេវនប្បច្ច័យ អនុលោមដែលប្រកបដោយអទុក្ខមសុខវេទនា ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទានៈ គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទានៈ ជាបច្ច័យនៃមគ្គ ដោយអាសេវនប្បច្ច័យ ។

[ ៥៥៧ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយសុខវេទនា ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនា ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនា ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយសុខវេទនាជាវិបាក ដោយកម្មប្បច្ច័យ ។

[ ៥៥៨ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយទុក្ខវេទនា ដោយកម្មប្បច្ច័យ បានដល់ នានាខណិកៈ គឺចេតនាដែលប្រកបដោយសុខវេទនាជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយទុក្ខវេទនាជាវិបាក ដោយកម្មប្បច្ច័យ ។

[ ៥៥៩ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយកម្មប្បច្ច័យ បានដល់ នានាខណិកៈ គឺចេតនាដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាវិបាក ដោយកម្មប្បច្ច័យ ។

[ ៥៦០ ] ធម៌ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃធម៌ដែលប្រកបដោយទុក្ខវេទនា ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនា ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃពួកខន្ធដែលប្រកបដោយទុក្ខវេទនា ជាវិបាក ដោយ

កម្មប្បច្ច័យ ។

[ ៥៦១ ] ធម៌ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយកម្មប្បច្ច័យ បានដល់ នានាខណិកៈ គឺចេតនាដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាវិបាក ដោយកម្មប្បច្ច័យ ។

[ ៥៦២ ] ធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃធម៌ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនា ដែលប្រកបដោយអទុក្ខមសុខ-វេទនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនា ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាវិបាក ដោយកម្មប្បច្ច័យ ។

[ ៥៦៣ ] ធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃធម៌ដែលប្រកបដោយសុខវេទនា ដោយកម្មប្បច្ច័យ បានដល់ នានាខណិកៈ គឺចេតនាដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃពួកខន្ធដែលប្រកបដោយសុខវេទនា ជាវិបាក ដោយកម្មប្បច្ច័យ ។

[ ៥៦៤ ] ធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃធម៌ដែលប្រកបដោយទុក្ខវេទនា ដោយកម្មប្បច្ច័យ បានដល់ នានាខណិកៈ គឺចេតនាដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃពួកខន្ធដែលប្រកបដោយទុក្ខវេទនា ជាវិបាក ដោយកម្មប្បច្ច័យ ។

[ ៥៦៥ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយសុខវេទនា ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធ ១ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃខន្ធ ២ ដោយវិបាកប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ១ ដោយវិបាកប្បច្ច័យ ខន្ធ ១ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ដោយវិបាកប្បច្ច័យ ខន្ធ ២ ( ជាបច្ច័យ ) នៃខន្ធ ១ ។បេ។

[ ៥៦៦ ] ធម៌ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយទុក្ខវេទនា ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធ ១ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃខន្ធ ២ ដោយវិបាកប្បច្ច័យ ។បេ។ ដោយអទុក្ខមសុខវេទនា ។បេ។ វិបាកក្ខន្ធ ១ ដែលប្រកបដោយអទុក្ខមសុខវេទនា ( ជាបច្ច័យ ) នៃខន្ធ ២ ។បេ។ ក្នុងខណៈនៃបដិសន្ធិ ។

[ ៥៦៧ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយសុខវេទនាដោយអាហារប្បច្ច័យ ... ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ជាបច្ច័យដោយឈានប្បច្ច័យ ជាបច្ច័យដោយមគ្គប្បច្ច័យ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ ជាបច្ច័យដោយអត្ថិប្បច្ច័យ ជាបច្ច័យដោយនត្ថិប្បច្ច័យ ជាបច្ច័យដោយវិគតប្បច្ច័យ ... ជាបច្ច័យដោយអវិគតប្បច្ច័យ ។

## ហេតុមូលកៈ

[ ៥៦៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ

៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៨ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៥៦៩ ] ក្នុងអធិបតិប្បច្ច័យ មានវារៈ ២ ព្រោះហេតុប្បច្ច័យ ... ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ២ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ២ ក្នុងមគ្គប្បច្ច័យ មានវារៈ ២ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៥៧០ ] ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា

សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះហេតុប្បច្ច័យ ។

## អារម្មណមូលកៈ

[ ៥៧១ ] ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ព្រោះអារម្មណប្បច្ច័យ ... ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ។ ពាក្យថា អធិបតិប្បច្ច័យ ឧបនិស្សយប្បច្ច័យ ដូច្នេះ មានវារៈ ៤ ព្រោះអារម្មណប្បច្ច័យ ។

## អធិបតិមូលកៈ

[ ៥៧២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ព្រោះអធិបតិប្បច្ច័យ ... ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុង

អញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ២ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៥៧៣ ] ពាក្យថា អារម្មណប្បច្ច័យ ឧបនិស្សយប្បច្ច័យ ដូច្នេះ មានវារៈ ៤ ព្រោះអធិបតិប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអធិបតិប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះអធិបតិប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអធិបតិប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះអធិបតិប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអធិបតិប្បច្ច័យ ។ ពាក្យថា

សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះអធិបតិប្បច្ច័យ ។

[ ៥៧៤ ] ពាក្យថា ហេតុប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះអធិបតិប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះអធិបតិប្បច្ច័យ ។

## អនន្តរសមនន្តរមូលកៈ

[ ៥៧៥ ] ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ព្រោះអនន្តរប្បច្ច័យ ... ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ២ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ។

[ ៥៧៦ ] ពាក្យថា សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ នត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៧ ព្រោះអនន្តរប្បច្ច័យ ។ ពាក្យថា សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអនន្តរប្បច្ច័យ ។ ពាក្យថា សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ កម្មប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ ដូច្នេះ

មានវារៈ ២ ព្រោះអនន្តរប្បច្ច័យ ។ សមនន្តរប្បច្ច័យ ដូចគ្នានឹងអនន្តរប្បច្ច័យដែរ ។

## សហជាតអញ្ញមញ្ញនិស្សយមូលកៈ

[ ៥៧៧ ] ព្រោះសហជាតប្បច្ច័យ ... ព្រោះអញ្ញមញ្ញប្បច្ច័យ ... ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ព្រោះនិស្សយប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មាន វារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៥៧៨ ] ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះនិស្សយប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ វិបាកប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះនិស្សយប្បច្ច័យ ។

## ឧបនិស្សយមូលកៈ

[ ៥៧៩ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះឧបនិស្សយប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យមានវារៈ ៧ ក្នុងសមនន្ត-

វប្បច្ច័យ មានវារៈ ៧ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៨ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ។

[ ៥៨០ ] ពាក្យថា អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ ដូច្នេះ មានវារៈ ៤ ព្រោះឧបនិស្សយប្បច្ច័យ ។ ពាក្យថា អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ ដូច្នេះ មានវារៈ ៧ ព្រោះឧបនិស្សយប្បច្ច័យ ។ ពាក្យថា អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះឧបនិស្សយប្បច្ច័យ ។ ពាក្យថា កម្មប្បច្ច័យ ដូច្នេះ មានវារៈ ៨ ព្រោះឧបនិស្សយប្បច្ច័យ ។ ពាក្យថា អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ កម្មប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះឧបនិស្សយប្បច្ច័យ ។

## អាសេវនមូលកៈ

[ ៥៨១ ] ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ព្រោះអាសេវនប្បច្ច័យ ... ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងវិគតប្បច្ច័យ មានវារៈ ៣ ។ ពាក្យថា អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអាសេវនប្បច្ច័យ ។

## កម្មមូលកៈ

[ ៥៨២ ] ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ព្រោះកម្មប្បច្ច័យ ... ក្នុង

សមនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៨ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ២ ក្នុងវិគតប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៥៨៣ ] ពាក្យថា ឧបនិស្សយប្បច្ច័យ ដូច្នេះ មានវារៈ ៨ ព្រោះកម្មប្បច្ច័យ ។ ពាក្យថា អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះកម្មប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ អាហារប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះកម្មប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះកម្មប្បច្ច័យ ។

## វិបាកមូលកៈ

[ ៥៨៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ព្រោះវិបាកប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ។ សេចក្តីបង្រួញ ។ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្ប-យុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះវិបា-កប្បច្ច័យ ។

## អាហារមូលកៈ

[ ៥៨៥ ] ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះអាហារប្បច្ច័យ ... ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៥៨៦ ] ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអាហារប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្ស-យប្បច្ច័យ វិបាកប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអាហារប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ កម្មប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអាហារប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ កម្មប្បច្ច័យ វិបា-កប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអាហារប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ

និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអាហារប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអាហារប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះអាហារប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះអាហារប្បច្ច័យ ។

## ឥន្ទ្រិយមូលកៈ

[ ៥៨៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ព្រោះឥន្ទ្រិយប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៥៨៨ ] ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ

សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះឥន្ទ្រិយប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះឥន្ទ្រិយប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះឥន្ទ្រិយប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះឥន្ទ្រិយប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឈានប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះឥន្ទ្រិយប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឈានប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះឥន្ទ្រិយប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះឥន្ទ្រិយប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះឥន្ទ្រិយប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញ-

មញ្ញប្បច្ច័យ និស្សយប្បច្ច័យ អាហារប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះឥន្ទ្រិយប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះឥន្ទ្រិយប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ អាហារប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះឥន្ទ្រិយប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះឥន្ទ្រិយប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះឥន្ទ្រិយប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះឥន្ទ្រិយប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះឥន្ទ្រិយប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ

អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះឥន្ទ្រិយប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះឥន្ទ្រិយប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះឥន្ទ្រិយប្បច្ច័យ ។

## ឈានមូលកៈ

[ ៥៨៩ ] ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ព្រោះឈានប្បច្ច័យ ... ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ២ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៥៩០ ] ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះឈានប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះឈានប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ

អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះឈានប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះឈានប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះឈានប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ មគ្គប្បច្ច័យ សម្ប-យុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះឈានប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្ស-យប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះឈានប្បច្ច័យ ។ ពាក្យថា សហ-ជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះឈានប្បច្ច័យ ។

## មគ្គមូលកៈ

[ ៥៩១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ព្រោះមគ្គប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញ-មញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ

មានវារៈ ២ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៥៩២ ] ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឈានប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឈានប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះ

មគ្គប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្ស-យប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈា-នប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ សហជាតប្បច្ច័យ អញ្ញ-មញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបា-កប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ អធិប-តិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះមគ្គប្បច្ច័យ ។ ពាក្យថា ហេតុប្បច្ច័យ អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្ប-យុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះ

មគ្គប្បច្ច័យ ។

## សម្បយុត្តមូលកៈ

[ ៥៩៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ព្រោះសម្បយុត្តប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៥៩៤ ] ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះសម្បយុត្តប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះសម្បយុត្តប្បច្ច័យ ។ ព្រោះអត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ និងអវិគតប្បច្ច័យ ។

### អនុលោមនៃបញ្ហាវារៈ ចប់

[ ៥៩៥ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ដែលប្រកបដោយសុខវេទនាដោយអារម្មណប្បច្ច័យ... ជាបច្ច័យដោយសហជាតប្បច្ច័យ...

ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ៥៩៦ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយទុក្ខវេទនា ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ... ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ៥៩៧ ] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ៥៩៨ ] ធម៌ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយទុក្ខវេទនា ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយសហជាតប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ៥៩៩ ] ធម៌ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយសុខវេទនា ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៦០០ ] ធម៌ ដែលប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ៦០១ ] ធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយសហជាតប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យ

ដោយកម្មប្បច្ច័យ ។

[ ៦០២ ] ធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃធម៌ដែលប្រកបដោយសុខវេទនា ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ៦០៣ ] ធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃធម៌ដែលប្រកបដោយទុក្ខវេទនា ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ៦០៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងនសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងននិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៩ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ៩ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងនឈានប្បច្ច័យ មានវារៈ ៩ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៦០៥ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។ សេចក្ដីបង្រួញ ។ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ នអារម្មណប្បច្ច័យ ... ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៨ ។ សេចក្ដីបង្រួញ ។ ... ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។ ព្រោះនហេតុប្បច្ច័យ និងនអារម្មណប្បច្ច័យ ។ សេចក្ដីបង្រួញ ។ ព្រោះនឧបនិស្សយប្បច្ច័យ នបុរេជាតប្បច្ច័យ នបច្ឆាជាតប្បច្ច័យ នអាសេវនប្បច្ច័យ នវិបាកប្បច្ច័យ និងនអាហារប្បច្ច័យ ។ សេចក្ដីបង្រួញ ។ ... ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៨ ។

## នហេតុមូលកៈ ចប់

ការរាប់បច្ចនីយៈរបស់កុសលត្តិកៈ ដែលលោករាប់ហើយ យ៉ាងណា មូលកៈទាំងអស់ បណ្ឌិតកាលមិនកាន់ច្រឡំចំពោះការរាប់នេះ គប្បីកាន់យក យ៉ាងនេះចុះ ។

## បច្ចនីយៈ ចប់

[ ៦០៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុង

នវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនអាហារប្បច្ច័យ មានវារៈ ៣ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងនឈានប្បច្ច័យ មានវារៈ ៣ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ។ សេចក្តីបង្រួញ ។ ... ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។ ការរាប់អនុលោមប្បច្ចនីយៈរបស់កុសលត្តិកៈដែលលោករាប់ហើយ តាមដំណើរនៃការស្វាធ្យាយ យ៉ាងណា បទនេះ បណ្ឌិតក៏គប្បីរាប់យ៉ាងនោះផងចុះ ។ ក្នុងនហេតុប្បច្ច័យ មានវារៈ ៨ ព្រោះកម្មប្បច្ច័យ ... ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៨ ។បេ។ ... ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៨ ។

## អនុលោមប្បច្ចនីយគណនា ចប់

[ ៦០៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៨ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ

៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៦០៨ ] ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ នអារម្មណប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ។ សេចក្តីបង្រួញ ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ នអារម្មណប្បច្ច័យ នអធិបតិប្បច្ច័យ នអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៨ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៦០៩ ] ព្រោះនហេតុប្បច្ច័យ នអារម្មណប្បច្ច័យ ។ សេចក្តីបង្រួញនូវមូលកៈ ។ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ព្រោះននិស្សយប្បច្ច័យ ... ក្នុងកម្មប្បច្ច័យ មានវារៈ ៨ ។ ព្រោះនហេតុប្បច្ច័យ នអារម្មណប្បច្ច័យ ។ សេចក្តីបង្រួញ ។ ក្នុងកម្មប្បច្ច័យ មានវារៈ ៨ ព្រោះនឧបនិស្សយប្បច្ច័យ នបុរេជាតប្បច្ច័យ នបច្ឆាជាតប្បច្ច័យ នអាសេវនប្បច្ច័យ នវិបាកប្បច្ច័យ នអាហារប្បច្ច័យ នឥន្ទ្រិយប្បច្ច័យ នឈានប្បច្ច័យ នមគ្គប្បច្ច័យ នសម្បយុត្តប្បច្ច័យ នវិប្បយុត្តប្បច្ច័យ នោអត្ថិប្បច្ច័យ នោនត្ថិប្បច្ច័យ នោវិគតប្បច្ច័យ និងនោអវិគតប្បច្ច័យ ។

នហេតុមូលកៈ ចប់

[ ៦១០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ព្រោះនអារម្មណប្បច្ច័យ ។ សេចក្តីបង្រួញ ។ ... ក្នុងកម្មប្បច្ច័យ មានវារៈ ៨ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៦១១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនោអវិគតប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៨ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ។

[ ៦១២ ] ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ព្រោះនោអវិគតប្បច្ច័យ នហេតុប្បច្ច័យ នអារម្មណប្បច្ច័យ ... ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៨ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ។

[ ៦១៣ ] ក្នុងកម្មប្បច្ច័យ មានវារៈ ៨ ព្រោះនោអវិគតប្បច្ច័យ នហេតុប្បច្ច័យ នអារម្មណប្បច្ច័យ នអធិបតិប្បច្ច័យ នអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នសហជាតប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ ននិស្សយប្បច្ច័យ នឧបនិស្សយប្បច្ច័យ នបុរេជាតប្បច្ច័យ នបច្ឆាជាតប្បច្ច័យ នអាសេវនប្បច្ច័យ នវិបាកប្បច្ច័យ នអាហារប្បច្ច័យ នឥន្ទ្រិយប្បច្ច័យ នឈានប្បច្ច័យ នមគ្គប្បច្ច័យ នសម្បយុត្តប្បច្ច័យ នវិប្បយុត្តប្បច្ច័យ នោអត្ថិប្បច្ច័យ

នោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ ។

ការរាប់បច្ចនីយានុលោមរបស់កុសលត្តិកៈ ដែលលោករាប់ហើយ តាមគន្លងនៃការស្វាធ្យាយ យ៉ាងណា ( បទនេះ ) បណ្ឌិតគប្បីរាប់យ៉ាងនោះផងចុះ ។

បច្ចនីយានុលោម ចប់

វេទនាត្តិកៈទី ២ ចប់

# អដ្ឋកថា

## វេទនាត្តិកៈ

[ ៤៥៣-៦១៣ ] ធម៌ទាំងនេះ គឺវេទនា ៣ រូប ១ និព្វាន ១ រមែង មិនបានក្នុងវេទនាត្តិកៈ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ឯកំ ខន្ធំ បដិច្ច ទ្វេ ខន្ធា** ជាដើម ។ បទថា **បដិសន្ធិក្ខណេ សុខាយ វេទនាយ** ត្រាស់ដោយអំណាចសហេតុកប្បដិសន្ធិ ចំណែកទុក្ខវេទនារមែង មិនបានក្នុងបដិសន្ធិកាល ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់មិន ប្រារព្ធដល់បដិសន្ធិ ក្នុងវារៈទី ២ ។ បទថា **បដិសន្ធិក្ខណេ** ក្នុងវារៈទី ៣ ត្រាស់ដោយអំណាចសហេតុកប្បដិសន្ធិ ។ ពាក្យដ៏សេសក្នុងអធិការនេះ ក្នុង បច្ច័យដទៃអំពីនេះ រមែងប្រព្រឹត្តទៅ តាមព្រះបាលីនោះឯង ក្នុងទីទាំងពួង ត្រាស់វារៈ ៣ វារៈ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ហេតុយា តីណិ ។បេ។ អវិគតេ តីណិ ។**

ក្នុងការប្រៀបធៀបបច្ច័យ ទ្រង់ត្រាស់ថា **វិបាកេ ទ្វេ** ក្នុងហេតុមូលក- ន័យ ព្រោះទុក្ខវេទនាចំណែកវិបាក ដែលជាសហេតុកៈ មិនមាន ។ ក្នុង ការប្រៀបធៀបជាមួយអធិបតិប្បច្ច័យជាដើម ក្នុងវិបាកប្បច្ច័យ មានវិសជ្ជនា ២ វារៈប៉ុណ្ណោះ ។ ព្រោះហេតុអ្វី ព្រោះអធិបតី ឈាន និងមគ្គប្បច្ច័យមិន មានដោយភាពជាវិបាកទុក្ខវេទនា ។ ក្នុងការប្រៀបធៀប ជាមួយបច្ច័យទាំង ឡាយណា ក្នុងវិបាកប្បច្ច័យ រមែងបានវារៈ ២ ក្នុងការប្រៀបធៀបជាមួយ វិបាកប្បច្ច័យ ក្នុងបច្ច័យទាំងនោះ ក៏បានវារៈ ២ ដូចគ្នា ។

ក្នុងបច្ចនីយៈ ក្នុងនបុរេជាតប្បច្ច័យ វារៈ ២ មកហើយ ព្រោះមិនមានទុក្ខវេទនា ក្នុងអរូបភព និងក្នុងបដិសន្ធិកាល ។ ក្នុងវិប្បយុត្តប្បច្ច័យ ក៏មានវារៈ ២ ដូចគ្នា ព្រោះមិនមានទុក្ខវេទនា ក្នុងអរូបភព ។ បច្ច័យទាំងឡាយមានសហជាតប្បច្ច័យជាដើម ដែលគ្របដណ្តប់ដល់អរូបធម៌ទាំងអស់ រមែងដាច់ទៅ ក្នុងបច្ចនីយវារៈនេះ ។ ព្រោះហេតុអ្វី ព្រោះធម៌ដែលសម្បយុត្តដោយវេទនា អាស្រ័យធម៌ដែលសម្បយុត្តដោយវេទនា កើតឡើងមិនបានដោយវៀរចាកសហជាតប្បច្ច័យជាដើម តែវៀរចាកបច្ឆាជាតប្បច្ច័យ ក៏កើតឡើងមិនបាន ។

ក្នុងការប្រៀបធៀបបច្ច័យ បទថា **ឆបុរេជាតេ ឃកំ** ទ្រង់ត្រាស់សំដៅដល់ធម៌ក្នុងបដិសន្ធិ ក្នុងអរូបភព និងធម៌ដែលសម្បយុត្តដោយអហេតុក-អទុក្ខមសុខវេទនា ។ បទថា **ឆកម្មេ ទេ្វ** ទ្រង់ត្រាស់ដោយអំណាចចេតនាដែលសម្បយុត្តដោយអហេតុកកិរិយា ព្រោះអហេតុកកិរិយាដែលសម្បយុត្តដោយវេទនាទាំងនោះ រមែងកើតឡើងព្រោះអាស្រ័យធម៌ទាំងឡាយ ដែលសម្បយុត្តដោយសុខវេទនា និងអទុក្ខមសុខវេទនា ។ ក្នុងបទថា **ឆហេ–តុប្បច្ចយា ឆវិចាកេ** ក៏ន័យនេះដូចគ្នា ។ បទថា **ឆវិប្បយុត្តេ ឃកំ** ទ្រង់ត្រាស់ដោយអំណាចអាវជ្ជនចិត្ត ក្នុងអរូបភព ។ ក្នុងការប្រៀបធៀបបច្ច័យគ្រប់អន្លើ គប្បីជ្រាបវិធីរាប់ដោយឧបាយនេះ ។

បច្ច័យដែលបានក្នុងអនុលោមប្បច្ចនីយៈប៉ុណ្ណោះ តាំងនៅដោយភាពជាបច្ចនីយៈ ។ សហជាតប្បច្ច័យជាដើម ដែលគ្របដណ្តប់ដល់អរូបធម៌ទាំង

អស់ ក្នុងបច្ចនីយានុលោម រមែងតាំងនៅដោយអនុលោមប៉ុណ្ណោះ មិនតាំងនៅដោយភាពជាបច្ចនីយៈ តែអធិបតីរបស់អហេតុកចិត្តុប្បាទមិនមាន ព្រោះហេតុនោះ ទើបអធិបតិប្បច្ច័យ មិនតាំងនៅដោយភាពជាអនុលោម ។

ក្នុងបដិច្ចវារៈជាដើម បច្ឆាជាតប្បច្ច័យ រមែងមានមិនបានឡើយ ព្រោះហេតុនោះ ទើបដាច់ទៅ ។ ម្យ៉ាងទៀត ក្នុងអធិការនេះ បច្ច័យទាំងឡាយណា មានដោយភាពជាអនុលោម បច្ច័យទាំងនោះ លោកប្រកបអធិប្បាយបន្ថិលទៅជាមួយបច្ច័យដែលបាន ដោយភាពជាបច្ចនីយៈ ។ ក្នុងបច្ច័យទាំងនោះ មានកំណត់វារៈ ៣ ប៉ុណ្ណោះ គឺ ៣-២-១ អ្នកសិក្សាគប្បីកំណត់តាមភាពសមគួរ និងគប្បីជ្រាបបច្ច័យទាំងនោះក្នុងទីគ្រប់អន្ទើ ឯន័យរបស់វណ្ណនាណា ទ្រង់ត្រាស់ហើយក្នុងបដិច្ចវារៈ ន័យរបស់វណ្ណនានោះ ទ្រង់ត្រាស់ក្នុងសហជាតវារៈជាដើមផងដែរ ។

ក្នុងបញ្ហាវារៈ បទថា **សម្បយុត្តកានំ ខន្ធានំ** បានដល់ ខន្ធទាំងឡាយ ដែលសម្បយុត្តដោយធម៌នោះ ឬដែលសម្បយុត្តដោយហេតុទាំងឡាយនោះ ឬដោយសុខវេទនាជាដើម ។ បទថា **វិប្បដិសារិស្ស** គឺមានការក្តៅក្រហាយក្នុងកុសល មានទានជាដើម យ៉ាងនេះថា ហេតុអ្វី ទើបអាត្មាអញធ្វើកម្មនេះ កម្មអាក្រក់អញធ្វើហើយ អញមិនធ្វើល្អជាង ។ មានការក្តៅក្រហាយ ព្រោះឈានវិនាសទៅ យ៉ាងនេះថា ឈានរបស់អញវិនាសហើយ អញជាបុគ្គលវិនាសធំហ្ន៎ ។ បទថា **មោហោ ឧប្បជ្ជតិ** បានដល់ មោហៈដែលសម្បយុត្តជាមួយទោសៈប៉ុណ្ណោះ ។ បទថា **មោហំ អារព្ភ** បានដល់

មោហៈដែលសម្បយុត្តជាមួយទោសៈដូចគ្នា ។

បទថា **សុខាយ វេទនាយ សម្បយុត្តំ ភវង្គំ អទុក្ខមសុខាយ វេទនាយ សម្បយុត្តស្ស ភវង្គស្ស** សេចក្តីថា ភវង្គជួនក្រោយ ពោលគឺ តទារម្មណៈ ជាបច្ច័យដល់ភវង្គដើម ។ បទថា **វុដ្ឋានស្ស** គឺតទារម្មណៈ ឬភវង្គ ។ ពិតហើយ ចិត្តទាំងពីរនោះ លោកហៅថា **វុដ្ឋាន** ព្រោះចេញចាក កុសលជវន ឬអកុសលជវន ។ ក្នុងបទថា **កិរិយំ វុដ្ឋានស្ស** នេះ ក៏ន័យ នេះដូចគ្នា ។ បទថា **ផលំ វុដ្ឋានស្ស** បានដល់ ផលចិត្ត ជាបច្ច័យដល់ ភវង្គចិត្ត ។ ពិតហើយ ឈ្មោះថា ការចេញចាកផលចិត្ត រមែងមានដោយ ភវង្គចិត្ត ។ សូម្បីក្នុងបទថា **វុដ្ឋានំ** ដែលមកខាងមុខ ក៏ន័យនេះដូចគ្នា ។

បទថា **ទុក្ខាយ វេទនាយ សម្បយុត្តា ខន្ធា** បានដល់ អកុសលក្ខន្ធ ដែលសម្បយុត្តដោយទោមនស្សវេទនា ។ បទថា **អទុក្ខមសុខាយ វេទនាយ សម្បយុត្តស្ស វុដ្ឋានស្ស** បានដល់ អាគន្តុកភវង្គ គឺតទារម្មណៈ ឬមូលភវង្គ ដែលសម្បយុត្តដោយឧបេក្ខា ។ បើចិត្តដែលសហគតៈដោយ សោមនស្ស ជាមូលភវង្គ ហេតុដែលនឹងឲ្យកើតតទារម្មណៈ រមែងមិនមាន អកុសលវិបាកដែលជាឧបេក្ខាវេទនា រមែងកើតឡើងក្នុងអារម្មណ៍ដទៃ អំពី អារម្មណ៍របស់ជវន ។ ពិតហើយ អកុសលវិបាកនោះ លោកហៅថា **វុដ្ឋាន** ព្រោះចេញចាកជវន ។ និទ្ទេសនៃសហជាតបច្ច័យជាដើម មានអត្ថងាយ យល់ហើយ ព្រោះថា ក្នុងអធិការនេះ ពាក្យដែលមិនអាចដឹងតាមន័យដែលខ្ញុំ ពោលទុកហើយខាងដើមមិនមាន ព្រោះហេតុនោះ អ្នកសិក្សាគប្បីកំណត់

ឡើយ ។

វារៈទាំងឡាយណា បានហើយក្នុងបច្ច័យណាមួយ ឥឡូវនេះ ដើម្បីសង្ខេបសម្តែងបច្ច័យ និងវារៈទាំងអស់នោះ ដោយអំណាចនៃការរាប់ ទើបព្រះមានព្រះភាគត្រាស់ថា **ហេតុយា តីណិ** ជាដើម ។ វិសជ្ជនា ៣ វារៈទាំងអស់នោះ ក្នុងបទថា **ហេតុយា តីណិ** អ្នកសិក្សាគប្បីជ្រាបដោយអំណាចនៃសុទ្ធបទ ៣ ។ វិសជ្ជនា ៩ វារៈ ក្នុងអារម្មណប្បច្ច័យ មានបច្ច័យដែលមានមូល ១ មានមូល ១ ជាទីបំផុត ។ ក្នុងអធិបតិប្បច្ច័យ មានវិសជ្ជនា ៥ វារៈ គឺវិសជ្ជនា ៣ មិនលាយឡំគ្នាដោយអំណាចរបស់សហជាតាធិបតិប្បច្ច័យ និងវិសជ្ជនា ២ គឺធម៌ដែលសម្បយុត្តដោយសុខវេទនា ជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយសុខវេទនា ដោយអំណាចនៃអារម្មណាធិបតិប្បច្ច័យ ធម៌ដែលសម្បយុត្តដោយឧបេក្ខាវេទនា ជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយឧបេក្ខាវេទនា ដោយអំណាចនៃអារម្មណាធិបតិប្បច្ច័យ ។ វិសជ្ជនា ២ នោះ អ្នកសិក្សាមិនគួររាប់ តែគួររាប់វិសជ្ជនាទាំង ២ នេះ គឺធម៌ ដែលសម្បយុត្តដោយសុខវេទនា ជាបច្ច័យដល់ធម៌ ដែលសម្បយុត្តដោយឧបេក្ខាវេទនា ធម៌ដែលសម្បយុត្តដោយឧបេក្ខាវេទនា ជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយសុខវេទនា រួមជាវិសជ្ជនា ៥ វារៈ ដោយប្រការដូច្នេះ ។

បទថា **សត្ត** ក្នុងអនន្តរៈ និងសមនន្តរប្បច្ច័យ បានដល់ វិសជ្ជនា ៧ វារៈយ៉ាងនេះ គឺសុខវេទនាជាបច្ច័យដល់ធម៌ ២ យ៉ាង ទុក្ខវេទនាជាបច្ច័យ

ដល់ធម៌ ២ យ៉ាង ឧបេក្ខាវេទនា ជាបច្ច័យដល់ធម៌ទាំង ៣ យ៉ាង ។

បទថា **ឧបនិស្សយេ នវ** បានដល់ វិសជ្ជនា ៩ វារៈ គឺធម៌ដែលសម្បយុត្តដោយសុខវេទនា ជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយសុខវេទនា ដោយឧបនិស្សយប្បច្ច័យទាំង ៣ យ៉ាង ជាបកតូបនិស្សយប្បច្ច័យតែម្យ៉ាង ដល់ធម៌ដែលសម្បយុត្តដោយទុក្ខវេទនា ជាឧបនិស្សយប្បច្ច័យទាំង ៣ យ៉ាង ដល់ធម៌ដែលសម្បយុត្តដោយឧបេក្ខាវេទនា ធម៌ដែលសម្បយុត្តដោយទុក្ខ-វេទនា ជាអនន្តរូបនិស្សយប្បច្ច័យ និងបកតូបនិស្សយប្បច្ច័យ ដល់ធម៌ដែលសម្បយុត្តដោយទុក្ខវេទនា ជាបកតូបនិស្សយប្បច្ច័យដល់ធម៌ដែលសម្បយុត្តដោយសុខវេទនា ជាអនន្តរូបនិស្សយៈ និងបកតូនិស្សយប្បច្ច័យ ទាំង ២ យ៉ាង ដល់ធម៌ដែលសម្បយុត្តដោយឧបេក្ខាវេទនា ។ ធម៌ដែលសម្បយុត្តដោយឧបេក្ខាវេទនា ជាអារម្មណូបនិស្សយៈ អនន្តរូបនិស្សយៈ និងបកតូ-បនិស្សយៈ ដល់ធម៌ដែលសម្បយុត្តដោយឧបេក្ខាវេទនា និងសុខវេទនា ជាអនន្តរូបនិស្សយៈ និងបកតូបនិស្សយប្បច្ច័យ ដល់ធម៌ដែលសម្បយុត្តដោយទុក្ខវេទនា ។ ក្នុងអធិការនេះ កាលពោលដោយការផ្សេងគ្នានៃបច្ច័យ បកតូ-បនិស្សយប្បច្ច័យ មាន ៩ វារៈ អនន្តរូបនិស្សយប្បច្ច័យ មាន ៧ វារៈ អារម្មណូបនិស្សយប្បច្ច័យ មាន ៤ វារៈ រួមជាឧបនិស្សយប្បច្ច័យ ២០ វារៈ ។

ក្នុងអធិការនេះ បុរេជាតប្បច្ច័យ និងបច្ឆាជាតប្បច្ច័យ ដាច់ទៅ ព្រោះថាអរូបធម៌ដែលកើតមុន ឬកើតក្រោយ រមែងមិនជាបច្ច័យដល់អរូបធម៌ ។

បទថា **កាម្ម អដ្ឋ** បានដល់ វិសជ្ជនា ៨ វារៈយ៉ាងនេះ គឺធម៌ដែលសម្បយុត្ត ដោយសុខវេទនា ជាកម្មប្បច្ច័យទាំងពីរយ៉ាង ដល់ធម៌ដែលសម្បយុត្តដោយ សុខវេទនា ជាបច្ច័យដល់នានាខណិកកម្មប្បច្ច័យតែម្យ៉ាង ដល់ធម៌ដែល សម្បយុត្តដោយទុក្ខវេទនា និងដល់ធម៌ ដែលសម្បយុត្តដោយឧបេក្ខាវេទនា ធម៌ដែលសម្បយុត្តដោយទុក្ខវេទនា ជាបច្ច័យដោយកម្មប្បច្ច័យ ២ យ៉ាង ដល់ធម៌ដែលសម្បយុត្តដោយទុក្ខវេទនា ដែលជាបច្ច័យដល់ធម៌ដែលសម្បយុត្ត ដោយសុខវេទនាមិនមាន ជាបច្ច័យដល់ឧបេក្ខាវេទនា ដោយនានាខណិក-កម្មប្បច្ច័យតែម្យ៉ាង ធម៌ដែលសម្បយុត្តដោយឧបេក្ខាវេទនា ជាបច្ច័យដោយ កម្មប្បច្ច័យទាំងពីរយ៉ាង ដល់ធម៌ដែលសម្បយុត្តដោយឧបេក្ខាវេទនា ជា នានាខណិកកម្មប្បច្ច័យតែម្យ៉ាង ដល់ធម៌ដែលសម្បយុត្តដោយសុខវេទនា និង ទុក្ខវេទនា ក្រៅអំពីនេះ ។ ក្នុងអធិការនេះ ពោលដោយការផ្សេងគ្នានៃ បច្ច័យ នានាខណិកកម្មប្បច្ច័យ មាន ៨ សហជាតកម្មប្បច្ច័យ មាន ៣ រួមជាកម្មប្បច្ច័យ ១១ ប្រភេទ ។ ក្នុងនិទ្ទេសនៃកម្មប្បច្ច័យនេះ វិប្ប-យុត្តប្បច្ច័យ រមែងដាច់ទៅ ដូចបុរេជាត និងបច្ឆាជាតប្បច្ច័យដូច្នោះ ព្រោះថា អរូបធម៌ទាំងឡាយ មិនជាវិប្បយុត្តប្បច្ច័យដល់អរូបធម៌ផងគ្នាឡើយ ។

វារៈ ៧ ក្នុងនត្ថិ និងវិគតប្បច្ច័យ ដូចគ្នានឹងអនន្តរប្បច្ច័យ និងសម-នន្តរប្បច្ច័យ ។ ក្នុងអធិការនេះ មានការកំណត់វិធីរាប់ ៥ យ៉ាង គឺវិសជ្ជនា ៣-៥-៧-៨-៩ ដោយប្រការដូច្នេះ ។ ក្នុងការរួមបច្ច័យ ដោយអំណាចការ កំណត់វិធីរាប់ទាំងនោះ អ្នកសិក្សាគប្បីដកចេញនូវបច្ច័យដែលលើស និង

ដែលមិនបាន ក្នុងការរួមជាមួយបច្ច័យដែលមានវិធីរាប់បានតិចជាង ហើយជ្រាបវិធីរាប់តទៅ ក្នុងការរួមជាមួយហេតុប្បច្ច័យរមែងមិនបានអារម្មណប្បច្ច័យនិងសមនន្តរប្បច្ច័យជាដើម ។

បទថា **អធិបតិយា ទ្វេ** បានដល់ វិសជ្ជនា ២ វារៈដ៏សេស វៀរបទដែលទាក់ទងនឹងទុក្ខវេទនា ។ ពិតហើយ ឈ្មោះថា ហេតុដែលសម្បយុត្តដោយទុក្ខវេទនាដែលជាអធិបតី មានមិនបាន ព្រោះហេតុនោះ ទើបលោកនាំចេញ ក្នុង ២ វារៈដ៏សេស ក៏ន័យនេះដូចគ្នា ។

ក្នុងហេតុមូលកន័យ មានការកំណត់វិធីរាប់ ២ វារៈ ប៉ុណ្ណោះ គឺ ២-៣ ដោយប្រការដូច្នេះ ។ យជនា ៦ ព្រះមានព្រះភាគ ត្រាស់ដោយអំណាចការកំណត់វិធីរាប់ទាំងនោះ ។ បណ្តាយជនា ៦ នោះ យជនាទី ១ ទ្រង់ត្រាស់ដោយអំណាចធម៌ដែលមានអធិបតី ដែលមិនប្រកបដោយញាណដែលជាអវិបាក ។ យជនាទី ២ ទ្រង់ត្រាស់ដោយអំណាចធម៌នោះឯងដែលជាវិបាក ។ យជនាទី ៣ និងយជនាទី ៤ ទ្រង់ត្រាស់ដោយអំណាចធម៌ទាំងនោះទៀត តែជាញាណសម្បយុត្ត ។ យជនាទី ៥ ទ្រង់ត្រាស់ដោយអំណាចអមោហៈដែលជាអធិបតី ដែលជាអវិបាក ។ យជនាទី ៦ ទ្រង់ត្រាស់ដោយអំណាចអមោហៈដែលជាអធិបតី ដែលជាវិបាក ។ម្យ៉ាងទៀត យជនាទី ១ ទ្រង់ត្រាស់ដោយអំណាចហេតុទាំងអស់ ។ យជនាទី ២ ទ្រង់ត្រាស់ដោយអំណាចវិបាកហេតុទាំងអស់ ។ យជនាទី ៣ ទ្រង់ត្រាស់ដោយអំណាចអមោហហេតុទាំងអស់ ។ យជនាទី ៤ ទ្រង់ត្រាស់ដោយអំណាច

អមោហហេតុ ដែលជាវិបាកទាំងអស់ ។ យជនាទី ៥ ទ្រង់ត្រាស់ដោយអំណាចអមោហៈដែលជាអធិបតីទាំងអស់ ។ យជនាទី ៦ ទ្រង់ត្រាស់ដោយអំណាចអមោហៈដែលជាវិបាក មានអធិបតីទាំងអស់ ។

ក្នុងអារម្មណមូលកន័យ បទថា **អធិបតិយា ចត្តារិ** សេចក្តីថា ក្នុងអធិបតិប្បច្ច័យ មានយជនា ៤ វារៈ យ៉ាងនេះ គឺសុខជាបច្ច័យដល់សុខដល់ឧបេក្ខា ដោយអំណាចរបស់អារម្មណាធិបតិប្បច្ច័យ ឧបេក្ខាជាបច្ច័យដល់ឧបេក្ខា ដល់សុខ ដោយអំណាចអារម្មណាធិបតិប្បច្ច័យ ។

ក្នុងឧបនិស្សយប្បច្ច័យ ព្រះមានព្រះភាគ ក៏ត្រាស់វារៈ ៤ វារៈ ដោយអំណាចអារម្មណូបនិស្សយប្បច្ច័យ ។ ក្នុងឧបនិស្សយប្បច្ច័យ មានយជនា ១ ប៉ុណ្ណោះ ។ ក្នុងន័យដែលមានអធិបតិប្បច្ច័យជាដើម យជនាណា ដែលបាន និងមិនបាន តាមន័យដែលពោលហើយខាងដើម អ្នកសិក្សាកំណត់យជនាទាំងអស់ហើយ គប្បីជ្រាបចំនួនយជនាដែលប្រៀបធៀបគ្នា ។

ព្រះមានព្រះភាគ ទ្រង់លើកឡើងនូវបច្ច័យទាំងឡាយ ដោយអនុលោមតាមន័យដែលត្រាស់ក្នុងកុសលត្តិកៈ ក្នុងបច្ចនីយន័យ ហើយទ្រង់សម្តែងវារៈ ៩ ក្នុងបច្ច័យទាំងពួងថា **នហេតុយា នវ** ជាដើម ដោយអំណាចការរាប់ដោយបច្ចនីយៈ ទាក់ទងនឹងវារៈដែលបានក្នុងបច្ច័យទាំងនោះ វារៈទាំងនោះ អ្នកសិក្សាគប្បីលើកឡើងនូវបាលីសម្តែងដោយន័យថា បុគ្គលឲ្យទានដោយចិត្តដែលសម្បយុត្តដោយសុខវេទនា ធម៌ដែលសម្បយុត្តដោយសុខ-វេទនា ជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយសុខវេទនា ដោយនហេតុប្បច្ច័យ

*ដូច្នេះជាដើម ដោយអំណាចនៃវិសជ្ជនា ៩ វារៈ ដែលមានបច្ច័យ ១ ជាមូល និងមានបច្ច័យ ១ ជាទីបំផុត ។*

*ក្នុងការរួមបច្ច័យ ក្នុងអធិការនេះ បទថា* **នហេតុប្បច្ចយា ។បេ។ នឧបនិស្សយេ អដ្ឋ** *អ្នកសិក្សាគប្បីជ្រាបវារៈ ដោយអំណាចនានាខណិកកម្មប្បច្ច័យ ។ ពិតហើយ កម្មដែលមានកម្លាំងថោកថយ រមែងមិនជាឧបនិស្សយប្បច្ច័យ តែជាបច្ច័យដោយនានាខណិកកម្មប្បច្ច័យតែម្យ៉ាងប៉ុណ្ណោះ ។ យជនាដ៏សេស ទាំងក្នុងអនុលោមប្បច្ចនីយៈ និងបច្ចនីយានុលោម ក្នុងអធិការនេះ អ្នកសិក្សាអាចរាប់បានដោយន័យ ដែលខ្ញុំពោលហើយខាងដើម ដោយអំណាចនៃវារៈដែលបានហើយ ក្នុងការប្រកបនៃបច្ច័យនោះៗ ព្រោះហេតុនោះ ទើបមិនអធិប្បាយឲ្យពិស្តារ ។*

## **អដ្ឋកថាវេទនាត្តិកៈ ចប់**

# អភិធម្មបិដក

## បដ្ឋាន តតិយភាគ

## វិបាកត្តិកៈ

## បដិច្ចវារៈ

[ ១ ] វិបាកធម៌អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ។បេ។ ខន្ធ ២ អាស្រ័យខន្ធ ២ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យវិបាកក្ខន្ធទាំងឡាយ កដត្តារូប អាស្រ័យវិបាកក្ខន្ធទាំងឡាយ ក្នុងខណៈនៃបដិសន្ធិ ។ វិបាកក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យវិបាកក្ខន្ធ ១ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យវិបាកក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ២ ។

[ ២ ] ធម៌ មានវិបាកជាប្រក្រតី អាស្រ័យធម៌ មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌ មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលជាធម៌

មានវិបាកជាប្រក្រតី ។ ធម៌មានវិបាកជាប្រក្រតី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ។

[ ៣ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ មហាភូត ៣ អាស្រ័យមហាភូត ១ មហាភូត ២ អាស្រ័យមហាភូត ២ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។ វិបាកធម៌ អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺវិបាកក្ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាក ជាប្រក្រតីក្តី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាក ជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺវិបាកក្ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យមហាភូតទាំងឡាយ ។

[ ៤ ] វិបាកធម៌ អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យ

ខន្ធ ២ ផង វត្ថុផង ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង កដត្តារូប អាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ក្នុងខណៈនៃបដិសន្ធិ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង កដត្តារូប អាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ។

[ ៥ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតីផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលជាធម៌មានវិបាកជាប្រក្រតីផង មហាភូតទាំងឡាយផង ។

[ ៦ ] វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ខន្ធ ២ អាស្រ័យខន្ធ ២ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ។

[ ៧ ] ធម៌មានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើប

កើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ខន្ធ ២ អាស្រ័យខន្ធ ២ ។

[ ៨ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាក ជាប្រក្រតី ខន្ធ ២ អាស្រ័យខន្ធ ២ ។ វិបាកធម៌ អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺវិបាកក្ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។

[ ៩ ] វិបាកធម៌ អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យ ខន្ធ ២ ផង វត្ថុផង ។

[ ១០ ] វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យវិបាកក្ខន្ធទាំងឡាយ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្ត-

សមុដ្ឋានរូបក្តី អាស្រ័យវិបាកក្ខន្ធ ១ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ខន្ធ ៣ អាស្រ័យធម៌មានវិបាកជាប្រក្រតី ។

[ ១១ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ខន្ធ ២ ក្តី ចិត្តសមុដ្ឋាន-រូបក្តី អាស្រ័យខន្ធ ២ មហាភូត ៣ អាស្រ័យមហាភូត ១ ចិត្តសមុដ្ឋានរូបកដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។

[ ១២ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ។

[ ១៣ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតីផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យពួកខន្ធ ដែលជាធម៌មានវិបាកជាប្រក្រតីផង មហាភូតទាំងឡាយផង ។

[ ១៤ ] វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះអនន្តរប្បច្ច័យ ... ព្រោះសមនន្តរប្បច្ច័យ ... ប្រហែលគ្នានឹងអារម្មណប្បច្ច័យដែរ ។ ព្រោះសហជាតប្បច្ច័យ ... សហជាតប្បច្ច័យទាំងអស់ ប្រហែលគ្នានឹង

ហេតុប្បច្ច័យដែរ ។

[ ១៥ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះសហជាតប្បច្ច័យ គឺពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... របស់ពួកអសញ្ញសត្វ ។ ការធ្វើឲ្យផ្សេងៗ គ្នានេះ ក្នុងសហជាតប្បច្ច័យ ។

[ ១៦ ] វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ខន្ធ ២ អាស្រ័យខន្ធ ២ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺវត្ថុអាស្រ័យវិបាកក្ខន្ធទាំងឡាយ ក្នុងខណៈនៃបដិសន្ធិ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ៣ ក្តី វត្ថុក្តី អាស្រ័យវិបាកក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី វត្ថុក្តី អាស្រ័យខន្ធ ២ ។

[ ១៧ ] ធម៌មានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ខន្ធ ២ អាស្រ័យខន្ធ ២ ។

[ ១៨ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះ

អញ្ញមញ្ញប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី មហាភូត ១ ... ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... ( មហាភូត ៣ ) អាស្រ័យមហាភូត ១ របស់ពួកអសញ្ញសត្វ ។ វិបាកធម៌ អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺវិបាកក្ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។

[ ១៩ ] វិបាកធម៌ អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យ ខន្ធ ២ ផង វត្ថុផង ។

[ ២០ ] វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនិស្សយប្បច្ច័យ ។ សេចក្តីបង្រួញ ។ ព្រោះឧបនិស្សយប្បច្ច័យ ព្រោះបុរេជាតប្បច្ច័យ ។

[ ២១ ] ធម៌មានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអាសេវនប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ខន្ធ ២ អាស្រ័យខន្ធ ២ ។

[ ២២ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអាសេវនប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក

មិនមែនមានវិបាកជាប្រក្រតី ខន្ធ ២ អាស្រ័យខន្ធ ២ ។

[ ២៣ ] វិបាកធម៌អាស្រ័យវិបាកធម៌ ទើបកើតឡើងព្រោះកម្មប្បច្ច័យ ។ សេចក្ដីបង្រួញ ។ ព្រោះវិបាកប្បច្ច័យ មានវារៈ ៣ ។

[ ២៤ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាក ជាប្រក្រតី ទើបកើតឡើង ព្រោះវិបាកប្បច្ច័យ គឺមហាភូត ៣ អាស្រ័យមហាភូត ១ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។ វិបាកធម៌ អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះវិបាកប្បច្ច័យ គឺវិបាកក្ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ វិបាកធម៌ក្ដី ធម៌មិនមែនជាវិបាក មិនមែនមានវិបាក ជាប្រក្រតីក្ដី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះវិបាកប្បច្ច័យ គឺវិបាកក្ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យមហាភូតទាំងឡាយ ។

[ ២៥ ] វិបាកធម៌ អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាក ជាប្រក្រតីផង ទើបកើតឡើង ព្រោះវិបាកប្បច្ច័យ ។បេ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះវិបាកប្បច្ច័យ ។បេ។ វិបាកធម៌ក្ដី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្ដី ទើបកើតឡើង ព្រោះវិបាកប្បច្ច័យ ។

[ ២៦ ] វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះអាហា-

របច្ច័យ ។ សេចក្ដីបង្រួញ ។ ព្រោះឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ និងអវិគតប្បច្ច័យ ។

[ ២៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសហជាតប្បច្ច័យ មានវារៈ ១៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៧ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ១៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ១៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ១៣ ក្នុងឈានប្បច្ច័យ មានវារៈ ១៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ១៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ១៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងវិគតប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

[ ២៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះហេតុប្បច្ច័យ ។បេ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។ បណ្ឌិតគប្បីរាប់ ដូចជាការរាប់នូវកុសលត្តិកៈដែរ ។

[ ២៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ព្រោះអាសេវនប្បច្ច័យ ...

ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសហជាតប្បច្ច័យ មានវារៈ ២ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ២ ក្នុងអាហារប្បច្ច័យ មានវារៈ ២ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ២ ក្នុងឈានប្បច្ច័យ មានវារៈ ២ ក្នុងមគ្គប្បច្ច័យ មានវារៈ ២ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងអត្ថិប្បច្ច័យ មានវារៈ ២ ក្នុងនត្ថិប្បច្ច័យ មានវារៈ ២ ក្នុងវិគតប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

[ ៣០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ព្រោះវិបាកប្បច្ច័យ ... ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៩ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុង

នត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងវិគតប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

## អនុលោមគណនា ចប់

[ ៣១ ] វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យអហេតុកវិបាកក្ខន្ធ ១ ខន្ធ ២ អាស្រ័យខន្ធ ២ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យអហេតុកវិបាកក្ខន្ធទាំងឡាយ កដត្តារូប អាស្រ័យវិបាកក្ខន្ធទាំងឡាយ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យអហេតុកវិបាកក្ខន្ធ ១ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យវិបាកក្ខន្ធ ១ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបក្តី អាស្រ័យ ខន្ធ ២ ។

[ ៣២ ] ធម៌មានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។

[ ៣៣ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យអហេតុកក្ខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាក ជាប្រក្រតី ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ មហាភូត ៣ អាស្រ័យមហាភូត ១ មហាភូត ២ អាស្រ័យមហាភូត ២ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... មហាភូត ៣ អាស្រ័យមហាភូត ១ របស់ពួកអសញ្ញសត្វ កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។ វិបាកធម៌អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺវិបាកក្ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺវិបាកក្ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ កដត្តារូប អាស្រ័យមហាភូតទាំងឡាយ ។

[ ៣៤ ] វិបាកធម៌ អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជា

ប្រក្រតី អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូបអាស្រ័យអហេតុកវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង កដត្តារូបអាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង កដត្តារូប អាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ។

[ ៣៥ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូបអាស្រ័យវិបាកក្ខន្ធទាំងឡាយ កដត្តារូប អាស្រ័យវិបាកក្ខន្ធទាំងឡាយ ក្នុងខណៈនៃបដិសន្ធិ ។

[ ៣៦ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យពួកខន្ធ ដែលជាធម៌មានវិបាកជាប្រក្រតី ។

[ ៣៧ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលជាធម៌

មិនមែនជាវិបាក មិនមែនមានវិបាក ជាប្រក្រតី មហាភូត ៣ អាស្រ័យមហាភូត ១ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... មហាភូត ៣ អាស្រ័យមហាភូត ១ របស់ពួកអសញ្ញសត្វ កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។

[ ៣៨ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង កដត្តារូប អាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ក្នុងខណៈនៃបដិសន្ធិ ។

[ ៣៩ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតីផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយដែលជាធម៌មានវិបាកជាប្រក្រតីផង មហាភូតទាំងឡាយផង ។

[ ៤០ ] វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។ អនុលោម ប្រហែលគ្នានឹងសហជាតប្បច្ច័យ តាមដែលលោកបង្រួញហើយ ។

[ ៤១ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនអនន្តរប្បច្ច័យ ... ព្រោះនសមនន្តរប្បច្ច័យ

ព្រោះនអញ្ញមញ្ញប្បច្ច័យ គឺចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ របស់ពួកអសញ្ញសត្វ សេចក្តីផ្សេងៗ គ្មាននេះ ព្រោះនអញ្ញមញ្ញប្បច្ច័យ ព្រោះឧបនិស្សយប្បច្ច័យ ។

[ ៤២ ] វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ក្នុងអរូបភព ខន្ធ ២ អាស្រ័យខន្ធ ២ ( ខន្ធទាំងឡាយ ) អាស្រ័យវិបាកក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ។ សេចក្តីបង្រួញ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យវិបាកក្ខន្ធទាំងឡាយ ក្នុងខណៈនៃបដិសន្ធិ ។ សេចក្តីបង្រួញ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យវិបាកក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ២ ។

[ ៤៣ ] ធម៌មានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ក្នុងអរូបភព ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌ មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺចិត្តសមុដ្ឋានរូបអាស្រ័យ

ខន្ធទាំងឡាយ ដែលជាធម៌មានវិបាកជាប្រក្រតី ។

[ ៤៤ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ក្នុងអរូបភព ខន្ធ ២ អាស្រ័យខន្ធ ២ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី មហាភូត ៣ អាស្រ័យមហាភូត ១ ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... ( មហាភូត ៣ ) អាស្រ័យមហាភូត ១ របស់ពួកអសញ្ញសត្វ ។ វិបាកធម៌ អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺវិបាកក្ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺវិបាកក្ខន្ធទាំងឡាយ អាស្រ័យវត្ថុក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យមហាភូតទាំងឡាយ ។

[ ៤៥ ] វិបាកធម៌ អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាក

ជាប្រក្រតី អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង កដត្តារូបអាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ក្នុងខណៈនៃបដិសន្ធិ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ផងវត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង កដត្តារូប អាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ។

[ ៤៦ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតីផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលជាធម៌មានវិបាកជាប្រក្រតីផង មហាភូតទាំងឡាយផង ។ វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនបច្ឆាជាតប្បច្ច័យ ។ សេចក្តីបង្រួញ ។ ព្រោះនអាសេវនប្បច្ច័យ ។ ធម៌មានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺចេតនា ជាធម៌មានវិបាកជាប្រក្រតី អាស្រ័យខន្ធទាំងឡាយដែលជាធម៌មានវិបាកជាប្រក្រតី ។

[ ៤៧ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យ

ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺចេតនាជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យខន្ធទាំងឡាយ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... មហាភូត ៣ អាស្រ័យមហាភូត ១ ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។

[ ៤៨ ] ធម៌មានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនវិបាកប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមានវិបាកជាប្រក្រតី ទើបកើតឡើងព្រោះនវិបាកប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលជាធម៌មានវិបាកជាប្រក្រតី ។ ធម៌មានវិបាកជាប្រក្រតីក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនវិបាកប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ។

[ ៤៩ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើងព្រោះនវិបាកប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូប

ក្តី អាស្រ័យខន្ធ ២ មហាភូត ៣ អាស្រ័យមហាភូត ១ ចិត្តសមុដ្ឋានរូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... មហាភូត ៣ អាស្រ័យមហាភូត ១ របស់ពួកអសញ្ញ-សត្វ កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។

[ ៥០ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតីផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនវិបាកប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយដែលជាធម៌មានវិបាកជាប្រក្រតីផង មហាភូតទាំងឡាយផង ។

[ ៥១ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនអាហារប្បច្ច័យ គឺពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... មហាភូត ៣ អាស្រ័យមហាភូត ១ របស់ពួកអសញ្ញសត្វ កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។

[ ៥២ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនឥន្ទ្រិយប្បច្ច័យ គឺពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... មហាភូត ៣ អាស្រ័យមហាភូត ១ រូបជីវិតិន្ទ្រិយ អាស្រ័យមហាភូតទាំងឡាយ របស់ពួកអសញ្ញសត្វ ។

[ ៥៣ ] វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះ

នឈានប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយបញ្ចវិញ្ញាណ ខន្ធ ២ អាស្រ័យខន្ធ ២ ។

[ ៥៤ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនឈានប្បច្ច័យ គឺពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... មហាភូត ៣ អាស្រ័យមហាភូត ១ របស់ពួកអសញ្ញសត្វ ។បេ។

[ ៥៥ ] វិបាកធម៌អាស្រ័យវិបាកធម៌ ទើបកើតឡើងព្រោះនមគ្គប្បច្ច័យ គឺខន្ធ ៣ អាស្រ័យអហេតុកវិបាកក្ខន្ធ ១ ។

[ ៥៦ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនមគ្គប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាអហេតុកៈ ជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ។

[ ៥៧ ] វិបាកធម៌ អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនមគ្គប្បច្ច័យ គឺខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។

[ ៥៨ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនសម្បយុត្តប្បច្ច័យ គឺខន្ធ ២ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនសម្បយុត្តប្បច្ច័យ គឺខន្ធ ២ ។ ខន្ធ ១ អាស្រ័យ

ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ។

[ ៥៩ ] វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ក្នុងអរូបភព ខន្ធ ៣ អាស្រ័យខន្ធ ២ ខន្ធ ២ អាស្រ័យខន្ធ ២ ។

[ ៦០ ] ធម៌មានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ក្នុងអរូបភព ខន្ធ ២ អាស្រ័យខន្ធ ២ ។

[ ៦១ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ក្នុងអរូបភព ខន្ធ ២ អាស្រ័យខន្ធ ២ ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... មហាភូត ៣ អាស្រ័យមហាភូត ១ របស់ពួកអសញ្ញសត្វ កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។

[ ៦២ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនោនត្ថិប្បច្ច័យ ... នោវិគតប្បច្ច័យ ... ។

[ ៦៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១០ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១៣ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ មាន

វារៈ ៥ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ២ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៥ ។

[ ៦៤ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១០ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១០ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១០ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១០ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ២ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៦៥ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ព្រោះនអារម្មណប្បច្ច័យ ... ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្ត-

វប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

នហេតុមូលកៈ[១]

បណ្ឌិតគប្បីរាប់ក្នុងនហេតុមូលកៈ[២] នេះដូចជាលោករាប់ហើយ ដោយផ្លូវនៃការស្វាធ្យាយ ក្នុងកុសលត្តិកៈដែរ ។

**បច្ចនីយៈ ចប់**

[ ៦៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១៣ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៥ ។

[ ៦៧ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ព្រោះហេតុប្បច្ច័យ ព្រោះអារម្មណប្បច្ច័យ ... ក្នុងនបុរេជាតប្បច្ច័យមានវារៈ ៥ ក្នុងនបច្ឆាជាតប្បច្ច័យ

---

១- ពាក្យថា នហេតុមូលកៈនេះ គួរថែមពាក្យថា ចប់ ។

២- ក្នុងពាក្យថា នហេតុមូលកៈ នេះគួរជាពាក្យថា វិបាកត្តិកៈ ព្រោះក្នុងទីនេះ ជាមាតិការបស់វិបាកត្តិកៈ ។

មានវារៈ ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ។

[ ៦៨ ] ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ព្រោះអារម្មណប្បច្ច័យ ព្រោះអធិបតិប្បច្ច័យ ... ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ។

[ ៦៩ ] ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ និងអនន្តរប្បច្ច័យ ។ មូលកៈ លោកបង្រួញហើយ ។ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ព្រោះបុរេជាតប្បច្ច័យ ... ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ។ សេចក្តីបង្រួញ ។ បណ្ឌិតគប្បីរាប់ ដូចជាការរាប់នូវអនុលោមប្បច្ចនីយៈ ក្នុងកុសលត្តិកៈ ដែលលោករាប់ហើយដែរ ។

## អនុលោមប្បច្ចនីយៈ ចប់

[ ៧០ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសហជាតប្បច្ច័យ មានវារៈ ១០ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៧ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១០ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ១០ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ

មានវារៈ ១០ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ១០ ក្នុងឈានប្បច្ច័យ មានវារៈ ១០ ក្នុងមគ្គប្បច្ច័យ មានវារៈ ១ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ១០ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១០ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងវិគតប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ១០ ។

[ ៧១ ] ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ព្រោះនអារម្មណប្បច្ច័យ ... ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៧២ ] ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ នអារម្មណប្បច្ច័យ នអធិបតិប្បច្ច័យ នអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ និងនអញ្ញមញ្ញប្បច្ច័យ ... ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។ សេចក្តីបង្រួញ ។

បណ្ឌិតគប្បីរាប់ដូចនហេតុមូលកៈ ដែលលោករាប់ហើយក្នុងកុសលត្តិកៈ

ដែរ ។

វារៈនេះ បណ្ឌិតគប្បីឲ្យពិស្តារ ដូចបច្ចនីយានុលោម ក្នុងកុសលត្តិកៈ ដែលលោកឲ្យពិស្តារហើយដែរ ។

បច្ចនីយានុលោម ចប់

បដិច្ចវារៈ ចប់

## សហជាតវារៈ

[ ៧៣ ] វិបាកធម៌ កើតជាមួយនឹងវិបាកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ កើតជាមួយនឹងវិបាកក្ខន្ធ ១ ខន្ធ ១ កើតជាមួយនឹងខន្ធ ៣ ខន្ធ ២ កើតជាមួយនឹងខន្ធ ២ ។ សេចក្តីបង្រួញ ។ ក្នុងហេតុប្បច្ច័យ មានវារៈ ១៣ ។បេ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។ ក្នុងនហេតុប្បច្ច័យ មានវារៈ ១០ ។បេ។ ក្នុងនោវិគតប្បច្ច័យមានវារៈ ៥ ។ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះហេតុប្បច្ច័យ ... ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ។ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះនហេតុប្បច្ច័យ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

សហជាតវារៈ ចប់

## បច្ចយវារៈ

[ ៧៤ ] វិបាកធម៌ ពឹងផ្អែកនឹងវិបាកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងវិបាកក្ខន្ធ ១ ខន្ធ ១ ពឹងផ្អែកនឹងខន្ធ ៣

ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពឹងផ្អែកនឹងវិបាកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងវិបាកក្ខន្ធទាំងឡាយ កដត្តារូប ពឹងផ្អែកនឹងវិបាកក្ខន្ធទាំងឡាយ ក្នុងខណៈនៃបដិសន្ធិ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី ពឹងផ្អែកនឹងវិបាកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងវិបាកក្ខន្ធ ១ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៧៥ ] ធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌ មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលជាធម៌មានវិបាកជាប្រក្រតី ។ ធម៌មានវិបាកជាប្រក្រតីក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី ពឹងផ្អែកនឹងធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ២ ។

[ ៧៦ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពឹងផ្អែក

នឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ២ ( មហាភូត ៣ ) ពឹងផ្អែកនឹងមហាភូត ១ ។បេ។ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ពួកខន្ធជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពឹងផ្អែកនឹងវត្ថុ ។ វិបាកធម៌ ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាក ជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺវិបាកក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ វិបាកក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាក ជាប្រក្រតី ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធទាំងឡាយ ជាធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងវត្ថុ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺវិបាកក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ វិបាកក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ កដត្តារូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ។ ធម៌មានវិបាកជាប្រក្រតីក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធទាំងឡាយ ជាធម៌មានវិបាកជាប្រក្រតី ពឹង

ផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ។

[ ៧៧ ] វិបាកធម៌ ពឹងផ្អែកនឹងវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងវិបាកក្ខន្ធ ១ ផង វត្ថុផង ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ខន្ធ ៣ ពឹងផ្អែកនឹងវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពឹងផ្អែកនឹងវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង កដត្តារូប ពឹងផ្អែកនឹងវិបាកក្ខន្ធទាំងឡាយផង ក្នុងខណៈនៃបដិសន្ធិ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាក ជាប្រក្រតីក្តី ពឹងផ្អែកនឹងវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងវិបាកក្ខន្ធ ១ ផង វត្ថុផង ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ខន្ធ ៣ ពឹងផ្អែកនឹងវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង កដត្តារូប ពឹងផ្អែកនឹងវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ។

[ ៧៨ ] ធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មានវិបាកជាប្រក្រតីផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង

ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតីផង វត្ថុផង ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មានវិបាកជាប្រក្រតីផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធទាំងឡាយដែលជាធម៌មានវិបាកជាប្រក្រតីផង មហាភូតទាំងឡាយផង ។ ធម៌មានវិបាកជាប្រក្រតីក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី ពឹងផ្អែកនឹងធម៌មានវិបាកជាប្រក្រតីផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតីផង វត្ថុផង ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលជាធម៌មានវិបាកជាប្រក្រតីផង មហាភូតទាំងឡាយផង ។

[ ៧៩ ] វិបាកធម៌ ពឹងផ្អែកនឹងវិបាកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងវិបាកក្ខន្ធ ១ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៨០ ] ធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ។

[ ៨១ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពឹងផ្អែក

នឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ខន្ធទាំងឡាយជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពឹងផ្អែកនឹងវត្ថុ ។ វិបាកធម៌ ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ សោតវិញ្ញាណ ពឹងផ្អែកនឹងសោតាយតនៈ ឃានវិញ្ញាណ ពឹងផ្អែកនឹងឃានាយតនៈ ជិវ្ហាវិញ្ញាណ ពឹងផ្អែកនឹងជិវ្ហាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ វិបាកក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ វិបាកក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធទាំងឡាយ ជាធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងវត្ថុ ។

[ ៨២ ] វិបាកធម៌ ពឹងផ្អែកនឹងវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយចក្ខុវិញ្ញាណផង ចក្ខាយតនៈផង ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង ចក្ខាយតនៈផង សោត ... ឃាន ... ជិវ្ហា ... កាយ ... ខន្ធ ៣ ពឹងផ្អែកនឹងវិបាកក្ខន្ធ ១ ផង វត្ថុផង ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ខន្ធ ៣ ពឹងផ្អែកនឹងវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ។

[ ៨៣ ] ធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មានវិបាកជាប្រក្រតីផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតីផង វត្ថុផង ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ។

[ ៨៤ ] វិបាកធម៌ ពឹងផ្អែកនឹងវិបាកធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងវិបាកក្ខន្ធ ១ ។ ខន្ធ ៣ មិនមានក្នុងខណៈនៃបដិសន្ធិ ព្រោះអធិបតិប្បច្ច័យទេ ។ ខន្ធ ៣ ក្នុងអធិបតិប្បច្ច័យ ពឹងផ្អែកនឹងធម៌មានវិបាកជាប្រក្រតី ។

[ ៨៥ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ២ មហាភូត ៣ ពឹងផ្អែកនឹងមហាភូត ១ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ខន្ធទាំងឡាយ ជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពឹងផ្អែកនឹងវត្ថុ ។

[ ៨៦ ] វិបាកធម៌ ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺវិបាកក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ។ ធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធទាំង

ឡាយ ជាធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងវត្ថុ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺវិបាកក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ។ ធម៌មានវិបាកជាប្រក្រតីក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធទាំងឡាយ ជាធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ។

[ ៨៧ ] វិបាកធម៌ ពឹងផ្អែកនឹងវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងវិបាកក្ខន្ធ ១ ផង វត្ថុផង ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពឹងផ្អែកនឹងវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី ពឹងផ្អែកនឹងវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងវិបាកក្ខន្ធ ១ ផង វត្ថុផង ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំង

ឡាយផង ។

[ ៨៨ ] ធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មានវិបាកជាប្រក្រតីផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើងព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតីផង វត្ថុផង ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មានវិបាកជាប្រក្រតីផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធទាំងឡាយដែលជាធម៌មានវិបាក ជាប្រក្រតីផង មហាភូតទាំងឡាយផង ។ ធម៌មានវិបាកជាប្រក្រតីក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី ពឹងផ្អែកនឹងធម៌មានវិបាកជាប្រក្រតីផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតីផង វត្ថុផង ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលជាធម៌មានវិបាកជាប្រក្រតីផង មហាភូតទាំងឡាយផង ។

[ ៨៩ ] វិបាកធម៌ ពឹងផ្អែកនឹងវិបាកធម៌ ទើបកើតឡើង ព្រោះអនន្តរប្បច្ច័យ ... ព្រោះសមនន្តរប្បច្ច័យ ... ។ ប្រហែលគ្នានឹងអារម្មណប្បច្ច័យដែរ ។

[ ៩០ ] ព្រោះសហជាតប្បច្ច័យ ... ព្រោះអញ្ញមញ្ញប្បច្ច័យ ខន្ធ ៣

ពឹងផ្អែកនឹងវិបាកក្ខន្ធ ១ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ខន្ធ ៣ ពឹងផ្អែកនឹងវិបាកក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពឹងផ្អែកនឹងវិបាកធម៌ ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺវត្ថុ ពឹងផ្អែកនឹងវិបាកក្ខន្ធទាំងឡាយ ក្នុងខណៈនៃបដិសន្ធិ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី ពឹងផ្អែកនឹងវិបាកធម៌ ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ៣ ក្តី វត្ថុក្តី ពឹងផ្អែកនឹងវិបាកក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី វត្ថុក្តី ពឹងផ្អែកនឹងខន្ធ ២ ។

[ ៩១ ] ធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ។

[ ៩២ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ មហាភូត ៣ ពឹងផ្អែកនឹងមហាភូត ១ ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... មហាភូត ៣ ពឹងផ្អែកនឹងមហាភូត ១ របស់ពួកអសញ្ញសត្វ មហាភូត ២ ពឹងផ្អែកនឹងមហាភូត ២ ពួកខន្ធ ជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពឹងផ្អែកនឹងវត្ថុ ។ វិបាកធម៌ ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក

មិនមែនមានវិបាក ជាប្រក្រតី ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ ។បេ។ កាយវិញ្ញាណ ពឹងផ្អែកនឹង កាយាយតនៈ វិបាកក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ វិបាកក្ខន្ធទាំងឡាយ ពឹង ផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះ អញ្ញមញ្ញប្បច្ច័យ គឺពួកខន្ធ ជាធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងវត្ថុ ។

[ ៩៣ ] វិបាកធម៌ ពឹងផ្អែកនឹងវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិន មែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយចក្ខុវិញ្ញាណផង ចក្ខាយតនៈផង ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង ចក្ខាយតនៈផង សោត ... ឃាន ... ជិវ្ហា ... កាយ ... ខន្ធ ៣ ពឹងផ្អែកនឹងវិបាកក្ខន្ធ ១ ផង វត្ថុផង ខន្ធ ២ ពឹងផ្អែក នឹងខន្ធ ២ ផង វត្ថុផង ខន្ធ ៣ ពឹងផ្អែកនឹងវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ។

[ ៩៤ ] ធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មានវិបាកជាប្រក្រតី ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលជាធម៌មានវិបាក ជាប្រក្រតីផង វត្ថុផង ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ។

[ ៩៥ ] វិបាកធម៌ ពឹងផ្អែកនឹងវិបាកធម៌ ទើបកើតឡើង ព្រោះនិស្សយប្បច្ច័យ ។ ប្រហែលគ្នានឹងសហជាតប្បច្ច័យដែរ ។ ខន្ធ ៣ ពឹងផ្អែកនឹង

វិបាកក្ខន្ធ ១ ទើបកើតឡើង ព្រោះឧបនិស្សយប្បច្ច័យ ព្រោះបុរេជាតប្បច្ច័យ គឺខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ( ខន្ធទាំងឡាយ ) ពឹងផ្អែកនឹងវត្ថុ ទើបកើតឡើង ព្រោះបុរេជាតប្បច្ច័យ ។ ប្រហែលគ្នានឹងអនន្តរប្បច្ច័យដែរ ។ សេចក្តីបង្រួញ ។

[ ៩៦ ] ធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអាសេវនប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ខន្ធ ១ ពឹងផ្អែកនឹងខន្ធ ៣ ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ។

[ ៩៧ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអាសេវនប្បច្ច័យ គឺ ( ខន្ធ ៣ ) ពឹងផ្អែកនឹងខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ។បេ។ ពួកខន្ធ ជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពឹងផ្អែកនឹងវត្ថុ ។ ធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអាសេវនប្បច្ច័យ គឺពួកខន្ធ ជាធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងវត្ថុ ។

[ ៩៨ ] ធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មានវិបាកជាប្រក្រតីផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះអាសេវនប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលជាធម៌មានវិបាក

ជាប្រក្រតីផង វត្ថុផង ខន្ធ ១ ពឹងផ្អែកនឹងខន្ធ ៣ ផង វត្ថុផង ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ២ ផង វត្ថុផង ។

[ ៩៩ ] វិបាកធម៌ ពឹងផ្អែកនឹងវិបាកធម៌ ទើបកើតឡើង ព្រោះកម្មប្បច្ច័យ គឺខន្ធ ៣ ។ ប្រហែលគ្នានឹងសហជាតប្បច្ច័យដែរ ។

[ ១០០ ] វិបាកធម៌ ពឹងផ្អែកនឹងវិបាកធម៌ ទើបកើតឡើង ព្រោះវិបាកប្បច្ច័យ គឺខន្ធ ៣ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះវិបាកប្បច្ច័យ មហាភូត ៣ ពឹងផ្អែកនឹងមហាភូត ១ មហាភូត ២ ពឹងផ្អែកនឹងមហាភូត ២ ចិត្តសមុដ្ឋានរូបក្តី កដត្តារូបក្តី ឧបាទារូបក្តី វិបាកក្តី ខន្ធទាំង ២ ក្តី ខន្ធ ៣ ក្តី ពឹងផ្អែកនឹងមហាភូតទាំងឡាយ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី ខន្ធ ៣ ក្តី ។ ព្រោះអាហារប្បច្ច័យ ព្រោះឥន្ទ្រិយប្បច្ច័យ ព្រោះឈានប្បច្ច័យ ព្រោះមគ្គប្បច្ច័យ ព្រោះសម្បយុត្តប្បច្ច័យ ព្រោះវិប្បយុត្តប្បច្ច័យ ព្រោះអត្ថិប្បច្ច័យ ព្រោះនត្ថិប្បច្ច័យ ព្រោះវិគតប្បច្ច័យ ព្រោះអវិគតប្បច្ច័យ ។

[ ១០១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៧ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១៧ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសហជាតប្បច្ច័យ មានវារៈ ១៧ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុង

អាសេវនប្បច្ច័យ មានវារៈ ៤ ក្នុងកម្មប្បច្ច័យ មានវារៈ ១៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ១៧ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ១៧ ក្នុងឈានប្បច្ច័យ មានវារៈ ១៧ ក្នុងមគ្គប្បច្ច័យ មានវារៈ ១៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៧ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ១៧ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៧ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៧ ។

[ ១០២ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១៧ ។ សេចក្តីបង្រួញ ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ១៧ ។ បណ្ឌិតគប្បីរាប់ដូចជាការរាប់ក្នុងកុសលត្តិកៈដែរ ។

### អនុលោម ចប់

[ ១០៣ ] វិបាកធម៌ ពឹងផ្អែកនឹងវិបាកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងអហេតុកវិបាកក្ខន្ធ ១ ។ ធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ ( ខន្ធ ៣ ) ពឹងផ្អែកនឹងអហេតុកក្ខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិន

មែនមានវិបាកជាប្រក្រតី ។ វិបាកធម៌ ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ ។បេ។ ធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងវត្ថុ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអហេតុកវិបាកក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ... ។ វិបាកធម៌ ពឹងផ្អែកនឹងវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាក ជាប្រក្រតីផង ទើបកើតឡើង ... ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ... វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។ ធម៌មានវិបាកជាប្រក្រតី ពឹងផ្អែកនឹងធម៌មានវិបាក ជាប្រក្រតីផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈផង វត្ថុផង ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពឹងផ្អែកនឹងវិបាកធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។ សេចក្តីបង្រួញ ។ បទទាំងអស់ បណ្ឌិតគប្បីឲ្យពិស្តារ

ចុះ ។

[ ១០៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១៧ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១៧ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ៤ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៥ ។

[ ១០៥ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១២ ។ សេចក្តីបង្រួញ ។ ... ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់ដូចជាការរាប់នូវបច្ចនីយៈ ក្នុងកុសលត្តិកៈដែរ ។

## បច្ចនីយៈ ចប់

[ ១០៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១៧ ។ សេចក្តីបង្រួញ ។ ក្នុង

នោវិគតប្បច្ច័យ មានវារៈ ៥ ។ បណ្ឌិតគប្បីរាប់ ដូចជាការរាប់នូវអនុលោមបច្ចនីយៈ ក្នុងកុសលត្តិកៈដែរ ។

អនុលោមបច្ចនីយៈ ចប់

[ ១០៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៧ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ។បេ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ១២ ។ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ព្រោះនអារម្មណប្បច្ច័យ ... ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ។ សេចក្តីបង្រួញ ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់ ដូចជាការរាប់នូវបច្ចនីយានុលោម ក្នុងកុសលត្តិកៈដែរ ។

បច្ចនីយានុលោម ចប់

បច្ចយវារៈ ចប់

## និស្សយវារៈ

[ ១០៨ ] វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ។

[ ១០៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១៧ ។ ក្នុងនហេតុប្បច្ច័យ មានវារៈ ១២ ... ក្នុងនោវិគតប្បច្ច័យ មានវារៈ ៥ ។ ក្នុងនអារម្មប្បច្ច័យ មានវារៈ ៥ ព្រោះហេតុប្បច្ច័យ ... ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ។

ក្នុងអារម្មណប្បច្ច័យ មានវារៈ ៧ ព្រោះនហេតុប្បច្ច័យ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ១២ ។

និស្សយវារៈ ចប់

## សំសដ្ឋវារៈ

[ ១១០ ] វិបាកធម៌ ប្រឡំដោយវិបាកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ប្រឡំដោយវិបាកក្ខន្ធ ១ ។ សេចក្តីបង្រួញ ។ បទទាំងអស់ បណ្ឌិតគប្បីដឹងដោយពិស្តារចុះ ។

[ ១១១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងវិគតប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។ សេចក្តីបង្រួញ ។

បណ្ឌិតគប្បីរាប់ ដូចជាការរាប់ក្នុងកុសលត្តិកៈដែរ ។

## អនុលោម ចប់

[ ១១២ ] វិបាកធម៌ ប្រឡំដោយវិបាកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ប្រឡំដោយអហេតុកវិបាកក្ខន្ធ ១ ខន្ធ ២ ប្រឡំដោយខន្ធ ២ ។ បទទាំងអស់ បណ្ឌិតចែកផងចុះ ។

[ ១១៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់ដូចជាការរាប់នូវបច្ចនីយៈ ក្នុងកុសលត្តិកៈដែរ ។

## បច្ចនីយៈ ចប់

[ ១១៤ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។ សេចក្តីបង្រួញ ។ ... ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់ដូចជាការរាប់នូវអនុលោមបច្ចនីយៈ ក្នុងកុសលត្តិកៈដែរ ។

## អនុលោមបច្ចនីយៈ ចប់

[ ១១៥ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ...

ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់ដូចជាការរាប់នូវបច្ចនីយានុលោម ក្នុងកុសលត្តិកៈដែរ ។

បច្ចនីយានុលោម ចប់

សំសដ្ឋវារៈ ចប់

## សម្បយុត្តវារៈ

[ ១១៦ ] វិបាកធម៌ ប្រកបដោយវិបាកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ប្រកបដោយវិបាកក្ខន្ធ ១ ។

ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ។

ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ។

សម្បយុត្តវារៈ ចប់

## បញ្ហាវារៈ

[ ១១៧ ] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយហេតុប្បច្ច័យ គឺពួកវិបាកជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ពួកវិបាកជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ដោយហេតុប្បច្ច័យ ។ វិបាកធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ( ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ) ដោយហេតុប្បច្ច័យ គឺពួកវិបាក

ជាហេតុ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ពួកវិបាកជាហេតុ ជាបច្ច័យនៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ដោយហេតុប្បច្ច័យ ។ វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយហេតុប្បច្ច័យ គឺពួកវិបាកជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ពួកវិបាកជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយហេតុប្បច្ច័យ ។

[ ១១៨ ] វិបាកធម្មធម៌ ( ធម៌មានវិបាកជាប្រក្រតី ) ជាបច្ច័យនៃវិបាកធម្មធម៌ ដោយហេតុប្បច្ច័យ គឺវិបាកធម្មធម៌ទាំងឡាយ ជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ វិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយហេតុប្បច្ច័យ គឺវិបាកធម្មធម៌ទាំងឡាយជាហេតុ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយហេតុប្បច្ច័យ គឺវិបាកធម្មធម៌ទាំងឡាយ ជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។

[ ១១៩ ] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយហេតុប្បច្ច័យ គឺនេវវិបាកនវិបាកធម្មធម៌ទាំងឡាយ ជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។

[ ១២០ ] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអារម្មណប្បច្ច័យ គឺ

បុគ្គលឃើញច្បាស់នូវវិបាកក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ក៏ត្រេកអរ រីករាយ រាគៈ ប្រារព្ធនូវវិបាកក្ខន្ធនោះ ទើបកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សកើតឡើង កាលបើកុសល និងអកុសល រលត់ហើយ វិបាក ទើបកើតឡើង ព្រោះអំពើនោះជាអារម្មណ៍ ។ វិបាកធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ គឺពួកសេក្ខបុគ្គល ពិចារណាឃើញនូវផល ក៏ឃើញច្បាស់នូវវិបាកក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន តែងត្រេកអរ រីករាយ រាគៈប្រារព្ធនូវវិបាកក្ខន្ធនោះ ទើបកើតឡើង ។បេ។ ទោមនស្ស កើតឡើង ពួកសេក្ខបុគ្គល ដឹងនូវចិត្តនៃបុគ្គលដែលប្រកបដោយវិបាកចិត្ត ដោយចេតោ-បរិយញ្ញាណ ។ វិបាកក្ខន្ធទាំងឡាយ ជាបច្ច័យនៃចេតោបរិយញ្ញាណ បុព្វេ-និវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ វិបាកធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ គឺព្រះអរហន្ត ពិចារណាឃើញនូវផល គឺឃើញច្បាស់នូវវិបាកក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ដឹងនូវចិត្តនៃបុគ្គលដែលប្រកបដោយវិបាកចិត្ត ដោយចេតោបរិយញ្ញាណ ។ វិបាកក្ខន្ធទាំងឡាយ ជាបច្ច័យនៃការពិចារណានូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្ស-តិញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ១២១ ] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ពិចារណានូវអំពើជា

កុសលនោះ ពិចារណានូវអំពើជាកុសលទាំងឡាយ ដែលខ្លួនធ្លាប់សន្សំល្អ ហើយ ក្នុងកាលមុន ចេញចាកឈាន ពិចារណាឈាន ពួកសេក្ខបុគ្គល ពិចារណានូវគោត្រភូ ពិចារណានូវវោទាន: ពួកសេក្ខបុគ្គលចេញចាកមគ្គ ពិចារណានូវមគ្គ ពួកសេក្ខបុគ្គលពិចារណានូវពួកកិលេស ដែលខ្លួនលះបង់ ហើយ ពិចារណានូវពួកកិលេស ដែលខ្លួនសង្កត់សង្កិនហើយ ដឹងនូវពួក កិលេសដែលខ្លួនធ្លាប់សន្សំទុកហើយ ក្នុងកាលមុន ឃើញច្បាស់នូវវិបាក-ធម្មធម្មក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន តែងត្រេកអរ រីករាយ រាគ: ប្រារព្ធនូវខន្ធនោះ ទើបកើតឡើង ។បេ។ ទោមនស្ស កើតឡើង ពួកសេក្ខបុគ្គល ដឹងនូវចិត្តនៃបុគ្គល ដែលប្រកបដោយវិបាកធម្មធម្មចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនកុសល ជាបច្ច័យនៃវិញ្ញា-ណញ្ចាយតនកុសល ដោយអារម្មណប្បច្ច័យ ។បេ។ អាកិញ្ចញ្ញាយតន-កុសល ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនកុសល ដោយអារម្មណប្បច្ច័យ វិបាកធម្មធម្មក្ខន្ធទាំងឡាយ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយ អារម្មណប្បច្ច័យ ។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយ អារម្មណប្បច្ច័យ គឺបុគ្គលឃើញច្បាស់នូវវិបាកធម្មធម្មក្ខន្ធទាំងឡាយ ថាមិន ទៀង ជាទុក្ខ មិនមែនខ្លួន តែងត្រេកអរ រីករាយ រាគ:ប្រារព្ធនូវខន្ធនោះ ទើបកើតឡើង ។បេ។ ទោមនស្សកើតឡើង កាលបើកុសល និងអកុសល រលត់ហើយ វិបាកកើតឡើងព្រោះអំពើនោះជាអារម្មណ៍ អាកាសានញ្ចាយតន-

កុសល ជាបច្ច័យនៃវិញ្ញាណញ្ចាយតនវិបាក ដោយអារម្មណប្បច្ច័យ ។បេ។ អាកិញ្ចញ្ញាយតនកុសល ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនវិបាក ដោយអារម្មណប្បច្ច័យ វិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ ព្រះអរហន្តចេញចាកមគ្គ ពិចារណាមគ្គ ពិចារណានូវអំពើទាំងឡាយ ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ព្រះអរហន្ត ពិចារណានូវកិលេសទាំងឡាយ ដែលខ្លួនលះបង់ហើយ ដឹងនូវកិលេសទាំងឡាយដែលខ្លួនសន្សំទុកក្នុងកាលមុន ឃើញច្បាស់នូវវិបាកធម្មធម្មក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ដឹងនូវចិត្តនៃបុគ្គល ដែលប្រកបដោយវិបាកធម្មធម្មចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនកុសល ជាបច្ច័យនៃវិញ្ញាណញ្ចាយតនកិរិយា ដោយអារម្មណប្បច្ច័យ ។បេ។ អាកិញ្ចញ្ញាយតនកុសល ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនកិរិយា ដោយអារម្មណប្បច្ច័យ វិបាកធម្មធម្មក្ខន្ធទាំងឡាយ ជាបច្ច័យនៃការពិចារណានូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ១២២ ] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ គឺព្រះអរហន្ត ពិចារណានូវព្រះនិព្វាន ព្រះនិព្វានជាបច្ច័យនៃការពិចារណា ដោយអារម្មណប្បច្ច័យ ។ ព្រះអរហន្ត ឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន សោតៈ ... ឃានៈ ជិវ្ហា កាយ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ វត្ថុ ... ឃើញច្បាស់នូវនេវវិបាក-

នវិបាកធម្មធម្មក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ឃើញច្បាស់នូវរូប ដោយទិព្វចក្ខុ ឮសំឡេងដោយទិព្វសោតធាតុ ដឹងនូវចិត្តនៃបុគ្គលដែលប្រកបដោយនេវវិបាកនវិបាកធម្មធម្មចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនកិរិយា ជាបច្ច័យនៃវិញ្ញាណញ្ចាយតនកិរិយា ដោយអារម្មណប្បច្ច័យ ។បេ។ អាកិញ្ចញ្ញាយតនកិរិយា ជាបច្ច័យនៃនេវសញ្ញា-នាសញ្ញាយតនកិរិយា ដោយអារម្មណប្បច្ច័យ នេវវិបាកនវិបាកធម្មធម្មក្ខន្ធទាំងឡាយ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអារម្មណប្បច្ច័យ គឺព្រះនិព្វានជាបច្ច័យនៃផល ដោយអារម្មណប្បច្ច័យ ពួកសេក្ខបុគ្គលក្តី ពួកបុថុជ្ជនក្តី ពិចារណាឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន តែងត្រេកអរ រីករាយ រាគៈ ប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង ។បេ។ ទោមនស្សកើតឡើង កាលបើកុសល និងអកុសល រលត់ហើយ វិបាក ទើបកើតឡើង ព្រោះអំពើនោះជាបច្ច័យ សោតៈ ... ឃានៈ ជិវ្ហា កាយ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ វត្ថុ ... ពួកសេក្ខបុគ្គលពិចារណាឃើញច្បាស់ នូវនេវវិបាកនវិបាកធម្មធម្មក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ត្រេកអររីករាយ រាគៈ ប្រារព្ធនូវខន្ធនោះ ទើបកើតឡើង ។បេ។ ទោមនស្សកើតឡើង កាលបើកុសល និងអកុសល រលត់ហើយ វិបាកកើតឡើងព្រោះអំពើនោះជាអារម្មណ៍ រូបាយតនៈ ( ជាបច្ច័យ )

នៃចក្ខុវិញ្ញាណ ។បេ។ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអារម្មណប្បច្ច័យ ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ គឺពួកសេក្ខបុគ្គល ពិចារណានូវព្រះនិព្វាន ព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទាន: និងមគ្គ ដោយអារម្មណប្បច្ច័យ ។ ពួកសេក្ខបុគ្គលក្តី ពួកបុថុជ្ជនក្តី ពិចារណាឃើញច្បាស់នូវចក្ខុ ថាមិនទៀងជាទុក្ខ មិនមែនខ្លួន តែងត្រេកអររីករាយចំពោះចក្ខុនោះ ។បេ។ ទោមនស្សកើតឡើង សោតៈ ... ។បេ។ ពួកសេក្ខបុគ្គល ពិចារណាឃើញច្បាស់នូវនេវវិបាកនវិបាកធម្មធម្មក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន តែងត្រេកអរ រីករាយ ឃើញច្បាស់នូវរូបដោយទិព្វចក្ខុ ឮសំឡេងដោយទិព្វសោតធាតុ ដឹងនូវចិត្តនៃបុគ្គលដែលប្រកបដោយនេវវិបាកនវិបាកធម្មធម្មចិត្ត ដោយចេតោបរិយញ្ញាណ នេវវិបាកនវិបាកធម្មធម្មក្ខន្ធទាំងឡាយ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ១២៣ ] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអធិបតិប្បច្ច័យ គឺបានដល់ សហជាតាធិបតិ គឺវិបាកាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។ វិបាកធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអធិបតិប្បច្ច័យ គឺបានដល់អារម្មណាធិបតិ គឺពួកសេក្ខបុគ្គលធ្វើផលឲ្យជាទីគោរព ទើបពិចារណា ធ្វើវិបាកក្ខន្ធទាំងឡាយឲ្យជាទីគោរព ទើបត្រេកអររីករាយ រាគៈធ្វើខន្ធនោះឲ្យជាទីគោរពទើបកើតឡើង ទិដ្ឋិកើតឡើង ។បេ។ វិបាកធម៌

ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយអធិបតិប្បច្ច័យ គឺបានដល់អា-
រម្មណាធិបតិ និងសហជាតាធិបតិ ។ ឯអារម្មណាធិបតិ ព្រះអរហន្ត ធ្វើផល
ឲ្យជាទីគោរព ទើបពិចារណា ។ ឯសហជាតាធិបតិ គឺវិបាកាធិបតិ ជា
បច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។ វិបាកធម៌ ជាបច្ច័យ
នៃវិបាកធម៌ផង នៃនេវវិបាកធម្មធម៌ផង ដោយអធិបតិប្បច្ច័យ គឺបានដល់
សហជាតាធិបតិ គឺវិបាកាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួក
ចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។

[ ១២៤ ] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអធិបតិប្បច្ច័យ
គឺបានដល់អារម្មណាធិបតិ និងសហជាតាធិបតិ ។ ឯអារម្មណាធិបតិ គឺបុគ្គល
ឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ធ្វើអំពើទាំងនោះ ឲ្យជាទីគោរព
ទើបពិចារណា ធ្វើអំពើទាំងឡាយ ដែលខ្លួនសន្សំល្អហើយ ក្នុងកាលមុន
ឲ្យជាទីគោរព ទើបពិចារណា ចេញចាកឈាន ធ្វើឈានឲ្យជាទីគោរព ទើប
ពិចារណា ពួកសេក្ខបុគ្គលធ្វើគោត្រភូ ឲ្យជាទីគោរព ទើបពិចារណា ធ្វើ
វោទានៈឲ្យជាទីគោរព ទើបពិចារណា ពួកសេក្ខបុគ្គលចេញចាកមគ្គ ធ្វើមគ្គ
ឲ្យជាទីគោរព ទើបពិចារណា ធ្វើវិបាកធម្មធម្មក្ខន្ធទាំងឡាយ ឲ្យជាទីគោរព
ទើបត្រេកអរ រីករាយ រាគៈធ្វើខន្ធនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិ
កើតឡើង ។បេ។ ឯសហជាតាធិបតិ វិបាកធម្មធម្មាធិបតិ ជាបច្ច័យនៃពួក
សម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។ វិបាកធម្មធម៌ ជាបច្ច័យនៃនេវ-
វិបាកនវិបាកធម្មធម៌ ដោយអធិបតិប្បច្ច័យ គឺបានដល់អារម្មណាធិបតិ និង

សហជាតាធិបតិ ។ ឯអារម្មណាធិបតិ គឺព្រះអរហន្ត ចេញចាកមគ្គ ធ្វើមគ្គឲ្យជាទីគោរព ទើបពិចារណា ។ ឯសហជាតាធិបតិ គឺវិបាកធម្មធម្មាធិបតិ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយអធិបតិប្បច្ច័យ គឺបានដល់សហជាតាធិបតិ គឺវិបាកធម្មធម្មាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។

[ ១២៥ ] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយអធិបតិប្បច្ច័យ គឺបានដល់អារម្មណាធិបតិ និងសហជាតាធិបតិ ។ ឯអារម្មណាធិបតិ គឺព្រះអរហន្តធ្វើនូវព្រះនិព្វានឲ្យជាទីគោរព ទើបពិចារណា ។ ឯសហជាតាធិបតិ គឺនេវវិបាកនវិបាកធម្មធម្មាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអធិបតិប្បច្ច័យ គឺបានដល់អារម្មណាធិបតិ ព្រះនិព្វាន ជាបច្ច័យនៃផល ដោយអធិបតិប្បច្ច័យ ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអធិបតិប្បច្ច័យ គឺបានដល់អារម្មណាធិបតិ គឺពួកសេក្ខបុគ្គល ធ្វើព្រះនិព្វាន ឲ្យជាទីគោរព ទើបពិចារណា ព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ និងមគ្គ ដោយអធិបតិប្បច្ច័យ ពួកសេក្ខបុគ្គល ធ្វើចក្ខុឲ្យជាទីគោរព ទើបត្រេកអរ រីករាយ រាគៈធ្វើចក្ខុនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិ កើតឡើង ។បេ។ សោតៈ ... ។បេ។ ពួកសេក្ខបុគ្គល ធ្វើនេវវិបាកនវិបាកធម្មធម្មក្ខន្ធទាំងឡាយ

ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើខន្ធទាំងនោះឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។បេ។

[ ១២៦ ] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអនន្តរប្បច្ច័យ គឺពួកវិបាកក្ខន្ធមុនៗ ជាបច្ច័យនៃពួកវិបាកក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ បញ្ចវិញ្ញាណ ជាបច្ច័យនៃវិបាកមនោធាតុ ដោយអនន្តរប្បច្ច័យ វិបាកមនោ-ធាតុ ជាបច្ច័យនៃវិបាកមនោវិញ្ញាណធាតុ ដោយអនន្តរប្បច្ច័យ ។ វិបាកធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយអនន្តរប្បច្ច័យ គឺភវង្គៈជាបច្ច័យនៃអាវជ្ជនៈដោយអនន្តរប្បច្ច័យ វិបាកមនោវិញ្ញាណធាតុ ជាបច្ច័យនៃកិរិយា-មនោវិញ្ញាណធាតុ ដោយអនន្តរប្បច្ច័យ ។

[ ១២៧ ] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអនន្តរប្បច្ច័យ គឺពួកវិបាកធម្មធម្មក្ខន្ធមុនៗ ជាបច្ច័យនៃពួកវិបាកធម្មធម្មក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោមជាបច្ច័យនៃគោត្រភូ អនុលោមជាបច្ច័យនៃវោទានៈ គោត្រភូជាបច្ច័យនៃមគ្គ វោទានៈជាបច្ច័យនៃមគ្គ ដោយអនន្តរប្បច្ច័យ ។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ដោយអនន្តរប្បច្ច័យ គឺពួកវិបាកធម្មធម្មក្ខន្ធជាបច្ច័យនៃវុដ្ឋានៈ មគ្គជាបច្ច័យនៃផល អនុលោមរបស់ពួកសេក្ខបុគ្គលជាបច្ច័យនៃផលសមាបត្តិ នេវសញ្ញានាសញ្ញាយតនកុសល របស់បុគ្គលដែលចេញចាកនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។

[ ១២៨ ] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនេវវិបាកនវិបាកធម្មធម្មក្ខន្ធមុនៗ ជាបច្ច័យនៃពួក

នេវវិបាកនវិបាកធម្មធម្មក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ។ នេវវិបាក-នវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអនន្តរប្បច្ច័យ គឺអាវជ្ជនៈ ជាបច្ច័យនៃបញ្ចវិញ្ញាណ ដោយអនន្តរប្បច្ច័យ ពួកនេវវិបាកនវិបាកធម្មធម្មក្ខន្ធ ជាបច្ច័យវុដ្ឋានៈ អនុលោម របស់ព្រះអរហន្ត ជាបច្ច័យនៃផលសមាបត្តិ នេវសញ្ញានាសញ្ញាយតនកិរិយា របស់បុគ្គលដែលចេញពីនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអនន្តរប្បច្ច័យ គឺអាវជ្ជនៈ ជាបច្ច័យនៃពួកវិបាកធម្ម-ធម្មក្ខន្ធ ដោយអនន្តរប្បច្ច័យ ។

[ ១២៩ ] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយសមនន្តរប្បច្ច័យ គឺប្រហែលគ្នានឹងអនន្តរប្បច្ច័យដែរ ។ វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយសហជាតប្បច្ច័យ គឺវិបាកក្ខន្ធ ១ ( ជាបច្ច័យ ) នៃវិបាកក្ខន្ធ ៣ ។បេ។ ខន្ធ ៣ ។

[ ១៣០ ] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយសហជាតប្បច្ច័យ គឺខន្ធ ៣ ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយសហជាតប្បច្ច័យ គឺនេវវិបាកនវិបាកធម្មធម្មក្ខន្ធ ១ មហាភូត ១ ... ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... មហាភូត ១ របស់ពួកអសញ្ញសត្វ ។

[ ១៣១ ] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយសហជាតប្បច្ច័យ គឺវត្ថុ ជាបច្ច័យនៃពួកវិបាកក្ខន្ធក្នុងខណៈនៃបដិសន្ធិ ដោយ

សហជាតប្បច្ច័យ ។

[ ១៣២ ] វិបាកធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យនៃវិបាកធម៌ ដោយសហជាតប្បច្ច័យ គឺវិបាកក្ខន្ធ ១ ក្តី វត្ថុក្តី ( ជាបច្ច័យ ) នៃខន្ធ ៣ ក្នុងខណៈនៃបដិសន្ធិ ។ វិបាកធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយសហជាតប្បច្ច័យ គឺពួកវិបាកក្ខន្ធក្តី ពួកមហាភូតក្តី ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ។

[ ១៣៣ ] វិបាកធម្មធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយសហជាតប្បច្ច័យ គឺពួកវិបាកធម្មធម្មក្ខន្ធក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយសហជាតប្បច្ច័យ ។

[ ១៣៤ ] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអញ្ញមញ្ញប្បច្ច័យ គឺវិបាកក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ... ។ វិបាកធម៌ ជាបច្ច័យនៃនេវ-វិបាកនវិបាកធម្មធម៌ ដោយអញ្ញមញ្ញប្បច្ច័យ គឺពួកវិបាកក្ខន្ធ ជាបច្ច័យនៃវត្ថុក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ។ វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយអញ្ញមញ្ញប្បច្ច័យ គឺវិបាកក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ផង នៃវត្ថុផង ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ១៣៥ ] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអញ្ញមញ្ញប្បច្ច័យ គឺវិបាកធម្មធម្មក្ខន្ធ ១ ( ជាបច្ច័យ ) នៃខន្ធ ៣ ខន្ធ ២ ( ជាបច្ច័យ ) នៃខន្ធ ២ ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌

ដោយអញ្ញមញ្ញប្បច្ច័យ គឺនេវវិបាកនវិបាកធម្មធម្មក្ខន្ធ ១ ( ជាបច្ច័យ ) នៃខន្ធ ៣ ខន្ធ ២ ( ជាបច្ច័យ ) នៃខន្ធ ២ ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអញ្ញមញ្ញប្បច្ច័យ គឺវត្ថុ ( ជាបច្ច័យ ) នៃពួកវិបាកក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ។

[ ១៣៦ ] វិបាកធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ( ជាបច្ច័យ ) នៃវិបាកធម៌ គឺវិបាកក្ខន្ធ ១ ក្តី វត្ថុក្តី ( ជាបច្ច័យ ) នៃខន្ធ ៣ ក្នុងខណៈនៃបដិសន្ធិ ។ បញ្ហា ៧ ។

[ ១៣៧ ] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយនិស្សយប្បច្ច័យ គឺខន្ធ ៣ ។ វិបាកធម្មធម៌ ( ជាបច្ច័យ ) នៃវិបាកធម្មធម៌ គឺខន្ធ ៣ ។ នេវវិបាកនវិបាកធម្មធម៌ ( ជាបច្ច័យ ) នៃនេវវិបាកនវិបាកធម្មធម៌ ។បេ។ នេវវិបាកនវិបាកធម្មធម៌ ( ជាបច្ច័យ ) នៃវិបាកធម៌ គឺចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយនិស្សយប្បច្ច័យ ។បេ។ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុ ( ជាបច្ច័យ ) នៃពួកវិបាកក្ខន្ធ វត្ថុ ( ជាបច្ច័យ ) នៃពួកវិបាកក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយនិស្សយប្បច្ច័យ គឺវត្ថុ ( ជាបច្ច័យ ) នៃពួកវិបាកធម្មធម្មក្ខន្ធ ។

[ ១៣៨ ] វិបាកធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យនៃវិបាកធម៌ ដោយនិស្សយប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយចក្ខុវិញ្ញាណក្តី ចក្ខាយតនៈក្តី ។បេ។ កាយាយតនៈក្តី វិបាកក្ខន្ធ ១ ក្តី វត្ថុក្តី ( ជាបច្ច័យ ) នៃ

ខន្ធ ៣ វិបាកក្ខន្ធ ១ ក្តី វត្ថុក្តី ក្នុងខណៈនៃបដិសន្ធិ ។ វិបាកធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយនិស្សយប្បច្ច័យ គឺពួកវិបាកក្ខន្ធក្តី ពួកមហាភូតក្តី ។ សេចក្តីបង្រួញ ។ ក្នុងខណៈនៃបដិសន្ធិ ... វិបាកធម្មធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យនៃវិបាកធម្មធម៌ ដោយនិស្សយប្បច្ច័យ គឺវិបាកធម្មធម្មក្ខន្ធ ១ ក្តី វត្ថុក្តី ។ វិបាកធម្មធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយនិស្សយប្បច្ច័យ គឺពួកវិបាកធម្មធម្មក្ខន្ធក្តី ពួកមហាភូតក្តី ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ។ បញ្ហា ១៣ ។

[ ១៣៩ ] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយឧបនិស្សយប្បច្ច័យ គឺបានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺកាយិកសុខ ជាបច្ច័យនៃកាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ កាយិកទុក្ខ ជាបច្ច័យនៃកាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ផលសមាបត្តិ ជាបច្ច័យនៃកាយិកសុខ ដោយឧបនិស្សយប្បច្ច័យ ។ វិបាកធម៌ ( ជាបច្ច័យ ) នៃវិបាកធម្មធម៌ ដោយឧបនិស្សយប្បច្ច័យ គឺបានដល់អារម្មណូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យកាយិកសុខ ហើយឲ្យទាន សមាទានសីល ។បេ។ បំបែកសង្ឃ អាស្រ័យកាយិកទុក្ខ ហើយឲ្យទាន សមាទានសីល ។បេ។ បំបែកសង្ឃ កាយិកសុខ ... កាយិកទុក្ខ ( ជាបច្ច័យ ) នៃសទ្ធា ។បេ។ ជាបច្ច័យនៃសេចក្តីប្រាថ្នា ដោយឧបនិស្ស-

យប្បច្ច័យ ។ វិបាកធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយឧបនិស្សយប្បច្ច័យ គឺបានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺព្រះអរហន្ត អាស្រ័យកាយិកសុខ ធ្វើកិរិយាសមាបត្តិ ដែលមិនទាន់កើតឲ្យកើតឡើង ចូលកាន់កិរិយាសមាបត្តិ ដែលកើតឡើងហើយ ពិចារណាឃើញច្បាស់នូវសង្ខារទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន អាស្រ័យកាយិកទុក្ខ ធ្វើកិរិយាសមាបត្តិ ដែលមិនទាន់កើតឲ្យកើតឡើង ចូលកាន់កិរិយាសមាបត្តិ ដែលកើតឡើងហើយ ។

[ ១៤០ ] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយឧបនិស្សយប្បច្ច័យ គឺបានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យសទ្ធា ហើយឲ្យទាន ។បេ។ ដំឡើងមានះ ប្រកាន់ទិដ្ឋិ សីល ... សុតៈ ... ចាគៈ ... អាស្រ័យបញ្ញា ហើយឲ្យទាន ។បេ។ ដំឡើងមានះ ប្រកាន់ទិដ្ឋិ រាគៈ ... ទោសៈ មោហៈ ... មានះ ទិដ្ឋិ ... អាស្រ័យសេចក្តីប្រាថ្នា ហើយឲ្យទាន ។បេ។ ធ្វើសមាបត្តិឲ្យកើតឡើង សម្លាប់សត្វ ។បេ។ បំបែកសង្ឃ ។បេ។ សទ្ធា ។បេ។ សេចក្តីប្រាថ្នា ( ជាបច្ច័យ ) នៃសទ្ធា នៃសីល ។បេ។ ជាបច្ច័យនៃសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃបឋមជ្ឈាន ( ជាបច្ច័យ ) នៃបឋមជ្ឈាន ។បេ។ បរិកម្មនៃនេវសញ្ញានាសញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ បឋមជ្ឈាន ( ជាបច្ច័យ ) នៃទុតិយជ្ឈាន ។បេ។ អាកិញ្ចញ្ញាយតនៈ ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនៈ ដោយឧបនិស្សយប្បច្ច័យ ។បេ។

បរិកម្មនៃមគ្គទី ១ ( ជាបច្ច័យ ) នៃមគ្គទី ១ ។បេ។ បរិកម្មនៃមគ្គទី ៤ ( ជាបច្ច័យ ) នៃមគ្គទី ៤ មគ្គទី ១ ( ជាបច្ច័យ ) នៃមគ្គទី ២ មគ្គទី ២ ( ជាបច្ច័យ ) នៃមគ្គទី ៣ មគ្គទី ៣ ( ជាបច្ច័យ ) នៃមគ្គទី ៤ ដោយឧបនិស្សយប្បច្ច័យ ពួកសេក្ខបុគ្គលអាស្រ័យមគ្គ ហើយធ្វើកុសលសមាបត្តិដែលមិនទាន់កើតឲ្យកើតឡើង ។បេ។ មគ្គ ( ជាបច្ច័យ ) នៃអត្ថប្បដិសម្ភិទា របស់ពួកសេក្ខបុគ្គល ។បេ។ ជាបច្ច័យនៃសេចក្តីឈ្លាស ក្នុងឋានាឋានៈ ដោយឧបនិស្សយប្បច្ច័យ បាណាតិបាត ( ជាបច្ច័យ ) នៃបាណាតិបាត ។បេ។ ជាបច្ច័យនៃមិច្ឆាទិដ្ឋិ ដោយឧបនិស្សយប្បច្ច័យ ។បេ។ មិច្ឆាទិដ្ឋិ ( ជាបច្ច័យ ) នៃមិច្ឆាទិដ្ឋិ ។បេ។ នៃព្យាបាទ មាតុឃាតកម្ម ជាបច្ច័យនៃមាតុឃាតកម្ម ដោយឧបនិស្សយប្បច្ច័យ ។បេ។ ជាបច្ច័យនៃនិយតមិច្ឆាទិដ្ឋិ ដោយឧបនិស្សយប្បច្ច័យ និយតមិច្ឆាទិដ្ឋិ ( ជាបច្ច័យ ) នៃនិយតមិច្ឆាទិដ្ឋិ ជាបច្ច័យនៃសង្ឃភេទកម្មដោយឧបនិស្សយប្បច្ច័យ ។បេ។

[ ១៨១ ] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយឧបនិស្សយប្បច្ច័យ គឺបានដល់អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យសទ្ធា ធ្វើឧទនឲ្យក្តៅ ឲ្យក្តៅសព្វ រងនូវទុក្ខដែលមានការស្វែងរកជាមូល ។បេ។ អាស្រ័យសេចក្តីប្រាថ្នា ធ្វើឧទនឲ្យក្តៅ ឲ្យក្តៅសព្វ ។បេ។ សទ្ធា ។បេ។ សេចក្តីប្រាថ្នា ជាបច្ច័យនៃកាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ កុសល និងអកុសល ជាបច្ច័យនៃកម្មវិបាក ដោយឧបនិស្សយប្បច្ច័យ មគ្គ ជាបច្ច័យនៃផលសមាបត្តិ ដោយ

ឧបនិស្សយប្បច្ច័យ ។ វិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយឧបនិស្សយប្បច្ច័យ គឺបានដល់អារម្មណូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺព្រះអរហន្ត អាស្រ័យមគ្គ ធ្វើកិរិយាសមាបត្តិ ដែលមិនទាន់កើត ឲ្យកើតឡើង ចូលកាន់កិរិយាសមាបត្តិ ដែលកើតឡើង ហើយ ពិចារណាឃើញច្បាស់នូវសង្ខារទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ។បេ។ មគ្គ ជាបច្ច័យនៃអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា និងឋានាឋានកោសល្លរបស់ព្រះអរហន្ត ដោយឧបនិស្សយប្បច្ច័យ ។

[ ១៤២ ] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយឧបនិស្សយប្បច្ច័យ គឺបានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺព្រះអរហន្ត អាស្រ័យរដូវ ... ភោជន ... សេនាសនៈ ធ្វើកិរិយាសមាបត្តិ ដែលមិនទាន់កើត ឲ្យកើតឡើង ចូលកាន់កិរិយាសមាបត្តិដែលកើតឡើងហើយ ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយឧបនិស្សយប្បច្ច័យ គឺបានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺរដូវ ... ភោជន ... សេនាសនៈ ជាបច្ច័យនៃកាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយឧបនិស្សយប្បច្ច័យ គឺបានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យរដូវ ហើយឲ្យទាន ។បេ។ បំបែកសង្ឃ

អាស្រ័យភោជន ... សេនាសនៈ ហើយឲ្យទាន ។បេ។ បំបែកសង្ឃ រដូវ ... ភោជន ... សេនាសនៈ ( ជាបច្ច័យ ) នៃសទ្ធា ។បេ។ ជាបច្ច័យនៃសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។

[ ១៤៣ ] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយបុរេជាតប្បច្ច័យ គឺបានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺព្រះអរហន្ត ( ពិចារណាឃើញ ) នូវចក្ខុ ជាមិនទៀង ។បេ។ នូវកាយ នូវរូបទាំងឡាយ ។បេ។ នូវផ្សព្វទាំងឡាយ នូវវត្ថុ ជាមិនទៀង ។បេ។ នូវរូបដោយទិព្វចក្ខុ ។បេ។ នូវសំឡេង ដោយទិព្វសោតធាតុ ។បេ។ ឯវត្ថុបុរេជាត គឺវត្ថុ ជាបច្ច័យនៃនេវវិបាកនវិបាក-ធម្មធម្មក្ខន្ធទាំងឡាយ ដោយបុរេជាតប្បច្ច័យ ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយបុរេជាតប្បច្ច័យ គឺបានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺពួកសេក្ខបុគ្គលក្តី ពួកបុថុជ្ជនក្តី ពិចារណាឃើញច្បាស់នូវចក្ខុ ជាមិនទៀង ជាទុក្ខ មិនមែនខ្លួន ហើយត្រេកអរ រីករាយ រាគៈប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង ។បេ។ ទោមនស្សកើតឡើង កាលបើកុសល និងអកុសល រលត់ហើយ វិបាកកើតឡើងព្រោះអំពើនោះជាអារម្មណ៍ នូវសោតៈ ។បេ។ នូវវត្ថុ ជាមិនទៀង ។បេ។ ( វិបាក ) កើតឡើង ព្រោះអំពើនោះជាអារម្មណ៍ រូបាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណដោយបុរេជាតប្បច្ច័យ ។បេ។ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុ-

វិញ្ញាណ ។បេ។ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃពួកវិបាកក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយបុរេជាតប្បច្ច័យ គឺបានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺពួកសេក្ខបុគ្គលក្តី ពួកបុថុជ្ជនក្តី ( ពិចារណាឃើញ ) នូវចក្ខុ ។បេ។ រាគៈ ប្រារព្ធ ទើបកើតឡើង ។បេ។ ទោមនស្ស កើតឡើង នូវសោតៈ ។បេ។ នូវវត្ថុ ថាមិនទៀង ។បេ។ ទោមនស្ស ។បេ។ នូវរូប ដោយទិព្វចក្ខុ ។បេ។ នូវសំឡេង ដោយទិព្វ-សោតធាតុ ។ ឯវត្ថុបុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកវិបាកធម្មធម្មក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។

[ ១៨៤ ] វិបាកធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយបច្ឆា-ជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកវិបាកក្ខន្ធជាបច្ច័យនៃកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ១៨៥ ] វិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយបច្ឆាជាតប្បច្ច័យ គឺនេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាក-ធម្មធម៌ ដោយបច្ឆាជាតប្បច្ច័យ ។

[ ១៨៦ ] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអាសេវនប្បច្ច័យ គឺពួកវិបាកធម្មធម្មក្ខន្ធមុនៗ ( ជាបច្ច័យ ) នៃពួកវិបាកធម្មធម្មក្ខន្ធក្រោយៗ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទានៈ គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទានៈជាបច្ច័យនៃមគ្គ ដោយ

អាសេវនប្បច្ច័យ ។

[ ១៤៧ ] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយអាសេវនប្បច្ច័យ គឺ ( ពួកខន្ធ ) មុនៗ ។បេ។ ជាបច្ច័យ ដោយអាសេវនប្បច្ច័យ ។

[ ១៤៨ ] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយកម្មប្បច្ច័យ គឺវិបាកចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ វិបាកចេតនា ក្នុងខណៈនៃបដិសន្ធិ ។ វិបាកធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយកម្មប្បច្ច័យ គឺវិបាកចេតនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ វិបាកចេតនា ក្នុងខណៈនៃបដិសន្ធិ ( ជាបច្ច័យ ) នៃពួកកដត្តារូប ។ វិបាកធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយកម្មប្បច្ច័យ គឺវិបាកចេតនា ( ជាបច្ច័យ ) នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង វិបាកចេតនា ( ជាបច្ច័យ ) នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ។

[ ១៤៩ ] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយកម្មប្បច្ច័យ គឺវិបាកធម្មធម្មចេតនា ( ជាបច្ច័យ ) នៃពួកសម្បយុត្តកក្ខន្ធ ។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយកម្មប្បច្ច័យ បានដល់ នានាខណិកា គឺពួកវិបាកធម្មធម្មចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធ ដោយកម្មប្បច្ច័យ ។ វិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយកម្មប្បច្ច័យ គឺបានដល់ សហជាតានានាខណិកា ។ សហជាតា គឺវិបាកធម្មធម្មចេតនា ( ជា

បច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ។ ឯនានាខណិកា គឺវិបាកធម្មធម្មចេតនា ( ជាបច្ច័យ ) នៃពួកកដត្តារូប ។ វិបាកធម្មធម៌ ( ជាបច្ច័យ ) នៃវិបាកធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង គឺបានដល់ នានាខណិកា គឺវិបាកធម្មធម្មចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយកម្មប្បច្ច័យ គឺវិបាកធម្មធម្មចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។

[ ១៥០ ] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយកម្មប្បច្ច័យ គឺនេវវិបាកនវិបាកធម្មធម្មចេតនា ( ជាបច្ច័យ ) នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ។

[ ១៥១ ] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធ ១ ( ជាបច្ច័យ ) នៃខន្ធ ៣ ក្នុងខណៈនៃបដិសន្ធិ ... ។ វិបាកធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយវិបាកប្បច្ច័យ គឺពួកវិបាកក្ខន្ធ ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ពួកវិបាកក្ខន្ធ ( ជាបច្ច័យ ) នៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ។ វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធ ១ ( ជាបច្ច័យ ) នៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង វិបាកក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិដោយវិបាកប្បច្ច័យ ។ វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ដោយអាហារប្បច្ច័យ គឺវិបាកាហារ ( ជាបច្ច័យ )

នៃពួកសម្បយុត្តកក្ខន្ធ គឺខន្ធ ៣ ។ ឯបដិសន្ធិនៃខន្ធទាំង ៣ នេះ បណ្ឌិតគប្បីធ្វើចុះ ។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអាហារប្បច្ច័យ គឺខន្ធ ៣ ។

[ ១៥២ ] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយអាហារប្បច្ច័យ គឺនេវវិបាកនវិបាកធម្មធម្មាហារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ កវឡិង្ការាហារ ជាបច្ច័យនៃកាយនេះ ដោយអាហារប្បច្ច័យ ។

[ ១៥៣ ] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺខន្ធ ៣ ។ បដិសន្ធិ បណ្ឌិតគប្បីធ្វើចុះ ។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺខន្ធ ៣ ។

[ ១៥៤ ] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺឥន្ទ្រិយទាំងឡាយ ជានេវវិបាកនវិបាកធម្មធម៌ ( ជាបច្ច័យ ) នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ដោយឥន្ទ្រិយប្បច្ច័យ ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺចក្ខុន្ទ្រិយ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ ។ កាយិន្ទ្រិយ ។បេ។

[ ១៥៥ ] វិបាកធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យនៃវិបាកធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺចក្ខុន្ទ្រិយក្តី ចក្ខុវិញ្ញាណក្តី ជាបច្ច័យនៃពួកខន្ធដែលប្រកបដោយចក្ខុវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ ។បេ។ កាយិន្ទ្រិយក្តី កាយ-

វិញ្ញាណក្តី ជាបច្ច័យនៃពួកខន្ធ ដែលច្រឡំដោយកាយវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ ។

[ ១៥៦ ] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយឈានប្បច្ច័យ គឺខន្ធ ៣ ។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយឈានប្បច្ច័យ គឺខន្ធ ៣ ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយឈានប្បច្ច័យ គឺអង្គឈានទាំងឡាយ ជានេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយឈានប្បច្ច័យ ។

[ ១៥៧ ] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ដោយមគ្គប្បច្ច័យ គឺខន្ធ ៣ ។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយមគ្គប្បច្ច័យ គឺខន្ធ ៣ ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយមគ្គប្បច្ច័យ គឺអង្គមគ្គទាំងឡាយ ជានេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយមគ្គប្បច្ច័យ ។

[ ១៥៨ ] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយសម្បយុត្តប្បច្ច័យ គឺវិបាកក្ខន្ធ ១ ( ជាបច្ច័យ ) នៃខន្ធ ៣ ខន្ធ ២ ( ជាបច្ច័យ ) នៃខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ១៥៩ ] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយសម្បយុត្តប្បច្ច័យ ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយសម្បយុត្តប្បច្ច័យ ។បេ។ គឺខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយសម្បយុត្តប្បច្ច័យ ។

[ ១៦០ ] វិបាកធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺវិបាកក្ខន្ធទាំងឡាយ ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប វិបាកក្ខន្ធទាំងឡាយ ( ជាបច្ច័យ ) នៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ។ ឯបច្ឆាជាត គឺវិបាកក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ១៦១ ] វិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួកវិបាកធម្មធម្មក្ខន្ធ ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ។ ឯបច្ឆាជាត គឺពួកវិបាកធម្មធម្មក្ខន្ធ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ១៦២ ] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សហជាត គឺពួកនេវវិបាកនវិបាកធម្មធម្មក្ខន្ធ ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ។ ឯបុរេជាត គឺវត្ថុ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម្មក្ខន្ធទាំងឡាយ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺនេវវិបាកនវិបាកធម្មធម្មក្ខន្ធទាំងឡាយ ( ជាបច្ច័យ ) នៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺវត្ថុ ជាបច្ច័យនៃពួកវិបាកក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ដោយវិប្បយុត្តប្បច្ច័យ ។ ឯ

បុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ។បេ។ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យនៃពួកវិបាកក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកវិបាកធម្មធម្មក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។

[ ១៦៣ ] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអត្ថិប្បច្ច័យ គឺ វិបាកក្ខន្ធ ១ ( ជាបច្ច័យ ) នៃខន្ធ ៣ វិបាកក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ក្នុងខណៈនៃបដិសន្ធិ ។ វិបាកធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺ វិបាកក្ខន្ធទាំងឡាយ ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប វិបាកក្ខន្ធទាំងឡាយ ( ជាបច្ច័យ ) នៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ។ ឯបច្ឆាជាត គឺវិបាកក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយអត្ថិប្បច្ច័យ គឺវិបាកក្ខន្ធ ១ ( ជាបច្ច័យ ) នៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ក្នុងខណៈនៃបដិសន្ធិ ... ។

[ ១៦៤ ] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអត្ថិប្បច្ច័យ គឺខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយអត្ថិប្បច្ច័យ ។ វិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺវិបាកធម្មធម្មក្ខន្ធទាំងឡាយ ជាបច្ច័យនៃពួក

ចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺវិបាកធម្មធម្មក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយអត្ថិប្បច្ច័យ គឺវិបាកធម្មធម្មក្ខន្ធ ១ ( ជាបច្ច័យ ) នៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ។

[ ១៦៥ ] នេវវិបាកនវិបាកធម្មធម៌ ( ជាបច្ច័យ ) នៃនេវវិបាកនវិបាកធម្មធម៌ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺនេវវិបាកនវិបាកធម្មធម្មក្ខន្ធ ១ ( ជាបច្ច័យ ) នៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ មហាភូត ១ ... មហាភូតទាំងឡាយ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប នៃពួកកដត្តារូប នៃពួកឧបាទារូប ដោយអត្ថិប្បច្ច័យ ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... មហាភូត ១ របស់ពួកអសញ្ញសត្វ ។ ឯបុរេជាត គឺព្រះអរហន្ត ( ពិចារណាឃើញ ) នូវចក្ខុ ថាមិនទៀង ។បេ។ នូវសោតៈ ។បេ។ នូវវត្ថុ ថាមិនទៀង ។បេ។ ឃើញរូបដោយទិព្វចក្ខុ ឮសំឡេង ដោយទិព្វសោតធាតុ ។បេ។ វត្ថុ ជាបច្ច័យនៃពួកនេវវិបាកនវិបាកធម្មធម្មក្ខន្ធ ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកនេវវិបាកនវិបាកធម្មធម្មក្ខន្ធ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ កពឡិង្ការាហារ ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ ។ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប

ដោយអត្ថិប្បច្ច័យ ។ នៅវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺវត្ថុជាបច្ច័យនៃពួកវិបាកក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ដោយអត្ថិប្បច្ច័យ ។ ឯបុរេជាត គឺពួកសេក្ខបុគ្គលក្តី ពួកបុថុជ្ជនក្តី ( ពិចារណាឃើញ ) នូវចក្ខុ ជាមិនទៀង ។បេ។ រមែងត្រេកអរ រាគៈប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង ។បេ។ ទោមនស្ស កើតឡើង កាលបើកុសល និងអកុសល រលត់ហើយ វិបាក ( កើតឡើង ) ព្រោះអំពើនោះ ជាអារម្មណ៍ ... នូវសោតៈ ... ។បេ។ នូវវត្ថុ ... វិបាក ( កើតឡើង ) ព្រោះអំពើនោះ ជាអារម្មណ៍ ... រូបាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ។បេ។ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយ-វិញ្ញាណ ចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យនៃពួកវិបាកក្ខន្ធ ដោយអត្ថិប្បច្ច័យ ។ នៅវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត គឺពួកសេក្ខបុគ្គលក្តី ពួកបុថុជ្ជនក្តី ( ពិចា-រណាឃើញ ) នូវចក្ខុ ជាមិនទៀង ។បេ។ រមែងត្រេកអរ ។បេ។ ទោមនស្សកើតឡើង នូវសោតៈ ... នូវវត្ថុ ជាមិនទៀង ។បេ។ ទោមនស្ស កើតឡើង ដោយទិព្វចក្ខុ ។បេ។ វត្ថុ ជាបច្ច័យនៃពួកវិបាកធម្មធម្មក្ខន្ធ ដោយអត្ថិប្បច្ច័យ ។

[ ១៦៦ ] វិបាកធម៌ក្តី នៅវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យនៃវិបាកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺខន្ធ

១ ដែលប្រឡំដោយចក្ខុវិញ្ញាណក្តី ចក្ខាយតនៈក្តី ( ជាបច្ច័យ ) នៃខន្ធ ៣ ។បេ។ វិបាកក្ខន្ធ ១ ដែលប្រឡំដោយកាយវិញ្ញាណក្តី វត្ថុក្តី ( ជាបច្ច័យ ) នៃខន្ធ ៣ វិបាកក្ខន្ធ ១ ក្តី វត្ថុក្តី ( ជាបច្ច័យ ) នៃខន្ធ ៣ ក្នុងខណៈនៃបដិសន្ធិ ។ វិបាកធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺពួកវិបាកក្ខន្ធក្តី ពួកមហាភូតក្តី ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ពួកវិបាកក្ខន្ធក្តី មហាភូតក្តី ជាបច្ច័យនៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកវិបាកក្ខន្ធក្តី កពឡិង្ការាហារក្តី ( ជាបច្ច័យ ) នៃកាយនេះ ។ ឯបច្ឆាជាត គឺពួកវិបាកក្ខន្ធក្តី រូបជីវិតិន្ទ្រិយក្តី ( ជាបច្ច័យ ) នៃពួកកដត្តារូប ។

[ ១៦៧ ] វិបាកធម្មធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យនៃវិបាកធម្មធម៌ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺវិបាកធម្មធម្មក្ខន្ធ ១ ក្តី វត្ថុក្តី ( ជាបច្ច័យ ) នៃខន្ធ ៣ ។ វិបាកធម្មធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺពួកវិបាកធម្មធម្មក្ខន្ធក្តី ពួកមហាភូតក្តី ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ។ ឯបច្ឆាជាត គឺពួកវិបាកធម្មធម្មក្ខន្ធក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺ

ពួកវិបាកធម្មធម្មក្ខន្ធក្តី រូបជីវិតិន្ទ្រិយក្តី ( ជាបច្ច័យ ) នៃពួកកដត្តារូប ។ វិបាកធម៌ គឺនត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ប្រហែលគ្នានឹងអនន្តរប្បច្ច័យ អវិគតប្បច្ច័យ ប្រហែលគ្នានឹងអត្ថិប្បច្ច័យ ។

[ ១៦៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១០ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសហជាតប្បច្ច័យ មានវារៈ ១១ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៧ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៧ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៧ ក្នុងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

[ ១៦៩ ] ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ... ក្នុងសហជាតប្បច្ច័យ មានវារៈ ៧ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ

៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

ការរាប់ជាអនុលោមនូវបញ្ហាវារៈ ក្នុងកុសលត្តិកៈ ដែលលោកបានរាប់ហើយយ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនោះចុះ ។

## អនុលោម ចប់

[ ១៧០ ] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយសហជាតប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ វិបាកធម៌ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ វិបាកធម៌ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយសហជាតប្បច្ច័យ ... ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។ វិបាកធម៌ជាបច្ច័យនៃវិបាកធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយសហជាតប្បច្ច័យ ។

[ ១៧១ ] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយសហជាតប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ វិបាកធម្មធម៌ជាបច្ច័យនៃវិបាកធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយកម្មប្បច្ច័យ ។ វិបាកធម្មធម៌ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយសហ-ជាតប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយបច្ឆា-

ជាតប្បច្ច័យ ... ជាបច្ច័យដោយកម្មប្បច្ច័យ ។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយកម្មប្បច្ច័យ ។ វិបាក-ធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយសហជាតប្បច្ច័យ ។

[ ១៧២ ] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្ម-ធម៌ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយសហជាតប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយបុរេជាតប្បច្ច័យ ... ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ... ជាបច្ច័យដោយអាហារប្បច្ច័យ ... ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយសហជាតប្បច្ច័យ ... ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ នេវវិបាកនវិបាក-ធម្មធម៌ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។

[ ១៧៣ ] វិបាកធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ( ជាបច្ច័យ ) នៃវិបាកធម៌ បានដល់ សហជាត និងបុរេជាត ។ វិបាកធម៌ក្តី នេវវិបាក-នវិបាកធម្មធម៌ក្តី ( ជាបច្ច័យ ) នៃនេវវិបាកនវិបាកធម្មធម៌ បានដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។

[ ១៧៤ ] វិបាកធម្មធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ( ជាបច្ច័យ ) នៃវិបាកធម្មធម៌ បានដល់ សហជាត និងបុរេជាត ។ វិបាកធម្មធម៌ក្តី

នៅវិបាកនវិបាកធម្មធម៌ក្តី ( ជាបច្ច័យ ) នៃនេវវិបាកនវិបាកធម្មធម៌ បាន ដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។

[ ១៧៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១៦ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១៦ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១៦ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ១៦ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ១៦ ក្នុងនសហជាតប្បច្ច័យ មានវារៈ ១២ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ១២ ក្នុងននិស្សយប្បច្ច័យ មានវារៈ ១២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ១៦ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១៤ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១៦ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១៦ ក្នុងនកម្មប្បច្ច័យ មានវារៈ ១៥ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១៤ ក្នុងនអាហារប្បច្ច័យ មានវារៈ ១៦ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១៦ ក្នុងនឈានប្បច្ច័យ មានវារៈ ១៦ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១៦ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១០ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ១០ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១៦ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១៦ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ១០ ។

[ ១៧៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១៦ ព្រោះនហេតុប្បច្ច័យ ។ សេចក្តីបង្រួញ ។ ... ក្នុងនោវិគតប្បច្ច័យ មានវារៈ ១០ ។ ដែលបណ្ឌិតគប្បីឲ្យពិស្តារដូចជាការរាប់នូវបច្ចនីយៈ ក្នុងកុសលត្តិកៈ ដែលលោកឲ្យពិស្តារហើយដែរ ។

**បច្ចនីយៈ ចប់**

[ ១៧៧ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៧ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៧ ក្នុងនកម្មប្បច្ច័យ មានវារៈ ៧ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងនអាហារប្បច្ច័យ មានវារៈ ៧ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងនឈានប្បច្ច័យ មានវារៈ ៧ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៧ ។

[ ២៨៤ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសេចក្តីសុខប្រព្រឹត្តទៅក្នុងកាយ ហើយឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ធ្វើឈានឲ្យ

កើត ធ្វើវិបស្សនាឲ្យកើត ធ្វើអភិញ្ញាឲ្យកើត ធ្វើសមាបត្តិឲ្យកើត សម្លាប់សត្វ បំបែកសង្ឃ បុគ្គលអាស្រ័យសេចក្តីទុក្ខប្រព្រឹត្តទៅក្នុងកាយ ... រដូវ ... បុគ្គលអាស្រ័យភោជន ហើយឲ្យទាន បំបែកសង្ឃ សេចក្តីសុខប្រព្រឹត្តទៅក្នុងកាយ ... សេចក្តីទុក្ខប្រព្រឹត្តទៅក្នុងកាយ រដូវ ... ភោជន ជាបច្ច័យនៃអនុបាទិន្នុបាទានិយសទ្ធា នៃសីល សុតៈ ចាគៈ បញ្ញា រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ និងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។

[ ២៨៥ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នអនុបាទានិយធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យសេចក្តីសុខប្រព្រឹត្តទៅក្នុងកាយ ហើយធ្វើមគ្គឲ្យកើត ចូលកាន់ផលសមាបត្តិ អាស្រ័យសេចក្តីទុក្ខប្រព្រឹត្តទៅក្នុងកាយ ... រដូវ ... អាស្រ័យភោជន ហើយធ្វើមគ្គឲ្យកើត ចូលកាន់ផលសមាបត្តិ ។ សេចក្តីសុខប្រព្រឹត្តទៅក្នុងកាយ ... សេចក្តីទុក្ខប្រព្រឹត្តទៅក្នុងកាយ ... រដូវ ... ភោជន ជាបច្ច័យនៃមគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ២៨៦ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យអនុបាទិន្នុបាទានិយ-សទ្ធា ហើយឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ធ្វើឈានឲ្យកើត ធ្វើវិបស្សនាឲ្យកើត ធ្វើអភិញ្ញាឲ្យកើត ធ្វើសមាបត្តិឲ្យកើត សម្លាប់សត្វ បំបែកសង្ឃ ដំឡើងមានះ ប្រកាន់ទិដ្ឋិ បុគ្គលអាស្រ័យអនុបាទិន្នុបាទានិយ-

សីល ... សុតៈ ចាគៈ បញ្ញា រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ សេចក្តីប្រាថ្នា រដូវ និងភោជន ... អាស្រ័យសេនាសនៈ ហើយឲ្យទាន ធ្វើសមាបត្តិឲ្យកើត សម្លាប់សត្វ បំបែកសង្ឃ ដំឡើងមានះ ប្រកាន់ទិដ្ឋិ អនុបាទិន្នុបាទានិយសទ្ធា ... សីលៈ សុតៈ ចាគៈ បញ្ញា រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ សេចក្តីប្រាថ្នា រដូវ ភោជន ... សេនាសនៈ ជាបច្ច័យនៃអនុបាទិន្នុបាទានិយសទ្ធា ... នៃសីលៈ សុតៈ ចាគៈ បញ្ញា រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ ... នៃសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃបឋមជ្ឈាន ជាបច្ច័យនៃបឋមជ្ឈាន បរិកម្មនៃនេវសញ្ញានាសញ្ញាយតនជ្ឈាន ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនជ្ឈាន ឈានទី ១ ជាបច្ច័យនៃឈានទី ២ អាកិញ្ចញ្ញាយតនៈ ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនៈ បាណាតិបាត ជាបច្ច័យនៃបាណាតិបាត និយតមិច្ឆាទិដ្ឋិ ជាបច្ច័យនៃនិយតមិច្ឆាទិដ្ឋិ ។

[ ២៨៧ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យអនុបាទិន្នុបាទានិយសទ្ធា ហើយធ្វើខ្លួនឲ្យក្តៅ ឲ្យក្តៅសព្វ រមែងរងទុក្ខ ដែលមានការស្វែងរកជាមូល អាស្រ័យអនុបាទិន្នុបាទានិយសីល ... ។ សេចក្តីបន្រ្ទញ ។ ... បុគ្គលអាស្រ័យសេនាសនៈ ហើយធ្វើខ្លួនឲ្យក្តៅ ឲ្យក្តៅសព្វ រមែងរងទុក្ខ ដែលមានការស្វែងរកជាមូល អនុបាទិន្នុបាទានិយសទ្ធា ... ។ សេចក្តីបន្រ្ទញ ។ សេនាសនៈ ជាបច្ច័យនៃសេចក្តីសុខប្រព្រឹត្តទៅក្នុងកាយ និងសេចក្តីទុក្ខប្រព្រឹត្តទៅក្នុងកាយ ដោយ

ឧបនិស្សយប្បច្ច័យ កុសល និងអកុសលកម្ម ជាបច្ច័យនៃវិបាក ដោយឧបនិស្សយប្បច្ច័យ ។

[ ២៨៨ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នអនុបាទានិយធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបរិកម្មនៃមគ្គទី ១ ជាបច្ច័យនៃមគ្គទី ១ ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃមគ្គទី ២ មគ្គទី ៣ និងមគ្គទី ៤ ជាបច្ច័យនៃមគ្គទី ៤ ដោយឧបនិស្សយប្បច្ច័យ ។

[ ២៨៩ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នអនុបាទានិយធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺមគ្គទី ១ ជាបច្ច័យនៃមគ្គទី ២ ដោយឧបនិស្សយប្បច្ច័យ មគ្គទី ២ ជាបច្ច័យនៃមគ្គទី ៣ មគ្គទី ៣ ជាបច្ច័យនៃមគ្គទី ៤ មគ្គជាបច្ច័យនៃផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ២៩០ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺផលសមាបត្តិ ជាបច្ច័យនៃសេចក្តីសុខប្រព្រឹត្តទៅក្នុងកាយ ដោយឧបនិស្សយប្បច្ច័យ ។

[ ២៩១ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ និងបកតូបនិស្ស័យ ។

បកតូបនិស្ស័យ គឺពួកព្រះអរិយៈអាស្រ័យមគ្គ ហើយធ្វើសមាបត្តិដែលមិនទាន់កើត ឲ្យកើតឡើង ចូលកាន់សមាបត្តិដែលកើតឡើង ហើយពិចារណាឃើញច្បាស់នូវសង្ខារទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន មគ្គជាបច្ច័យនៃអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិ-សម្ភិទា និងឋានាឋានកោសល្លរបស់ពួកព្រះអរិយៈ ដោយឧបនិស្សយប្បច្ច័យ ។

[ ២៩២ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺពួកសេក្ខបុគ្គលក្តី ពួកបុថុជ្ជនក្តី ពិចារណាឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន រមែងត្រេកអរ រីករាយ រាគៈប្រារព្ធនូវចក្ខុនេះ ទើបកើតឡើង ទោមនស្សកើតឡើង កាលបើកុសល និងអកុសលរលត់ហើយ វិបាកក៏កើតឡើង ព្រោះអំពើនោះជាអារម្មណ៍ ( ពួកសេក្ខបុគ្គល និងបុថុជ្ជន ) ពិចារណាឃើញច្បាស់នូវសោតៈ ... ឃានៈ ជិវ្ហា កាយ ... នូវឧបាទិន្នុបាទានិយរូបទាំងឡាយ ... ក្លិន ... រស ... ផោដ្ឋព្វៈ ... នូវវត្ថុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន រមែងត្រេកអរ រីករាយ រាគៈប្រារព្ធនូវវត្ថុនោះ ទើបកើតឡើង ទោមនស្សកើតឡើង កាលបើកុសល និងអកុសលរលត់ហើយ វិបាកក៏កើតឡើង ព្រោះអំពើនោះជាអារម្មណ៍ រូបាយតនៈ ជាឧបាទិន្នុបាទានិយៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ គន្ធាយតនៈ ជាឧបាទិន្នុបាទានិយៈ ... រសាយតនៈ ... ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជា-តប្បច្ច័យ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ កាយា-

យតនៈ ជាបច្ច័យនៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ដោយបុរេជាតប្បច្ច័យ ។

[ ២៩៣ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺ ( ពួកសេក្ខបុគ្គល និងបុថុជ្ជន ) ពិចារណាឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន រមែងត្រេកអរ រីករាយ រាគៈប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង ទោមនស្សកើតឡើង ( ពួកសេក្ខបុគ្គល និងបុថុជ្ជន ) ពិចារណាឃើញច្បាស់នូវសោតៈ ... នូវវត្ថុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន រមែងត្រេកអរ រីករាយ រាគៈប្រារព្ធនូវវត្ថុនោះ ទើបកើតឡើង ទោមនស្សកើតឡើង ( ពួកព្រះអរិយៈ ) ឃើញនូវឧបាទិន្នុបាទានិយរូប ដោយទិព្វចក្ខុ ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃអនុបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ដោយបុរេជាតប្បច្ច័យ ។

[ ២៩៤ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នអនុបាទានិយធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ វត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃអនុបាទិន្នអនុបាទានិយក្ខន្ធទាំងឡាយ ដោយបុរេជាតប្បច្ច័យ ។

[ ២៩៥ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត គឺបុគ្គលឃើញច្បាស់នូវអនុបាទិន្នុបាទានិយរូបទាំងឡាយ ... សំឡេង ... ក្លិន ... រស ... ផោដ្ឋព្វៈ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន រមែងត្រេកអរ រីករាយ រាគៈ ប្រារព្ធនូវ

ផោដ្ឋព្វៈនោះ ទើបកើតឡើង ទោមនស្សកើតឡើង ( បុគ្គល ) ឃើញនូវអនុបាទិន្នុបាទានិយរូបដោយទិព្វចក្ខុ ឮសំឡេងដោយទិព្វសោតធាតុ ។

[ ២៩៦ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត គឺបុគ្គលឃើញច្បាស់នូវអនុបាទិន្នុបាទានិយរូបទាំងឡាយ ... សំឡេង ... ក្លិន ... រស ... ផោដ្ឋព្វៈ ជាមិនទៀង ជាទុក្ខ មិនមែនខ្លួន រមែងត្រេកអរ រីករាយ រាគៈ ប្រារព្ធនូវផោដ្ឋព្វៈទាំងនោះ ទើបកើតឡើង ទោមនស្សកើតឡើង កាលបើកុសល និងអកុសល រលត់ហើយ វិបាកក៏កើតឡើង ព្រោះអំពើនោះ ជាអារម្មណ៍ រូបាយតនៈជាអនុបាទិន្នុបាទានិយៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។

[ ២៩៧ ] ឧបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នុបាទានិយធម៌ក្តី ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ រូបាយតនៈ ជាអនុបាទិន្នុបាទានិយៈក្តី ចក្ខាយតនៈក្តី ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ សេចក្តីបង្រួញ ។ ផោដ្ឋព្វាយតនៈ ជាអនុបាទិន្នុបាទានិយៈក្តី កាយាយតនៈក្តី ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ រូបាយតនៈ ជាអនុបាទិន្នុបាទានិយៈក្តី វត្ថុក្តី ជាបច្ច័យនៃឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ដោយបុរេជាតប្បច្ច័យ ។ សេចក្តីបង្រួញ ។ ផោដ្ឋព្វាយតនៈ ជាអនុបាទិន្នុបាទានិយៈក្តី វត្ថុក្តី ជាបច្ច័យនៃឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ដោយបុរេជាតប្បច្ច័យ ។

[ ២៩៨ ] ឧបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នុបាទានិយធម៌ក្តី ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ រូបាយតនៈ ជាអនុបាទិន្នុបាទានិយៈក្តី វត្ថុក្តី ជាបច្ច័យនៃអនុបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ដោយបុរេជាតប្បច្ច័យ ។ សេចក្តីបង្រួញ ។ ផោដ្ឋព្វាយតនៈ ជាអនុបាទិន្នុបាទានិយៈក្តី វត្ថុក្តី ជាបច្ច័យនៃអនុបាទិន្នុ-បាទានិយក្ខន្ធទាំងឡាយ ដោយបុរេជាតប្បច្ច័យ ។

[ ២៩៩ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃឧបាទិន្នុបាទានិយកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៣០០ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃអនុបាទិន្នុបាទានិយកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៣០១ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃឧបាទិន្នុបាទានិយកាយនេះផង នៃអនុបាទិន្នុបាទានិយកាយនេះផង ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៣០២ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺអនុបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃអនុបាទិន្នុបាទានិយកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៣០៣ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺអនុបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃឧបាទិន្នុបាទានិយកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៣០៤ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺ អនុបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃឧបាទិន្នុបាទានិយកាយនេះផង នៃអនុបាទិន្នុបាទានិយកាយនេះផង ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៣០៥ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃឧបាទិន្នុបាទានិយកាយនេះ ដែលកើតមុន ដោយបច្ឆា-ជាតប្បច្ច័យ ។

[ ៣០៦ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃអនុបាទិន្នុបាទានិយកាយនេះដែលកើតមុន ដោយបច្ឆា-ជាតប្បច្ច័យ ។

[ ៣០៧ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃឧបាទិន្នុបាទានិយកាយនេះផង នៃអនុបាទិន្នុបាទានិយកាយនេះផងដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៣០៨ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយអាសេវនប្បច្ច័យ បានដល់ អនុបាទិន្នុបាទានិយក្ខន្ធទាំងឡាយមុនៗ ជាបច្ច័យនៃអនុបាទិន្នុបាទានិយក្ខន្ធទាំងឡាយក្រោយៗ ដោយអាសេវនប្បច្ច័យ អនុលោម ជាបច្ច័យនៃគោត្រភូ អនុលោម ជាបច្ច័យនៃវោទានៈ ដោយអាសេវនប្បច្ច័យ ។

[ ៣០៩ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នអនុបាទានិយធម៌ ដោយអាសេវនប្បច្ច័យ គឺគោត្រភូជាបច្ច័យនៃមគ្គ វោទានៈ ជាបច្ច័យនៃមគ្គ ដោយអាសេវនប្បច្ច័យ ។

[ ៣១០ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយកម្មប្បច្ច័យ គឺឧបាទិន្នុបាទានិយចេតនាជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ឧបាទិន្នុបាទានិយចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយកម្មប្បច្ច័យ ចេតនាជាបច្ច័យនៃវត្ថុ ដោយកម្មប្បច្ច័យ ។

[ ៣១១ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយកម្មប្បច្ច័យ គឺឧបាទិន្នុបាទានិយចេតនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។ ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយកម្មប្បច្ច័យ គឺឧបាទិន្នុបាទានិយ-ចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។

[ ៣១២ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយកម្មប្បច្ច័យ គឺអនុបាទិន្នុបាទានិយចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។

[ ៣១៣ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយកម្មប្បច្ច័យ បានដល់ នានាខណិកៈ គឺអនុបាទិន្នុបាទានិយចេតនា ជាបច្ច័យនៃពួកឧបាទិន្នុបាទានិយក្ខន្ធ ជាវិបាកផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ៣១៤ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នអនុបាទានិយធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺអនុបាទិន្នអនុបាទានិយចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺអនុបាទិន្នអនុបាទានិយកុសលចេតនា ជាបច្ច័យនៃពួកអនុបាទិន្នអនុបាទានិយក្ខន្ធ ជាវិបាក ដោយកម្មប្បច្ច័យ ។

[ ៣១៥ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយកម្មប្បច្ច័យ គឺអនុបាទិន្នអនុបាទានិយចេតនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។

[ ៣១៦ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នអនុបាទានិយធម៌ផង ដោយកម្មប្បច្ច័យ គឺអនុបាទិន្នអនុបាទានិយចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។

[ ៣១៧ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយវិបាកប្បច្ច័យ គឺឧបាទិន្នុបាទានិយក្ខន្ធ ១ ជាវិបាក ជាបច្ច័យនៃខន្ធ ៣ ដោយវិបាកប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយវិបាកប្បច្ច័យ ឧបា-ទិន្នុបាទានិយក្ខន្ធ ១ ជាវិបាក ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយវិបាកប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង នៃពួកកដត្តារូបផង ដោយវិបាកប្បច្ច័យ ខន្ធទាំងឡាយជាបច្ច័យនៃវត្ថុ ដោយវិបាកប្បច្ច័យ ។

[ ៣១៨ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយវិបាកប្បច្ច័យ គឺឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយជាវិបាក ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិបាកប្បច្ច័យ ។

[ ៣១៩ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយវិបាកប្បច្ច័យ គឺឧបាទិន្នុបាទានិយក្ខន្ធ ១ ជាវិបាក ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយវិបា-កប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយវិបាកប្បច្ច័យ ។

[ ៣២០ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នអនុបា-ទានិយធម៌ ដោយវិបាកប្បច្ច័យ គឺអនុបាទិន្នអនុបាទានិយក្ខន្ធ ១ ជាវិបាក ជាបច្ច័យនៃខន្ធ ៣ ដោយវិបាកប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយវិបាកប្បច្ច័យ ។

[ ៣២១ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយវិបាកប្បច្ច័យ គឺអនុបាទិន្នអនុបាទានិយក្ខន្ធទាំងឡាយ ជាវិបាក ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិបាកប្បច្ច័យ ។

[ ៣២២ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នអនុបាទានិយធម៌ផង ដោយវិបាកប្បច្ច័យ គឺអនុបាទិន្នអនុ-បាទានិយក្ខន្ធ ១ ជាវិបាក ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយវិបាកប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង នៃពួកចិត្ត-សមុដ្ឋានរូបផង ដោយវិបាកប្បច្ច័យ ។

[ ៣២៣ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយអាហារប្បច្ច័យ គឺពួកអាហារ ជាឧបាទិន្នុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអាហារប្បច្ច័យ ពួកអាហារជាឧបាទិន្នុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយអាហារប្បច្ច័យ កពឡិង្ការាហារ ជាឧបាទិន្នុបាទានិយៈ ជាបច្ច័យនៃកាយ ជាឧបាទិន្នុបាទានិយៈ ដោយអាហារប្បច្ច័យ ។

[ ៣២៤ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយអាហារប្បច្ច័យ គឺពួកអាហារ ជាឧបាទិន្នុបាទានិយៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអាហារប្បច្ច័យ កពឡិង្ការាហារ ជាឧបាទិន្នុបាទានិយៈ ជាបច្ច័យនៃកាយ ជាអនុបាទិន្នុបាទានិយៈ ដោយអាហារប្បច្ច័យ ។

[ ៣២៥ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង

នៃអនុបាទិន្នុបាទានិយធម៌ផង ដោយអាហារប្បច្ច័យ គឺពួកអាហារ ជាឧបា-ទិន្នុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ កពឡិង្ការាហារ ជាឧបាទិន្នុបាទានិយៈ ជាបច្ច័យនៃកាយ ជាឧបាទិន្នុបាទានិយៈផង ជាអនុបាទិន្នុបាទានិយៈផង ដោយអាហា-រប្បច្ច័យ ។

[ ៣២៦ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយអាហារប្បច្ច័យ គឺអាហារ ជាអនុបាទិន្នុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ កពឡិង្ការាហារ ជាអនុបាទិន្នុបាទានិយៈ ជាបច្ច័យនៃកាយ ជាអនុបាទិន្នុ-បាទានិយៈ ដោយអាហារប្បច្ច័យ ។

[ ៣២៧ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយអាហារប្បច្ច័យ គឺកពឡិង្ការាហារ ជាអនុបាទិន្នុបាទានិយៈ ជាបច្ច័យនៃកាយ ជាឧបាទិន្នុបាទានិយៈ ដោយអាហារប្បច្ច័យ ។

[ ៣២៨ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយអាហារប្បច្ច័យ គឺកពឡិង្ការាហារ ជាអនុបាទិន្នុបាទានិយៈ ជាបច្ច័យនៃកាយ ជាឧបាទិន្នុបាទានិយៈផង ជាអនុបា-ទិន្នុបាទានិយៈផង ដោយអាហារប្បច្ច័យ ។

[ ៣២៩ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នអនុបាទា-និយធម៌ ដោយអាហារប្បច្ច័យ គឺអាហារ ជាអនុបាទិន្នអនុបាទានិយៈ ជា

បច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអាហារប្បច្ច័យ ។

[ ៣៣០ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយអាហារប្បច្ច័យ គឺអាហារ ជាអនុបាទិន្នអនុបាទានិយៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអាហារប្បច្ច័យ ។

[ ៣៣១ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នអនុបាទានិយធម៌ផង ដោយអាហារប្បច្ច័យ គឺអាហារ ជាអនុបាទិន្នអនុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្ត-សមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ ។

[ ៣៣២ ] ឧបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នុបាទានិយធម៌ក្តី ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយអាហារប្បច្ច័យ គឺកពឡិង្ការាហារ ជាឧបាទិន្នុ-បាទានិយៈក្តី ជាអនុបាទិន្នុបាទានិយៈក្តី ជាបច្ច័យនៃកាយ ជាឧបាទិន្នុ-បាទានិយៈ ដោយអាហារប្បច្ច័យ ។

[ ៣៣៣ ] ឧបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នុបាទានិយធម៌ក្តី ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយអាហារប្បច្ច័យ គឺកពឡិង្ការាហារ ជាឧបាទិន្នុបាទានិយៈក្តី ជាអនុបាទិន្នុបាទានិយៈក្តី ជាបច្ច័យនៃកាយ ជាអនុបា-ទិន្នុបាទានិយៈ ដោយអាហារប្បច្ច័យ ។

[ ៣៣៤ ] ឧបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នុបាទានិយធម៌ក្តី ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយអាហារប្បច្ច័យ គឺកពឡិង្ការាហារ ជាឧបាទិន្នុបាទានិយៈក្តី ជាអនុបាទិន្នុបាទានិយៈក្តី ជាបច្ច័យ

នៃកាយ ជាឧបាទិន្នុបាទានិយៈផង ជាអនុបាទិន្នុបាទានិយផង ដោយអាហារប្បច្ច័យ ។

[ ៣៣៥ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយ ជាឧបាទិន្នុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយឥន្ទ្រិយប្បច្ច័យ ពួកឥន្ទ្រិយ ជាឧបាទិន្នុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយឥន្ទ្រិយប្បច្ច័យ ចក្ខុន្ទ្រិយ ជាបច្ច័យនៃចក្ខុវិញ្ញាណ កាយិន្ទ្រិយ ជាបច្ច័យនៃកាយវិញ្ញាណ រូបជីវិតិន្ទ្រិយជាបច្ច័យនៃពួកកដត្តារូប ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៣៣៦ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយ ជាឧបាទិន្នុបាទានិយៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៣៣៧ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយ ជាឧបាទិន្នុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៣៣៨ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយ ជាអនុបាទិន្នុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៣៣៩ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នអនុបាទា-

និយធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយ ជាអនុបាទិន្នុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៣៤០ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយ ជាអនុបាទិន្នអនុបាទានិយៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៣៤១ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នអនុបាទានិយធម៌ផង ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយ ជាអនុបាទិន្នអនុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្ត-សមុដ្ឋានរូបផង ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៣៤២ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយឈានប្បច្ច័យ គឺអង្គឈានទាំងឡាយ ជាឧបាទិន្នុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយឈានប្បច្ច័យ អង្គឈានទាំងឡាយ ជាឧបា-ទិន្នុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយឈានប្បច្ច័យ ។

[ ៣៤៣ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយឈានប្បច្ច័យ គឺអង្គឈានទាំងឡាយ ជាឧបាទិន្នុបាទានិយៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយឈានប្បច្ច័យ ។

[ ៣៤៤ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយឈានប្បច្ច័យ គឺអង្គឈានទាំងឡាយ

ជាឧបាទិន្នុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយឈានប្បច្ច័យ ។

[ ៣៨៥ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយឈានប្បច្ច័យ គឺអង្គឈានទាំងឡាយជាអនុបាទិន្នុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយឈានប្បច្ច័យ ។

[ ៣៨៦ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នអនុបាទានិយធម៌ ដោយឈានប្បច្ច័យ គឺអង្គឈានទាំងឡាយ ជាអនុបាទិន្នអនុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយឈានប្បច្ច័យ ។

[ ៣៨៧ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយឈានប្បច្ច័យ គឺអង្គឈានទាំងឡាយ ជាអនុបាទិន្នអនុបាទានិយៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយឈានប្បច្ច័យ ។

[ ៣៨៨ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នអនុបាទានិយធម៌ផង ដោយឈានប្បច្ច័យ គឺអង្គឈានទាំងឡាយ ជាអនុបាទិន្នអនុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយឈានប្បច្ច័យ ។

[ ៣៨៩ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយមគ្គប្បច្ច័យ គឺអង្គមគ្គទាំងឡាយ ជាឧបាទិន្នុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយមគ្គប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៩០ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌

ដោយមគ្គប្បច្ច័យ គឺអង្គមគ្គទាំងឡាយ ជាឧបាទិន្នុបាទានិយៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយមគ្គប្បច្ច័យ ។

[ ៣៥១ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយមគ្គប្បច្ច័យ គឺអង្គមគ្គទាំងឡាយ ជាឧបាទិន្នុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយមគ្គប្បច្ច័យ ។

[ ៣៥២ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយមគ្គប្បច្ច័យ គឺអង្គមគ្គទាំងឡាយ ជាអនុបាទិន្នុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយមគ្គប្បច្ច័យ ។

[ ៣៥៣ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នអនុបាទានិយធម៌ ដោយមគ្គប្បច្ច័យ គឺអង្គមគ្គទាំងឡាយ ជាអនុបាទិន្នអនុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយមគ្គប្បច្ច័យ ។

[ ៣៥៤ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយមគ្គប្បច្ច័យ គឺអង្គមគ្គទាំងឡាយ ជាអនុបាទិន្នអនុបាទានិយៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយមគ្គប្បច្ច័យ ។

[ ៣៥៥ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នអនុបាទានិយធម៌ផង ដោយមគ្គប្បច្ច័យ គឺអង្គមគ្គទាំងឡាយ ជាអនុបាទិន្នអនុបាទានិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយមគ្គប្បច្ច័យ ។

[ ៣៥៦ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយសម្បយុត្តប្បច្ច័យ គឺឧបាទិន្នុបាទានិយក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ដោយសម្បយុត្តប្បច្ច័យ ខន្ធ ២ ( ជាបច្ច័យ ) នៃខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៥៧ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយសម្បយុត្តប្បច្ច័យ គឺអនុបាទិន្នុបាទានិយក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ដោយសម្បយុត្តប្បច្ច័យ ខន្ធ ២ ( ជាបច្ច័យ ) នៃខន្ធ ២ ។

[ ៣៥៨ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នអនុបាទានិយធម៌ ដោយសម្បយុត្តប្បច្ច័យ គឺអនុបាទិន្នអនុបាទានិយក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ដោយសម្បយុត្តប្បច្ច័យ ខន្ធ ២ ( ជាបច្ច័យ ) នៃខន្ធ ២ ។

[ ៣៥៩ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សហជាត គឺឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ដោយវិប្បយុត្តប្បច្ច័យ ខន្ធទាំងឡាយជាបច្ច័យនៃវត្ថុ ដោយវិប្បយុត្តប្បច្ច័យ វត្ថុ ជាបច្ច័យនៃខន្ធទាំងឡាយ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបុរេជាត គឺចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ ។បេ។ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ វត្ថុជាបច្ច័យនៃឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ជាឧបាទិន្នុបាទានិយៈដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៦០ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សហ-ជាត គឺឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបុរេជាត គឺវត្ថុជាបច្ច័យនៃអនុបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ជាអនុបាទិន្នុបាទានិយៈ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៦១ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នអនុបាទានិយធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុជាបច្ច័យនៃអនុបាទិន្នអនុ-បាទានិយក្ខន្ធទាំងឡាយ ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៦២ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ បច្ឆាជាត គឺឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ជាឧបាទិន្នុបាទានិយៈផង ជាអនុបាទិន្នុបាទានិយៈផង ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៦៣ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺអនុបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺអនុបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ជាអនុបាទិន្នុបាទានិយៈដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៦៤ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ បច្ឆាជាត គឺអនុបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ជាឧបាទិន្នុបាទានិយៈ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៦៥ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ បច្ឆាជាត គឺអនុបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ជាឧបាទិន្នុបាទានិយៈផង ជាអនុបាទិន្នុបាទានិយៈផង ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៦៦ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ បច្ឆាជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ជាឧបាទិន្នុបាទានិយៈដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៦៧ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ជាអនុបាទិន្នុបាទានិយៈ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៦៨ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌

ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ បច្ឆាជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ជាឧបាទិន្នុបាទានិយៈផង ជាអនុបាទិន្នុបាទានិយៈផង ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៦៩ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺឧបាទិន្នុបាទានិយក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយអត្ថិប្បច្ច័យ ឧបាទិន្នុបាទានិយក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង នៃពួកកដត្តារូបផង ដោយអត្ថិប្បច្ច័យ ខន្ធទាំងឡាយ ( ជាបច្ច័យ ) នៃវត្ថុ វត្ថុ ( ជាបច្ច័យ ) នៃខន្ធទាំងឡាយ មហាភូត ១ ... មហាភូតទាំងឡាយ ជាបច្ច័យនៃពួកកដត្តារូប និងឧបាទារូប ដោយអត្ថិប្បច្ច័យ មហាភូត ១ របស់ពួកអសញ្ញសត្វ ... មហាភូតទាំងឡាយ ជាបច្ច័យនៃពួកកដត្តារូប និងឧបាទារូប ដោយអត្ថិប្បច្ច័យ ។ ឯបុរេជាត គឺពួកសេក្ខបុគ្គលក្តី បុថុជ្ជនក្តី ពិចារណាឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន រមែងត្រេកអរ រីករាយ រាគៈប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង ទោមនស្ស កើតឡើង កាលបើកុសល និងអកុសលរលត់ហើយ វិបាកក៏កើតឡើង ព្រោះអំពើនោះ ជាអារម្មណ៍ ( ពួកសេក្ខបុគ្គល និងបុថុជ្ជន ) ពិចារណាឃើញច្បាស់នូវសោតៈ ... ឃានៈ ជិវ្ហាកាយ ឧបាទិន្នុបាទានិយរូបទាំងឡាយ ក្លិន រស ផោដ្ឋព្វៈ ... នូវវត្ថុ ថា

មិនទៀង ជាទុក្ខ មិនមែនខ្លួន រមែងត្រេកអរ រីករាយ រាគៈ ប្រារព្ធនូវវត្ថុនោះ ទើបកើតឡើង ទោមនស្សកើតឡើង កាលបើកុសល និងអកុសលរលត់ហើយ វិបាកក៏កើតឡើង ព្រោះអំពើនោះជាអារម្មណ៍ រូបាយតនៈ ជាឧបាទិន្នុបាទានិយៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ គន្ធាយតនៈ ជាឧបាទិន្នុបាទានិយៈ ... រសាយតនៈ ... ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ។បេ។ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យនៃឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ជាឧបាទិន្នុបាទានិយៈដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ កពឡិង្ការាហារ ជាឧបាទិន្នុបាទានិយៈ ជាបច្ច័យនៃកាយ ជាឧបាទិន្នុបាទានិយៈ ដោយអត្ថិប្បច្ច័យ ។ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។

[ ៣៧០ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត និងអាហារ ។ សហជាត គឺឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ ឯបុរេជាត គឺពួកបុគ្គលពិចារណាឃើញច្បាស់នូវចក្ខុជាមិនទៀង ជាទុក្ខ មិនមែនខ្លួន រមែងត្រេកអរ រីករាយ រាគៈ ប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង ទោមនស្ស កើតឡើង ( ពួកបុគ្គល ) ពិចារណាឃើញច្បាស់នូវសោតៈ ... ឃានៈ ជិវ្ហា កាយ ឧបាទិន្នុបាទានិយរូបទាំង

ឡាយ ក្លិន រស ផោដ្ឋព្វៈ ... នូវវត្ថុ ជាមិនទៀង ជាទុក្ខ មិនមែនខ្លួន រមែងត្រេកអរ រីករាយ រាគៈប្រារព្ធនូវវត្ថុនោះ ទើបកើតឡើង ទោមនស្ស កើតឡើង ( បុគ្គល ) ឃើញនូវឧបាទិន្នុបាទានិយរូប ដោយទិព្វចក្ខុ វត្ថុជាបច្ច័យនៃអនុបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ជាអនុបាទិន្នុបាទានិយៈ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ កពឡិង្ការាហារ ជាឧបាទិន្នុបាទានិយៈ ជាបច្ច័យនៃកាយ ជាអនុបាទិន្នុបាទានិយៈ ដោយអត្ថិប្បច្ច័យ ។

[ ៣៧១ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នអនុបាទានិយធម៌ ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុជាបច្ច័យនៃអនុបាទិន្នអនុបាទា-និយក្ខន្ធទាំងឡាយ ដោយអត្ថិប្បច្ច័យ ។

[ ៣៧២ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បច្ឆា-ជាត និងអាហារ ។ សហជាត គឺឧបាទិន្នុបាទានិយក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ជាឧបាទិន្នុបាទានិយៈផង ជាអនុបាទិន្នុបាទានិយៈផង ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ កពឡិង្ការាហារ ជាឧបាទិន្នុបាទានិយៈ ជាបច្ច័យនៃកាយ ជាឧបាទិន្នុ-បាទានិយៈផង ជាអនុបាទិន្នុបាទានិយៈផង ដោយអត្ថិប្បច្ច័យ ។

[ ៣៧៣ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត និងអាហារ ។ សហជាត គឺអនុបាទិន្នុបាទានិយក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ មហាភូត ១ ជាបច្ច័យនៃមហាភូត ៣ មហាភូតទាំងឡាយ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ឧបាទារូប ដោយអត្ថិប្បច្ច័យ ពាហិររូប ... អាហារសមុដ្ឋានរូប ... មហាភូត ១ មានរដូវជាសមុដ្ឋាន ។ ឯបុរេជាត គឺបុគ្គលពិចារណាឃើញច្បាស់នូវអនុបាទិន្នុបាទានិយរូបទាំងឡាយ ... សំឡេង ក្លិន រស ... នូវផោដ្ឋព្វៈ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន រមែងត្រេកអរ រីករាយ រាគៈប្រារព្ធនូវផោដ្ឋព្វៈនោះ ទើបកើតឡើង ទោមនស្សកើតឡើង បុគ្គលឃើញនូវអនុបាទិន្នុបាទានិយរូប ដោយទិព្វចក្ខុ ស្តាប់សំឡេងដោយទិព្វសោតធាតុ ។ ឯបច្ឆាជាត គឺអនុបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ជាអនុបាទិន្នុបាទានិយៈ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ កពឡិង្ការាហារ ជាអនុបាទិន្នុបាទានិយៈ ជាបច្ច័យនៃកាយ ជាអនុបាទិន្នុបាទានិយៈ ដោយអត្ថិប្បច្ច័យ ។

[ ៣៧៤ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត បច្ឆាជាត និងអាហារ ។ បុរេជាត គឺបុគ្គលពិចារណាឃើញច្បាស់នូវអនុបាទិន្នុបាទានិយរូបទាំងឡាយ ... សំឡេង ក្លិន រស ... នូវផោដ្ឋព្វៈ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន រមែងត្រេកអរ

វិការយ ភាគៈប្រារព្ធនូវផោដ្ឋព្វៈនោះ ទើបកើតឡើង ទោមនស្សកើតឡើង កាលបើកុសល និងអកុសល រលត់ហើយ វិបាកក៏កើតឡើង ព្រោះអំពើនោះជាអារម្មណ៍ រូបាយតនៈជាអនុបាទិន្នុបាទានិយៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺអនុបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ជាឧបាទិន្នុបាទានិយៈ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ កពឡិង្ការាហារ ជាអនុបាទិន្នុបាទានិយៈ ជាបច្ច័យនៃកាយ ជាឧបាទិន្នុបាទានិយៈ ដោយអត្ថិប្បច្ច័យ ។

[ ៣៧៥ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ បច្ឆាជាត និងអាហារ ។ បច្ឆាជាត គឺអនុបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ជាឧបាទិន្នុបាទានិយៈផង ជាអនុបាទិន្នុបាទានិយៈផង ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ កពឡិង្ការាហារ ជាអនុបាទិន្នុបាទានិយៈ ជាបច្ច័យនៃកាយជាឧបាទិន្នុបាទានិយៈផង ជាអនុបាទិន្នុបាទានិយៈផង ដោយអត្ថិប្បច្ច័យ ។

[ ៣៧៦ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នអនុបាទានិយធម៌ ដោយអត្ថិប្បច្ច័យ គឺអនុបាទិន្នអនុបាទានិយក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយអត្ថិប្បច្ច័យ ។

[ ៣៧៧ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយអត្ថិប្បច្ច័យ បានដល់ បច្ឆាជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ជាឧបាទិន្នុបាទានិយៈដែលកើតមុន ដោយអត្ថិប្បច្ច័យ ។

[ ៣៧៨ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយ-ធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺ អនុបាទិន្នអនុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយ អត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យ នៃកាយនេះ ជាអនុបាទិន្នុបាទានិយៈដែលកើតមុន ដោយអត្ថិប្បច្ច័យ ។

[ ៣៧៩ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ផង នៃអនុបាទិន្នអនុបាទានិយធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហ-ជាត និងបច្ឆាជាត ។ សហជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធ ១ ជាបច្ច័យ នៃខន្ធ ៣ ផង នៃកាយនេះ ជាឧបាទិន្នុបាទានិយៈដែលកើតមុនផង ដោយ អត្ថិប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ១ ផង នៃកាយនេះ ជាឧបាទិន្នុបាទា-និយៈ ដែលកើតមុនផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង នៃកាយនេះ ជាឧបាទិន្នុបាទានិយៈ ដែលកើតមុនផង ដោយអត្ថិប្បច្ច័យ ។

[ ៣៨០ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយ-ធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃ ខន្ធ ១ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ជាបច្ច័យ នៃខន្ធ ២ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ផង នៃកាយនេះ ជា

អនុបាទិន្នុបាទានិយៈ ដែលកើតមុនផង ដោយអត្ថិប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ ផង នៃកាយនេះជាអនុបាទិន្នុបាទានិយៈ ដែលកើតមុនផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង នៃកាយនេះ ជាអនុបាទិន្នុបាទានិយៈដែលកើតមុនផង ដោយអត្ថិប្បច្ច័យ ។

[ ៣៨១ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ បច្ឆាជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ជាឧបាទិន្នុបាទានិយៈផង ជាអនុបាទិន្នុបាទានិយៈផង ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។

[ ៣៨២ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នអនុបាទានិយធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ផង នៃកាយនេះ ជាឧបាទិន្នុបាទានិយធម៌ផង ជាអនុបាទិន្នុបាទានិយៈផង ដែលកើតមុន ដោយអត្ថិប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ ផង នៃកាយនេះ ជាឧបាទិន្នុបាទានិយៈផង ជាអនុបាទិន្នុបាទានិយៈផង ដែលកើតមុន ដោយអត្ថិប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង នៃកាយនេះ ជាឧបាទិន្នុបាទានិយៈផង ជាអនុបាទិន្នុបាទានិយៈផង ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។

[ ៣៨៣ ] ឧបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នអនុបាទានិយធម៌ក្តី ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយអត្ថិប្បច្ច័យ បានដល់ បច្ឆាជាត និងឥន្ទ្រិយ ។

បច្ឆាជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធទាំងឡាយក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។

[ ៣៨៤ ] ឧបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នអនុបាទានិយធម៌ក្តី ជាបច្ច័យនៃអនុបាទិន្នអនុបាទានិយធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធ ១ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ៣ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ១ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ២ ដោយអត្ថិប្បច្ច័យ ។

[ ៣៨៥ ] អនុបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នអនុបាទានិយធម៌ក្តី ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយអត្ថិប្បច្ច័យ បានដល់ បច្ឆាជាត និងអាហារ ។ បច្ឆាជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធទាំងឡាយក្តី កពឡិង្ការាហារជាអនុបាទិន្នុបាទានិយៈក្តី ជាបច្ច័យនៃកាយ ជាឧបាទិន្នុបាទានិយៈ ដោយអត្ថិប្បច្ច័យ ។

[ ៣៨៦ ] អនុបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នអនុបាទានិយធម៌ក្តី ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បច្ឆាជាត និងអាហារ ។ សហជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធទាំងឡាយក្តី មហាភូតទាំងឡាយក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធទាំងឡាយក្តី កពឡិង្ការាហារ ជាអនុបាទិន្នុបាទានិយៈក្តី ជាបច្ច័យនៃកាយ ជាអនុបាទិន្នុបាទានិយៈ ដោយអត្ថិប្បច្ច័យ ។

[ ៣៨៧ ] អនុបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នអនុបាទានិយធម៌ក្តី ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ បច្ឆាជាត និងអាហារ ។ បច្ឆាជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធទាំងឡាយក្តី កពឡិង្ការាហារ ជាអនុបាទិន្នុបាទានិយៈក្តី ជាបច្ច័យនៃកាយ ជាឧបាទិន្នុបាទានិយៈផង ជាអនុបាទិន្នុបាទានិយៈផង ដោយអត្ថិប្បច្ច័យ ។

[ ៣៨៨ ] ឧបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នុបាទានិយធម៌ក្តី ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ បុរេជាត គឺរូបាយតនៈក្តី ចក្ខាយតនៈក្តី ជាអនុបាទិន្នុបាទានិយៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយអត្ថិប្បច្ច័យ ។ សេចក្តីបង្រួញ ។ ផោដ្ឋព្វាយតនៈក្តី កាយាយតនៈក្តី ជាអនុបាទិន្នុបាទានិយៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអត្ថិប្បច្ច័យ រូបាយតនៈក្តី វត្ថុក្តី ជាអនុបាទិន្នុបាទានិយៈ ( ជាបច្ច័យ ) នៃឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ។ សេចក្តីបង្រួញ ។ ផោដ្ឋព្វាយតនៈក្តី វត្ថុក្តី ជាអនុបាទិន្នុបាទានិយៈ ជាបច្ច័យនៃឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយក្តី កពឡិង្ការាហារ ជាអនុបាទិន្នុបាទានិយៈក្តី ជាបច្ច័យនៃកាយ ជាឧបាទិន្នុបាទានិយៈ ដោយអត្ថិប្បច្ច័យ កពឡិង្ការាហារ ជាឧបាទិន្នុបាទានិយៈក្តី ជាអនុបាទិន្នុបាទានិយៈក្តី ជាបច្ច័យនៃកាយ ជាឧបាទិន្នុបាទានិយៈ ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺអនុបាទិន្នុបាទានិយក្ខន្ធទាំងឡាយក្តី រូបជីវិ-

តិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។

[ ៣៨៩ ] ឧបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នុបាទានិយធម៌ក្តី ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត និងអាហារ ។ សហជាត គឺឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយក្តី មហាភូតទាំងឡាយក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ ឯបុរេជាត គឺរូបាយតនៈក្តី វត្ថុក្តី ជាអនុបាទិន្នុបាទានិយៈ ( ជាបច្ច័យ ) នៃអនុបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ។ សេចក្តីបង្រួញ ។ ផោដ្ឋព្វាយតនៈក្តី វត្ថុក្តី ជាអនុបាទិន្នុបាទានិយៈ ជាបច្ច័យនៃអនុបាទិន្នុបាទានិយក្ខន្ធទាំងឡាយ ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺឧបាទិន្នុបាទានិយក្ខន្ធទាំងឡាយក្តី កពឡិង្ការាហារ ជាអនុបាទិន្នុបាទានិយៈក្តី ជាបច្ច័យនៃកាយ ជាអនុបាទិន្នុបាទានិយៈ ដោយអត្ថិប្បច្ច័យ កពឡិង្ការាហារ ជាឧបាទិន្នុបាទានិយៈក្តី ជាអនុបាទិន្នុបាទានិយៈក្តី ជាបច្ច័យនៃកាយ ជាអនុបាទិន្នុបាទានិយៈ ដោយអត្ថិប្បច្ច័យ ។

[ ៣៩០ ] ឧបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នុបាទានិយធម៌ក្តី ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ អាហារ គឺកពឡិង្ការាហារ ជាឧបាទិន្នុបាទានិយៈក្តី ជាអនុបាទិន្នុបាទានិយៈក្តី ជាបច្ច័យនៃកាយ ជាឧបាទិន្នុបាទានិយៈផង ជាអនុបាទិន្នុបាទានិយៈផង ដោយអត្ថិប្បច្ច័យ ។

[ ៣៩១ ] ឧបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្ន-

អនុបាទានិយធម៌ក្តី ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយអត្ថិប្បច្ច័យ បាន ដល់ បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ បច្ឆាជាត គឺអនុបាទិន្នអនុបាទានិយក្ខន្ធទាំងឡាយក្តី កពឡិង្ការាហារ ជាអនុបាទិន្នុបាទានិយៈក្តី រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។

[ ៣៩២ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយនត្ថិប្បច្ច័យ ... ជាបច្ច័យដោយវិគតប្បច្ច័យ ... ជាបច្ច័យដោយអវិគតប្បច្ច័យ ។

សេចក្តីបង្រួញ ។

[ ៣៩៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១១ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៨ ក្នុងវិបាកប្បច្ច័យ មានវារៈ ៦ ក្នុងអាហារប្បច្ច័យ មានវារៈ ១២ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងឈានប្បច្ច័យ មានវារៈ ៧ ក្នុងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងអត្ថិប្បច្ច័យ មានវារៈ ២៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ២៣ ។

[ ៣៩៤ ] ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ព្រោះហេតុប្បច្ច័យ ... ក្នុងសហជាតប្បច្ច័យ មានវារៈ ៧ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ៦ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

## សេចក្តីបង្រួញ

បណ្ឌិតគប្បីរាប់ ដូចជាការរាប់នូវកុសលត្តិកៈ ដែលលោករាប់ហើយតាមផ្លូវនៃការស្វាធ្យាយដែរ ។ ការរាប់ក្នុងឧបាទិន្នត្តិកៈដ៏ជ្រាលជ្រៅ និងល្អិតល្អជាងការរាប់នូវកុសលត្តិកៈទៅទៀត បណ្ឌិតកាលមិនវង្វេង គប្បីធ្វើយ៉ាងនេះ ហើយរាប់ចុះ ។

## អនុលោម ចប់

[ ៣៩៥ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយសហជាតប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយបុរេជាតប្បច្ច័យ ... ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ... ជាបច្ច័យដោយអាហារប្បច្ច័យ ... ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

[ ៣៩៦ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌

ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយសហជាតប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយបុរេជាតប្បច្ច័យ ... ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ... ជាបច្ច័យដោយអាហារប្បច្ច័យ ។

[ ៣៩៧ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នអនុបាទានិយធម៌ ដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។

[ ៣៩៨ ] ឧបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយសហជាតប្បច្ច័យ ... ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ... ជាបច្ច័យដោយអាហារប្បច្ច័យ ។

[ ៣៩៩ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយសហជាតប្បច្ច័យ ... ជាបច្ច័យដោយ ឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយបុរេជាតប្បច្ច័យ ... ជាបច្ច័យដោយ បច្ឆាជាតប្បច្ច័យ ... ជាបច្ច័យដោយអាហារប្បច្ច័យ ។

[ ៤០០ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយបុរេជាតប្បច្ច័យ ... ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ... ជាបច្ច័យដោយកម្មប្បច្ច័យ ... ជាបច្ច័យដោយអាហារប្បច្ច័យ ។

[ ៤០១ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នអនុបាទានិយធម៌ ដោយឧបនិស្សយប្បច្ច័យ ។

[ ៤០២ ] អនុបាទិន្នុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង

នៃអនុបាទិន្នុបាទានិយធម៌ផង ដោយបច្ឆាជាតប្បច្ច័យ ... ជាបច្ច័យដោយអាហារប្បច្ច័យ ។

[ ៤០៣ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នអនុបាទានិយធម៌ ដោយសហជាតប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៤០៤ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។

[ ៤០៥ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ដោយអារម្មណប្បច្ច័យ ... ( ជាបច្ច័យ ) ដោយសហជាតប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។

[ ៤០៦ ] អនុបាទិន្នអនុបាទានិយធម៌ ( ជាបច្ច័យ ) នៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នអនុបាទានិយធម៌ផង បានដល់ សហជាត និង បច្ឆាជាត ។

[ ៤០៧ ] អនុបាទិន្នអនុបាទានិយធម៌ ( ជាបច្ច័យ ) នៃអនុបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នអនុបាទានិយធម៌ផង បានដល់ សហជាត និង បច្ឆាជាត ។

[ ៤០៨ ] អនុបាទិន្នអនុបាទានិយធម៌ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង ដោយបច្ឆាជាតប្បច្ច័យ ។

[ ៤០៩ ] អនុបាទិន្នអនុបាទានិយធម៌ ( ជាបច្ច័យ ) នៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នអនុបាទានិយធម៌ផង

បានដល់ សហជាត និងបច្ឆាជាត ។

[ ៦១០ ] ឧបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នអនុបាទានិយធម៌ក្តី ( ជាបច្ច័យ ) នៃឧបាទិន្នុបាទានិយធម៌ បានដល់ បច្ឆាជាត និងឥន្ទ្រិយ ។

[ ៦១១ ] ឧបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នអនុបាទានិយធម៌ក្តី ( ជាបច្ច័យ ) នៃអនុបាទិន្នអនុបាទានិយធម៌ បានដល់ សហជាត និងបុរេជាត ។

[ ៦១២ ] អនុបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នអនុបាទានិយធម៌ក្តី ( ជាបច្ច័យ ) នៃឧបាទិន្នុបាទានិយធម៌ បានដល់ បច្ឆាជាត និងអាហារ ។

[ ៦១៣ ] អនុបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នអនុបាទានិយធម៌ក្តី ( ជាបច្ច័យ ) នៃឧបាទិន្នុបាទានិយធម៌ បានដល់ សហជាត បច្ឆាជាត និងអាហារ ។

[ ៦១៤ ] អនុបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នអនុបាទានិយធម៌ក្តី ( ជាបច្ច័យ ) នៃអនុបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង បានដល់ បច្ឆាជាត និងអាហារ ។

[ ៦១៥ ] ឧបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នុបាទានិយធម៌ក្តី ( ជាបច្ច័យ ) នៃឧបាទិន្នុបាទានិយធម៌ បានដល់ បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។

[ ៦១៦ ] ឧបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នុបាទានិយធម៌ក្តី ( ជាបច្ច័យ ) នៃអនុបាទិន្នុបាទានិយធម៌ បានដល់ សហជាត បុរេជាត បច្ឆាជាត និងអាហារ ។

[ ៤១៧ ] ឧបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នុបាទានិយធម៌ក្តី ( ជាបច្ច័យ ) នៃឧបាទិន្នុបាទានិយធម៌ផង នៃអនុបាទិន្នុបាទានិយធម៌ផង បានដល់ អាហារ ។

[ ៤១៨ ] ឧបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នុបាទានិយធម៌ក្តី អនុបាទិន្នអនុបាទានិយធម៌ក្តី ( ជាបច្ច័យ ) នៃឧបាទិន្នុបាទានិយធម៌ បានដល់ បច្ឆាជាត អាហារ និងឥន្ទ្រិយ ។

[ ៤១៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២៤ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២៤ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ២៤ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ២៤ ក្នុងនសហជាតប្បច្ច័យ មានវារៈ ២០ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ២០ ក្នុងននិស្សយប្បច្ច័យ មានវារៈ ២០ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ២៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១៧ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ២៤ ក្នុងនកម្មប្បច្ច័យ មានវារៈ ២៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២៤ ក្នុងនអាហារប្បច្ច័យ មានវារៈ ២០ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ២២ ក្នុងនឈានប្បច្ច័យ មានវារៈ ២៤ ក្នុងនមគ្គប្បច្ច័យ មានវារៈ ២៤ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ២០ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១៤ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ២៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ ២៤ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៤២០ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២៤ ព្រោះនហេតុប្បច្ច័យ ។

សេចក្ដីបង្រួញ ។ បណ្ឌិតគប្បីឲ្យពិស្ដារ ដូចជាការរាប់នូវបច្ចនីយៈ ក្នុងកុសលត្តិកៈ ដែលលោកឲ្យពិស្ដារហើយដែរ ។

## បច្ចនីយៈ ចប់

[ ៤២១ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៤ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៧ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៧ ក្នុងនកម្មប្បច្ច័យ មានវារៈ ៧ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងនអាហារប្បច្ច័យ មានវារៈ ៧ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងនឈានប្បច្ច័យ មានវារៈ ៧ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៧ ។ ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៧ ។

## សេចក្ដីបង្រួញ

បណ្ឌិតគប្បីរាប់ ដូចជាការរាប់នូវអនុលោមបច្ចនីយៈ ក្នុងកុសលត្តិកៈ

ដែលលោកបានចែកហើយដែរ ។

## អនុលោមបច្ចនីយៈ ចប់

[ ៤២២ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១១ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៨ ក្នុងវិបាកប្បច្ច័យ មានវារៈ ៦ ក្នុងអាហារប្បច្ច័យ មានវារៈ ១២ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងឈានប្បច្ច័យ មានវារៈ ៧ ក្នុងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ១០ ក្នុងអត្ថិប្បច្ច័យ មានវារៈ ២៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ២៣ ។

### សេចក្តីបង្រួញ

បណ្ឌិតគប្បីរាប់ ដូចជាការរាប់នូវបច្ចនីយានុលោម ក្នុងកុសលត្តិកៈ ដែលលោកបានចែករួចហើយដែរ ។

## ឧបាទិន្នត្តិកៈទី ៤ ចប់

# អដ្ឋកថា

## ឧបាទិន្នត្តិកៈ

[ ១៨១-៤២២ ] ក្នុងបញ្ហាវារៈនៃឧបាទិន្នុបាទានិយតិកៈ ព្រះមានព្រះភាគ ត្រាស់សំដៅដល់បវត្តិកាលថា ហទយវត្ថុជាបច្ច័យដល់ខន្ធទាំងឡាយ ដែលជាឧបាទិន្នុបាទានិយៈ ដោយបុរេជាតប្បច្ច័យប៉ុណ្ណោះ តែក្នុងបដិសន្ធិកាល ហទយវត្ថុនោះ មិនជាបុរេជាតប្បច្ច័យឡើយ ។ ក្នុងបទនេះថា **ឧបាទិន្នុ-បាទានិយោ កពឡីការោ អាហារោ ឧបាទិន្នុបាទានិយស្ស កាយស្ស អាហារប្បច្ចយេន បច្ចយោ** សេចក្តីថា ឈ្មោះថា កពឡិង្ការាហារដែលជាឧបាទិន្នុបាទានិយៈ បានដល់ ឱជាដែលនៅខាងក្នុងនៃរូប ដែលមានកម្មជាសមុដ្ឋាន ។ បទថា **ឧបាទិន្នុបាទានិយស្ស កាយស្ស** សេចក្តីថា ជាបច្ច័យដល់កាយ គឺរូបដែលមានកម្មជាសមុដ្ឋាននោះឯង ដោយអាហារប្បច្ច័យ ។

អាហារ ជាបច្ច័យដោយអំណាចការរក្សា និងគាំទ្រដល់កដត្តារូប ដូចរូបជីវិតិន្ទ្រិយ មិនបានជាបច្ច័យដោយអំណាចការញុំាងរូបឲ្យកើតឡើង ។

ចំណែកពាក្យណា ដែលអាចារ្យពួកខ្លះ ពោលថា ឱជាក្នុងខ្លួនកន្ទេបជាដើម ដែលនៅរស់ ជាបច្ច័យដោយអាហារប្បច្ច័យ ដល់ពស់ដែលលេបកន្ទេបចូលទៅ ពាក្យនេះ មិនគប្បីកាន់យក ព្រោះថា ឱជាក្នុងខ្លួនសត្វដែលនៅរស់ រមែងមិនឲ្យសម្រេចភាពជាអាហារប្បច្ច័យ ដល់រាងកាយរបស់អ្នកដទៃ ។ ក្នុងបទនេះថា **អនុបាទិន្នុបាទានិយស្ស កាយស្ស** រមែងបានភាពជាបច្ច័យ ដោយអំណាចការឲ្យកើតឡើង ។ ក្នុងបទនេះថា **ឧបាទិន្នុបាទា-និយស្ស ច អនុបាទិន្នុបាទានិយស្ស ច** ព្រះមានព្រះភាគ ត្រាស់អាហា-

*របច្ច័យ ដោយអំណាចជាធម៌ឧបការៈ ដល់កាយណាមួយ ដោយអំណាចធ្វើឲ្យកើតដល់កាយណាមួយ ឬដោយអំណាចជាធម៌ឧបការៈប៉ុណ្ណោះ ដល់កាយដែលជាឧបាទិន្នុបាទានិយៈ និងដែលជាអនុបាទិន្នុបាទានិយៈទាំង ២ ។ អាហារ ២ កាលជាបច្ច័យរួមគ្នា រមែងជាឧបត្ថម្ភកសត្តិ គឺឧបការៈប៉ុណ្ណោះ មិនជាជនកសត្តិ គឺធ្វើឲ្យកើតឡើង ។ ពាក្យដ៏សេសក្នុងអធិការនេះ អ្នកសិក្សាគប្បីពិនិត្យបាលីឲ្យល្អ ហើយជ្រាបចុះ ។*

**អដ្ឋកថាឧទានិទ្ទេស្តិកៈ ចប់**

# អភិធម្មបិដក

## សង្កិលិដ្ឋត្តិកៈ

## បដិច្ចវារៈ

[ ៤២៣ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ( ធម៌ដែលសៅហ្មងហើយទាំងគួរដល់សេចក្តីសៅហ្មង ) អាស្រ័យសង្កិលិដ្ឋសង្កិលេសិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យសង្កិលិដ្ឋសង្កិលេសិកក្ខន្ធ ១ ខន្ធ ២ អាស្រ័យខន្ធ ២ ។ អសង្កិលិដ្ឋសង្កិលេសិកធម៌ ( ធម៌ដែលមិនសៅហ្មងហើយ តែគួរដល់សេចក្តីសៅហ្មង ) អាស្រ័យសង្កិលិដ្ឋសង្កិលេសិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយ ។ សង្កិលិដ្ឋសង្កិលេសិកធម៌ក្តី អសង្កិលិដ្ឋសង្កិលេសិកធម៌ក្តី អាស្រ័យសង្កិលិដ្ឋសង្កិលេសិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យសង្កិលិដ្ឋសង្កិលេសិកក្ខន្ធ ១ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ។

[ ៤២៤ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ អាស្រ័យអសង្កិលិដ្ឋសង្កិលេសិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យអសង្កិលិដ្ឋសង្កិលេសិកក្ខន្ធ ១ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យអសង្កិលិដ្ឋសង្កិលេសិកក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ២ វត្ថុ អាស្រ័យខន្ធទាំងឡាយ ខន្ធទាំងឡាយ អាស្រ័យវត្ថុ មហាភូត ៣

អាស្រ័យមហាភូត ១ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។

[ ៤២៥ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ( ធម៌ដែលមិនសៅហ្មងហើយទាំងមិនគួរដល់សេចក្តីសៅហ្មង ) អាស្រ័យអសង្កិលិដ្ឋអសង្កិលេសិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យអសង្កិលិដ្ឋអសង្កិ-លេសិកក្ខន្ធ ១ ខន្ធ ២ អាស្រ័យខន្ធ ២ ។ អសង្កិលិដ្ឋអសង្កិលេសិកធម៌ អាស្រ័យអសង្កិលិដ្ឋអសង្កិលេសិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យអសង្កិលិដ្ឋអសង្កិលេសិកក្ខន្ធទាំងឡាយ ។ អសង្កិលិដ្ឋសង្កិលេសិកធម៌ក្តី អសង្កិលិដ្ឋអសង្កិលេសិកធម៌ក្តី អាស្រ័យអសង្កិលិដ្ឋអសង្កិលេសិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យអសង្កិលិដ្ឋអសង្កិលេសិកក្ខន្ធ ១ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ។

[ ៤២៦ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ អាស្រ័យអសង្កិលិដ្ឋសង្កិ-លេសិកធម៌ផង អសង្កិលិដ្ឋអសង្កិលេសិកធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ចិត្តសមុដ្ឋានរូប អាស្រ័យអសង្កិលិដ្ឋអសង្កិលេសិកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ។

[ ៤២៧ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ អាស្រ័យសង្កិលិដ្ឋសង្កិលេសិ-កធម៌ផង អសង្កិលិដ្ឋសង្កិលេសិកធម៌ផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ ចិត្តសមុដ្ឋានរូប អាស្រ័យសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយផង មហាភូត

ទាំងឡាយផង ។ សេចក្តីបង្រួញ ។

[ ៤២៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ។ សេចក្តីបង្រួញ ។ ក្នុងវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិតគប្បីចែក ដូចជាបទដែលលោកចែកហើយ ក្នុងកុសលត្តិកៈដែរ ។

[ ៤២៩ ] សង្កិលិដ្ឋសង្កិលេសិកធម៌ អាស្រ័យសង្កិលិដ្ឋសង្កិលេសិកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យខន្ធទាំងឡាយដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។

[ ៤៣០ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ អាស្រ័យអសង្កិលិដ្ឋសង្កិលេសិកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យអសង្កិលិដ្ឋសង្កិលេសិកក្ខន្ធ ១ ដែលជាអហេតុកៈ មហាភូត ១ របស់ពួកអសញ្ញសត្វ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ... ។ សេចក្តីបំប្រួញ ។ បណ្ឌិតគប្បីចែក ដូចជាបទដែលលោកចែកហើយ ក្នុងកុសលត្តិកៈដែរ ។ ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៦ ។ សេចក្តីបង្រួញ ។

ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះហេតុប្បច្ច័យ ។ សេចក្តីបង្រួញ ។ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ។ សេចក្តីបង្រួញ ។ សហជាតវារៈក្តី

បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈ
ក្តី បណ្ឌិតគប្បីឲ្យពិស្តារចុះ ។

# បញ្ហាវារៈ

[ ៤៣១ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយហេតុប្បច្ច័យ ពួកហេតុជាសង្កិលិដ្ឋសង្កិលេសិកៈ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយ ដោយហេតុប្បច្ច័យ ។

[ ៤៣២ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយហេតុប្បច្ច័យ ពួកហេតុជាសង្កិលិដ្ឋសង្កិលេសិកៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ។

[ ៤៣៣ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកធម៌ផង នៃអសង្កិលិដ្ឋសង្កិលេសិកធម៌ផង ដោយហេតុប្បច្ច័យ ពួកហេតុជាសង្កិលិដ្ឋសង្កិលេសិកៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។

[ ៤៣៤ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយហេតុប្បច្ច័យ ពួកហេតុជាអសង្កិលិដ្ឋសង្កិលេសិកៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ពួកហេតុជាអសង្កិលិដ្ឋសង្កិលេសិកៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយហេតុប្បច្ច័យ ។

[ ៤៣៥ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋ-អសង្កិលេសិកធម៌ ដោយហេតុប្បច្ច័យ ពួកហេតុជាអសង្កិលិដ្ឋសង្កិលេសិកៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។

[ ៤៣៦ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិ-លេសិកធម៌ ដោយហេតុប្បច្ច័យ ពួកហេតុជាអសង្កិលិដ្ឋអសង្កិលេសិកៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ។

[ ៤៣៧ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិ-លេសិកធម៌ផង នៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ផង ដោយហេតុប្បច្ច័យ ពួកហេតុជាអសង្កិលិដ្ឋអសង្កិលេសិកៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។

[ ៤៣៨ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេ-សិកធម៌ ដោយអារម្មណប្បច្ច័យ បុគ្គលត្រេកអរ រីករាយនឹងរាគៈ រាគៈ ប្រារព្ធនូវរាគៈនោះទើបកើតឡើង ទិដ្ឋិក៏កើតឡើង វិចិកិច្ឆាកើតឡើង ឧទ្ធច្ចៈ កើតឡើង ទោមនស្សកើតឡើង បុគ្គលត្រេកអរនឹងទិដ្ឋិ ប្រារព្ធនូវវិចិកិច្ឆា ប្រារព្ធនូវឧទ្ធច្ចៈ ប្រារព្ធនូវទោមនស្ស ។ បណ្ឌិតគប្បីចែក ដូចជាបទដែល លោកចែកហើយ ក្នុងកុសលត្តិកៈដែរ ។

[ ៤៣៩ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិ-លេសិកធម៌ ដោយអារម្មណប្បច្ច័យ គឺព្រះអរិយៈទាំងឡាយ ពិចារណានូវ កិលេសទាំងឡាយ ដែលលះបង់ហើយ ពិចារណានូវកិលេសទាំងឡាយ

ដែលសន្សំតាំងហើយ ដឹងច្បាស់នូវកិលេសទាំងឡាយ ដែលសន្សំទុកហើយក្នុងកាលមុន ឃើញច្បាស់នូវសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ដឹងច្បាស់នូវចិត្តរបស់បុគ្គលអ្នកប្រកបដោយសង្កិលិដ្ឋសង្កិលេសិកៈ ដោយចេតោបរិយញ្ញាណ ពួកសេក្ខបុគ្គលក្តី ពួកបុថុជ្ជនក្តី ឃើញច្បាស់នូវសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន កាលបើកុសល រលត់ហើយ វិបាកកើតឡើង ព្រោះអំពើនោះជាអារម្មណ៍ ( ពួកសេក្ខបុគ្គល និងបុថុជ្ជន ) ត្រេកអរ រីករាយនឹងសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយ ទោមនស្ស ក៏កើតឡើង កាលបើអកុសល រលត់ហើយ វិបាកក៏កើតឡើង ព្រោះអំពើនោះ ជាអារម្មណ៍ សង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយ ជាបច្ច័យនៃការពិចារណានូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៤៤០ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ពិចារណានូវកុសលនោះ ពិចារណានូវកុសលទាំងឡាយដែលសន្សំទុកហើយក្នុងកាលមុន ចេញចាកឈាន ពិចារណាឈាន ពួកព្រះអរិយៈពិចារណាគោត្រភូ ពិចារណាវោទានៈ ឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ពិចារណាឃើញច្បាស់នូវសោតៈ ... ឃានៈ ជិវ្ហា កាយ រូបទាំងឡាយ សំឡេង ក្លិន រស ផោដ្ឋព្វៈ វត្ថុ ... នូវអសង្កិ-

លិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ឃើញរូប ដោយទិព្វចក្ខុ ឮសំឡេងដោយទិព្វសោតធាតុ ដឹងច្បាស់នូវចិត្តនៃបុគ្គលអ្នក ប្រកបដោយអសង្កិលិដ្ឋសង្កិលេសិកចិត្ត ដោយចេតោបរិយញ្ញាណ អាកា-សានញ្ចាយតនៈ ជាបច្ច័យនៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនៈ ដោយអារម្មណប្បច្ច័យ រូបាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយអារម្មណប្បច្ច័យ ។បេ។ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអារម្មណប្បច្ច័យ អសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៤៤១ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេ-សិកធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម រមែងត្រេកអរ រីករាយនឹងកុសលកម្មនោះ រាគៈ ប្រារព្ធនូវកុសលនោះ ទើបកើតឡើង ទិដ្ឋិកើតឡើង ទោមនស្សកើតឡើង បុគ្គលត្រេកអរនឹងកុសលទាំងឡាយ ដែលសន្សំទុកហើយក្នុងកាលមុន ចេញចាកឈាន ត្រេកអរនឹងឈាន ត្រេកអរនឹងចក្ខុ ... ផោដ្ឋព្វៈ ... នូវវត្ថុ ... ត្រេកអររីករាយនឹងអសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយ រាគៈប្រារព្ធនូវខន្ធទាំងនោះទើបកើតឡើង ទោមនស្សកើតឡើង ។

[ ៤៤២ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិ-

លេសិកធម៌ ដោយអារម្មណប្បច្ច័យ គឺព្រះនិព្វាន ជាបច្ច័យនៃមគ្គ និងផល ដោយអារម្មណប្បច្ច័យ ។

[ ៤៤៣ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈ ចេញចាកមគ្គ ពិចារណាមគ្គ ពិចារណាផល ពិចារណាព្រះនិព្វាន ព្រះនិព្វានជាបច្ច័យនៃការពិចារណានូវគោត្រភូ និងវោទានៈ ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈដឹងនូវចិត្ត នៃបុគ្គលដែលប្រកបដោយអសង្កិលិដ្ឋសង្កិលេសិកចិត្ត ដោយចេតោបរិយញ្ញាណ អសង្កិលិដ្ឋអសង្កិលេសិកក្ខន្ធទាំងឡាយ ជាបច្ច័យនៃការពិចារណានូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៤៤៤ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលធ្វើរាគៈ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើរាគៈនោះឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិ ក៏កើតឡើង បុគ្គលធ្វើទិដ្ឋិឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើទិដ្ឋិនោះឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិក៏កើតឡើង ។ ឯសហជាតាធិបតិ គឺអធិបតិជាសង្កិលិដ្ឋសង្កិលេសិកៈ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយ ដោយអធិបតិប្បច្ច័យ ។

[ ៤៤៥ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេ-

សិកធម៌ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិ ជាសង្កិលិដ្ឋសង្កិលេសិកៈជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។

[ ៤៤៦ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកធម៌ផង នៃអសង្កិលិដ្ឋសង្កិលេសិកធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិជាសង្កិលិដ្ឋសង្កិលេសិកៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។

[ ៤៤៧ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ធ្វើកុសលនោះឲ្យជាទីគោរពហើយពិចារណា ធ្វើនូវកុសលទាំងឡាយ ដែលសន្សំទុកហើយ ក្នុងកាលមុន ឲ្យជាទីគោរព ហើយពិចារណា ចេញចាកឈាន ធ្វើឈានឲ្យជាទីគោរព ហើយពិចារណា ពួកសេក្ខបុគ្គល ធ្វើនូវគោត្រភូឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវវោទានៈឲ្យជាទីគោរព ហើយពិចារណា ។ ឯសហជាតាធិបតិ គឺអធិបតិ ជាអសង្កិលិដ្ឋសង្កិលេសិកៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។

[ ៤៤៨ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ធ្វើកុសលនោះឲ្យជាទីគោរព ហើយ

ត្រេកអរ រីករាយ រាគៈធ្វើនូវកុសលនោះឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិ ក៏កើតឡើង បុគ្គលធ្វើនូវកុសលទាំងឡាយ ដែលសន្សំទុកហើយ ក្នុងកាល មុន ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ ចេញចាកឈាន ធ្វើឈានឲ្យ ជាទីគោរព ហើយត្រេកអរ រីករាយ ធ្វើចក្ខុឲ្យជាទីគោរព ហើយត្រេកអរ រីករាយ នូវផោដ្ឋព្វៈទាំងឡាយ ... វត្ថុ ... ធ្វើនូវអសង្កិលិដ្ឋសង្កិលេសិកក្ខន្ធ ទាំងឡាយ ឲ្យជាទីគោរព ហើយត្រេកអររីករាយ រាគៈធ្វើនូវខន្ធទាំងនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិក៏កើតឡើង ។

[ ៤៤៩ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិ- លេសិកធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជា- តាធិបតិ ។ អារម្មណាធិបតិ គឺព្រះនិព្វាន ជាបច្ច័យនៃមគ្គ និងផល ដោយ អធិបតិប្បច្ច័យ ។ ឯសហជាតាធិបតិ គឺអធិបតិជាអសង្កិលិដ្ឋអសង្កិលេសិកៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។

[ ៤៥០ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិ- លេសិកធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហ- ជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកព្រះអរិយៈ ចេញចាកមគ្គ ធ្វើមគ្គឲ្យ ជាទីគោរព ហើយពិចារណា ធ្វើផលឲ្យជាទីគោរព ហើយពិចារណា ធ្វើ ព្រះនិព្វានឲ្យជាទីគោរព ហើយពិចារណា ព្រះនិព្វានជាបច្ច័យនៃគោត្រភូ និង វោទានៈ ដោយអធិបតិប្បច្ច័យ ។ ឯសហជាតាធិបតិ គឺអធិបតិជាអសង្កិ- លិដ្ឋអសង្កិលេសិកៈជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។

[ ៤៥១ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ផង នៃអសង្កិលិដ្ឋសង្កិលេសិកធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិជាអសង្កិលិដ្ឋអសង្កិលេសិកៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។

[ ៤៥២ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយអនន្តរប្បច្ច័យ សង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយមុនៗ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយក្រោយៗ ដោយអនន្តរប្បច្ច័យ ។

[ ៤៥៣ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយអនន្តរប្បច្ច័យ សង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយ ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។

[ ៤៥៤ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយអនន្តរប្បច្ច័យ អសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយមុនៗ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទានៈ អាវជ្ជនៈ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយ ដោយអនន្តរប្បច្ច័យ ។

[ ៤៥៥ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយអនន្តរប្បច្ច័យ អាវជ្ជនៈ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយ ដោយអនន្តរប្បច្ច័យ ។

[ ៤៥៦ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិ-លេសិកធម៌ ដោយអនន្តរប្បច្ច័យ គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទាន: ( ជាបច្ច័យ ) នៃមគ្គ អនុលោម ( ជាបច្ច័យ ) នៃផលសមាបត្តិ នេវសញ្ញានាសញ្ញាយតនៈ របស់បុគ្គលកាលចេញចាកនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។

[ ៤៥៧ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិ-លេសិកធម៌ ដោយអនន្តរប្បច្ច័យ អសង្កិលិដ្ឋអសង្កិលេសិកក្ខន្ធទាំងឡាយមុនៗ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិលេសិកក្ខន្ធទាំងឡាយក្រោយៗ ដោយអនន្តរប្បច្ច័យ មគ្គ ( ជាបច្ច័យ ) នៃផល ផលជាបច្ច័យនៃផល ដោយអនន្តរប្បច្ច័យ ។

[ ៤៥៨ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិ-លេសិកធម៌ ដោយអនន្តរប្បច្ច័យ ផល ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្ត-រប្បច្ច័យ ។

[ ៤៥៩ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយសមនន្តរប្បច្ច័យ ។បេ។ ... ជាបច្ច័យដោយសហជាតប្បច្ច័យ ... ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ ... ជាបច្ច័យដោយនិស្សយប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យរាគៈហើយ សម្លាប់សត្វ បំបែកសង្ឃ អាស្រ័យទោសៈហើយ សម្លាប់សត្វ បំបែកសង្ឃ រាគៈ ...

សេចក្តីប្រាថ្នា ជាបច្ច័យនៃរាគៈ និងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ បាណាតិបាត ជាបច្ច័យនៃបាណាតិបាត ដោយឧបនិស្សយប្បច្ច័យ និយតមិច្ឆាទិដ្ឋិ ជាបច្ច័យនៃនិយតមិច្ឆាទិដ្ឋិ ដោយឧបនិស្សយប្បច្ច័យ ។

[ ៤៦០ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យរាគៈ ហើយឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ធ្វើឈាន ... វិបស្សនា ... ធ្វើអភិញ្ញាឲ្យកើតឡើង ធ្វើសមាបត្តិឲ្យកើតឡើង អាស្រ័យសេចក្តីប្រាថ្នា ហើយឲ្យទាន ធ្វើសមាបត្តិឲ្យកើតឡើង រាគៈ ... សេចក្តីប្រាថ្នា ជាបច្ច័យនៃសទ្ធា សេចក្តីសុខប្រព្រឹត្តទៅក្នុងកាយ និងសេចក្តីទុក្ខប្រព្រឹត្តទៅក្នុងកាយ ដោយឧបនិស្សយប្បច្ច័យ បុគ្គលសម្លាប់សត្វហើយឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ធ្វើឈានឲ្យកើតឡើង ធ្វើវិបស្សនាឲ្យកើតឡើង ធ្វើអភិញ្ញាឲ្យកើតឡើង ធ្វើសមាបត្តិ ឲ្យកើតឡើង ដើម្បីប្រយោជន៍ដល់ការឃាត់នូវផលនៃកម្មនោះ បំបែកសង្ឃហើយឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ដើម្បីប្រយោជន៍ដល់ការឃាត់នូវផលនៃកម្មនោះ អកុសលកម្ម ជាបច្ច័យនៃវិបាក ដោយឧបនិស្សយប្បច្ច័យ ។

[ ៤៦១ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យរាគៈ ហើយធ្វើមគ្គឲ្យកើតឡើង ចូលកាន់ផលសមាបត្តិ អាស្រ័យ

ទោសៈ ... អាស្រ័យសេចក្តីប្រាថ្នា ហើយធ្វើមគ្គឲ្យកើតឡើង ចូលកាន់ផលសមាបត្តិ រាគៈ ... សេចក្តីប្រាថ្នា ជាបច្ច័យនៃមគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ៤៦២ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យសទ្ធាហើយឲ្យទាន ធ្វើសមាបត្តិឲ្យកើតឡើង អាស្រ័យសីល ... សុតៈ ចាគៈ បញ្ញា សេចក្តីសុខប្រព្រឹត្តទៅក្នុងកាយ សេចក្តីទុក្ខប្រព្រឹត្តទៅក្នុងកាយ រដូវ ភោជន ... អាស្រ័យសេនាសនៈ ហើយឲ្យទាន ធ្វើសមាបត្តិឲ្យកើតឡើង សទ្ធា ... សេនាសនៈ ជាបច្ច័យនៃសទ្ធា និងសេចក្តីសុខប្រព្រឹត្តទៅក្នុងកាយ ដោយឧបនិស្សយប្បច្ច័យ កុសលកម្ម ជាបច្ច័យនៃវិបាក ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃឈានទី ១ ឈានទី ១ ( ជាបច្ច័យ ) នៃឈានទី ១[១] អាកិញ្ចញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ ។

[ ៤៦៣ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យសទ្ធា

---

១- ពាក្យថា បរិកម្មនៃឈានទី ១ ឈានទី ១ ( ជាបច្ច័យ ) នៃឈានទី ១ ប្រែមកពីពាក្យថា បឋមស្ស ឈានស្ស បរិកម្មំ បឋមំ បឋមស្ស ឈានស្ស តែក្នុងច្បាប់ឆដ្ឋសង្គាយនា មិនមានពាក្យថា បឋមំ ទេ ទើបគួរប្រែថា បរិកម្មនៃឈានទី ១ ( ជាបច្ច័យ ) នៃឈានទី ១ ។

ហើយជំរឿនមានះ ប្រកាន់ទិដ្ឋិ ( អាស្រ័យ ) សីល ... អាស្រ័យសេនាសនៈ ហើយសម្លាប់សត្វ បំបែកសង្ឃ សទ្ធា ... សេនាសនៈ ជាបច្ច័យនៃរាគៈ និងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។

[ ៤៦៤ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបរិកម្មនៃមគ្គទី ១ ( ជាបច្ច័យ ) នៃមគ្គទី ១ ... នៃមគ្គទី ២ នៃមគ្គទី ៣ នៃមគ្គទី ៤ ដោយឧបនិស្សយប្បច្ច័យ ។

[ ៤៦៥ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺមគ្គទី ១ ( ជាបច្ច័យ ) នៃមគ្គទី ២ មគ្គទី ២ ( ជាបច្ច័យ ) នៃមគ្គទី ៣ មគ្គទី ៣ ( ជាបច្ច័យ ) នៃមគ្គទី ៤ មគ្គទី ៤ ជាបច្ច័យនៃផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ៤៦៦ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺពួកព្រះអរិយៈ អាស្រ័យនូវមគ្គ ហើយធ្វើសមាបត្តិដែលមិនទាន់កើត ឲ្យកើតឡើង ចូលកាន់សមាបត្តិដែលកើតឡើង ហើយពិចារណាឃើញច្បាស់នូវសង្ខារទាំងឡាយ ជាមិនទៀង ជាទុក្ខ មិនមែនខ្លួន មគ្គ ( ជាបច្ច័យ ) នៃអត្ថប្បដិសម្ភិទា

របស់ពួកព្រះអរិយៈ ធម្ម ... និរុត្តិ ... បដិភាណ ... និងឋានាឋានកោសល្ល ដោយឧបនិស្សយប្បច្ច័យ ផលសមាបត្តិ ជាបច្ច័យនៃសេចក្តីសុខប្រព្រឹត្តទៅក្នុងកាយ ដោយឧបនិស្សយប្បច្ច័យ ។

[ ៤៦៧ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គលពិចារណាឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ពិចារណាឃើញច្បាស់នូវសោតៈ ... ឃានៈ ជិវ្ហា កាយ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ... នូវវត្ថុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ឃើញរូបដោយទិព្វចក្ខុ ឮសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបុរេជាត ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបុរេជាតនៃកាយវិញ្ញាណ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ វត្ថុ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយ ដោយបុរេជាតប្បច្ច័យ ។

[ ៤៦៨ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គលត្រេកអរ រីករាយនឹងចក្ខុ រាគៈប្រារព្ធនូវចក្ខុនោះទើបកើតឡើង ទោមនស្សកើតឡើង សោតៈ ... ។បេ។ ផោដ្ឋព្វៈ ... បុគ្គលត្រេកអរ រីករាយនឹងវត្ថុ រាគៈប្រារព្ធនូវវត្ថុនោះ ទើបកើតឡើង ទោមនស្សកើតឡើង ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំង

ឡាយ ដោយបុរេជាតប្បច្ច័យ ។

[ ៤៦៩ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិ-លេសិកធម៌ ដោយបុរេជាតប្បច្ច័យ គឺវត្ថុ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិ-លេសិកក្ខន្ធទាំងឡាយ ដោយបុរេជាតប្បច្ច័យ ។

[ ៤៧០ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេ-សិកធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺសង្កិលិដ្ឋសង្កិលេសិ-កក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៤៧១ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិ-លេសិកធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺអសង្កិលិដ្ឋ-សង្កិលេសិកក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៤៧២ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិ-លេសិកធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺអសង្កិលិដ្ឋ-សង្កិលេសិកក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៤៧៣ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេ-សិកធម៌ ដោយអាសេវនប្បច្ច័យ គឺសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយមុនៗ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយក្រោយៗ ដោយអាសេវនប្បច្ច័យ ។

[ ៤៧៤ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយអាសេវនប្បច្ច័យ គឺពួកខន្ធមុនៗ ។បេ។ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោមជាបច្ច័យនៃវោទានៈ ដោយអាសេវនប្បច្ច័យ ។

[ ៤៧៥ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ ដោយអាសេវនប្បច្ច័យ គឺគោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទានៈ ជាបច្ច័យនៃមគ្គ ដោយអាសេវនប្បច្ច័យ ។

[ ៤៧៦ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយកម្មប្បច្ច័យ គឺសង្កិលិដ្ឋសង្កិលេសិកចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។

[ ៤៧៧ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺសង្កិលិដ្ឋសង្កិលេសិកចេតនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺសង្កិលិដ្ឋសង្កិលេសិកចេតនា ជាបច្ច័យនៃវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ៤៧៨ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកធម៌ផង នៃអសង្កិលិដ្ឋសង្កិលេសិកធម៌ផង ដោយកម្មប្បច្ច័យ សង្កិលិដ្ឋសង្កិលេសិកចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។

[ ៤៧៩ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺអសង្កិលិដ្ឋសង្កិលេសិកចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺអសង្កិលិដ្ឋសង្កិលេសិកចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ៤៨០ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺអសង្កិលិដ្ឋអសង្កិលេសិកចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺអសង្កិលិដ្ឋអសង្កិលេសិកចេតនា ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិលេសិកក្ខន្ធទាំងឡាយ ដែលជាវិបាក ដោយកម្មប្បច្ច័យ ។

[ ៤៨១ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត គឺអសង្កិលិដ្ឋអសង្កិលេសិកចេតនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។

[ ៤៨២ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ផង នៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ផង ដោយកម្មប្បច្ច័យ បានដល់ សហជាត គឺអសង្កិលិដ្ឋអសង្កិលេសិកចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។

[ ៤៨៣ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយវិបាកប្បច្ច័យ គឺអសង្កិលិដ្ឋសង្កិលេសិកក្ខន្ធ ១ ជាវិបាក ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយវិបាកប្បច្ច័យ ខន្ធ ២ ( ជាបច្ច័យ ) នៃខន្ធ ២ អសង្កិលិដ្ឋសង្កិលេសិកក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយវិបាកប្បច្ច័យ ខន្ធ ២ ( ជាបច្ច័យ ) នៃខន្ធ ២ ខន្ធទាំងឡាយ ជាបច្ច័យនៃវត្ថុ ដោយវិបាកប្បច្ច័យ ។

[ ៤៨៤ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ ដោយវិបាកប្បច្ច័យ គឺអសង្កិលិដ្ឋអសង្កិលេសិកក្ខន្ធ ១ ជាវិបាក ជាបច្ច័យនៃខន្ធ ៣ ដោយវិបាកប្បច្ច័យ ខន្ធ ២ ( ជាបច្ច័យ ) នៃខន្ធ ២ ។

[ ៤៨៥ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ ដោយវិបាកប្បច្ច័យ គឺអសង្កិលិដ្ឋអសង្កិលេសិកក្ខន្ធទាំងឡាយ ជាវិបាក ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិបាកប្បច្ច័យ ។

[ ៤៨៦ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ផង នៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ផង ដោយវិបាកប្បច្ច័យ គឺ អសង្កិលិដ្ឋអសង្កិលេសិកក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយវិបាកប្បច្ច័យ ខន្ធទាំង ២ ។បេ។

[ ៤៨៧ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេ-

សិកធម៌ ដោយអាហារប្បច្ច័យ គឺ៦ន្ទ ៣ ។

[ ៤៨៨ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយអាហារប្បច្ច័យ គឺពួកអាហារ ជាអសង្កិលិដ្ឋសង្កិលេសិកៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ កពឡីង្ការាហារ ជាបច្ច័យនៃកាយនេះ ក្នុងខណៈនៃបដិសន្ធិ ដោយអាហារប្បច្ច័យ ។បេ។

[ ៤៨៩ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ ដោយអាហារប្បច្ច័យ គឺ៦ន្ទ ៣ ។

[ ៤៩០ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺ៦ន្ទ ៣ ។ អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយ ជាអសង្កិលិដ្ឋសង្កិលេសិកៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយឥន្ទ្រិយប្បច្ច័យ ចក្ខុន្ទ្រិយ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ក្នុងខណៈនៃបដិសន្ធិ កាយិន្ទ្រិយ ជាបច្ច័យនៃកាយវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូបដោយឥន្ទ្រិយប្បច្ច័យ ។ អសង្កិលិដ្ឋអសង្កិលេសិកធម៌ គឺ៦ន្ទ ៣ ។

[ ៤៩១ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយឈានប្បច្ច័យ ... ជាបច្ច័យដោយមគ្គប្បច្ច័យ ... ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ ។

[ ៤៩២ ] សន្កិលិដ្ឋសន្កិលេសិកធម៌ ជាបច្ច័យនៃអសន្កិលិដ្ឋសន្កិលេសិកធម៌ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺសន្កិលិដ្ឋសន្កិលេសិកក្ខន្ធទាំងឡាយ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺសន្កិលិដ្ឋសន្កិលេសិកក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៤៩៣ ] អសន្កិលិដ្ឋសន្កិលេសិកធម៌ ជាបច្ច័យនៃអសន្កិលិដ្ឋសន្កិលេសិកធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សហជាត គឺអសន្កិលិដ្ឋសន្កិលេសិកក្ខន្ធទាំងឡាយ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ អសន្កិលិដ្ឋសន្កិលេសិកក្ខន្ធទាំងឡាយ ជាបច្ច័យនៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ដោយវិប្បយុត្តប្បច្ច័យ ខន្ធទាំងឡាយ ( ជាបច្ច័យ ) នៃវត្ថុ វត្ថុ ជាបច្ច័យនៃខន្ធទាំងឡាយ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ វត្ថុជាបច្ច័យនៃអសន្កិលិដ្ឋសន្កិលេសិកក្ខន្ធទាំងឡាយ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺអសន្កិលិដ្ឋសន្កិលេសិកក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៤៩៤ ] អសន្កិលិដ្ឋសន្កិលេសិកធម៌ ជាបច្ច័យនៃសន្កិលិដ្ឋសន្កិលេសិកធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុ ជាបច្ច័យនៃសន្កិលិដ្ឋសន្កិលេសិកក្ខន្ធទាំងឡាយ ដោយវិប្បយុត្តប្បច្ច័យ ។

[ ៤៩៥ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិ-លេសិកធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិលេសិកក្ខន្ធទាំងឡាយ ដោយវិប្បយុត្តប្បច្ច័យ ។

[ ៤៩៦ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេ-សិកធម៌ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺអសង្កិលិដ្ឋអសង្កិលេសិកក្ខន្ធទាំងឡាយ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺអសង្កិលិដ្ឋអសង្កិលេសិកក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៤៩៧ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេ-សិកធម៌ ដោយអត្ថិប្បច្ច័យ គឺសង្កិលិដ្ឋសង្កិលេសិកក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ។បេ។

[ ៤៩៨ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេ-សិកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។

[ ៤៩៩ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេ-សិកធម៌ផង នៃអសង្កិលិដ្ឋសង្កិលេសិកធម៌ផង ដោយអត្ថិប្បច្ច័យ គឺសង្កិ-លិដ្ឋសង្កិលេសិកក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង

ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។

[ ៥០០ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺអសង្កិលិដ្ឋសង្កិលេសិកក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ មហាភូត ១ របស់ពួកអសញ្ញសត្វ ជាបច្ច័យនៃខន្ធ ៣ ក្នុងបដិសន្ធិក្ខណៈ ដោយអត្ថិប្បច្ច័យ ។បេ។ ឯបុរេជាត គឺបុគ្គលពិចារណាឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន នូវសោតៈ ... ។បេ។ នូវកាយ រូប ផោដ្ឋព្វៈ ... ពិចារណាឃើញច្បាស់នូវវត្ថុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ឃើញរូបដោយទិព្វចក្ខុ ឮសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអត្ថិប្បច្ច័យ ចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយ ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺអសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ កពឡិង្ការាហារ ( ជាបច្ច័យ ) នៃកាយនេះ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។

[ ៥០១ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត គឺបុគ្គលត្រេកអរ រីករាយ

នឹងចក្ខុ រាគៈប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង ទោមនស្សកើតឡើង បុគ្គល ត្រេកអរនឹងវត្ថុ វត្ថុជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយ ដោយអត្ថិប្បច្ច័យ ។

[ ៥០២ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិ-លេសិកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុជាបច្ច័យនៃអសង្កិ-លិដ្ឋអសង្កិលេសិកក្ខន្ធទាំងឡាយ ដោយអត្ថិប្បច្ច័យ ។

[ ៥០៣ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋ-អសង្កិលេសិកធម៌ ដោយអត្ថិប្បច្ច័យ គឺអសង្កិលិដ្ឋអសង្កិលេសិកក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ។

[ ៥០៤ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិ-លេសិកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺអសង្កិលិដ្ឋអសង្កិលេសិកក្ខន្ធទាំងឡាយ ជាបច្ច័យនៃពួកចិត្ត-សមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺអសង្កិលិដ្ឋអសង្កិលេសិកក្ខន្ធ ទាំងឡាយ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។

[ ៥០៥ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិ-លេសិកធម៌ផង នៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ផង ដោយអត្ថិប្បច្ច័យ គឺ អសង្កិលិដ្ឋអសង្កិលេសិកក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្ត-សមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។

[ ៥០៦ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ក្តី អសង្កិលិដ្ឋអសង្កិលេសិក-

ធម៌ក្តី ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺអសង្កិលិដ្ឋអសង្កិ-លេសិកក្ខន្ធទាំងឡាយក្តី មហាភូតទាំងឡាយក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺអសង្កិលិដ្ឋអសង្កិលេសិកក្ខន្ធទាំងឡាយក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺអសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។

[ ៥០៧ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ក្តី អសង្កិលិដ្ឋអសង្កិលេសិកធម៌ក្តី ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ ឯសហជាត គឺអសង្កិលិដ្ឋអសង្កិលេសិកក្ខន្ធ ១ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ។

[ ៥០៨ ] សង្កិលិដ្ឋសង្កិលេសិកធម៌ក្តី អសង្កិលិដ្ឋសង្កិលេសិកធម៌ក្តី ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហ-ជាត និងបុរេជាត ។ ឯសហជាត គឺសង្កិលិដ្ឋសង្កិលេសិកក្ខន្ធ ១ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ។

[ ៥០៩ ] សង្កិលិដ្ឋសង្កិលេសិកធម៌ក្តី អសង្កិលិដ្ឋសង្កិលេសិកធម៌ក្តី ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហ-ជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺសង្កិលិដ្ឋសង្កិលេសិកក្ខន្ធទាំងឡាយក្តី មហាភូតទាំងឡាយក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយ

អត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺសន្កិលិដ្ឋសន្កិលេសិកក្ខន្ធទាំងឡាយក្តី កព-ឡិង្ការាហារក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺសន្កិលិដ្ឋសន្កិលេសិកក្ខន្ធទាំងឡាយក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។

[ ៥១០ ] សន្កិលិដ្ឋសន្កិលេសិកធម៌ ជាបច្ច័យនៃសន្កិលិដ្ឋសន្កិលេ-សិកធម៌ ដោយនត្ថិប្បច្ច័យ ... ជាបច្ច័យដោយវិគតប្បច្ច័យ ... ជាបច្ច័យដោយអវិគតប្បច្ច័យ ។

[ ៥១១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៨ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៨ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងអាហារប្បច្ច័យ ក្នុងឥន្ទ្រិយប្បច្ច័យ ក្នុងឈានប្បច្ច័យ ក្នុងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

[ ៥១២ ] ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ព្រោះហេតុប្បច្ច័យ ... ក្នុង

សហជាតប្បច្ច័យ មានវារៈ ៧ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ ( មានវារៈ ៤ ) ក្នុងមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

[ ៥១៣ ] ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ៤ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ

និស្សយប្បច្ច័យ វិបាកប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ២ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ មានវារៈ ១ ព្រោះហេតុប្បច្ច័យ ។ បណ្ឌិតគប្បីឲ្យពិស្តារ ដូចជាក្នុងកុសលត្តិកៈដែរ ។

អនុលោម ចប់

[ ៥១៤ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយសហជាតប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៥១៥ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយសហជាតប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ... ជាបច្ច័យ ដោយកម្មប្បច្ច័យ ។

[ ៥១៦ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ ដោយឧបនិស្សយប្បច្ច័យ ។

[ ៥១៧ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកធម៌ផង នៃអសង្កិលិដ្ឋសង្កិលេសិកធម៌ផង ដោយសហជាតប្បច្ច័យ ។

[ ៥១៨ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេ-

សិកធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយសហជាតប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយបុរេជាតប្បច្ច័យ ... ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ... ជាបច្ច័យដោយកម្មប្បច្ច័យ ... ជាបច្ច័យដោយអាហារប្បច្ច័យ... ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

[ ៥១៩ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃសង្កិលិដ្ឋសង្កិលេសិកធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។

[ ៥២០ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ ដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។

[ ៥២១ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ ដោយសហជាតប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៥២២ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យដោយសហជាតប្បច្ច័យ ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។

[ ៥២៣ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ផង នៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ផង ដោយសហជាតប្បច្ច័យ ។

[ ៥២៤ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ក្តី អសង្កិលិដ្ឋអសង្កិលេសិកធម៌ក្តី ( ជាបច្ច័យ ) នៃអសង្កិលិដ្ឋសង្កិលេសិកធម៌ បានដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។

[ ៥២៥ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ក្តី អសង្កិលិដ្ឋអសង្កិលេសិកធម៌ក្តី ( ជាបច្ច័យ ) នៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ បានដល់ សហជាត និងបុរេជាត ។

[ ៥២៦ ] សង្កិលិដ្ឋសង្កិលេសិកធម៌ក្តី អសង្កិលិដ្ឋសង្កិលេសិកធម៌ក្តី ( ជាបច្ច័យ ) នៃសង្កិលិដ្ឋសង្កិលេសិកធម៌ បានដល់ សហជាត និងបុរេជាត ។

[ ៥២៧ ] សង្កិលិដ្ឋសង្កិលេសិកធម៌ក្តី អសង្កិលិដ្ឋសង្កិលេសិកធម៌ក្តី ( ជាបច្ច័យ ) នៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ បានដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។

[ ៥២៨ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១៤ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១៤ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ១៤ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ១៤ ក្នុងនសហជាតប្បច្ច័យ មានវារៈ ១០ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ១០ ក្នុងននិស្សយប្បច្ច័យ មានវារៈ ១០ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ១៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១៤ ក្នុងនអាសេវនប្បច្ច័យ ក្នុងនកម្មប្បច្ច័យ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១៤ ក្នុងនអាហារប្បច្ច័យ ក្នុងនឥន្ទ្រិយប្បច្ច័យ ក្នុងនឈានប្បច្ច័យ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១៤ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១០ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៨ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ៨ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១៤ ក្នុង

នោវិគតប្បច្ច័យ មានវារៈ ១៤ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៨ ។ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១៤ ព្រោះនហេតុប្បច្ច័យ ។ សេចក្តីបង្រួញ ។ បណ្ឌិតគប្បីរាប់ ដូចជាការរាប់នូវបច្ចនីយៈក្នុងកុសលត្តិកៈដែរ ។

**បច្ចនីយៈ ចប់**

[ ៥២៩ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ ក្នុងនអនន្តរប្បច្ច័យ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ ក្នុងនបុរេ-ជាតប្បច្ច័យ ក្នុងនបច្ឆាជាតប្បច្ច័យ ក្នុងនអាសេវនប្បច្ច័យ ក្នុងនកម្មប្បច្ច័យ ក្នុងនវិបាកប្បច្ច័យ ក្នុងនអាហារប្បច្ច័យ ក្នុងនឥន្ទ្រិយប្បច្ច័យ ក្នុងនឈា-នប្បច្ច័យ មានវារៈ ៧ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៧ ។ ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ។ សេចក្តីបង្រួញ ។ បណ្ឌិតគប្បីចែក ដូចជាការរាប់នូវអនុលោមបច្ចនីយៈ ក្នុងកុសលត្តិកៈ ដែលលោកចែកហើយដែរ ។

**អនុលោមបច្ចនីយៈ ចប់**

[ ៥៣០ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៨ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៨ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងអាហារប្បច្ច័យ ក្នុងឥន្ទ្រិយប្បច្ច័យ ក្នុងឈានប្បច្ច័យ ក្នុងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ព្រោះនហេតុប្បច្ច័យ ព្រោះនអារម្មណប្បច្ច័យ ។

សេចក្តីបង្រួញ ។

បណ្ឌិតគប្បីចែក ដូចជាការរាប់នូវបច្ចនីយានុលោម ក្នុងកុសលត្តិកៈ ដែលលោកចែកហើយដែរ ។

**បច្ចនីយានុលោម ចប់**

**សង្កិលិដ្ឋត្តិកៈទី ៥ ចប់**

**អនុលោមត្តិកប្បដ្ឋានខាងដើម ចប់**

# អដ្ឋកថា

## សង្កិលិដ្ឋត្តិកៈ

[ ៤២៣-៥៣០ ] ពាក្យទាំងអស់ ក្នុងសង្កិលិដ្ឋសង្កិលេសិកត្តិកៈ អ្នកសិក្សា គប្បីជ្រាបតាមគន្លងរបស់ន័យដែលពោលហើយ ក្នុងកុសលត្តិកៈ នោះឯង ។ល។

**អដ្ឋកថាសង្កិលិដ្ឋត្តិកៈ ចប់**

# ក្បាលទី ៧៧

# អភិធម្មបិដក ចាលីប្រែ ~៩៥

## សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ


អភិធម្មបិដក ហេតុមូលកៈ .......... .......... .......... .......... ......... ២
អភិធម្មបិដក អារម្មណមូលកៈ .......... .......... .......... .......... ....... ៦
អភិធម្មបិដក អធិបតិមូលកៈ .......... .......... .......... .......... ....... ៦
អភិធម្មបិដក អនន្តរមូលកៈ .......... .......... .......... .......... ..... ១០
អភិធម្មបិដក សមនន្តរមូលកៈ .......... .......... .......... .......... ....... ១១
អភិធម្មបិដក សហជាតមូលកៈ .......... .......... .......... .......... ...... ១១
អភិធម្មបិដក អញ្ញមញ្ញមូលកៈ .......... .......... .......... .......... ...... ១៣
អភិធម្មបិដក និស្សយមូលកៈ .......... .......... .......... .......... ...... ១៤
អភិធម្មបិដក ឧបនិស្សយមូលកៈ .......... .......... .......... .......... .......... ១៦
អភិធម្មបិដក បុរេជាតមូលកៈ .......... .......... .......... .......... .......... ១៧
អភិធម្មបិដក បច្ឆាជាតមូលកៈ .......... .......... .......... .......... .......... ១៨
អភិធម្មបិដក អាសេវនមូលកៈ .......... .......... .......... .......... .......... ១៩
អភិធម្មបិដក កម្មមូលកៈ .......... .......... .......... .......... .......... ១៩
អភិធម្មបិដក វិបាកមូលកៈ .......... .......... .......... .......... .......... ២១
អភិធម្មបិដក អាហារមូលកៈ .......... .......... .......... .......... ......... ២២
អភិធម្មបិដក ឥន្ទ្រិយមូលកៈ .......... .......... .......... .......... ......... ២៦
អភិធម្មបិដក ឈានមូលកៈ .......... .......... .......... ........ ៣៥
អភិធម្មបិដក មគ្គមូលកៈ .......... .......... .......... ........ ៤០
អភិធម្មបិដក សម្បយុត្តមូលកៈ .......... .......... .......... ........ ៤៧

អភិធម្មបិដក វិប្បយុត្តមូលកៈ .......... .......... .......... ......... ៤៧

អភិធម្មបិដក អត្ថិមូលកៈ .......... .......... .......... ......... ៤៩

អភិធម្មបិដក នត្ថិមូលកៈ .......... .......... .......... ....... ៥២

អភិធម្មបិដក វិគតមូលកៈ .......... .......... .......... ......... ៥៣

អភិធម្មបិដក អវិគតមូលកៈ .......... .......... .......... ....... ៥៣

អដ្ឋកថាបញ្ហាវារឃដនាអនុលោមគណនា .......... .......... .......... .......... ៥៧

អភិធម្មបិដក បញ្ហាវារៈ បច្ចនីយឧទ្ធារៈ .......... .......... .......... ...... ៩១


## បញ្ហាវារៈ បច្ចនីយគណនា

### នហេតុមូលកៈ


អភិធម្មបិដក នហេតុមូលកៈ .......... .......... .......... ....... ៩២

អភិធម្មបិដក នអារម្មណមូលកៈ .......... .......... .......... ...... ១០០

អភិធម្មបិដក នសហជាតមូលកៈ .......... .......... .......... ....... ១០១

អភិធម្មបិដក នអញ្ញមញ្ញមូលកៈ .......... .......... .......... ....... ១០២

អភិធម្មបិដក ននិស្សយមូលកៈ .......... .......... .......... ....... ១០៤

អភិធម្មបិដក នឧបនិស្សយមូលកៈ .......... .......... .......... ....... ១០៦

អភិធម្មបិដក នបុរេជាតមូលកៈ .......... .......... .......... ...... ១០៩

អភិធម្មបិដក នបច្ឆាជាតមូលកៈ .......... .......... .......... ...... ១១២

អភិធម្មបិដក នអាហារមូលកៈ .......... .......... .......... ...... ១១៧

អភិធម្មបិដក នឥន្ទ្រិយមូលកៈ .......... .......... .......... ...... ១២០

អភិធម្មបិដក នវិប្បយុត្តមូលកៈ .......... .......... .......... .......... ......... ១២២

អភិធម្មបិដក នោអត្ថិមូលកៈ .......... .......... .......... .......... .......... ១២៥

អដ្ឋកថាបច្ចនីយុទ្ធារៈ .......... .......... .......... .......... ............ ១២៨

អដ្ឋកថាបច្ចនីយគណនា .......... .......... .......... .......... .......... ១៤៣

# បញ្ហាវារៈ អនុលោមប្បច្ចនីយគណនា

## ហេតុមូលកៈ


អភិធម្មបិដក ហេតុមូលកៈ .......... .......... .......... .......... ......... ១៥៨

អភិធម្មបិដក អារម្មណមូលកៈ .......... .......... .......... .......... .......... ១៧១

អភិធម្មបិដក អធិបតិមូលកៈ .......... .......... .......... .......... ......... ១៧៥

អភិធម្មបិដក អនន្តរមូលកៈ .......... .......... .......... .......... ......... ១៩៣

អភិធម្មបិដក សមនន្តរមូលកៈ .......... .......... .......... .......... ......... ១៩៥

អភិធម្មបិដក សហជាតមូលកៈ .......... .......... .......... .......... ......... ១៩៧

អភិធម្មបិដក អញ្ញមញ្ញមូលកៈ .......... .......... .......... .......... ......... ២០៤

អភិធម្មបិដក និស្សយមូលកៈ .......... .......... .......... .......... ......... ២០៨

អភិធម្មបិដក ឧបនិស្សយមូលកៈ .......... .......... .......... .......... ......... ២២០

អភិធម្មបិដក បុរេជាតមូលកៈ .......... .......... .......... .......... .......... ២២៥

អភិធម្មបិដក បច្ឆាជាតមូលកៈ .......... .......... .......... .......... .......... ២៣០

អភិធម្មបិដក អាសេវនមូលកៈ .......... .......... .......... .......... .......... ២៣១

អភិធម្មបិដក កម្មមូលកៈ .......... .......... .......... .......... .......... ២៣៣

អភិធម្មបិដក វិបាកមូលកៈ .......... .......... .......... .......... .......... ២៣៩

អភិធម្មបិដក អាហារមូលកៈ .......... .......... .......... .......... .......... ២៤៣

អភិធម្មបិដក ឥន្ទ្រិយមូលកៈ .......... .......... .......... .......... .......... ២៦២

អភិធម្មបិដក ឈានមូលកៈ .......... .......... .......... .......... ...... ២៨៣

អភិធម្មបិដក មគ្គមូលកៈ .......... .......... .......... .......... ...... ២៩០

អភិធម្មបិដក សម្បយុត្តមូលកៈ .......... .......... .......... .......... ...... ៣០០

អភិធម្មបិដក វិប្បយុត្តមូលកៈ .......... .......... .......... .......... ...... ៣០១

អភិធម្មបិដក អត្ថិមូលកៈ .......... .......... .......... .......... ...... ៣០៩

អភិធម្មបិដក នត្ថិវិគតអវិគតមូលកៈ .......... .......... .......... .......... ..... ៣២៧

អដ្ឋកថាអនុលោមបច្ចនីយៈ .......... .......... .......... .......... ........ ៣២៨

# បញ្ហាវារៈ បច្ចនីយានុលោមគណនា

## នហេតុមូលកៈ

អភិធម្មបិដក នហេតុមូលកៈ .......... .......... .......... .......... ...... ៣៣៣

អភិធម្មបិដក នអារម្មណមូលកៈ .......... .......... .......... .......... ....... ៣៣៨

អភិធម្មបិដក នអធិបតិមូលកៈ .......... .......... .......... .......... ....... ៣៣៩

អភិធម្មបិដក នអនន្តរមូលកៈ .......... .......... .......... .......... ....... ៣៣៩

អភិធម្មបិដក នសមនន្តរមូលកៈ .......... .......... .......... .......... ....... ៣៤០

អភិធម្មបិដក នសហជាតមូលកៈ .......... .......... .......... .......... ....... ៣៤០

អភិធម្មបិដក នអញ្ញមញ្ញមូលកៈ .......... .......... .......... .......... ....... ៣៤២

អភិធម្មបិដក ននិស្សយមូលកៈ .......... .......... .......... .......... ....... ៣៤៣

អភិធម្មបិដក នឧបនិស្សយមូលកៈ .......... .......... .......... .......... ..... ៣៤៥

អភិធម្មបិដក នបុរេជាតមូលកៈ .......... .......... .......... .......... ....... ៣៤៦

អភិធម្មបិដក នបច្ឆាជាតមូលកៈ .......... .......... .......... .......... ....... ៣៤៧

អភិធម្មបិដក នអាសេវនមូលកៈ .......... .......... .......... .......... ...... ៣៤៩

អភិធម្មបិដក នកម្ម នវិបាកមូលកៈ .......... .......... .......... .......... ...... ៣៥០

អភិធម្មបិដក នអាហារមូលកៈ .......... .......... .......... .......... ....... ៣៥១

អភិធម្មបិដក នឥន្ទ្រិយមូលកៈ .......... .......... .......... .......... ....... ៣៥៣

អភិធម្មបិដក នឈានមូលកៈ .......... .......... .......... .......... ....... ៣៥៣

អភិធម្មបិដក នមគ្គមូលកៈ .......... .......... .......... .......... ....... ៣៥៤

អភិធម្មបិដក នសម្បយុត្តមូលកៈ .......... .......... .......... .......... ....... ៣៥៤

អភិធម្មបិដក នវិប្បយុត្តមូលកៈ .......... .......... .......... .......... ....... ៣៥៦

អភិធម្មបិដក នោអត្ថិមូលកៈ .... ៣៥៩
អភិធម្មបិដក នោនត្ថិមូលកៈ .... ៣៦១
អភិធម្មបិដក នោវិគតមូលកៈ .... ៣៦១
អភិធម្មបិដក នោអវិគតមូលកៈ .... ៣៦២
អដ្ឋកថាបច្ចនីយានុលោម .... ៣៦៣

### វេទនាត្តិកៈ

អភិធម្មបិដក បដិច្ចវារៈ .... ៣៧១
អភិធម្មបិដក បញ្ហាវារៈ .... ៣៩០
អភិធម្មបិដក ហេតុមូលកៈ ជាដើម .... ៤១៤
អដ្ឋកថាវេទនាត្តិកៈ .... ៤៣៨

# បាលីប្រែ-៥៦

# បដ្ឋាន តតិយភាគ

### វិបាកត្តិកៈ

អភិធម្មបិដក បដិច្ចវារៈ .... ៤៤៨
អភិធម្មបិដក សហជាតវារៈ .... ៤៧៣
អភិធម្មបិដក បច្ចយវារៈ .... ៤៧៣
អភិធម្មបិដក និស្សយវារៈ .... ៤៨៩
អភិធម្មបិដក សំសដ្ឋវារៈ .... ៤៩០
អភិធម្មបិដក សម្បយុត្តវារៈ .... ៤៩២
អភិធម្មបិដក បញ្ហាវារៈ .... ៤៩២
អដ្ឋកថាវិបាកត្តិកៈ .... ៥២៦

### ឧបាទិន្នត្តិកៈ

អភិធម្មបិដក បដិច្ចវារៈ .... ៥៣០

អភិធម្មបិដក សហជាតវារៈ .......... .......... .......... .......... ............ ៥៤៣

អភិធម្មបិដក បច្ចយវារៈ .......... .......... .......... .......... ............. ៥៤៣

អភិធម្មបិដក និស្សយវារៈ .......... .......... .......... .......... ............. ៥៥៣

អភិធម្មបិដក សំសដ្ឋវារៈ .......... .......... .......... .......... ............. ៥៥៣

អភិធម្មបិដក សម្បយុត្តវារៈ .......... .......... .......... .......... ............... ៥៥៥

អភិធម្មបិដក បញ្ហាវារៈ .......... .......... .......... .......... .............. ៥៥៥

អដ្ឋកថាឧបាទិន្នត្តិកៈ .......... .......... .......... .......... .......... .... ៦០៨

## សង្កិលិដ្ឋត្តិកៈ

អភិធម្មបិដក បដិច្ចវារៈ .......... .......... .......... .......... ............. ៦១០

អភិធម្មបិដក បញ្ហាវារៈ .......... .......... .......... .......... ............. ៦១៣

អដ្ឋកថាសង្កិលិដ្ឋត្តិកៈ .......... .......... .......... .......... .............. ៦៤៣